ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# បំណិនជីវិតតាមមូលដ្ឋាន

# ឯកសារណែនាំអនុវត្ត

## សម្រាប់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលា

## ការអនុវត្តបំណិនជីវិតក្នុងបរិបទជីវិតរស់នៅជាក់ស្តែង




នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ឆ្នាំ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៧៣៧៥ អយក.ប្រក

# ប្រកាស
# ស្ដីពី
# ការអនុញ្ញាតឱ្យបោះពុម្ព និងប្រើប្រាស់
# សៀវភៅ «បំណិនជីវិតតាមមូលដ្ឋាន ឯកសារណែនាំអនុវត្ត»

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញ អនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យ លេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្ដីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្ដីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- របាយការណ៍ ស្ដីពី ដំណើរការនៃការកែសម្រួលឯកសារណែនាំអនុវត្តបំណិនជីវិតតាមមូលដ្ឋានសម្រាប់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន ចុះថ្ងៃចន្ទ ៧កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០
- យោងលិខិតលេខ១៥២ អគ.អរ ស្ដីពីសំណើសុំការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ និងប្រើប្រាស់សៀវភៅ «បំណិនជីវិតតាមមូលដ្ឋាន ឯកសារណែនាំអនុវត្ត» ចុះថ្ងៃអង្គារ ១៥កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៤ ខែសីហា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានអប់រំ
- យោងលិខិតលេខ១៥១ អកស ស្ដីពីសំណើសុំការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ និងប្រើប្រាស់សៀវភៅ «បំណិនជីវិតតាមមូលដ្ឋាន ឯកសារណែនាំអនុវត្ត» ចុះថ្ងៃអង្គារ ១៥កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៤ ខែសីហា ឆ្នាំ២០២០ របស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

## សម្រេច

**ប្រការ១.**_ អនុញ្ញាតឱ្យបោះពុម្ពផ្សាយ និងប្រើប្រាស់សៀវភៅ «បំណិនជីវិតតាមមូលដ្ឋាន ឯកសារណែនាំអនុវត្ត» ដែលនិពន្ធ និងរៀបរៀងដោយគណៈកម្មការនិពន្ធនៃនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាឯកសារជំនួយសម្រាប់គ្រូ និងគណៈគ្រប់គ្រងសាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.**_ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ នាយកដ្ឋានបឋមសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា មន្ទីរអប់រំ យុវជន និង កីឡារាជធានី/ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ សាលាបឋមសិក្សា និងសាលារៀនមធ្យមសិក្សាចំណេះទូទៅ មានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ ចន្ទ ៦ កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ សីហា ឆ្នាំ២០២០

**កន្លែងទទួល៖**
- គ្រប់សាលារាជធានីខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- ដូចប្រការ២ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# អារម្ភកថា

ការកែលម្អឯកសារណែនាំនេះ ជាលទ្ធផលនៃកិច្ចសហការរវាងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាជាមួយនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ និងអង្គការអភិវឌ្ឍវិស័យអប់រំមួយចំនួនក្រោមការឧបត្ថម្ភពីអង្គការយូនីសេហ្វ។ ឯកសារណែនាំនេះត្រូវបានបោះពុម្ពផ្សាយលើកដំបូងនៅឆ្នាំ ២០១៥ និងបោះពុម្ពឡើងវិញនៅឆ្នាំ ២០១៨ ដោយនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ក្រោមការឧបត្ថម្ភគាំទ្រពីអង្គការយូនីសេហ្វ។

ផ្អែកតាមបទពិសោធនៃការសាកល្បង អនុវត្តបំណិនជីវិតតាមមូលដ្ឋាន និងនិន្នាការថ្មីនៃការអប់រំអន្តរជាតិ ចាំបាច់ទាមទារឱ្យមានការកែលម្អឯកសារនេះឡើងវិញ ដើម្បីបញ្ចូលបញ្ញត្តិសំខាន់ៗក្នុងការគាំទ្រដល់ការអនុវត្តបំណិនជីវិតតាមមូលដ្ឋាននៅកម្រិតសាលារៀន។ កំណែទម្រង់កម្មវិធីសិក្សានៅកម្ពុជា បានកំណត់ជាផ្លូវការក្នុងក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសឆ្នាំ ២០១៦ ដោយបញ្ចូលមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានជាមុខវិជ្ជាគោលក្នុងកម្មវិធីសិក្សា ទាំងកម្រិតបឋមសិក្សា និងកម្រិតមធ្យមសិក្សាបឋមភូមិ។  សមត្ថភាពសំខាន់ៗរបស់សិស្ស ត្រូវបានកំណត់ក្នុងក្របខណ្ឌកម្មវិធីសិក្សា ហើយការបញ្ជ្រាបបំណិនទន់ជា សមាសភាពសំខាន់ ក្នុងដំណើរការបង្រៀននិងរៀនគ្រប់មុខវិជ្ជាគោល។ ការរៀនសូត្រសកម្ម និងការរៀនដោយខ្លួនឯង ក្លាយជាសមាសភាគសំខាន់នៃដំណើរការបង្រៀននិងរៀនតាមរយៈការជំរុញការសិក្សាតាមបែបរិះរក បច្ចេកទេសសិក្សាផ្អែកលើបញ្ហា និងបែបគម្រោងដើម្បីឱ្យសមត្ថភាពសិស្សឆ្លើយតបបានទៅនឹងបរិបទសង្គម នៅសតវត្សរ៍ទី២១។

ឯកសារណែនាំនេះមានបំណងប្តូរការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន ពីការអនុវត្តការសិក្សាអសកម្មទៅជាការអនុវត្តការសិក្សាបែបសកម្ម ដែលសិស្សចូលរួមក្នុងការកសាងចំណេះដឹងផ្ទាល់ខ្លួនក្រោមការណែនាំរបស់គ្រូ។ សិស្សនឹងត្រូវបានណែនាំឱ្យរុករក រិះរក រកដំណោះស្រាយ និងបង្កើតសកម្មភាពដើម្បីផ្សព្វផ្សាយ  លទ្ធផលដែលជាផ្នែកមួយនៃដំណើរការសិក្សាថ្មីរបស់ពួកគេ។

ក្រសួងអប់រំ យុវជន និងកីឡា រំពឹងថា អ្នកគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ប្រើប្រាស់ឯកសារនេះ ដើម្បីជួយជំរុញការអនុវត្តការបង្រៀនបំណិនជីវិតតាមមូលដ្ឋាននៅតាមសាលារៀន ក្នុងការរួមចំណែកផ្តល់នូវការអប់រំប្រកបដោយគុណភាពសម្រាប់ទាំងអស់គ្នា ក្រោមគោលដៅរួមនៃការអភិវឌ្ឍប្រកបដោយចិរភាព។

# គណៈកម្មការគ្រប់គ្រង

ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ឯកឧត្តមបណ្ឌិត អ៊ឹម កុច** លោកជំទាវ ទន់ សាអ៊ីម

លោក **ស៊ុន ប៊ុណ្ណា** លោក **វ៉ា វុទ្ធី**

# គណៈកម្មការនិពន្ធ

លោក **ព្រុំ វិបុល**
លោក **អ៊ុង សារ៉ាត**
លោកស្រី **គង់ សារី**
លោកស្រី **ប៊ូ អាង**
លោក **សូរ ច័ន្ទបូរី**
លោកស្រី **ទេព ប៊ុណ្ណារី**
លោក **លឹម សុជាតិ**
លោក **សោមនស្ស ភិរម្យ**
លោក **ផេង វិមាន**
លោកស្រី **រស់ ចាន់អមរ៉ា**
លោក **ជា យូទ្រី**

# ជំនួយការបច្ចេកទេស

លោកស្រី **ប៉ាវឡា ម៉ាសា** ( Poalla Massa )
លោក **នួន វណ្ណសឿន**
លោក **ព្រុំ វិបុល**

# គណៈកម្មការពិនិត្យ

លោក **នួន វណ្ណសឿន**
លោក **ចាន់ សូលីន**
លោក **ព្រុំ វិបុល**
លោកស្រី **ប៉ាវឡា ម៉ាសា**

# គណៈកម្មការកុំព្យូទ័រ និងរចនា

លោក **សោមនស្ស ភិរម្យ**
លោក **ទុយ សម្បត្តិ**

# មាតិកា


ជំពូក ១

សេចក្តីផ្តើម ..... 10
១.១. បំណិនមូលដ្ឋាន ..... 10
១.២. បំណិនអាជីព ..... 10
១.៣.បំណិនទន់ បំណិនបុរេវិជ្ជាជីវៈ ឬបំណិនសតវត្សរ៍ទី២១ ..... 11
១.៤. បំណិនជីវិតតាមមូលដ្ឋាន ..... 11

ជំពូក ២

បញ្ញត្តិ និងគំរូនៃការអប់រំបំណិនជីវិត ..... 12
២.១. បំណិនជីវិត (បំណិនមូលដ្ឋាន និងបំណិនអាជីព) ..... 12
២.២. យុទ្ធសាស្ត្របង្រៀនបំណិនជីវិត ..... 13

ជំពូក ៣

ការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន ..... 18
៣.១. ការជ្រើសរើសប្រធានបទ ..... 18
៣.២. វិធីសាស្ត្របង្រៀន និងរៀនមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន ..... 22

ជំពូក ៤

បំណិនទន់ បំណិនបុរេវិជ្ជាជីវៈ ឬបំណិនសតវត្សរ៍ទី២១ ..... 28
៤.១. ហេតុអ្វីបានជាបំណិនទន់មានសារៈសំខាន់? ..... 28
៤.២. បំណិនទន់ និងបំណិនជីវិត ..... 28
៤.៣. អត្ថន័យបំណិនទន់ ..... 29
៤.៤. ការបញ្ចូលបំណិនទន់ទៅក្នុងមុខវិជ្ជា បំណិនជីវិតតាមមូលដ្ឋាន ..... 29
បំណិនសម្រាប់ការរៀនសូត្រ ..... 30
បំណិនពង្រឹងអំណាចផ្ទាល់ខ្លួន ..... 36
បំណិនសម្រាប់ការងារ ..... 40
បំណិនសម្រាប់ភាពជាពលរដ្ឋ ..... 44

ជំពូក ៥

ផែនការបង្រៀន និងប្រភពធនធាន ..... 50
៥.១. ការរៀបចំផែនការបង្រៀន ឬផែនការប្រចាំឆមាស ..... 50
៥.២. ស្តង់ដាបំណិនជីវិតតាមមូលដ្ឋាន ..... 52
៥.៣. ការសម្របសម្រួលជាមួយគ្រូមុខវិជ្ជាដទៃ និងភាគីពាក់ព័ន្ធ ..... 54
៥.៤. ប្រភពព័ត៌មាន ..... 54

ជំពូក ៦

ការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន ..... 58
៦.១. ការបង្កើតសហគមន៍នៃការរៀន ..... 58
៦.២. ការផ្សព្វផ្សាយបំណិនជីវិតតាមមូលដ្ឋាន និងយន្តការគាំទ្រ ..... 60

មាតិកា


ដំណើរការវាយតម្លៃ ... 64

៧.១. ទិដ្ឋភាពទូទៅនៃការវាយតម្លៃ ... 64

៧.២. រង្វាយតម្លៃបំណិនជីវិតតាមមូលដ្ឋាន ... 65

ឧបសម្ព័ន្ធជំពូក៤ ... 76

៤.១. បង្ការព័ត៌មានក្លែងបន្លំ ... 76

៤.២. តើវាគឺជាការពិត ឬជាគំនិតផ្ទាល់ខ្លួន? ... 76

៤.៣. ឧបករណ៍វាស់អារម្មណ៍ ... 77

៤.៤. ដំណោះស្រាយឈ្នះ-ឈ្នះ ... 78

៤.៥. ការសង្កេតមើលពីទីតាំងផ្សេងគ្នានៅពេលបង្រៀន ... 80

ឧបសម្ព័ន្ធជំពូក៥ ... 82

៥.១. តារាងលម្អិតអំពីគំរូសង្គម និងគំរូអាជីពងាយ ... 82

៥.២. ស្តង់ដាសិក្សា ... 83

៥.៣. ព័ត៌មានលម្អិតអំពីគម្រោងបង្រៀន៦ដំណាក់កាល ... 90

៥.៤. ផូស្ទ័រនៃការបង្រៀន ៦ដំណាក់កាល( សកម្មភាព និង បំណិនទន់ ) ... 93

ឧបសម្ព័ន្ធជំពូក៧ ... 94

៧.១. ឧបករណ៍វាយតម្លៃការប្រតិបត្តិ-Joint ... 94

៧.១.១. ឧបករណ៍វាយតម្លៃការប្រតិបត្តិ-ការអង្កេតផ្លូវការរបស់គ្រូនៅកម្រិតមធ្យមសិក្សាបឋមភូមិ ... 96

៧.២. ឧទាហរណ៍នៃទម្រង់សង្កេតសម្រាប់គ្រូបឋមសិក្សា ... 98

៧.២.១. ឧទាហរណ៍នៃទម្រង់សង្កេតសម្រាប់គ្រូអនុវិទ្យាល័យ ... 99

៧.២.២. លំណែនាំការសង្កេត ... 100

៧.៣. កំណត់សម្គាល់ការសង្កេតរបស់គ្រូ ... 103

៧.៤. ស្វ័យរង្វាយតម្លៃរបស់សិស្សនៅអនុវិទ្យាល័យ ... 104

៧.៤.១. ស្វ័យរង្វាយតម្លៃសិស្សនៅកម្រិតបឋមសិក្សា ... 106

៧.៥. ទម្រង់រួម ការវាយតម្លៃផ្អែកលើថ្នាក់រៀន ... 107

៧.៦. ឧបករណ៍វាយតម្លៃក្រៅផ្លូវការផ្សេងៗទៀត ... 110

សកម្មភាពបង្រៀនតាម ៦ដំណាក់កាល ... 112

ដំណាក់កាលទី១- ការស្វែងយល់ប្រធានបទ ... 112

ដំណាក់កាលទី២- ការប្រមូលព័ត៌មាន ... 118

ដំណាក់កាលទី៣- ការវិភាគព័ត៌មាន ... 122

ដំណាក់កាលទី៤- ការរៀបចំផែនការសកម្មភាព ... 128

ដំណាក់កាលទី៥- ការអនុវត្តផែនការសកម្មភាព ... 138

ដំណាក់កាលទី៦- ការឆ្លុះបញ្ចាំង និងវាយតម្លៃ ... 140

ធនធានសម្ភារៈផ្សេងទៀត ... 143

បទានុក្រម ... 144

ឯកសារយោង ... 146

## សញ្ញាសម្គាល់

 ព័ត៌មានសំខាន់ៗបន្ថែមសម្រាប់ការបង្រៀន

 គំនិត ឧទាហរណ៍ជួយក្នុងកិច្ចការបង្រៀន

 ការស្វែងយល់បរិបទបញ្ញត្តិ

 គោលដៅចុងក្រោយ

 ស្វ័យឆ្លុះបញ្ចាំងនៅចុងបញ្ចប់នៃជំពូកនីមួយៗ អ្នកអាននឹងឃើញសំណួរមួយចំនួនសម្រាប់ត្រួតពិនិត្យចំណេះដឹងពីបញ្ញត្តិសំខាន់ៗ

## អក្សរកាត់

| | | |
|---|---|---|
| DCD | : | Department of Curriculum Development |
| DOE | : | District Office of Education |
| DTMT | : | District Technical Monitoring Team |
| KAPE | : | Kampuchean Action to Promote Education |
| LLS | : | Local Life Skills |
| MoEYS | : | Ministry of Education, Youth and Sports |
| NGO | : | Non-governmental organization |
| PBL | : | Problem-Based Learning |
| POE | : | Provincial Office of Education |
| PTTC | : | Provincial Teaching Training Centers |
| RtR | : | Room To Read |
| RTTC | : | Regional Teaching Training Centers |
| VOD | : | Vocational Orientation Department |
| WEI | : | World Education Inc. |
| WVI | : | World Vision International |

# ជំពូក ១ សេចក្តីផ្តើម

ការអប់រំបំណិនជីវិត គឺជាផ្នែកមួយនៃគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០០៥-២០០៩ និងដំណាក់កាលបន្តបន្ទាប់។ ការអប់រំបំណិនជីវិតត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់សិស្ស ដែលកំពុងរស់នៅក្នុងយុគសម័យសកលភាវូបនីយកម្ម។

ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់និយមន័យបំណិនជីវិត ដែលមានចែងក្នុងគោលនយោបាយបំណិនជីវិតឆ្នាំ២០០៦ ថាជាបំណិនបញ្ញា បុគ្គលិកលក្ខណៈ អន្តរបុគ្គល និងវិជ្ជាជីវៈ ដែលអាចជួយដល់ការធ្វើការសម្រេចចិត្ត ការធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព ព្រមទាំងអាចដោះស្រាយ និងគ្រប់គ្រងខ្លួនឯងបាន "គឺជាបំណិនដែលរួមចំណែកក្នុងការលើកស្ទួយសុខមាលភាព និងជីវិតប្រកបដោយផលិតភាព"។ គោលនយោបាយបានកំណត់ថា បំណិនជីវិតមានពីរប្រភេទគឺ បំណិនមូលដ្ឋាន និងបំណិនអាជីព។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បញ្ញត្តិបំណិនជីវិតត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការថ្មីរបស់សិស្ស ដោយផ្តោតការយកចិត្តទុកដាក់លើគំរូសង្គម និងគំរូអាជីពងាយ ។

## ១.១. គំរូសង្គម (បំណិនមូលដ្ឋាន)

បំណិនមូលដ្ឋានត្រូវបានគេចាត់ទុកថាជាផ្នែកមួយនៃបំណិនជីវិត។ នៅក្នុងកម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋានឆ្នាំ២០១៨ បំណិនមូលដ្ឋានត្រូវបានបែងចែកជា៣ផ្នែកតូចៗទៀតគឺ "ចំណេះដឹងទូទៅ (ជុំវិញសហគមន៍ និងសកលដែលប៉ះពាល់ដល់ជីវិត) បំណិនបុរេវិជ្ជាជីវៈ (បំណិនទន់) និងគុណតម្លៃផ្ទាល់ខ្លួន"។ នៅក្នុងឯកសារនេះ ពាក្យបំណិនបុរេវិជ្ជាជីវៈ គឺស្មើនឹងបំណិនទន់ ឬបំណិនសតវត្សរ៍ទី២១។ បំណិនមូលដ្ឋានត្រូវបានបញ្ជ្រាបចូលតាមមុខវិជ្ជាសំខាន់ៗដូចជា ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងសិក្សាសង្គម ក៏មានដូចគ្នានៅក្នុងការអប់រំបំណិនជីវិតតាមមូលដ្ឋានដែរ។ បំណិនមូលដ្ឋានត្រូវបានបង្កើតឡើង នៅពេលដែលអ្នកសិក្សាឆ្លុះបញ្ចាំងស៊ីជម្រៅពីអ្វីដែលគេបានធ្វើ ដោយសួរសំណួរដូចជា "តើខ្ញុំអាចធ្វើអ្វីផ្សេងពីនេះបានឬទេ?" "តើខ្ញុំអាចកែលម្អវានៅពេលក្រោយដោយរបៀបណា?" "ប្រសិនបើខ្ញុំជាគាត់តើខ្ញុំគួរធ្វើអ្វី?"

## ១.២. គំរូអាជីពងាយ (បំណិនអាជីព)

បំណិនអាជីពជាផ្នែកមួយនៃបំណិនជីវិត គឺសំដៅទៅលើការអនុវត្តអាជីវកម្ម និងការគ្រប់គ្រងខ្នាតតូចក្នុងមូលដ្ឋាន ដែលបង្កើតឱ្យមានភាពជាដៃគូ នៅតាមសាលារៀន និងទីកន្លែងធ្វើការ។ ក្នុងឯកសារក្របខ័ណ្ឌកម្មវិធីសិក្សាអប់រំបំណិនជីវិតឆ្នាំ២០១៨ បានចាត់ថ្នាក់បំណិនអាជីពជា បំណិនមូលដ្ឋាន បំណិនអាជីវកម្មនិងគ្រប់គ្រង និងបំណិនបច្ចេកទេស។ តាមឯកសារគោលនយោបាយបំណិនជីវិតឆ្នាំ ២០០៦ បានបែងចែកបំណិនអាជីពជាពីរប្រភេទគឺ បំណិនអាជីពងាយ និងបំណិនវិជ្ជាជីវៈ។ ការផ្លាស់ប្តូរគួរឱ្យកត់សំគាល់បំផុតគឺការដាក់បញ្ចូលបំណិនមូលដ្ឋាន និងបំណិនអាជីវកម្មនិងគ្រប់គ្រង។

## ១.៣.បំណិនទន់ បំណិនបុរេវិជ្ជាជីវៈ ឬបំណិនសតវត្សរ៍ទី២១

បំណិនទន់គឺជាផ្នែកមួយនៃបំណិនជីវិត ដែលមាននៅក្នុងបំណិនទាំងពីរគឺ ក្នុងបំណិនមូលដ្ឋាន និងបំណិនអាជីព ក្នុងទម្រង់ជាបំណិនបុរេវិជ្ជាជីវៈ និងបំណិនអាជីវកម្មនិងគ្រប់គ្រង។ បំណិនទន់អាចហៅថា បំណិនបុរេវិជ្ជាជីវៈ ឬ បំណិនសតវត្សរ៍ទី២១។ នៅក្នុងឯកសារណែនាំនេះ បំណិនជីវិតផ្តោតលើ “ បំណិនទន់” ជាចង្កោមនៃចរិតលក្ខណៈផ្ទាល់ខ្លួនដូចជា ទំនាក់ទំនង ការត្រិះរិះពិចារណា ការដោះស្រាយបញ្ហា ការច្នៃប្រឌិត... ដែលជាតម្រូវការនៅក្នុងបរិបទសង្គមណាមួយ ដើម្បីទំនាក់ទំនង និងធ្វើការជាមួយគ្នាឱ្យបានល្អ។ ការបង្រៀនបំណិនជីវិតតាមមូលដ្ឋាននឹងផ្តោតជាពិសេសក្នុងការអភិវឌ្ឍបំណិនទន់ក្នុងប្រធានបទ និងគំរូណាមួយដែលត្រូវបានជ្រើសរើសសម្រាប់ការបង្រៀន( សូមមើលជំពូក៤ )។

## ១.៤. បំណិនជីវិតតាមមូលដ្ឋាន

កម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋានឆ្នាំ២០១៨ បានណែនាំបញ្ញត្តិថ្មីនៃបំណិនជីវិតតាមមូលដ្ឋានជាមុខវិជ្ជាកាតព្វកិច្ច។ សិស្សត្រូវបានណែនាំឱ្យបង្កើតគម្រោង ឬស្វែងរកដំណោះស្រាយបញ្ហាក្នុងជីវភាពប្រចាំថ្ងៃ ស្វែងយល់ និងរៀនពីបរិបទក្នុងមូលដ្ឋានរបស់ពួកគេ ដោយសំដៅពិសេសលើប្រធានបទអាជីពងាយនិងសង្គម និងការអភិវឌ្ឍបំណិនមូលដ្ឋាន បំណិនអាជីវកម្មនិងគ្រប់គ្រង និងបំណិនបច្ចេកទេសជាចម្បង។ និយមន័យនេះមានការខុសគ្នាពីនិយមន័យមុន ដែលបំណិនជីវិតតាមមូលដ្ឋានគឺជាបំណិនអាជីពងាយ “មានជំនាញរកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់គ្រួសារ” ពង្រីកចំណេះដឹង បំណិន ឥរិយាបថ និងគុណតម្លៃផ្ទាល់ខ្លួន ដែលនឹងជួយសិស្សកសាងទស្សនវិស័យអនាគតរបស់ពួកគេ។

ប្រធានបទបំណិនជីវិតតាមមូលដ្ឋានជំរុញការអភិវឌ្ឍបំណិនជីវិតទាំងបំណិនមូលដ្ឋាន និងអាជីពស្របតាមគោលនយោបាយបំណិនជីវិត។

ចុងបញ្ចប់ការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន បានចូលរួមចំណែកដោយផ្ទាល់ដល់សមត្ថភាពគោល៣ ក្នុងចំណោម៨ ដែលកំណត់ដោយក្រសួងអប់រំក្នុងក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស ឆ្នាំ ២០១៦។ សមត្ថភាពគោលទាំងបីរួមមាន៖

- ៤.៤.បំណិនប្រាស្រ័យទាក់ទង និងធ្វើការងារជាក្រុម
- ៤.៥.បំណិនពិចារណា និងការបង្កើតថ្មី
- ៤.៧.បំណិនអភិវឌ្ឍបុគ្គល គ្រួសារ និងសង្គម

ការអភិវឌ្ឍសមត្ថភាពគោលទាំង៣នេះ ក៏នឹងជួយសម្រួលដល់សិស្ស ក្នុងការទទួលបាននូវសមត្ថភាពចុងក្រោយដែលត្រូវបានលើកឡើងនៅក្នុងក្របខណ្ឌកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា គឺចំណុច “៤.៨.បំណិនសហគ្រិនភាព និងភាពជាអ្នកដឹកនាំ” ដែលនៅពេលអនាគតរំពឹងថា សិស្សនឹងអនុវត្តសមត្ថភាពផ្សេងទៀតទាំងអស់ដើម្បី “ អាចធានាបាននូវភាពជោគជ័យ ក្នុងការតម្រង់ទិសរកប្រាក់ចំណូលពីអាជីវកម្មខ្នាតតូច” ។ វិធីសាស្ត្រដែលបានអនុវត្តក៏នឹងចូលរួមចំណែកក្នុងសមត្ថភាព ៤.៦ ផងដែរ៖ ការអនុវត្តចំណេះដឹង និងបំណិន។

[១]សូមស្រាវជ្រាវបន្ថែមលើ App ត្រីវិស័យ

# ជំពូក ២ បញ្ញត្តិនិងគំរូនៃការអប់រំបំណិនជីវិត

ការផ្លាស់ប្ដូរចុងក្រោយបានលើកឡើងក្នុងបញ្ញត្តិបំណិនជីវិត ដូចបានរៀបរាប់ខាងលើក្នុងបំណងឆ្លើយតបទៅនឹងតម្រូវការដែលកំពុងកើតឡើងថ្មីៗនៃសកលកម្មសង្គមដែលយើងកំពុងរស់នៅ ហើយបញ្ញត្តិដែលបានកែសម្រួលគឺផ្អែកលើអនុសាសន៍របស់វិស័យអប់រំ។

## ២.១. បំណិនជីវិត (បំណិនមូលដ្ឋាន និងបំណិនអាជីព)

ដ្យាក្រាមខាងក្រោមបង្ហាញពីបញ្ញត្តិ និងគំរូនៃការអប់រំបំណិនជីវិត៖







| បំណិនមូលដ្ឋាន( គំរូសង្គម ) | បំណិនអាជីព( គំរូអាជីពងាយ ) |
|---|---|
| បំណិនមូលដ្ឋាន ត្រូវបានបញ្ជ្រាបតាមមុខវិជ្ជាគោលទាំងអស់ ក្នុងនោះមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានក៏ដូចមុខវិជ្ជាគោលដទៃទៀតដែរ។ បំណិនមូលដ្ឋានរួមមាន៖<br>• ចំណេះដឹងទូទៅ( ភាសាខ្មែរ គណិតវិទ្យា ចំណេះដឹងទាក់ទងក្នុងសហគមន៍ ការយល់ដឹងពីពលរដ្ឋវិទ្យា សុខភាព បរិស្ថាន និងវប្បធម៌... )<br>• បំណិនបុរេវិជ្ជាជីវៈ( បំណិនទន់ ឬបំណិនសតវត្សរ៍ទី២១ )<br>• ឥរិយាបថ និងគុណតម្លៃផ្ទាល់ខ្លួន។<br>បំណិនមូលដ្ឋាន ដែលមានក្នុងការបង្រៀនបំណិនជីវិត | បំណិនអាជីពមានបំណងឱ្យសិស្សទទួលបាន៖<br>• បំណិនមូលដ្ឋាន<br>• បំណិនបច្ចេកទេស( កសិកម្ម សេវាកម្ម សិប្បកម្ម )<br>• បំណិនអាជីវកម្ម និងការគ្រប់គ្រង( បំណិន ទីផ្សារ ការសរសេរពាក្យសុំធ្វើការ( CV ) ការសម្ភាសសុំការងារ ធ្វើ ផែនការអនាគត គ្រូបង្រៀន គ្រូពេទ្យ ប៉ូលីស... )។<br>ការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន អំពីគំរូអាជីពងាយ៖ គឺសំដៅការបង្រៀនប្រធានបទអាជីពងាយ នៅក្នុងគំរូអាជីពងាយ។ គ្រូមិនត្រឹមតែផ្ដោតលើបំណិនបច្ចេកទេស |

តាមមូលដ្ឋាន៖ ក្នុងការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន សំដៅទៅលើគំរូនៃការបង្រៀន ដែលផ្តោតសំខាន់លើការ អភិវឌ្ឍបំណិនមូលដ្ឋានជាគំរូសង្គម។ ក្នុងនោះសិស្ស នឹងពង្រឹងចំណេះដឹង ដែលពាក់ព័ន្ធក្នុងមូលដ្ឋានរបស់ពួកគេ នឹងអភិវឌ្ឍបំណិនទន់ ឥរិយាបថ និងគុណតម្លៃផ្ទាល់ខ្លួនក្នុងការធ្វើការជាក្រុម ការអង្កេត និងការអនុវត្តតាមគំរូប្រធានបទ និងការណែនាំពីគ្រូ។

(ការចិញ្ចឹមមាន់ ការដាំដំណាំ... )ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់អាទិភាព ទៅលើការអភិវឌ្ឍបំណិនមូលដ្ឋានផងដែរ ( ទំនាក់ទំនង ការចរចា ការដោះស្រាយបញ្ហា... )។

ទន្ទឹមនឹងនោះ ក៏មានការអភិវឌ្ឍបំណិនអាជីវកម្ម និងគ្រប់គ្រងផងដែរ( ការគ្រប់គ្រងពេលវេលា វិធីបង្កើតអាជីវកម្ម មូលដ្ឋានគ្រឹះនៃទីផ្សារ ផែនការថវិកា... )។

## ២.២. យុទ្ធសាស្ត្របង្រៀនបំណិនជីវិត

មានយុទ្ធសាស្ត្របីសំខាន់ក្នុងការអនុវត្តបំណិនជីវិតនៅប្រទេសកម្ពុជា៖




**រូបភាព៖ យុទ្ធសាស្ត្រអនុវត្តបំណិនជីវិតនៅប្រទេសកម្ពុជា**

១- មុខវិជ្ជាសិក្សាគោលក្នុងកម្មវិធីសិក្សា៖ បំណិនមូលដ្ឋានគឺជាផ្នែកមួយនៃដំណើរការបង្រៀន និងរៀន នៅពេលការរៀនត្រូវបានរៀបចំតាមគោលវិធីឱ្យមានការចូលរួមកាន់តែច្រើន ដោយសកម្មភាពក្រៅថ្នាក់ជាផ្នែកនៃការរុករកនៅក្នុងពិភពពិតជាក់ស្តែង។

២- ការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន៖ បង្ហាញពីតម្រូវការរបស់អ្នកសិក្សាទាំងបំណិនមូលដ្ឋាន(សង្គម) និងបំណិនអាជីព។ កម្មវិធីសិក្សាបែបពិគ្រោះយោបល់នៅកម្រិតសាលារៀនបានបង្ហាញថា៖ អ្នកសិក្សា និងអ្នកពាក់ព័ន្ធអាចសម្រេចចិត្តនូវអ្វីដែលពួកគេចង់រៀន ដោយផ្អែកលើតម្រូវការជាក់ស្តែង និងមានការចូលរួមពីអ្នកពាក់ព័ន្ធនានា រួមទាំងអ្នកជំនាញនៅក្នុងមូលដ្ឋាន ក្នុងដំណើរការសិក្សារបស់ពួកគេ។ ការអប់រំបំណិនជីវិតតាមមូលដ្ឋានមានពីរគំរូគឺ គំរូសង្គម(ចំណេះដឹងទូទៅ យកចិត្តទុកដាក់ដោយឡែកទៅលើចំណេះដឹងទាក់ទងនឹងសង្គម បំណិនបុរេវិជ្ជាជីវៈ ឥរិយាបថ និងគុណតម្លៃផ្ទាល់ខ្លួន) និងគំរូអាជីពងាយ(បំណិនមូលដ្ឋាន បំណិនបច្ចេកទេស និងបំណិនអាជីវកម្មនិងការគ្រប់គ្រង)។

ក. គំរូសង្គមមានប្រធានបទជាច្រើនដូចជា ៖ សុខភាពនិងសុខុមាលភាព បរិស្ថាន អភិបាលកិច្ចល្អ វប្បធម៌ ទំនៀមទម្លាប់ សិល្បៈ សេដ្ឋកិច្ចសង្គម សិទ្ធិមនុស្ស (ឬប្រធានបទពាក់ព័ន្ធផ្សេងទៀតដែលត្រូវបានជ្រើសរើសដោយសាលារៀន និងសហគមន៍)។ ការបង្រៀននឹងផ្តោតជាចម្បងលើការអភិវឌ្ឍបំណិនមូលដ្ឋាន។

ខ. គំរូអាជីពងាយមានប្រធានបទជាច្រើនដូចជា ៖ កសិកម្ម សិប្បកម្ម សេវាកម្ម សហគ្រិនភាពនិងភាពជាអ្នកដឹកនាំ។ ការបង្រៀននឹងផ្តោតជាចម្បងទៅលើការអភិវឌ្ឍបំណិនអាជីព។

៣- កម្មវិធីបំណិនជីវិតផ្តោតសំខាន់លើ និន្នាការសកល បញ្ហានិងតម្រូវការ៖ ជាប្រធានបទដោយមានការឯកភាពពីភាគីម្ចាស់ជំនួយ និងអង្គការអន្តរជាតិនានាដូចជា ការអប់រំពីជំងឺអេដស៍ គំនិតផ្តួចផ្តើមសហគ្រិនភាព គ្រោះថ្នាក់នៃគ្រាប់មីន សុខភាពផ្លូវចិត្ត ការអភិវឌ្ឍបំណិនទន់ និងចំណេះដឹងហិរញ្ញវត្ថុ។ ជាបទពិសោធអ្នកផ្តល់ជំនួយ និងអង្គការអន្តរជាតិមួយចំនួនប្រើកម្មវិធីសិក្សាក្រសួង កាលវិភាគបំណិនជីវិតតាមមូលដ្ឋាន និងខ្លះទៀតត្រូវបានបង្រៀនជាសកម្មភាពកម្មវិធីសិក្សាបន្ថែម(កម្មវិធីសិក្សាក្រៅផ្លូវការ)។

**ទោះសិស្សរៀនតាមគំរូណាក៏ដោយ ចុងបញ្ចប់រំពឹងថាសិស្សនឹងអភិវឌ្ឍបានបំណិនដូចខាងក្រោម៖**
**បំណិនមូលដ្ឋាន (គំរូសង្គម) បំណិនអាជីព (គំរូអាជីពងាយ)**

| បំណិនមូលដ្ឋាន (គំរូសង្គម) | | បំណិនអាជីព (គំរូអាជីពងាយ) | |
|---|---|---|---|
| ចំណេះដឹងទូទៅ | ខ្លឹមសារជាក់លាក់ជួយសិស្សឱ្យសម្រេចចិត្តបានត្រឹមត្រូវផ្អែកតាមព័ត៌មានដែលគេបានយល់ដឹង ដូចជា៖<br>• ការអាន និងការគណនា<br>• អនាម័យ និងជំងឺក្នុងមូលដ្ឋាន និងបរិបទតំបន់<br>• ស្វែងយល់ពីបរិស្ថានជុំវិញខ្លួន<br>• ដំណើរការអភិវឌ្ឍតាមមូលដ្ឋាន<br>• សេដ្ឋកិច្ច និងកិច្ចការសង្គម<br>• និន្នាការសកល ។ល។ | បំណិនទូទៅ | • ចំណេះដឹងទូទៅ<br>• បំណិនបុរេវិជ្ជាជីវៈ (បំណិនទន់)<br>• ឥរិយាបថ និងគុណតម្លៃផ្ទាល់ខ្លួន |

| | | | |
|---|---|---|---|
| បំណិនបុរេវិជ្ជាជីវៈ (បំណិនទន់)[២] | បំណិនដែលជួយសិស្សទទួលបានជោគជ័យក្នុងការងារ និងជីវិតរស់នៅ៖<br>១- ការច្នៃប្រឌិត<br>២- ការត្រិះរិះពិចារណា<br>៣- ការដោះស្រាយបញ្ហា<br>៤- ការគ្រប់គ្រងខ្លួនឯង<br>៥- ទំនាក់ទំនង<br>៦- ភាពធន់<br>៧- កិច្ចសហប្រតិបត្តិការ<br>៨- ការចរចា<br>៩-ការសម្រេចចិត្ត<br>១០-ការគោរពលក្ខណៈចម្រុះ<br>១១- ការចូលរួម<br>១២- សមានចិត្ត | បំណិនអាជីវកម្ម និងគ្រប់គ្រង | បំណិនដែលជួយសិស្សទទួលបានជោគជ័យក្នុងការងារនិងអាជីវកម្ម៖<br>• ការធ្វើផែនការ និងចាត់ចែង<br>• ការគ្រប់គ្រងពេលវេលា<br>• ការគ្រប់គ្រងថវិកា<br>• ការស្វែងរកទីផ្សារ<br>• សហគ្រិនភាព<br>• ការស្វែងរកការងារ<br>• បច្ចេកទេសសម្ភាសន៍<br>• ពង្រឹងការងារ<br>• រៀនបន្ថែមជំនាញខ្លីៗ ... |
| ឥរិយាបថ និងគុណតម្លៃផ្ទាល់ខ្លួន | ចង្កោមគុណតម្លៃមួយចំនួនដែលជួយសិស្សឱ្យទទួលបាននូវសេចក្ដីថ្លៃថ្នូរ និងការគោរពដូចជា៖<br>• ភាពស្មោះត្រង់<br>• ការទទួលខុសត្រូវ<br>• ភាពយុត្តិធម៌<br>• ការមានអធ្យាស្រ័យល្អ<br>• ឥរិយាបថវិជ្ជមាន<br>• ការគោរពគ្នាទៅវិញទៅមក<br>• ការយល់ចិត្ត ... | បំណិនបច្ចេកទេស | ចង្កោមបំណិនមួយចំនួនដែលពាក់ព័ន្ធទៅនឹងបច្ចេកទេសក្នុងការប្រតិបត្តិអាជីពងាយដូចជា៖<br>• បដិសណ្ឋារកិច្ច<br>• បច្ចេកទេសសម្អាងការ<br>• បច្ចេកទេសចុងភៅ<br>• បច្ចេកទេសចិញ្ចឹមសត្វ<br>• បច្ចេកទេសដាំបន្លែ<br>• បច្ចេកទេសកាត់ដេរ<br>• បច្ចេកទេសជាងកំបោរ ... |

**កំណត់សម្គាល់៖** បំណិនទាំងនេះមានការរីកចម្រើនពីកម្រិតមូលដ្ឋានដល់កម្រិតមធ្យម និងខ្ពស់។ វាតម្រូវឱ្យគ្រូត្រួតពិនិត្យការរីកចម្រើនរបស់សិស្ស និងកំណត់គោលដៅរួមគ្នាដើម្បីអភិវឌ្ឍបំណិនដែលមានកម្រិតទាប។ ស្តង់ដាសិក្សាសម្រាប់ការអភិវឌ្ឍបំណិនទន់ (យោងតាមបំណិនទាំង១២ ដែលនឹងត្រូវពិនិត្យតាមដាន) ត្រូវបានបញ្ចូលក្នុងឯកសារណែនាំនេះ។

[២]បំណិនទាំងនេះ នឹងជាផ្នែកមួយនៃការវាយតម្លៃបំណិនជីវិតតាមមូលដ្ឋាន ប៉ុន្តែសាលារៀនអាចផ្តោតលើបំណិនបន្ថែមដើម្បីដោះស្រាយតម្រូវការរបស់អ្នកសិក្សា។

## ហេតុអ្វីការរៀនបំណិនជីវិតតាមមូលដ្ឋានមានសារៈសំខាន់?

ពីព្រោះការអប់រំបំណិនជីវិតតាមមូលដ្ឋានជំរុញឱ្យមានការរៀនសូត្រសកម្ម រៀនដោយខ្លួនឯង និងឆ្លុះបញ្ចាំង ហើយដោយសារតែការបង្រៀនបំណិនជីវិត គឺជាសមាសធាតុសំខាន់នៃមុខវិជ្ជាបំណិនជីវិតតាម មូលដ្ឋាន។ គ្រូនឹងធ្វើការដើម្បីផ្តល់ឱ្យសិស្សនូវ ឱកាស ឧបករណ៍ និងចំណេះដឹងដើម្បីអនុវត្តបំណិនទាំងនេះនៅក្នុងជីវិតប្រចាំថ្ងៃ និងរៀបចំវាសម្រាប់ពេលអនាគត។

ដោយសារតែចាប់ផ្តើមពីបញ្ហា ឬឱកាសជាក់ស្តែងសិស្សនឹងរៀនរកដំណោះស្រាយលើប្រធានបទដែលពាក់ព័ន្ធនឹងជីវិតប្រចាំថ្ងៃរបស់ពួកគេ។

ដោយសារតែសិស្សនឹងរៀនដោយសប្បាយរីករាយ និងចូលរួមធ្វើសកម្មភាពដែលនឹងមានផលប៉ះពាល់ជាវិជ្ជមានដល់បរិស្ថានសាលារៀនទាំងមូល បង្កើនកិច្ចសហប្រតិបត្តិការ និងឥរិយាបថវិជ្ជមាន។

### ស្វ័យត្រួតពិនិត្យជំពូក១ និងជំពូក២

ចូរចំណាយពេល១០នាទីដើម្បីពិនិត្យការយល់ដឹងរបស់អ្នក

| | | |
|---|---|---|
| ១ | មានវិធីជាច្រើនក្នុងបង្រៀនបំណិនជីវិតក្នុងប្រទេសកម្ពុជា។ | ☐ បាទ/ចាំ ☐ ទេ<br>ចូរពណ៌នា:........................................... |
| ២ | បំណិនជីវិតតាមមូលដ្ឋានជាមុខវិជ្ជាគោល។ | ☐ បាទ/ចាំ ☐ ទេ |
| ៣ | អ្វីជាបំណិនមូលដ្ឋាន? | ☐ ចំណេះដឹងក្នុងមូលដ្ឋាន បំណិនបុរេវិជ្ជាជីវៈឥរិយាបថនិងគុណតម្លៃផ្ទាល់ខ្លួន<br>☐ គុណតម្លៃ<br>☐ កសិកម្ម និងសិប្បកម្ម |
| ៤ | បំណិនអាជីពងាយត្រូវបានបង្រៀនក្រៅផ្លូវការ និងតាមរយៈសកម្មភាពកម្មវិធីសិក្សាបន្ថែម។ | ☐ បាទ/ចាំ ☐ ទេ |
| ៥ | តើមួយណាជាគូគំរូនៃការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន? | ☐ គំរូសង្គម និងគំរូអាជីពងាយ<br>☐ គំរូកសិកម្ម និងគំរូសិប្បកម្ម<br>☐ គំរូសង្គម និងគំរូបំណិនមូលដ្ឋាន |
| ៦ | ហេតុអ្វីបានជាការសិក្សាបំណិនជីវិតតាមមូលដ្ឋានមានសារៈសំខាន់(គូសចម្លើយដែលត្រូវទាំងអស់)? | ☐ បំណិនជីវិតតាមមូលដ្ឋានជំរុញការសិក្សា កាន់តែសកម្ម<br>☐ បំណិនជីវិតតាមមូលដ្ឋានជំរុញក្នុងការប្រើវិធីសាស្រ្តសិក្សាតាមបែបរិះរក<br>☐ បំណិនជីវិតតាមមូលដ្ឋានបង្រៀនពីមុខរបរដល់សិស្ស |

ល្មអពុន្ ៈ៥

ញាយ្មេបង្គអវម្លែ្ពុទ្ធ គង៉ុលម្លែ្ ៈ៦ នរ ៈ៦ ទខឹ្លុ ឃ្លើគឹរុមហេង៉ពុទ្ធ ឯណហារម្ល ៉ៈរព្លឃ្លើររ៉ាធទប្លបក្ ៉ទឃ្លើលគំពុង៉

ពុទ្ធៈហបរេ្ ៈឃ ឃ្/នឃ ៈ៧ ៈ ឃេរ្សីនគ្ន័ ឃេរ្សីឃ្លមរ្ព្លួនប្អូបក្នព្រំែរណេយេម្នុហេប៉្ ៈម ៉លមេបេម្លល្អឃ្លើរខង៉ពុង៉

នឃ្លើលគំនប្អូបក្ណឈ៌វ៉ៃណេយេៈខ៉ទឃ្លើលគំគយេមរ្ព្លួនប្អូបក្នព្រំែរណេយេ ៈម ឃ្លឺជពុឆ្ញែរយេស៉ុរលេធ្ល្ ឃ្/នឃ ៈ៤

**ៈញាគ្ហ៊ីរេធ**

# ជំពូក ៣ ការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន

## ៣.១. ការជ្រើសរើសប្រធានបទ

ដើម្បីរៀបចំការប្រជុំជ្រើសរើសប្រធានបទឱ្យមានប្រសិទ្ធភាព សាលារៀនចាំបាច់ត្រូវត្រៀមថាត្រូវធ្វើអ្វីខ្លះ ទាំងមុនពេលប្រជុំ ពេលប្រជុំ និងក្រោយប្រជុំ។ ម្យ៉ាងទៀតគណៈគ្រប់គ្រងសាលារៀនត្រូវពន្យល់អ្នកដែលចូលរួមអំពីអ្វីជាបំណិនជីវិត ការរំពឹងទុកពីអ្នកចូលរួម ការប្រើប្រាស់បំណិនឬជំនាញដែលពួកគាត់មានក្នុងការងារ ដើម្បីឱ្យអ្នកចូលរួមងាកមកគាំទ្រ និងសហការជាមួយគ្រូក្នុងការអនុវត្ត។ ការប្រជុំត្រូវមានការបង្ហាញពីភាពចាំបាច់នៃការជ្រើសរើសប្រធានបទ ដោយបង្កើតសកម្មភាពជជែកដេញដោលរកហេតុផល។ រាល់ការប្រជុំជ្រើសរើសប្រធានបទត្រូវមានកំណត់ត្រាអង្គប្រជុំដោយមានបញ្ជីវត្តមាន។

### ក-ពេលវេលាប្រជុំជ្រើសរើសប្រធានបទ ៖ ខែតុលា

**ខ-អ្នកចូលរួម ៖** នាយកសាលាត្រូវទំនាក់ទំនង និងអញ្ជើញក្រុមពិនិត្យតាមដានបច្ចេកទេសថ្នាក់ស្រុក(DTMT) អាជ្ញាធរមូលដ្ឋាន សហគមន៍ មាតាបិតាសិស្ស អ្នកជំនាញសហគមន៍ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមប្រជុំជ្រើសរើសប្រធានបទផ្អែកតាមតម្រូវការរបស់ពួកគាត់ដោយមានលិខិតអញ្ជើញ។ នាយកសាលា ត្រូវជម្រាបជូនដំណឹងដល់សមាជិកដែលត្រូវចូលរួមក្នុងអង្គប្រជុំ ក្នុងចំណោមគ្រូបង្រៀន សិស្ស សហគមន៍ ដូចខាងក្រោម៖

១- **កំណត់រកបញ្ហា និងឱកាស**ដែលជះឥទ្ធិពលលើជីវិតប្រចាំថ្ងៃ ការសិក្សា និងការងាររបស់សិស្ស ដែលត្រូវដោះស្រាយ និងរៀនសូត្រ។

២-**កំណត់បញ្ហាអាទិភាព** ៦ទៅ៩ ប្រធានបទ(ដែលបានកំណត់ក្នុងចំណុច១) ដែលត្រូវសិក្សានៅសាលារៀនដោយប្រើប្រាស់តារាងសកម្មភាព ដើម្បីជួយដល់ដំណើរការជ្រើសរើស។ កម្រិតថ្នាក់នីមួយៗរៀនពីរប្រធានបទក្នុងមួយឆ្នាំសិក្សា តាមក្របខណ្ឌកម្មវិធីសិក្សាបានកំណត់ ២ម៉ោងសិក្សាក្នុងមួយសប្តាហ៍នៅបឋមសិក្សា និង១ម៉ោងសិក្សាក្នុងមួយសប្តាហ៍នៅមធ្យមសិក្សាបឋមភូមិ។

៣-**បែងចែកប្រធានបទតាមកម្រិតថ្នាក់នីមួយៗ** (ប្រធានបទអ្វីខ្លះរៀនថ្នាក់ទី៤, ៥, ៦ និងថ្នាក់ទី៧, ៨, ៩) ទៅតាមការយល់ដឹង សមត្ថភាព និងលទ្ធភាព។

៤- **កំណត់ធនធានក្នុងសាលារៀន និងសហគមន៍** ដើម្បីជួយដល់ការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន។ ធនធានក្នុងសាលារៀនរួមមាន សម្ភារៈ និងថវិកាសាលារៀន។ រីឯធនធានសហគមន៍រួមមានអ្នកជំនាញតាមផ្នែកប្រធានបទដែលបានជ្រើសរើសដូចជា កសិករគំរូ បុគ្គលិកមណ្ឌលសុខភាព បុគ្គលិកធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងជនបង្គោលឃុំទទួលបន្ទុកកិច្ចការនារីនិងកុមារ នគរបាលប៉ុស្តិ៍រដ្ឋបាល អាជីវករដែលអាចចូលរួមចែករំលែកបទពិសោធរបស់ខ្លួនដល់សិស្ស។

៥- បញ្ចូលការបង្រៀន និងរៀនមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានក្នុងផែនការអភិវឌ្ឍសាលារៀនប្រចាំឆ្នាំ ដើម្បីស្វែងរកធនធានចាំបាច់សម្រាប់ការអនុវត្តកម្មវិធីនេះ។

**តារាង-ឧទាហរណ៍អំពីបញ្ហា និងឱកាស**

| កម្រិតថ្នាក់ | បញ្ហា (គំរូសង្គម) | ឱកាស (គំរូអាជីពងាយ) |
| --- | --- | --- |
| **បឋមសិក្សា** | សំរាមនៅក្នុងសាលារៀន<br>ការគំរាមកំហែង<br>គ្រោះថ្នាក់ចរាចរណ៍<br>.............................. | បរិស្ថានស្អាត<br>អាហារប្រកបដោយគុណភាព<br>សិក្សាពីវប្បធម៌ជនជាតិផ្សេងៗ<br>.............................. |
| **អនុវិទ្យាល័យ** | អំពើឆបោកតាមអ៊ីនធឺណិត<br>កង្វះព័ត៌មានអំពីការសិក្សានាពេលអនាគត<br>បញ្ហាផ្លូវចិត្តការគំរាមកំហែង<br>.............................. | ស្វែងយល់ពីជម្រើសនាពេលអនាគត<br>អ្នកស្ម័គ្រចិត្ត<br>បេតិកភណ្ឌវប្បធម៌<br>ស្វែងយល់ពីការច្នៃប្រឌិតក្នុងវិស័យកសិកម្ម<br>.............................. |

**ធ្វើដូចម្តេចដើម្បីធានាថា សិស្សបានចូលរួម ?**

## ក.ការអនុវត្តនៅឆ្នាំដំបូង

នាយកសាលា ឬគ្រូបង្រៀន ត្រូវជួយក្រុមប្រឹក្សាកុមារឱ្យជួបជាមួយសិស្សផ្សេងទៀតនៅក្នុងថ្នាក់រៀន មុនពេលដែលសាលារៀនរៀបចំកម្មវិធីសិក្សាបែបពិគ្រោះយោបល់នៅកម្រិតសាលារៀន ដើម្បីប្រមូលគំនិត យោបល់ក្នុងការជ្រើសរើសប្រធានបទដែលគេត្រូវការ។ គ្រូ ឬនាយកសាលានឹង៖

> ដំណើរការជ្រើសរើសប្រធានបទត្រូវផ្តល់អាទិភាពដល់ចំណាប់អារម្មណ៍ និងតម្រូវការរបស់សិស្ស។

- ជួយសិស្សក្នុងការជ្រើសរើស ប្រធានបទដែលទាក់ទង ក្នុងជីវិតរស់នៅប្រចាំថ្ងៃ ដែលអាចជាបញ្ហាជះឥទ្ធិពល ឬឱកាសការងារដល់ពួកគេ។
- ជួយសិស្សក្នុងការលើកសំណើរៀបចំការប្រជុំជ្រើសរើសប្រធានបទ និងបោះឆ្នោតជ្រើសរើសប្រធានបទ
- ក្រុមប្រឹក្សាកុមារគាំទ្រប្រធានបទដែលទទួលបានសំឡេងច្រើនជាងគេ។



ត្រូវធានាថាសិស្សទាំងអស់ចូលរួមតាមរយៈការលើកឡើងពីបញ្ហាដែលពួកគេបានជួបប្រទះញឹកញាប់នៅក្នុងសហគមន៍ផ្ទាល់។

- ផ្តល់ឱកាសដល់អ្នកស្នើប្រធានបទដែលមានសំឡេងគាំទ្រតិចបកស្រាយ និងពន្យល់ហេតុផល ព្រោះថា ពេលខ្លះសំឡេងភាគតិចក៏មានឥទ្ធិពលខ្លាំង និងចាំបាច់សម្រាប់សហគមន៍ដែរ។

## ខ. ការអនុវត្តនៅឆ្នាំបន្តបន្ទាប់

- គ្រូបង្រៀន និងសិស្សពិនិត្យមើលប្រធានបទបំណិនជីវិតតាមមូលដ្ឋាន ដែលបានអនុវត្តឆ្នាំកន្លងទៅដើម្បីវាយតម្លៃពីសកម្មភាព បញ្ហាប្រឈម ហើយប្រធានបទអ្វីដែលចាប់អារម្មណ៍ ដើម្បីសិក្សានៅឆ្នាំសិក្សាថ្មី។
- សាលាត្រូវរក្សាទុកឯកសារនៃដំណើរការ សម្រាប់ពិគ្រោះយោបល់ជាមួយ មន្ទីរអប់រំ យុវជន និងកីឡា រាជធានីខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក ក្រុង ខណ្ឌ។

**ជាទូទៅ មុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានបែងចែកជាពីរគំរូប្រធានបទ**

| គំរូ | ប្រធានបទ | ឧទាហរណ៍លម្អិតជម្រើសប្រធានបទ |
|---|---|---|
| - **ប្រធានបទសង្គម**<br>- **បំណិនគោលដៅ** : បំណិនមូលដ្ឋាន (ចំណេះដឹងដែលពាក់ព័ន្ធក្នុងមូលដ្ឋាន បំណិនបុរេវិជ្ជាជីវៈ និងគុណតម្លៃផ្ទាល់ខ្លួន) | សុខភាព និង សុខុមាលភាព | • ទឹក អនាម័យ និងអនាម័យខ្លួនប្រាណ<br>• អំពើហិង្សាក្នុងគ្រួសារ<br>• ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន<br>• ច្បាប់ចរាចរណ៍<br>• ការអប់រំអំពីទំនាក់ទំនងផ្លូវភេទ<br>• ភាពពេញវ័យ<br>• សុខភាពបញ្ញា ស្មារតី<br>•ការគំរាមកំហែង |
| | បរិស្ថាន | • ប្រព័ន្ធផ្តល់ព័ត៌មានជាមុន ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ<br>• បម្រែបម្រួលអាកាសធាតុ<br>• ទឹកស្អាត<br>• ការគ្រប់គ្រងកាកសំណល់<br>• ការកែច្នៃឡើងវិញ |
| | អភិបាលកិច្ចល្អ | • ទំនាក់ទំនង និងការបង្កើតសន្តិភាព<br>• អាជ្ញាធរមូលដ្ឋាន តួនាទី និងការទទួលខុសត្រូវ<br>• ការបោះឆ្នោតតាមមូលដ្ឋាន |
| | វប្បធម៌ ប្រពៃណី និងសិល្បៈ | • វប្បធម៌ខ្មែរ និងក្រុមជនជាតិភាគតិចផ្សេងៗ តន្ត្រី ប្រពៃណី ម្ហូបអាហារ ពិធីបុណ្យផ្សេងៗ សម្លៀកបំពាក់ប្រពៃណី ចម្រៀង រឿងនិទាន របាំ។ |

| | | | |
|---|---|---|---|
| | សេដ្ឋកិច្ចសង្គម<br>សិទ្ធិមនុស្ស | • សិទ្ធិកុមារ ការយល់ដឹងពីយេនឌ័រ ការប្រកាន់ពូជសាសន៍ វិធីថែរក្សាសុខភាព ការរៀបចំគេហដ្ឋាន អាហារ និងទឹកដែល មានសារជាតុចិញ្ចឹមគ្រប់គ្រាន់ ការទទួលបានការអប់រំ។ | |
| - **គំរូអាជីពងាយ**<br>- **បំណិនគោលដៅ** :<br>បំណិនមូលដ្ឋាន<br>បំណិនបច្ចេក | កសិកម្ម | • សួនដំណាំ និងចំណីអាហារ<br>• សួនជីវៈចម្រុះ<br>• ការដាំដំណាំ ការចិញ្ចឹមសត្វ | |
| | សិប្បកម្ម | • ការផលិតអំបោស ត្រកផ្កា ការបត់ក្រដាស ការសូន្យរូប... | |
| | សេវាកម្ម | • បដិសណ្ឋារកិច្ច ការកាត់សក់ គ្រូពេទ្យ គ្រូបង្រៀន ប៉ូលីស...<br>• ការចម្អិនអាហារ ... | |
| **បំណិនគោលដៅ:**<br>បំណិន បច្ចេកទេស និងបំណិនគ្រប់គ្រងអាជីវកម្ម | សហគ្រិនភាព និងភាពជាអ្នកដឹកនាំ | **បឋមសិក្សា និង អនុវិទ្យាល័យ**<br>• ការអប់រំហិរញ្ញវត្ថុ<br>• ទីផ្សារ<br>• ការអភិវឌ្ឍអាជីវកម្ម<br>• ការសន្សំ និងការចំណាយ<br>• សហគ្រាសសង្គម និងកុមារ | អនុវិទ្យាល័យ<br>• ការប្រឹក្សាអាជីព ( Appត្រីវិស័យ )<br>• ការតម្រង់ទិសការងារនៅអនាគត<br>• សហគ្រិនភាព |

វីដេអូអំពីការជ្រើសរើសប្រធានបទ៖ សូមទស្សនាវីដេអូដំណើរការជ្រើសរើសប្រធានបទ មាននៅក្នុងគេហទំព័រក្រសួងអប់រំ យុវជន និងកីឡា។

សូមអានសំណួរខាងក្រោមមុននឹងទស្សនាវីដេអូ។ ខ្លឹមសារសំណួរនឹងជួយអ្នកឱ្យយល់ពីបញ្ញត្តិសំខាន់ៗដែលវីដេអូបានបង្ហាញ។

• តើសាលារៀនជ្រើសរើសប្រធានបទបំណិនជីវិតតាមមូលដ្ឋាននៅពេលណា ?
• ហេតុអ្វីយើងត្រូវជ្រើសរើសប្រធានបទមុនបវេសនកាល ?
• តើការជ្រើសរើសប្រធានបទមានដំណើរការយ៉ាងដូចម្តេច ?
• តើអ្នកណាខ្លះចូលរួមក្នុងដំណើរការជ្រើសរើសប្រធានបទ ?
• តើការចូលរួមរបស់តំណាងសហគមន៍ មាតាបិតាសិស្ស នាយកសាលា គ្រូបង្រៀន និងសិស្ស មានសារៈសំខាន់យ៉ាងដូចម្តេច ?
• តើអ្នកធានាថា សិស្សចូលរួមឬទេ ?

## ៣.២. វិធីសាស្ត្របង្រៀន និងរៀនមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន

មុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន មានបំណងលើកកម្ពស់សិស្សជាមជ្ឈមណ្ឌលនៃដំណើរការសិក្សារបស់ពួកគេ។ នៅដើមឆ្នាំសិក្សា សហគមន៍ សាលារៀន ជាមួយនឹងសិស្ស ជ្រើសរើសប្រធានបទសម្រាប់រៀន។ គោលដៅចុងក្រោយនៃមុខវិជ្ជានេះគឺឱ្យសិស្សរៀនដើម្បីកសាងវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទានិងគុណតម្លៃរបស់ពួកគេជាប្រយោជន៍ក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ គ្រូបង្រៀនមានតួនាទីសម្របសម្រួលក្នុងដំណើរការបង្រៀន និងរៀន ដោយប្រើគោលវិធីសិស្សមជ្ឈមណ្ឌល ដើម្បីធានាការចូលរួមរបស់សិស្ស និងការអភិវឌ្ឍបំណិនទន់។ ទន្ទឹមនេះ គ្រូបង្រៀនក៏ទទួលចំណេះដឹង និងបច្ចេកទេសពីអ្នកជំនាញតាម មូលដ្ឋានផងដែរ។ ជាចាំបាច់យើងត្រូវផ្លាស់ប្ដូរការបង្រៀនពីឱ្យសិស្សទន្ទេញចាំមាត់ ដោយប្រើវិធីសាស្ត្របង្រៀនថ្មីដែលជួយជំរុញការចូលរួមរបស់សិស្សនៅក្នុងដំណើរការសិក្សា។ បើតាមទ្រឹស្តី ប្លូមតាក់សូណូមី យើងអាចនិយាយថា ការរៀនដោយទន្ទេញចាំមាត់ អាចមានប្រយោជន៍ចំពោះបំណិននៅកម្រិតទាបដូចជា “ការចងចាំ” និង “ការយល់ដឹង” ប៉ុន្តែមិនល្អសម្រាប់បំណិនកម្រិតខ្ពស់ដូចជា “ការអនុវត្ត” “ការវិភាគ” “ការវាយតម្លៃ” “ការបង្កើតថ្មី” ។ ជំពូកនេះនឹងណែនាំបង្ហាញវិធីសាស្ត្របង្រៀនតាមបែប ការសិក្សាផ្អែកលើបញ្ហា(PBL) ជាវិធីបង្រៀនដ៏សមស្របបំផុតសម្រាប់អភិវឌ្ឍបំណិនកម្រិតខ្ពស់។

### ក- វិធីសាស្ត្របង្រៀន និងរៀនតាមបែបការសិក្សាផ្អែកលើបញ្ហា (PBL)



រូបភាព៖ ទំនាក់ទំនងរវាងវិធីសិក្សាបែបការរិះរកនិង វិធីសិក្សាផ្អែកលើបញ្ហា និងការសិក្សាបែបសកម្ម

- ការសិក្សាផ្អែកលើបញ្ហា គឺជាបច្ចេកទេសឱ្យសិស្សសិក្សាបែបរិះរក ដើម្បីដោះស្រាយបញ្ហាជាក់ស្តែង ដោយចាប់ផ្តើមពីសំណួរបើក។ វិធីនេះជំរុញតួនាទីសិស្សជាមជ្ឈមណ្ឌលក្នុងការសិក្សា ដោយចាប់ផ្តើមពីបញ្ហាក្នុងជីវិតរស់នៅជាក់ស្តែង ដែលលើកយកមកសិក្សាសម្រាប់មុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន។
- ចាប់ផ្តើមពីបញ្ហាក្នុងជីវិតរស់នៅជាក់ស្តែង ឬតម្រូវការតាមមូលដ្ឋានដែលប៉ះពាល់ដល់សិស្ស ឧទា. ជំងឺគ្រុនចាញ់ កង្វះអនាម័យខ្លួនប្រាណ កង្វះប្រឹក្សាអាជីព ការប្រើប្រាស់គ្រឿងញៀននៅក្នុងភូមិ ការចូលរួមតិចតួចរបស់សិស្សនៅក្នុងការងារសង្គម...)លើកកម្ពស់ការអភិវឌ្ឍបំណិនទន់ (ការសហការ ការដោះស្រាយបញ្ហា ការត្រិះរិះពិចារណា ទំនាក់ទំនង)
- សិស្សអាចរៀនពីអ្នកជំនាញក្នុងមូលដ្ឋាននូវបទពិសោធ បច្ចេកទេស ការគ្រប់គ្រងអាជីវកម្ម...
- លើកកម្ពស់បំណិនស្វ័យសិក្សា រៀនដោយ អនុវត្ត និងឆ្លុះបញ្ចាំង ដើម្បីបង្កើតគំនិតថ្មីពីការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធឺណិត ទស្សនាវដ្តី...

- លទ្ធផលរំពឹងទុកគឺជាដំណោះស្រាយ (អ្វីដែលអាចកើតមាន ១-ដំណើរការនៃការសិក្សាមានការជជែកដេញដោល វិភាគ ពិចារណា និងរកដំណោះស្រាយ ២-ផលិតផលរួមមាន ផលដំណាំ ផលចិញ្ចឹម កម្រងស្នាដៃសិស្ស ...)។

សិស្សកសាងចំណេះដឹងផ្ទាល់ខ្លួន ក្រោមការណែនាំរបស់គ្រូ ដែលគាំទ្រពួកគេគ្រប់ជំហាននៃការរៀនសូត្រ( ១.កំណត់នូវអ្វីដែលគេដឹង; ២.រកមើលព័ត៌មានចាំបាច់ ៣.វិភាគទិន្នន័យដែលប្រមូលបាន ៤.កំណត់ចម្លើយចំពោះបញ្ហា ៥.បង្ហាញការសន្និដ្ឋាន ៦.ឆ្លុះបញ្ចាំង

តួនាទីរបស់គ្រូបង្រៀនគឺជួយសម្រួលដល់ដំណើរការនេះ ហើយនៅពេលរៀបចំផែនការបង្រៀនគ្រូត្រូវបញ្ចូលសកម្មភាពដែលជំរុញសិស្សឱ្យមានការចូលរួម។ ការអនុវត្តវិធីសាស្រ្តបង្រៀនតាមបែបការសិក្សាផ្អែកលើបញ្ហា គ្រូបង្រៀនត្រូវធ្វើតាមចំណុចសំខាន់ៗដូចខាងក្រោម៖

- កំណត់បញ្ហាដែលមិនស្មុគស្មាញពេក ដោយគិតពីអាយុរបស់សិស្ស និងបទពិសោធជាមុននៅពេលប្រើវិធីសាស្រ្តការសិក្សាផ្អែកលើបញ្ហា។ (បញ្ហានឹងត្រូវបានជ្រើសរើសក្នុងអំឡុងពេលដំណើរការកម្មវិធីសិក្សាពិគ្រោះយោបល់នៅកម្រិតសាលារៀន ហើយនៅពេលនោះគ្រូនឹងសម្របសម្រួលដល់ដំណើរការ ផ្តល់នូវធាតុចូលលើបញ្ហាដែលបានកំណត់)។

- លើកកម្ពស់ការងារក្រុម និងកិច្ចសហការក្នុងការរៀនសូត្រ។

- ផ្តោតលើដំណើរការនៃការដោះស្រាយបញ្ហា ក៏ដូចជាដំណោះស្រាយចុងក្រោយ (មានដំណោះស្រាយច្រើន)។ សិស្សនឹងអង្កេតបញ្ហាជីវិតជាក់ស្តែង។ សិស្សអាចកំណត់ដំណោះស្រាយដែលពួកគេនឹងមិនអាចអនុវត្តបានដោយសារកង្វះខាតធនធាន ឬជំនាញ ប៉ុន្តែពួកគេនឹងរៀនពីដំណើរការដើម្បីកំណត់បញ្ហានោះ។ បំណិនដំណោះស្រាយបញ្ហានឹងត្រូវបានអភិវឌ្ឍ ហើយសិស្សនឹងអាចអនុវត្តដំណើរការនេះក្នុងបរិបទផ្សេងទៀតដើម្បីដោះស្រាយបញ្ហាក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។

- ការសិក្សាឆ្លុះបញ្ចាំង៖ តើខ្ញុំបានរៀនអ្វីខ្លះ? (ចំណេះដឹង បំណិន និងគុណតម្លៃផ្ទាល់ខ្លួន) តើខ្ញុំរៀនដោយរបៀបណា? តើមានអ្វីកើតឡើងប្រសិនបើខ្ញុំធ្វើបែបនេះ? តើខ្ញុំអាចធ្វើខុសពីនេះបានទេនៅពេលក្រោយ? ប្រសិនបើខ្ញុំជាអ្នក តើខ្ញុំអាចធ្វើអ្វី ឬមានអារម្មណ៍យ៉ាងណា? ...។

- កំណត់ហេតុផ្ទាល់ខ្លួន៖ គ្រូឱ្យសិស្សម្នាក់ៗមានសៀវភៅកំណត់ហេតុផ្ទាល់ខ្លួន ដើម្បីកត់ត្រាការឆ្លុះបញ្ចាំងរបស់ពួកគេពីបណ្ណវាយតម្លៃការសិក្សា។

## ខ- វិធីអនុវត្តការសិក្សាផ្អែកលើបញ្ហា : ដំណើរការសិក្សា៦ដំណាក់កាល

គ្រូនឹងប្រើវិធីសាស្រ្ត ៦ដំណាក់កាលជាគោលការណ៍ដើម្បីរៀបចំផែនការបង្រៀនរបស់ពួកគេ។

ឯកសារណែនាំនេះស្នើឱ្យមានដំណើរការបង្រៀន៦ដំណាក់កាល ដើម្បីជួយសម្រួលដល់ការងាររបស់គ្រូនៅក្នុងថ្នាក់រៀន ដើម្បីប្រើប្រាស់ក្នុងការអនុវត្តបច្ចេកទេសសិក្សាផ្អែកលើបញ្ហា។ នៅពេលដែលគ្រូអនុវត្តតាមដំណើរការ

៦ដំណាក់កាល ពួកគេត្រូវបានដឹកនាំដោយស្វ័យប្រវត្តិក្នុងការប្រើបច្ចេកទេសសិក្សាផ្អែកលើបញ្ហាក្នុងការបង្រៀនរបស់ពួកគេ ហេតុដូច្នេះហើយ គ្រូត្រូវប្រើវិធីសាស្ត្របង្រៀន៦ដំណាក់កាលជាមូលដ្ឋានដើម្បីរៀបចំផែនការបង្រៀនរបស់ពួកគេ។

- **ដំណាក់កាលទី១** ស្វែងយល់ប្រធានបទ (បញ្ហា/ឱកាស)
- **ដំណាក់កាលទី២** ប្រមូលព័ត៌មាន
- **ដំណាក់កាលទី៣** វិភាគព័ត៌មាន
- **ដំណាក់កាលទី៤** អភិវឌ្ឍផែនការផ្សព្វផ្សាយ
- **ដំណាក់កាលទី៥** អនុវត្តផែនការសកម្មភាព
- **ដំណាក់កាលទី៦** ឆ្លុះបញ្ចាំង និងវាយតម្លៃ

**សកម្មភាពក្នុងដំណាក់កាលនីមួយៗ**

- ១. ការសិក្សាសកម្ម និងស្វ័យសិក្សា
- ២. ការងារក្រុម និងបុគ្គលរៀងខ្លួន
- ៣. ការអភិវឌ្ឍបំណិនទន់
- ៤. ការឆ្លើយតបពីគ្រូ និងការឆ្លុះបញ្ចាំងខ្លួនឯងរបស់សិស្ស

នៅដំណាក់កាលនីមួយៗ តម្រូវឱ្យគ្រូរកសកម្មភាពដែលគាំទ្រដូចដ្យាក្រាមខាងឆ្វេង។

ដើម្បីស្វែងយល់បន្ថែមពីដំណើរការបង្រៀន៦ដំណាក់កាល សូមរកមើលវីដេអូតាមគេហទំព័ររបស់ក្រសួងអប់រំ។ សូមឆ្លើយសំណួរខាងក្រោម ដើម្បីឆ្លុះបញ្ចាំងពីគោលគំនិតសំខាន់ៗដែលបង្ហាញក្នុងវីដេអូ។

សំណួរដើម្បីជំរុញការឆ្លុះបញ្ចាំងលើវីដេអូអំពីដំណើរការ៦ដំណាក់កាលសម្រាប់ការបង្រៀនប្រធានបទបំណិនជីវិត

1- តើការបង្រៀននិងរៀន ៦ដំណាក់កាលមានដំណើរការយ៉ាងដូចម្ដេច?

2- តើគ្រូបង្រៀនមានតួនាទីអ្វីខ្លះក្នុងដំណាក់កាលនីមួយៗ?

3- តើយើងអាចរៀបចំសកម្មភាពផ្សេងពីសកម្មភាពដែលបានលើកឡើងនៅក្នុងវីដេអូបានទេ? បើមិនបាន ហេតុអ្វី?

4- តើមានសកម្មភាពអ្វីទៀតដែលអាចរៀបចំនៅដំណាក់កាលទី១? ហើយនិងនៅក្នុងដំណាក់កាលទី២ ឬ ៥? ហេតុអ្វីត្រូវរៀបចំសកម្មភាពទាំងនោះ?

5- តើគ្រូនិងសិស្សមានភាពសកម្មយ៉ាងដូចម្ដេចក្នុងដំណើរការរៀននិងបង្រៀន៦ដំណាក់កាល?

6- តើសិស្សនឹងអភិវឌ្ឍបំណិនអ្វីខ្លះនៅក្នុងដំណើរការបង្រៀននិងរៀន៦ដំណាក់កាលរបស់ពួកគេ?

7- តើអ្វីជាគោលបំណងនៃដំណាក់កាលនីមួយៗ? (ដំណាក់កាលទី១?ដំណាក់កាលទី២? ល។ )

សូមមើលជំពូក ៥ សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីផែនការបង្រៀន។

## ខ-១. តួនាទីគ្រូបង្រៀន និងសិស្ស

| តួនាទីគ្រូបង្រៀន | តួនាទីសិស្ស |
|---|---|
| បង្រៀន | កសាងចំណេះដឹងរបស់ពួកគេ |
| ធ្វើជាគំរូ | រៀនសូត្រដោយខ្លួនឯងផ្ទាល់ |
| ផ្តល់ធនធាន | យកចិត្តទុកដាក់ស្តាប់គ្រូ និងមិត្តភក្តិ |
| រៀបចំសកម្មភាព | រកដំណោះស្រាយ |
| ណែនាំសិស្សធ្វើសកម្មភាព | ទទួលខុសត្រូវភារកិច្ចរបស់ខ្លួន |
| សម្របសម្រួលដំណើរការរៀន | រៀនធ្វើការជាមួយមិត្តភក្តិ |
| ផ្តល់យោបល់ | ស្វ័យវាយតម្លៃ |
| វាយតម្លៃ | |

## ខ-២. អត្ថប្រយោជន៍ក្នុងការប្រើប្រាស់ការសិក្សាផ្អែកលើបញ្ហា (PBL)

មានអត្ថប្រយោជន៍ដ៏សំខាន់ជាច្រើនក្នុងការប្រើប្រាស់ PBL៖

- សិស្សរៀនសូត្រអំពីបទពិសោធជីវិតជាក់ស្តែង
- សិស្សរៀនផ្ទេរចំណេះដឹង និងបំណិន
- សិស្សរៀនពីរបៀបធ្វើការជាក្រុម និងអភិវឌ្ឍបំណិនទន់ជាច្រើន
- សិស្សមានការលើកទឹកចិត្តកាន់តែច្រើន
- បង្កើនការប្រាស្រ័យទាក់ទងក្នុងចំណោមសមាជិកក្រុម (ទាំងសិស្ស និងគ្រូ)
- ទាមទារការចូលរួមជាប្រចាំ និងលើកកម្ពស់ការរៀនសូត្រឱ្យសកម្ម
- ជំរុញការរៀន និងការឆ្លុះបញ្ចាំងដោយខ្លួនឯង។

## ខ-៣. ការប្រើប្រាស់ករណីសិក្សា

ការប្រើករណីសិក្សាបានបង្ហាញថាសិស្សរៀនបានល្អបំផុត ប្រសិនបើមានការចូលរួមក្នុងការសិក្សាសកម្មហើយករណីសិក្សាគឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពដែលគ្រូអាចបញ្ចូលជាផ្នែកនៃការបង្រៀនសិស្ស។

ករណីសិក្សាគឺជាឧទាហរណ៍ដែលបង្ហាញពីការយល់ដឹងអំពីស្ថានភាពមួយ និងផ្តល់ឱកាសឱ្យសិស្សចូលរួម និងឆ្លើយសំណួរដែលទាក់ទងទៅនឹងស្ថានភាពដែលបានពិពណ៌នា ដើម្បីដោះស្រាយបញ្ហា។ សម្រាប់ហេតុផលនេះករណីសិក្សាត្រូវបានគេចាត់ទុកថាជាឧបករណ៍ដ៏មានប្រសិទ្ធភាពសម្រាប់PBL។

ចំណុចសំខាន់គឺថាករណីសិក្សាណែនាំសិស្សឱ្យដឹងពីបញ្ហាក្នុងពិភពពិតដែលសិស្សអាចនឹងប្រឈមមុខ។

**គ្រូអាចប្រើករណីសិក្សាដើម្បីៈ**

- ណែនាំបង្ហាញប្រធានបទ
- ឆ្លុះបញ្ចាំងពីអាកប្បកិរិយាជាក់លាក់(ឧទាហរណ៍ អាកប្បកិរិយាអនាម័យផ្ទាល់ខ្លួនមិនល្អ ការខ្វះចំណេះដឹងអំពីច្បាប់ចរាចរណ៍ ការប្រើប្រាស់គ្រឿងញៀន។ល។)
- ដើម្បីពន្យល់ពីការអនុវត្តបំណិនទន់ (ឧទាហរណ៍ ការសម្រេចចិត្ត ទំនាក់ទំនងល្អ ឬការយល់ចិត្ត)។ យោងតាមដំណើរការសិក្សា ៦ដំណាក់កាល ករណីសិក្សានឹងមានប្រយោជន៍ច្រើនក្នុងដំណាក់កាលទី១ ប៉ុន្តែឧបករណ៍នេះអាចប្រើបាននៅក្នុងជំហានណាមួយ នៅពេលដែលគ្រូត្រូវការសិស្សដើម្បីចាប់ផ្តើមឆ្លុះបញ្ចាំងលើប្រធានបទជាក់លាក់ ការងារ ឬការប្រើប្រាស់បំណិនជាក់លាក់មួយ។

ក្នុងឧបសម្ព័ន្ធ ជំហានទី១ សកម្មភាពទី៤ "ការប្រើករណីសិក្សា" យើងផ្តល់ការចង្អុលបង្ហាញបន្ថែមទៀតអំពីរបៀបរៀបចំ និងប្រើប្រាស់ករណីសិក្សាក្នុងការបង្រៀន។

## ស្វ័យឆ្លុះបញ្ចាំងលើជំពូកទី៣

| | | |
|---|---|---|
| ១ | ហេតុអ្វីបានជាការសិក្សាផ្អែកលើបញ្ហា(PBL) មានសារៈសំខាន់? | ☐ ព្រោះវាជំរុញសិស្សឱ្យរៀនយ៉ាងសកម្ម<br>☐ ព្រោះវាជំរុញការរៀនសូត្រដោយទន្ទេញចាំមាត់<br>☐ ពីព្រោះសិស្សរៀនដោយអនុវត្តផ្ទាល់ |
| ២ | តើតួនាទីរបស់គ្រូនៅក្នុងវិធីសាស្ត្រសិក្សាផ្អែកលើបញ្ហាខុសគ្នាពីវិធីសាស្ត្របែបប្រពៃណីដែរឬទេ?បើបាទ / ចាស តើខុសគ្នាដូចម្តេច? | ☐ បាទ/ចាំ ☐ ទេ ☐ មិនដឹង<br>.............................................................................<br>............................................................................. |
| ៣ | តើសាលារៀន ជ្រើសរើសប្រធានបទបំណិនជីវិតនៅពេលណា? | ☐ នៅចន្លោះខែតុលា និងវិច្ឆិកា‌រៀងរាល់ឆ្នាំ<br>☐ នៅចុងឆមាសនីមួយៗ<br>☐ នៅចុងបញ្ចប់នៃឆ្នាំសិក្សានីមួយៗ |
| ៤ | តើអ្នកណាខ្លះចូលរួមជ្រើសរើសប្រធានបទក្នុងកម្មវិធីសិក្សាបែបពិគ្រោះយោបល់នៅកម្រិតសាលារៀន? | ☐ មានតែគ្រូបង្រៀន និងអាជ្ញាធរមូលដ្ឋាន<br>☐ មានតែគ្រូបង្រៀន សិស្ស និងគណៈគ្រប់គ្រងសាលា<br>☐ សិស្ស គ្រូ គណៈគ្រប់គ្រងសាលា អាជ្ញាធរមូលដ្ឋានអ្នកជំនាញក្នុងមូលដ្ឋាន(រួមមានមាតាបិតាសិស្ស) |

| | | |
|---|---|---|
| ៥ | តើគំរូពីរនៃការអនុវត្តបំណិនជីវិតតាមមូលដ្ឋានមួយណាដែលត្រឹមត្រូវ ? | □ គំរូសង្គម និងគំរូអាជីពងាយ<br>□ កសិកម្ម និងសិប្បកម្ម<br>□ សង្គម និង បំណិនមូលដ្ឋាន |
| ៦ | តើវិធីសាស្ត្របង្រៀន៦ដំណាក់កាលគឺជាដំណើរការមួយដើម្បីអនុវត្តការរៀនផ្អែកលើបញ្ហាដែរឬទេ ? | □ បាទ/ចាស □ ទេ □ មិនដឹង |

**ចម្លើយ៖**

១. ក.ព្រោះវាជំរុញសិស្សឱ្យរៀនយ៉ាងសកម្ម។ខ.ពីព្រោះសិស្សរៀនដោយអនុវត្តផ្ទាល់

២. បាទ/ចាស ព្រោះគ្រូជាអ្នកសម្របសម្រួលក្នុងដំណើរការរៀន និងបង្រៀន គ្រូជំរុញសិស្សឱ្យសកម្ម។ អ្នកជំនាញក្នុងមូលដ្ឋានផ្តល់បច្ចេកទេស

៣. នៅចន្លោះខែតុលា និងវិច្ឆិការៀងរាល់ឆ្នាំ

៤. សិស្ស គ្រូ គណៈគ្រប់គ្រងសាលា អាជ្ញាធរមូលដ្ឋាន សមាជិកសហគមន៍(រួមមានមាតាបិតាសិស្ស)

៥. គំរូសង្គម និងគំរូអាជីពងាយ

៦. បាទ/ចាស

ជំពូក ៣

ការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន

# ជំពូក ៤ បំណិនទន់ បំណិនបុរេវិជ្ជាជីវៈ ឬបំណិនសតវត្សរ៍ទី២១

## ៤.១. ហេតុអ្វីបានជាបំណិនទន់មានសារៈសំខាន់?

មានតែចំណេះដឹងបច្ចេកទេសគឺមិនគ្រប់គ្រាន់ដើម្បីទទួលជោគជ័យក្នុងកម្រិតការងារទេ៖ យើងត្រូវចេះបញ្ចូលចំណេះដឹងបច្ចេកទេសនេះជាមួយបំណិនដែលនឹងជួយឱ្យយើងទំនាក់ទំនង និងដោះស្រាយនូវរាល់បញ្ហាដែលយើងនឹងប្រឈម។ ឧទាហរណ៍ ក្នុងការចិញ្ចឹមមាន់ វាមិនគ្រប់គ្រាន់ទេក្នុងការរៀនពីរបៀបថែទាំសត្វឱ្យទទួលបានជោគជ័យ ប្រសិនបើយើងមិនដឹងពីរបៀបរៀបចំផែនការអាជីវកម្ម ឬវិធីដោះស្រាយជាមួយអ្នកលក់និងអតិថិជន។ ដើម្បីគាំទ្រដល់ដំណើរការនេះ បំណិនជីវិតតាមមូលដ្ឋានសង្កត់ធ្ងន់ជាពិសេសទៅលើការអភិវឌ្ឍបំណិនទាំងនេះដែលហៅថាបំណិនទន់។ បំណិនទន់នេះត្រូវបានអភិវឌ្ឍតាមរយៈសកម្មភាពដែលសិស្សរៀនតាមលំនាំ៦ដំណាក់កាល នៅក្នុងកម្មវិធីបំណិនជីវិតតាមូលដ្ឋាន(គំរូសង្គម និងគំរូអាជីពងាយ)។

## ៤.២. បំណិនទន់ និងបំណិនជីវិត

យោងតាមនិយមន័យបំណិនជីវិត ដ្យាក្រាមខាងក្រោមបង្ហាញពីទំនាក់ទំនងរវាងបំណិនទន់ និងបំណិនជីវិត(បំណិនមូលដ្ឋាន និងបំណិនអាជីព)។

បំណិនទន់គឺជាផ្នែកមួយនៃបំណិនមូលដ្ឋាន និងបំណិនអាជីពក្នុងទម្រង់ជាបំណិនបុរេវិជ្ជាជីវៈ និងបំណិនអាជីវកម្ម និងការគ្រប់គ្រងដូចជា បំណិនទីផ្សារ ការធ្វើផែនការអាជីវកម្ម បំណិនក្នុងការសម្រេចចិត្ត ការប្រស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមួយអតិថិជន។ បំណិនទាំងនេះនឹងជួយអភិវឌ្ឍបន្ថែមនៅពេលដែលមានការឆ្លុះបញ្ចាំងក្នុងដំណាក់កាលនីមួយៗនៃការសិក្សាបំណិនជីវិត តាមរយៈការសួរសំណួរដែលមានអានុភាពដូចជា ហេតុអ្វី? ដូចម្តេច? តើខ្ញុំអាចធ្វើអ្វីថ្មីប្លែកពីនេះដូចម្តេច?



## ៤.៣. អត្ថន័យបំណិនទន់

ដើម្បីយល់ច្បាស់ពីបញ្ញត្តិ បំណិនទន់ សូមចាប់ផ្តើមពីលំហាត់ងាយៗ ដើម្បីស្វែងយល់ពីភាពផ្សេងគ្នារវាង បំណិនរឹង និងបំណិនទន់។

ដូចអ្វីដែលបានសង្ខេប ក្នុងដ្យាក្រាមរង្វង់ខាងលើ ជាទូទៅបំណិនទន់សំដៅលើ បំណិនដែលទាក់ទងនឹងបុគ្គលិកលក្ខណៈផ្ទាល់ខ្លួន រីឯបំណិនរឹង គឺជាបំណិនបច្ចេកទេស ដូចជា៖ ការជួសជុល ម៉ូតូ ការជួសជុលកុំព្យូទ័រ ការធ្វើកសិកម្ម...។

| បំណិនទន់ | បំណិនរឹង |
|---|---|
| ទំនាក់ទំនង | និយាយភាសាអង់គ្លេស |
| សហប្រតិបត្តិការ | បំណិនប្រើប្រាស់កុំព្យូទ័រ |
| ការបង្កើតថ្មី | គណនេយ្យ |

*ប្រភព:* សៀវភៅឯកសារណែនាំ ពិភពការងារ KAPE / WEI 2015

គួរសម្គាល់ថា បំណិនបច្ចេកទេសត្រូវការបំណិនទន់ដើម្បីបង្កើនប្រសិទ្ធភាព។

## ៤.៤. ការបញ្ចូលបំណិនទន់នៅក្នុងមុខវិជ្ជា បំណិនជីវិតតាមមូលដ្ឋាន

ការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន នឹងផ្តោតសំខាន់ទៅលើបំណិនទន់១២ ដែលចាត់ចូលជា៤ក្រុមដូចខាងក្រោម៖



បំណិនទន់ទាំង១២ដែលបានលើកឡើងនេះជាជំនួយដល់ការធ្វើផែនការបង្រៀន ការបង្រៀន និងការវាយតម្លៃបំណិនជីវិតតាមមូលដ្ឋាន។ ការចាត់ជាក្រុមនូវបំណិនទាំង១២នេះ ផ្តល់ជាក្របខ័ណ្ឌការងារសម្រាប់គ្រូបង្រៀនងាយស្រួលក្នុងការបង្រៀន និងសម្រេចចិត្តធ្វើការអភិវឌ្ឍបំណិនកាន់តែប្រសើរ។ ការវាយតម្លៃនឹងផ្តោតលើការចាត់ក្រុមបំណិនទាំងនេះផងដែរ (សូមមើលជំពូកទី៧)

**ឧទាហរណ៍នៃបំណិនដែលបានប្រើញឹកញាប់ក្នុងការអនុវត្តបំណិនជីវិតតាមមូលដ្ឋានគឺ៖**

- **បំណិនភាពជាអ្នកដឹកនាំ** គឺជាការរួមបញ្ចូលគ្នានៃបំណិនស្វ័យគ្រប់គ្រង បំណិនចរចា សមានចិត្ត សហការ ទំនាក់ទំនង ការគ្រប់គ្រងខ្លួនឯង។
- បំណិនស្រាវជ្រាវ ជាការរួមបញ្ចូលគ្នានៃបំណិនការរិះគិតពិចារណា ការដោះស្រាយបញ្ហា ការសម្រេចចិត្ត ទំនាក់ទំនង ។.
- បំណិនវិភាគ ជាការរួមបញ្ចូលគ្នារវាងបំណិន ការរិះគិតពិចារណា និងការសម្រេចចិត្ត ដើម្បីដោះស្រាយបញ្ហា និងតំណាងឱ្យសមត្ថភាពប្រមូល និងវិភាគព័ត៌មាន ការសម្រេចចិត្ត និងការដោះស្រាយបញ្ហា។
- ចង្កោមសំណុំបំណិនរង គ្រូអាចចាប់អារម្មណ៍ផ្តោតលើទិដ្ឋភាពជាក់លាក់នៃបំណិនស្នូលមួយ ដោយផ្អែកលើតម្រូវការរបស់សិស្ស។ ឧទាហរណ៍សម្រាប់បំណិនទំនាក់ទំនង៖ ការនិយាយជាសាធារណៈបំណិនធ្វើបទបង្ហាញ បំណិនសម្ភាសន៍ ឬការស្តាប់យ៉ាងយកចិត្តទុកដាក់ដោយផ្តោតលើឧទាហរណ៍មួយចំនួន។

# បំណិនសម្រាប់ការរៀនសូត្រ

## ១-ការបង្កើតថ្មី ឬការច្នៃប្រឌិត ២-ការរិះគិតពិចារណា ៣-ការដោះស្រាយបញ្ហា

ការបង្កើតថ្មី ការដោះស្រាយបញ្ហា និងការរិះគិតពិចារណា ត្រូវបានចាត់ទុកថា ជាបំណិនសម្រាប់ការរៀនសូត្រ ដោយសារបំណិនទាំងនេះគ្របដណ្តប់លើវិសាលភាពនៃការគិត ដែលជាចំណុចគន្លឹះនៃដំណើរការរៀនសូត្រ។ បំណិនទាំងនេះគឺជាមូលដ្ឋាននៃការអភិវឌ្ឍ និងអនុវត្តបំណិនផ្សេងៗទៀត។

**១.ការបង្កើតថ្មី ឬការច្នៃប្រឌិត**

ង្រៀន នឹងបង្រៀនសិស្សនឹងសិក្សាពីរបៀបបង្កើតគំនិត ដោយប្រើបច្ចេកទេសសាមញ្ញៗ ដែលគ្រូបង្រៀននឹងបង្រៀននៅក្នុងថ្នាក់រៀន។..

សិស្សប្រើឧបករណ៍ពិសេសដើម្បីបង្ហាញគំនិតរបស់ពួកគេ (គំនូរ អត្ថបទរឿង ការសម្តែងតួ)។ សិស្សអាចផ្តល់នូវដំណោះស្រាយថ្មី ឬដំណោះស្រាយមិនបានគិតទុកចំពោះបញ្ហាដែលបានប្រឈមនៅផ្ទះ ឬសាលារៀន។

## អនុសាសន៍មួយចំនួនក្នុងការបង្រៀន (វិធីបង្រៀន)

- ជាការសិក្សាតាមការអនុវត្ត ការសាកល្បងអនុវត្តស្វែងរកកំហុសឆ្គង និងការឆ្លុះបញ្ចាំង
- មានភាពច្នៃប្រឌិតក្នុងការរៀបចំថ្នាក់រៀន៖ បង្កើតឱ្យមានកន្លែងក្នុងថ្នាក់ សម្រាប់ស្វែងរកគំនិត ឧទាហរណ៍ រៀបចំតុមួយសម្រាប់សិស្សគិត និងជ្រុងម្ខាងទៀតនៃថ្នាក់សម្រាប់ពិភាក្សាយោបល់។ល។
- ការសិក្សាមានទាំងនៅក្នុងថ្នាក់រៀន និងក្រៅថ្នាក់រៀន
- លើកឡើងនូវគំនិតច្នៃប្រឌិតថ្មីៗ ដែលពួកគេអាចប្រើក្នុងជីវភាពរស់នៅប្រចាំថ្ងៃ (ការតែងនិពន្ធ ការគូរ ការអានរឿង ការធ្វើព្យុះគំនិត ការពិភាក្សាជាដៃគូ)
- រៀបចំឱ្យមានការប្រកួតប្រជែង ដើម្បីស្វែងរកគំនិតយោបល់ ដោយផ្តើមចេញពីបញ្ហាមួយ
- ផ្តល់រង្វាន់ដល់អ្នកដែលលើកឡើងនូវគំនិតច្នៃប្រឌិត
- ប្រើប្រាស់សម្ភារឧបទេសខុសៗគ្នា ដើម្បីធ្វើសកម្មភាពផ្សេងៗ និងណែនាំបង្ហាញសម្ភារឧបទេសថ្មីៗ (វីដេអូ ចម្រៀង បង្កើតវត្ថុផ្សេងៗដោយប្រើប្រាស់ដបប្លាស្ទិកដែលបានប្រើរួច ដុំថ្ម ស្លឹកឈើ ។ល។)

## ឧទាហរណ៍ពីផលិតផលច្នៃប្រឌិត ឬសកម្មភាពនៅសាលារៀន (គំនិត ឬស្នាដៃផ្ទាល់ខ្លួន)




**រៀបចំតុបតែងសាលា** ដោយប្រើព័ត៌មាន ឬប្រធានបទដែលសិស្សកំពុងសិក្សា។ ប្រើទីធ្លាដែលទំនេរ។



ឱ្យសិស្សចូលរួមក្នុង**ការបង្កើតផលិតផល** ដោយប្រើប្រាស់សម្ភារៈផ្សេងៗ។ ឧ.ច្នៃដបប្លាស្ទិកប្រើរួច ស្លឹកឈើ និងដាក់តាំងបង្ហាញនៅក្នុងសាលារៀន ឬនៅក្នុងថ្នាក់ រៀន។



**សម្តែងតួ៖** ការសម្តែងតួជាសកម្មភាពដ៏ប្រសើរមួយ ក្នុងការជួយបង្កើនភាពរីករាយ និងគំនិតច្នៃប្រឌិត។ សិស្សដែលស្ទៀមស្ងាត់មានឱកាសបានចូលរួមកាន់តែច្រើន (សូមមើលឧបសម្ព័ន្ធ)



**រៀបចំវីដេអូបង្ហាញពី**លទ្ធផលការងារបំណិនជីវិតតាមមូលដ្ឋាន។ ឧ. អនុវិទ្យាល័យល្វេសបានផលិតវីដេអូចំនួន៨ លើប្រធានបទផ្សេងៗគ្នារួមមាន៖ បម្រែបម្រួលអាកាសធាតុ បញ្ហាសំរាម ការធ្លាក់ទឹកចិត្ត បញ្ហាកង្វះទឹកនៅប្រទេសចិន[3]

[3] Rubbish: http://tiny.cc/ref77y Global warming: http://tiny.cc/ggf77y, Water Shortages: https://youtu.be/kOibfXvaI7I, Stroke: https://youtu.be/1w9pu3daF6I

## ២.ការរិះគិតពិចារណា

គ្រូបង្រៀនត្រូវផ្តល់ឱកាស និងសម្ភារៈនានាដល់សិស្ស ដើម្បីឱ្យពួកគេស្រាវជ្រាវរកព័ត៌មានដោយខ្លួនឯងផ្ទាល់ ទាំងក្នុង និងក្រៅថ្នាក់។ សិស្សនឹងអាចពិភាក្សាវិភាគពីស្ថានការណ៍ និងឆ្លុះបញ្ចាំង ក្រោមការណែនាំរបស់គ្រូបង្រៀន។

សិស្សអាចយល់ស្រប ឬមិនយល់ស្រប និងពន្យល់ពីមូលហេតុនៅពេលនិយាយជាមួយគ្រួសារ និងមិត្តភក្តិរបស់ពួកគេ។

### អនុសាសន៍មួយចំនួនក្នុងការបង្រៀន (វិធីបង្រៀន)

- លើកទឹកចិត្តសិស្សឱ្យសួរអំពីបញ្ហាក្នុងពិភពជាក់ស្តែងថាតើមកពីមូលហេតុអ្វី និងកើតឡើងដូចម្តេចមិនមែនគ្រាន់តែជាការសិក្សាតាមឯកសារប៉ុណ្ណោះទេ
- លើកទឹកចិត្តសិស្សឱ្យចេះវិភាគ ដោយប្រៀបធៀបភាពខុសគ្នាតាមរយៈក្រាហ្វិក តារាង ផែនទី លំនាំ
- លើកទឹកចិត្តសិស្សឱ្យចេះវិនិច្ឆ័យព័ត៌មាន និងធ្វើសេចក្តីសន្និដ្ឋាន។

1. ការសួរសំណួរ → 2. ការវិភាគ → 3. ការវិនិច្ឆ័យ

## 1- ការសួរសំណួរ ការសង្កេត ការស្វែងរកព័ត៌មាន

ការសួរសំណួរៈ គឺជាចំណុចសំខាន់នៃដំណើរការសិក្សារៀនសូត្រ ការសួរជាជំហានដំបូងមុនចាប់ផ្តើម ការសិក្សា។ គ្រូបង្រៀនប្រើសំណួរដើម្បីត្រួតពិនិត្យកម្រិតយល់ដឹងរបស់សិស្សជាមុន មុននឹងបន្ថែមនូវចំណេះដឹងថ្មី។ ការសួរសំណួរជួយឱ្យសិស្សយល់បានពីស្ថានការណ៍។ ជាលទ្ធផល សិស្សនិងអាចរៀនបង្កើតសំណួរដោយខ្លួនគេផ្ទាល់ នៅពេលដែលពួកគេជួបស្ថានការណ៍អ្វីមួយនៅសាលា ក្រៅសាលា ឬនៅផ្ទះ នេះជាការលើកកម្ពស់ឱ្យសិស្សចេះរៀនដោយខ្លួនឯង។

### អនុសាសន៍មួយចំនួនសម្រាប់ការបង្រៀនក្នុងថ្នាក់ (វិធីបង្រៀន)

- ជៀសវាងប្រើសំណួរបិទ (បាទ/ចា៎) សួរសិស្សដើម្បីឱ្យពួកគេពន្យល់ (ពិភាក្សាពីហេតុផល)
- ទុកពេលឱ្យសិស្សបានគិត
- លើកទឹកចិត្តសិស្សឱ្យផ្តល់យោបល់លើចម្លើយរបស់មិត្តភក្តិ ដោយសួរសិស្សថា “តើប្អូនមានយោបល់ដូចម្តេច ចំពោះចម្លើយរបស់មិត្តភក្តិ ...?”
- មិនបន្ទុចបង្អាក់ ឬរំខានសិស្សនៅពេលពួកគេកំពុងឆ្លើយ
- ប្រសិនបើសិស្សសួរសំណួរ អ្នកអាចបង្វែរសំណួរនោះទៅមិត្តរួមថ្នាក់របស់គេ “តើប្អូនឆ្លើយទៅនឹងសំណួរនេះដូចម្តេច?”
- ក្នុងសកម្មភាពសង្កេត ត្រូវឱ្យសិស្សសួរខ្លួនឯងពីបញ្ហា ដែលពួកគេកំពុងពិនិត្យដោយប្រើសំណួរ អ្វី? ពេលណា? នៅទីណា? ហេតុអ្វី?

## 2- ការវិភាគ

សិស្សយល់បានពីស្ថានការណ៍តាមរយៈសំណួររបស់គ្រូបង្រៀន ដោយពួកគេធ្វើការវិភាគស្វែងយល់។ គ្រូបង្រៀនត្រូវណែនាំសិស្សដើម្បី៖

1- **រៀបចំព័ត៌មាន៖** រៀបចំព័ត៌មានតាមលំដាប់ អ្វីកើតឡើងមុនដំបូង? អ្វីដែលកើតឡើងបន្ទាប់? (ទំនាក់ទំនងហេតុ និងផល)។ គ្រូអាចប្រើលំនាំ**ដើមឈើបញ្ហា** ការវិភាគ**ផែនទីគំនិត** តារាងសំណួរគន្លឹះរបស់គ្រូ (អ្វី ពេលណា កន្លែងណា ហេតុអ្វី?)

2- **រៀបចំព័ត៌មានទៅតាមប្រភេទ៖** ផ្តុំព័ត៌មានទៅតាមប្រភេទ រាល់ព័ត៌មានស្រដៀងគ្នាត្រូវដាក់ជាមួយគ្នា ដោយរៀបចំទៅតាមប្រភេទ ព័ត៌មានទាំងអស់ត្រូវប្រើប្រាស់សំណួរដែលមានពាក្យ "អ្វី? ពេលណា?កន្លែងណា? និងហេតុអ្វី?"

3- **ប្រៀបធៀបព័ត៌មាន៖** ជាមួយស្ថានការណ៍នៃពិភពពិតផ្សេងទៀត ដូចជាបទពិសោធ ឬស្ថានការណ៍ដែលមានពីមុនមក។ ដោយប្រៀបធៀបភាពខុសគ្នាតាមរយៈក្រាហ្វិក តារាង ផែនទី លំនាំផ្សេងៗ

4- **ញែកការពិត និងមតិយោបល់ និងផ្ទៀតផ្ទាត់ការសន្និដ្ឋាន៖** នៅពេលអានព័ត៌មានណាមួយ ត្រូវសួរសិស្សឱ្យឆ្លុះបញ្ចាំងដោយសួរសំណួរ "តើវាពិតជាអញ្ចឹងទេ? តើវាអាចបញ្ជាក់បានទេ?" រាល់ការពិតគឺតែងតែពិត និងអាចបញ្ជាក់បាន។ "រាល់មតិយោបល់ជាទស្សនៈរបស់បុគ្គល អាចពិត ឬមិនពិត "។ សិស្សអាចទទួលយក ឬបដិសេធមតិយោបល់ណាមួយ ផ្អែកលើចំណេះដឹង បទពិសោធន៍ និងជំនឿជាក់របស់គេ។ ការយល់នេះអាចផ្លាស់ប្តូរនៅពេលដែលមានព័ត៌មាន និងភស្តុតាងថ្មី។

- **តើធ្វើការបង្ហាញបញ្ជាក់យ៉ាងដូចម្តេច?** បង្រៀនសិស្សឱ្យពិនិត្យពីភស្តុតាងនៃព័ត៌មានពីប្រភព ផ្សេងៗគ្នា (យ៉ាងហោចណាស់ពីរ ឬបីប្រភព) មុននឹងធ្វើការសម្រេចចិត្តទទួលយកភស្តុតាងនៃ ព័ត៌មានដែលពួកគេប្រមូល។ មធ្យោបាយនៃការប្រើប្រភពព័ត៌មានច្រើននេះ គឺដើម្បីផ្តល់នូវព័ត៌មានពិត(ជាគំរូ)។
- **ការសន្មត់** គឺជាអំណះអំណាងមួយដែលគេជឿថាពិត ប៉ុន្តែគ្មានភស្តុតាងបញ្ជាក់។ ឧទាហរណ៍ "សិស្សដែលប្រើប្រាស់ប្រព័ន្ធបច្ចេកទេសព័ត៌មានវិទ្យា ជាសិស្សដែលសិក្សាបានល្អ។ ការសន្មត់នេះអាចត្រូវ ឬខុស លុះត្រាតែមានការផ្ទៀងផ្ទាត់បញ្ជាក់!

5- **ជ្រើសរើសប្រភពព័ត៌មានត្រឹមត្រូវ**

- គ្រូបង្រៀន និងសិស្សត្រូវរៀនកំណត់ពីប្រភពព័ត៌មានដែលអាចជឿជាក់បាន ឬមិនអាចជឿជាក់បាន ជាពិសេសនៅពេលប្រើប្រាស់ប្រព័ន្ធអ៊ិនធើណេត ដើម្បីស្វែងរកព័ត៌មាន (សូមមើលឧបសម្ព័ន្ធ "វិធីនៃការកំណត់ព័ត៌មានក្លែងបន្លំ")។

## 3- ការវិនិច្ឆ័យព័ត៌មាន និងការសន្និដ្ឋាន

ជាការចាំបាច់ណាស់ រាល់ព័ត៌មានទាំងអស់ដែលយកមកវិភាគ ត្រូវតែជាហេតុការណ៍ពិត មិនមែនជាមតិយោបល់ ឬការសន្មត់របស់បុគ្គលណាមួយឡើយ។ គ្រូអាចជួយសិស្សឱ្យកំណត់ព័ត៌មានពិតដោយប្រើបច្ចេកទេសដូចខាងក្រោម៖

- ធ្វើតារាងការគាំទ្រ និងមិនគាំទ្រ(តារាងអក្សរT) ដើម្បីពិនិត្យមើល "តើព័ត៌មានមួយណាជាការពិត ឬមតិយោបល់ ឬការសន្និដ្ឋាន?"

- បង្កើតលក្ខណវិនិច្ឆ័យ ដែលអាចជួយសិស្សក្នុងការជ្រើសរើសដំណោះស្រាយល្អបំផុត និងផ្តល់អនុសាសន៍ផ្សេងៗ (ឧ.ពីលក្ខណវិនិច្ឆ័យដូចជា៖ តើខ្ញុំអាចបង្ហាញបញ្ជាក់បានទេ? តើខ្ញុំអាចផ្ទៀងផ្ទាត់បានទេ?)
- ជ្រើសរើស និងអនុវត្ត។




**ប្រភពបន្ថែម** ៖ឧបសម្ព័ន្ធ ៤.១-ការបង្ការព័ត៌មានក្លែងបន្លំ ឧបសម្ព័ន្ធ ៤.២-ឯកសារ៖ តើវាគឺជាការពិត ឬជាគំនិតផ្ទាល់ខ្លួន?

## ៣. ដំណោះស្រាយបញ្ហា

ដោយចាប់ផ្តើមពីបញ្ហាក្នុងជីវិតរស់នៅជាក់ស្តែង សិស្សនឹងរៀនស្វែងរក និងអនុវត្តវិធីផ្សេងៗគ្នាដើម្បីដោះស្រាយបញ្ហាក្រោមការណែនាំរបស់គ្រូ ។

នៅពេលសិស្សខូចកង់របស់ពួកគេ ហើយរកវិធីដើម្បីជួសជុលវា ដោយដឹងថាវាខូចអ្វី ហើយជ្រើសរើសវិធីជួសជុលរវាងជម្រើសផ្សេងទៀត។ តើដោះស្រាយបញ្ហានេះយ៉ាងដូចម្តេច?

### អនុសាសន៍មួយចំនួនក្នុងការបង្រៀន(វិធីបង្រៀន)

- លើកឡើងពីស្ថានការណ៍សិក្សាក្នុងភាពជាក់ស្តែង៖ វិធីនេះនឹងជួយសិស្សដើម្បីផ្សារភ្ជាប់ពីអ្វីដែលពួកគេបានសិក្សាអនុវត្តនៅសាលារៀន ហើយអាចយកទៅអនុវត្តក្នុងជីវិតប្រចាំថ្ងៃ។
- សួរសិស្សឱ្យពន្យល់ពីជំហាន ដែលពួកគេបានប្រើក្នុងការដោះស្រាយបញ្ហាណាមួយ (ជំរុញឱ្យមានស្វ័យឆ្លុះបញ្ចាំង)។
- ជួយសិស្សកំណត់រកទំនាក់ទំនងរវាងហេតុ និងផល ដោយចាប់ផ្តើមពីឧទាហរណ៍ក្នុងជីវិតប្រចាំថ្ងៃ។
- សួរសិស្សឱ្យរកដំណោះស្រាយ ដោយមិនផ្តល់ដំណោះស្រាយដល់ពួកគេទេ។ សិស្សនឹងរៀនពីវិធីដើម្បីដោះស្រាយបញ្ហាដោយខ្លួនឯង ប្រសិនបើគ្រូបង្រៀនលើកទឹកចិត្តសិស្សឱ្យអនុវត្តបែបនេះជាប្រចាំ។
- គ្រូបង្រៀនគួរតែដឹកនាំសិស្សតាមដំណើរការដូចខាងក្រោម៖ ១-កំណត់រកបញ្ហា ២-វិភាគបញ្ហា ៣-រកដំណោះស្រាយ ៤-អនុវត្តផែនការ ៥-វាយតម្លៃវឌ្ឍនភាព។
- បង្ហាញពីការអនុវត្តដំណើរការដោះស្រាយបញ្ហា និងស្ថានការណ៍ផ្សេងៗគ្នា។

## ក- ដំណើរការដោះស្រាយបញ្ហា

| សកម្មភាព | សំណួរទាក់ទងនឹងសកម្មភាព | បច្ចេកទេសដោះស្រាយបញ្ហា (មើលឧបសម្ព័ន្ធជំហាន៣) | តួនាទីសិស្ស |
|---|---|---|---|
| ១.ការកំណត់បញ្ហា | • តើអ្វីកំពុងកើតឡើង?<br>• តើនោះជាបញ្ហាឬ?<br>• តើបញ្ហានេះមានសារៈសំខាន់យ៉ាងណា | បច្ចេកទេសព្យុះគំនិត | • ជួយបង្កើតគំនិត ប្រមូលព័ត៌មានដែលមានស្រាប់។ ពង្រឹងផងដែរនូវបំណិនច្នៃប្រឌិត។<br>• ជួយក្នុងការកំណត់រកឫសគល់ ហេតុផលនៃបញ្ហា និងទំនាក់ទំនងរវាងហេតុនិងផលជាក់ស្តែង។ |
| ២.វិភាគបញ្ហា | • តើបញ្ហាកើតឡើងនៅពេលណា?<br>• តើបញ្ហានេះមានផលប៉ះពាល់ដល់អ្នកណាខ្លះ?<br>• តើបញ្ហានេះកើតឡើងនៅទីណា?<br>• តើអ្នកធ្លាប់ឆ្លងកាត់បញ្ហាបែបនេះឬទេ? នៅផ្ទះ? នៅសាលា? | • ដើមឈើបញ្ហា (កំណត់រកហេតុ-ផល)<br>• ឆ្អឹងត្រី (កំណត់រកហេតុ-ផល) ហេតុអ្វី៥ដង (5 Whys)។<br>• ត្រូវតាមលក្ខខណ្ឌ (មានពេលវេលា មានសុវត្ថិភាព អាចដំណើរការបាន...)។ | • ជួយកំណត់មូលហេតុដើមនៃបញ្ហា និងទំនាក់ទំនងរវាងហេតុ និងផលនៅក្នុងអង្គហេតុ។<br>• ទាញសេចក្តីសន្និដ្ឋានដែលអាចជាដំណោះស្រាយ |
| ៣.ស្វែងរកដំណោះស្រាយបញ្ហា | • តើអ្នកនឹងមានដំណោះស្រាយអ្វីខ្លះលើបញ្ហានេះ?<br>• តើអ្នកជ្រើសរើសដំណោះស្រាយណាខ្លះ?<br>• តើដំណោះស្រាយបែបណាដែលអ្នកអាចធ្វើបាន? (តើមានពេលវេលា ធនធានដើម្បីដោះស្រាយឬទេ?) | • តារាងវិជ្ជមាន និងអវិជ្ជមាន<br>• តារាងគាំទ្រ និងមិនគាំទ្រ (តារាងអក្សរ T)។ | ផ្តល់ការគាំទ្រដើម្បីវាយតម្លៃស្ថានការណ៍។ ជួយផ្ទៀងផ្ទាត់ដំណោះស្រាយនេះឱ្យត្រឹមត្រូវតាមលក្ខខណ្ឌសមស្រប។ តើអ្នកអាចធ្វើបានសម្រេច ដែរឬទេ? |
| ៤.ការអនុវត្តផែនការ | តើអ្នកធ្វើអ្វីដូចដែលអ្នកបាននិយាយទេ? | • តារាងត្រួតពិនិត្យ<br>• ការធ្វើផែនការ | ផ្តល់ការគាំទ្រ ដើម្បីធានាអនុវត្តតាមផែនការដែលបានកំណត់។ |
| ៥.ការវាយតម្លៃវឌ្ឍនភាព | • តើអ្នកដោះស្រាយបញ្ហា ដោយវិធីណាខ្លះ?<br>• តើអ្នកត្រូវការព័ត៌មានអ្វីខ្លះ?<br>• តើមានជំហានសំខាន់អ្វីខ្លះដែលជួយអ្នកក្នុងដំណើរការដោះស្រាយបញ្ហា។ | • ការសង្កេតរបស់គ្រូ<br>• ស្វ័យវាយតម្លៃរបស់សិស្ស<br>• ឧបករណ៍វាយតម្លៃក្រៅផ្លូវការផ្សេងទៀត (វាយតម្លៃជាក្រុម វាយតម្លៃជាដៃគូ)។ | ជួយធ្វើការឆ្លុះបញ្ចាំងការងារ។ ឧបករណ៍ទាំងនេះជំរុញឱ្យមានស្វ័យឆ្លុះបញ្ចាំង។ |

## ឧទាហរណ៍នៃសកម្មភាពក្នុងការដោះស្រាយបញ្ហានៅសាលារៀន៖

- នៅរាល់ដើមឆ្នាំសិក្សា អ្នកអាចបង្កើតផ្ទាំងកាតុង ដោយមានសំណួរ និងសកម្មភាពសិស្សដោះស្រាយបញ្ហា។ ក្នុងអំឡុងឆ្នាំសិក្សាផ្ទាំងកាតុងនេះ នឹងត្រូវសរសេរព័ត៌មានបន្ថែម(ជាពិសេស សម្រាប់សិស្សនៅកម្រិតបឋមសិក្សា)។
- នៅក្នុងថ្នាក់ ឬបណ្ណាល័យ អ្នកអាចរៀបចំផ្ទាំង កាតុងមួយសន្លឹក ដែលបង្ហាញពីដំណើរការដោះស្រាយបញ្ហា៥ជំហាន(ជាពិសេសសម្រាប់សិស្សអនុវិទ្យាល័យ) ដើម្បីឱ្យសិស្ស មើលឃើញដំណើរការដោះស្រាយបញ្ហា៥ជំហាននោះជាប្រចាំ និងស្វ័យវាយតម្លៃចំពោះកិច្ចការរបស់ខ្លួន។




## ប្រភពព័ត៌មានបន្ថែម

ឧបសម្ព័ន្ធ- ដំណើរការបង្រៀន៦ដំណាក់កាល(សកម្ម ភាពក្នុងដំណាក់កាល ទី៣-ដំណើរការដោះស្រាយបញ្ហា)



# បំណិនពង្រឹងអំណាចផ្ទាល់ខ្លួន

## ៤-ការគ្រប់គ្រងខ្លួនឯង ៥-ភាពធន់ ៦-ទំនាក់ទំនង

បំណិនពង្រឹងអំណាចផ្ទាល់ខ្លួននឹងលើកកម្ពស់លទ្ធភាពក្នុងការគ្រប់គ្រងអារម្មណ៍ ស្ថានភាពបាក់ទឹកចិត្ត និងលើកតម្លៃផ្ទាល់ខ្លួន ប្រសិទ្ធភាពបុគ្គល ទំនុកចិត្តបុគ្គល។

**៤. ការគ្រប់គ្រងខ្លួនឯង**

គ្រូបង្រៀននឹងបង្កើតស្ថានភាពដែលតម្រូវឱ្យសិស្សឆ្លុះបញ្ចាំង និងពន្យល់ពីអារម្មណ៍របស់ពួកគេ។ ទន្ទឹមនឹងនោះដែរ សិស្សនឹងរៀនទទួលស្គាល់ការងាររបស់ខ្លួន ដោយបំពេញកិច្ចការដែលគ្រូបង្រៀន និងក្រុមបានដាក់ឱ្យ។ ជាចុងក្រោយសិស្សនឹងរៀនស្វែងយល់ និងគ្រប់គ្រងអារម្មណ៍របស់ខ្លួន និងមានភាពម្ចាស់ការ។

សិស្សអាចបំពេញដោយមិនមានការចាំបាច់គាំទ្រ ពីឪពុកម្ដាយ ឬបុគ្គលឡើយ។

### អនុសាសន៍មួយចំនួនក្នុងការបង្រៀន (វិធីបង្រៀន)

- កុំព្រងើយកន្តើយនឹងអារម្មណ៍របស់សិស្ស។ ជួយសិស្សឱ្យចេះសួរលម្អិតអំពីអ្វីដែលពួកគេគិត ដោយចាប់ផ្ដើមពីពាក្យ "ហេតុអ្វី"។ ជួយសិស្សឱ្យស្គាល់ខ្លួនឯង។
- ឆ្លុះបញ្ចាំងពីបញ្ហាជាមួយពួកគេ ដោយស្វែងរកដំណោះស្រាយដែលអាចមាន(ជួយជាបុគ្គល ឬជាក្រុម)។
- ផ្ទេរការទទួលខុសត្រូវទៅសិស្សទាំងអស់ក្នុងថ្នាក់(មិនមែនផ្ទេរឱ្យប្រធានថ្នាក់ ឬក្រុមប្រឹក្សាកុមារទេ)។
- បង្រៀនសិស្សឱ្យធ្វើបញ្ជីត្រួតពិនិត្យ ឬធ្វើផែនការ និងគោរពកាលបរិច្ឆេទកំណត់...។
- ជួយឱ្យសិស្សចេះស្វែងរកចម្លើយ ដោយមិនផ្ដល់ចម្លើយដល់ពួកគេឡើយ។
- ពោលពាក្យសរសើរចំពោះមុខសិស្សទាំងអស់ពីគុណភាពការងារដែលគេធ្វើបានល្អ "ប្អូនធ្វើ.....បានល្អ ឬប្អូនធ្វើការងារនេះបានយ៉ាងល្អ។ល។"

### ឧទាហរណ៍ សកម្មភាពលើកកម្ពស់បំណិនស្វ័យគ្រប់គ្រងនៅសាលារៀន

- បង្កើតផ្ទាំងកាតុងបង្ហាញអារម្មណ៍ដាក់ក្នុងថ្នាក់(សូមមើលឧបសម្ព័ន្ធ) ហើយចាប់ផ្ដើមបង្រៀនមេរៀនដោយសួរសិស្សពីអារម្មណ៍របស់ពួកគេ។

- បង្កើតផ្ទាំងកាតុង ពីគោលការណ៍ស្វ័យគ្រប់គ្រងដាក់ក្នុងថ្នាក់រៀន ដើម្បីលើកកម្ពស់ស្វ័យត្រួតពិនិត្យ (ឧទាហរណ៍៖ ការត្រៀមខ្លួន ការសហការ ការគោរព វិន័យសាលា ការញ៉ាំអាហារក្រៅថ្នាក់ការធ្វើកិច្ចការផ្ទះ។ល។)

- ប្រើប្រាស់តារាងត្រួតពិនិត្យ។ បង្កើតឧទាហរណ៍នៃសកម្មភាពជីវិតប្រចាំថ្ងៃ "តើអ្វីខ្លះដែលប្អូនបានធ្វើ មុនពេលមកសាលារៀន បន្ទាប់មកឱ្យពួកគេអនុវត្តសកម្មភាពនោះនៅក្នុងថ្នាក់"។

ឧបករណ៍វាស់អារម្មណ៍គឺជាឧបករណ៍សំខាន់ ដើម្បី ជួយសិស្សក្នុងការបង្ហាញពីអារម្មណ៍ និងរៀននិយាយ ហើយពិភាក្សាជាមួយមិត្តភក្តិ។ តាមរយៈការបញ្ចេញពាក្យសម្ដី សិស្សចាប់ផ្ដើមយល់ពីខ្លួនគេកាន់តែច្រើន ហេតុអ្វីបានជាពួកគេមានអារម្មណ៍តាមបែបណាមួយ។ ពួកគេនឹងរៀនពីរបៀបដើម្បីសម្រាលបញ្ហាជាមួយមិត្តភក្តិ ហើយនឹងធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងជាមួយខ្លួនគេ និងអ្នកដទៃ។




នៅពេលសួរដំបូង សិស្សមួយចំនួនមានការលំបាកក្នុងការឆ្លើយសំណួរនេះ ដោយសារសិស្សមិនធ្លាប់ត្រូវបានគេសួរសំណួរពីអារម្មណ៍បែបនេះ។ សូមបន្តសួរបែបនេះរៀងរាល់សប្ដាហ៍។ លើកឧទាហរណ៍ពីស្ថានភាពអារម្មណ៍ ដើម្បីបំផុសចម្លើយដល់ពួកគេ(ដូចជា៖ រីករាយ ភ័យព្រួយ រំភើប ធុញទ្រាន់ ភាន់ភាំង...)

**ប្រភពបន្ថែម៖ ឧបសម្ព័ន្ធ ៤.៣.** ឧបករណ៍វាស់អារម្មណ៍សម្រាប់សិស្សបឋមសិក្សា និងអនុវិទ្យាល័យ។

## ៥. ភាពធន់

បង្រៀននឹងរៀបចំសកម្មភាពសម្រាប់សិស្ស ដើម្បីឱ្យពួកគេទទួលបានបទពិសោធក្នុងការជួយមិត្តរួមថ្នាក់ និងបង្កើតឱ្យមានបរិស្ថានគាំទ្រក្នុងសាលារៀន ដែលពួកគេដឹងនៅពេលពួកគេត្រូវការជំនួយ ដោយរៀនពីវិធីប្រឈមមុខស្ថានការណ៍លំបាក និងយកឈ្នះលើស្ថានការណ៍ទាំងនោះ។

នៅពេលសិស្សផ្លាស់ប្ដូរពីបឋមសិក្សាទៅអនុវិទ្យាល័យ ពួកគេប្រឈមនឹងការផ្លាស់ប្ដូរដ៏ធំមួយ។ សមត្ថភាពក្នុងការប្រឈមមុខនឹងការផ្លាស់ប្ដូរនេះដោយអាកប្បកិរិយាវិជ្ជមាន ជាឧទាហរណ៍ដ៏សាមញ្ញមួយនៃបំណិនភាពធន់។

## អនុសាសន៍មួយចំនួនក្នុងការបង្រៀន (វិធីបង្រៀន)

- នៅក្នុងថ្នាក់រៀន ត្រូវរំលឹកសិស្សថា គ្រូជាអ្នកជួយ នៅពេលពួកគេត្រូវការជំនួយ
- គ្រូបង្រៀនត្រូវកំណត់ចំណុចខ្លាំងរបស់សិស្ស នៅពេលដែលពួកគេធ្វើការឆ្លុះបញ្ចាំងលើសកម្មភាព
- លើកឡើងពីចំណុចផ្លាស់ប្តូរ នៅពេលដែលអ្វីមួយនៅជាធម្មតា និងកំពុងស្តាបនា
- លើកទឹកចិត្តសិស្សឱ្យធ្វើសកម្មភាពដោយសហការជាមួយមិត្តភក្តិ
- លើកទឹកចិត្តសិស្សឱ្យឈ្មុសឈ្មុលចំពោះគោលបំណងរបស់គេ ដោយជួយពួកគេឱ្យហ៊ានប្រឈមមុខ និងយកឈ្នះលើឧបសគ្គ(លើកកម្ពស់បំណិនដោះស្រាយបញ្ហា ដោយជំនះស្ថានការណ៍លំបាកៗ)។
    - តើប្អូនបានរៀនអ្វីខ្លះពីបញ្ហានេះ?
    - តើប្អូននឹងធ្វើអ្វីនៅពេលដែលប្អូនជួបស្ថានការណ៍បែបនេះពេលក្រោយ?
- ទំនាក់ទំនងជាមួយឪពុកម្តាយសិស្សនៅពេលចាំបាច់។

## ឧទាហរណ៍ សកម្មភាពលើកកម្ពស់បំណិនភាពធន់នៅសាលារៀន

- បង្កើតប្រព័ន្ធសុវត្ថិភាព និងការយល់ដឹងនៅសាលារៀន(ដូចជា ទប់ទល់នឹងការគំរាមកំហែង)
- រៀបចំ និងលើកកម្ពស់សកម្មភាព មិត្តជួយមិត្ត(ទំនាក់ទំនងជាវិជ្ជមានរវាងមិត្តភក្តិ)
- បង្កើតឱ្យមានឱកាសដែលសិស្សអាចសួររកជំនួយទាំងនៅក្នុង និងក្រៅថ្នាក់
- ចូលរួមជាមួយសិស្សក្នុងការបង្កើតផែនការបន្ថយហានិភ័យនៃមហន្តរាយ ឬបង្កើតសកម្មភាពប្រព័ន្ធព្រមានជាមុន ក្នុងការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន(ទឹកជំនន់ បោះបង់ការសិក្សា...)
- ជំរុញឱ្យមានក្លឹបសិក្សារវាងមិត្តភក្តិ និងសកម្មភាពមិត្តជួយមិត្ត។

**ប្រភពបន្ថែម៖** Family resilience in emergency, UNICEF (2013). Available in the MoEYS website.

## ៦. ទំនាក់ទំនង

គ្រូបង្រៀននឹងបង្កើតឱ្យមានសកម្មភាពដែលសិស្ស នឹងអនុវត្តវិធីសួរសំណួរ ដើម្បីពន្យល់ និងការពារគំនិតរបស់ពួកគេដោយជាក់លាក់ នៅចំពោះមុខសមាសភាពមនុស្សផ្សេងៗគ្នា ប្រកបដោយទំនុកចិត្តក្នុងការប្រើវិធីទំនាក់ទំនងផ្សេងៗ ទាំងការប្រើពាក្យសម្ដី កាយវិការ និងលិខិត។

នៅពេលសិស្សអាចនិយាយដោយភាពជឿជាក់ជាមួយមនុស្សប្រភេទផ្សេងគ្នា នៅខាងក្រៅសាលា ដោយគ្មានការភ័យខ្លាច។

### អនុសាសន៍មួយចំនួនក្នុងការបង្រៀន (វិធីបង្រៀន)

- បង្កើតគោលការណ៍សម្រាប់ការទំនាក់ទំនងល្អរបស់សិស្ស ដាក់ក្នុងថ្នាក់រៀន(បង្កើតផ្ទាំងកាតុងណែនាំ)
- ជំរុញបំណិនទំនាក់ទំនងជាក់លាក់ (គ្រូបង្រៀនត្រូវតែជាគំរូ)។ ចំណុចគន្លឹះមួយចំនួន៖
  - o សួរបញ្ជាក់
  - o ស្ដាប់ដោយយកចិត្តទុកដាក់
  - o មើលឱ្យចំមុខសិស្សនៅពេលនិយាយជាមួយគេ
  - o ឱ្យតម្លៃសិស្សស្មើៗគ្នា(ទាំងប្រុស និងស្រី)
- ជំរុញឱ្យមានសកម្មភាពពិភាក្សានៅក្នុងថ្នាក់រៀន (ក្នុងថ្នាក់ទាំងមូល ជាក្រុម ជាដៃគូ)
- រួមបញ្ចូលវិធីផ្សេងៗក្នុងសកម្មភាពទំនាក់ទំនងទៅក្នុងការបង្រៀនដូចជា៖ ការធ្វើបទបង្ហាញ ធ្វើផ្ទាំងរូបភាពផ្សព្វផ្សាយ គូររូបភាព វីដេអូ ចម្រៀង...
- ផ្ដល់ឱកាសដល់សិស្សក្នុងការធ្វើទំនាក់ទំនងជាមួយមនុស្សប្រភេទផ្សេងៗ (ដៃគូ សមាជិកសហគមន៍ គណៈគ្រប់គ្រងសាលា អង្គការក្រៅរដ្ឋាភិបាល ...)

### ការស្ដាប់ប្រកបដោយប្រសិទ្ធភាព

ការស្ដាប់ប្រកបដោយប្រសិទ្ធភាពគឺត្រូវធ្វើរឿងបួនយ៉ាងដូចខាងក្រោម៖

- គិតពីអ្វីដែលអ្នកនោះកំពុងនិយាយ
- សួរបញ្ជាក់នូវអ្វីដែលពួកគេមិនយល់
- រំលឹកពីពាក្យដែលគេបាននិយាយ
- គិតពីអ្វីដែលពួកគេចង់ដឹងបន្ថែមទៀត និងសួរសំណួរតាមលំដាប់លំដោយ។

ប្រភព ៖ WVI Peace road.

### ឧទាហរណ៍ សម្មភាពជំរុញបំណិនទំនាក់ទំនងនៅសាលារៀន៖



បង្ហាញពីលទ្ធផលនៃសកម្មភាពសិស្សនៅក្នុងសាលារៀន។



ដាក់បញ្ចូលបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការផ្សព្វផ្សាយការងាររបស់សិស្ស (វីដេអូខ្លី អូឌីយ៉ូ ការរៀបរៀងសារព័ត៌មានសាលា)



បង្កើតឱកាសឱ្យមានការជជែកពិភាក្សាជាសាធារណៈរវាងសិស្សនឹងសិស្សនៅក្នុងសាលា។ (សិស្សត្រូវតែជ្រើសរើសប្រធានបទដើម្បីបង្ហាញ)



ការប្រកួតប្រជែងកម្រិតសាលារៀន (ការគូរគំនូរ ការតែងនិពន្ធ...) ដែលជាផ្នែកមួយនៃសកម្មភាពផ្សព្វផ្សាយ។

**ប្រភពបន្ថែម៖** ឧបសម្ព័ន្ធ ដំណើរការបង្រៀន៦ដំណាក់កាល ដំណាក់កាលទី៥៖ គន្លឹះនៃបំណិនទំនាក់ទំនង (ការប្រើកាយវិការ ការប្រើពាក្យសម្តី)

# បំណិនសម្រាប់ការងារ

## ៧-សហប្រតិបត្តិការ ៨-ការចរចា ៩-ការសម្រេចចិត្ត

ក្រុមនៃបំណិននេះហៅថា បំណិនសម្រាប់ការងារ បំណិននេះមានទំនាក់ទំនងទៅនឹងពិភពការងារ។ ជាក់ស្តែង ការសិក្សាពីបំណិនសហប្រតិបត្តិការ ការចរចា ការសម្រេចចិត្ត នឹងធ្វើឱ្យសិស្សអាចបំពេញការងារបានល្អនៅក្នុងក្រុម មានភាពចុះសម្រុងគ្នាជាមិត្តភាពក្នុងការស្វែងរកដំណោះស្រាយរួម ទទួលយកបានទាំងអស់គ្នា (ការចរចា) ឬមានផែនការយុទ្ធសាស្ត្រ និងកំណត់គោលដៅច្បាស់លាស់។ បំណិនទាំងបីនេះគឺជាបំណិនស្នូលសម្រាប់បំណិនការងារ។ មានបំណិនសម្រាប់ការងារជាច្រើនផ្សេងទៀត ដែលជាការអនុវត្តផ្ទាល់ដូចជា ការសម្ភាស៍ ការសរសេរប្រវត្តិរូបសង្ខេបសម្រាប់ដាក់ពាក្យសុំធ្វើការងារ ដែលបំណិនទាំងនេះ នឹងត្រូវបានរុករកបន្ថែមក្នុងការសិក្សាប្រធានបទអាជីពងាយ ជាពិសេសក្នុងប្រធានបទ សហគ្រិនភាព និងភាពជាអ្នកដឹកនាំ។



៧.សហប្រតិបត្តិការ

សិស្សានុសិស្សនឹងបានសិក្សាពី គោលការណ៍ធ្វើការជាដៃគូ ឬក្រុម ប្រកបដោយប្រសិទ្ធផល និងវិធីក្នុងការចូលរួម។ គ្រូបង្រៀននឹង ផ្តល់យន្តការដើម្បីអនុវត្តបំណិននេះ។ បំណិននេះនឹងជួយសិស្សនៅពេលដែលពួកគេជួបស្ថានការណ៍ការងារនៅពេលខាងមុខ នៅពេលដែលពួកគេធ្វើការងារជាមួយក្រុមផ្សេងៗ។

នៅពេលសិស្សចូលរួមយ៉ាងងាយស្រួលក្នុងការងារក្រុមណាមួយ នៅក្នុងសាលារៀន ឬនៅផ្ទះ។

### អនុសាសន៍មួយចំនួនក្នុងការបង្រៀន (វិធីបង្រៀន)

- បង្កើតនូវក្តីរំពឹង និងបទដ្ឋានសម្រាប់ការងាររួមគ្នា និងបញ្ចៀសជម្លោះជាមួយសិស្ស
- លើកកម្ពស់ឱ្យសិស្សស្តាប់គ្នាទៅវិញទៅមក ស្តាប់សិនមុនពេលឆ្លើយតប
- បង្កើតឱ្យមានសកម្មភាពមិនស្មុគស្មាញពេក ដែលតម្រូវឱ្យសិស្សត្រូវតែសហការគ្នាដោះស្រាយ
- បង្កើតក្រុមការងារតូចៗ (ដើម្បីឱ្យមានការចូលរួមគ្រប់គ្នា ព្រោះក្រុមធំពិបាកក្នុងការសហប្រតិបត្តិការ)
- ផ្តល់ឱកាសឱ្យមានការពិភាក្សាក្នុងថ្នាក់ ដែលសិស្សអាចជជែកជាមួយគ្នាបាន (សិស្សទាំងអស់ក្នុងថ្នាក់ ឬជាដៃគូ)
- ប្រើជម្រើសចៃដន្យក្នុងការផ្តល់តួនាទីដល់សិស្សឱ្យបំពេញការងារក្នុងក្រុម គឺពួកគេបានរៀនពីតួនាទីផ្សេងៗដើម្បីសហការគ្នា ដោយមិនឱ្យគេបំពេញតែតួនាទីដែលងាយស្រួលសម្រាប់គេរហូតឡើយ។

### ឧទាហរណ៍ សកម្មភាពជំរុញបំណិនសហប្រតិបត្តិការនៅសាលារៀន៖



ធ្វើការជាក្រុមដើម្បីសម្រេចឱ្យបាននូវផលិតផល។



ធ្វើការជាក្រុមក្នុងអំឡុងពេលធ្វើសកម្មភាពបំ ណិនជីវិតតាមមូលដ្ឋាន។



ការសម្ភាសជាមួយអ្នកជំនាញក្នុងមូលដ្ឋាន។



ពិភាក្សាអភិវឌ្ឍកម្រងសំណួរ ឬធ្វើការសម្រេចរករបៀបផ្សព្វផ្សាយព័ត៌មានដែលបានរកឃើញ។

## ៨. ការចរចា

សិស្សនឹងត្រូវបានណែនាំ ឱ្យចេះជម្នះរាល់បញ្ហារួមជាមួយនរណាម្នាក់ ហើយគេត្រូវតែស្វែងយល់ពីអ្វីដែលដៃគូចង់ធ្វើ នឹងអ្វីដែលគេមាន ដើម្បីឱ្យពួកគេធ្វើបាន និងមានការពេញចិត្តនៅពេលដែលមានការផ្លាស់ប្តូរថ្មី។ ការកសាងទំនាក់ទំនងល្អ គឺជាកិច្ចការដែលត្រូវធ្វើរៀងរាល់ពេល ទាំងនៅកន្លែងធ្វើការ និងនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។

នៅពេលសិស្សទៅផ្សារជាមួយក្រុមគ្រួសារ និងជួយក្នុងការតថ្លៃ ឬនៅពេលពួកគេសម្របសម្រួលជាច្រើន ជាមួយបងប្អូនបង្កើតរបស់ពួកគេ ដើម្បីរកដំណោះស្រាយដែលធ្វើឱ្យភាគីទាំងពីរសប្បាយចិត្ត។

### អនុសាសន៍មួយចំនួនក្នុងការបង្រៀន (វិធីបង្រៀន)

- សួរសិស្ស ឱ្យពួកគេគិតអំពីអ្វីដែលពួកគេតែងធ្វើនៅពេលដែលពួកគេចង់បានអ្វីមួយ។
- លើកទឹកចិត្តសិស្ស ឱ្យផ្តោតលើតម្រូវការអ្នកដទៃ៖
  ហេតុអ្វីបានជាអ្នកធ្វើវា ? ឬ ហេតុអ្វីបានជាពួកគេគិតបែបនេះ ? ហេតុអ្វីបានជាគេចង់បានវា ?
- លើកទឹកចិត្តសិស្ស ឱ្យសកម្មក្នុងការស្តាប់អ្នកផ្សេងនិយាយ និងគិតពីអ្វីដែលអ្នកដទៃកំពុងគិត។
- លើកទឹកចិត្តសិស្ស ឱ្យយល់ច្បាស់ពីហេតុផល និងចេះពន្យល់ហេតុផលនោះ។
- បង្រៀនសិស្សឱ្យស្វែងយល់ពីដំណោះស្រាយឈ្នះ-ឈ្នះ (សូមមើលឧបសម្ព័ន្ធខាងក្រោម) ជាដំណោះស្រាយដែលល្អសម្រាប់ទាំងអស់គ្នា។
- ធ្វើសម្មភាពជាអ្នកកណ្តាល ឬជាអ្នកសម្របសម្រួលនៅពេលដែលសិស្សត្រូវការ ឬបង្រៀនឱ្យសិស្សផ្សេងធ្វើក្រោមការណែនាំរបស់អ្នក។

## ឧទាហរណ៍ សកម្មភាពជំរុញឱ្យមានបំណិនចរចានៅសាលារៀន

- **ឧបករណ៍វិភាគទំនាស់** ៖ នៅពេលដែលអ្នកចង់ដោះស្រាយជម្លោះជាមួយសិស្ស សូមស្វែងយល់ពីបញ្ហានោះជាមុន ដែលវាធ្វើឱ្យអ្នកងាយស្រួល។ ប្រើឧបករណ៍សាមញ្ញធម្មតា ដូចជាឧបករណ៍ខ្ទឹមបារាំងក្នុងការបង្រៀន( សូមមើលខាងក្រោម )។

### ឧបករណ៍ខ្ទឹមបារាំង




### គូសរង្វង់ចំនួនបី និងសួរសិស្សឱ្យគិតអំពី៖

1. តើយើងចង់និយាយពីអ្វី? រង្វង់ខាងក្រៅ
2. តើយើងពិតជាចង់បានអ្វី? រង្វង់កណ្ដាល
3. តើអ្វីដែលយើងត្រូវតែមាន? រង្វង់ខាងក្នុង

ដំណើរការនេះ នឹងជួយសិស្សឱ្យបញ្ជាក់ពីអ្វីដែលពួកគេមាន និងអ្វីដែលពួកគេអាចសម្របសម្រួលបាននៅទីបញ្ចប់។

- **ដំណោះស្រាយ ឈ្នះ-ឈ្នះ**

ដំណោះស្រាយ ឈ្នះ-ឈ្នះ គឺជាយុទ្ធសាស្ត្រដើម្បីស្វែងរកដំណោះស្រាយដែលអាចសម្របសម្រួលភាគីទាំងពីរ។ដំណើរការនេះទាមទារឱ្យសិស្សរៀនសម្របសម្រួលពីអ្វីដែលពួកគេចង់បាន និងពួកគេត្រូវយល់ពីសារប្រយោជន៍ដែលពួកគេនឹងទទួលបានជំនួយពីអ្វីដែលពួកគេមិនទទួលបានទាល់តែសោះ។




**ប្រភពបន្ថែម ៖** ឧបសម្ព័ន្ធ ៤.៤. ឯកសារដំណោះស្រាយ ឈ្នះ-ឈ្នះ

**៩-ការសម្រេចចិត្ត**

សិស្សនឹងពិសោធធ្វើការសម្រេចចិត្តក្នុងលក្ខណៈជាក់លាក់ និងបង្កើតគោលដៅក្រោមការណែនាំរបស់គ្រូបង្រៀន ហើយពួកគេនឹងដឹងថា ពួកគេអាចអនុវត្តដំណើរការដូចគ្នានេះក្នុងជីវិតរស់នៅប្រចាំថ្ងៃ ដែលជាយន្តការជីវិតជាក់ស្តែង។

នៅពេលសិស្សសម្រេចថាលេងហ្គេមអ្វីជាមួយអ្នកដទៃ។ នៅពេលសិស្សអាចពី ។ សម្រេមូលហេតុចចិត្តនូវអ្វីដែលពួកគេចង់ធ្វើនៅពេលអនាគត និងពន្យល់ មូលហេតុ។

### អនុសាសន៍មួយចំនួនក្នុងការបង្រៀន (វិធីបង្រៀន)

- ផ្ដល់កិច្ចការដោយឡែកៗដល់សិស្ស។
- បង្កើតនូវផែនការសាមញ្ញៗ លើអ្វីដែលសិស្សចង់ធ្វើ។
- លើកទឹកចិត្តសិស្សកំណត់បង្ហាញនូវមតិយោបល់លើសពីមួយ មុនពេលធ្វើការសម្រេចចិត្ត៖ តើវាពិតជាយោបល់តែមួយគត់ឬ? តើមានអ្វី...ប្រសិនបើ...?
- លើកទឹកចិត្តសិស្ស ឱ្យធ្វើការសម្រេចចិត្ត និងព្យាយាម។ សាលារៀនជាកន្លែងមួយដែលកំហុសទាំងឡាយជាផ្នែកមួយនៃការសិក្សា។
- អភិវឌ្ឍតាមអាយុ ដោយចាប់ផ្ដើមជួយពួកគេក្នុងការកំណត់គោលដៅរយៈពេលខ្លី មធ្យម និងវែងក្នុងពេលធ្វើសកម្មភាពបំណិនជីវិតតាមមូលដ្ឋាន។
- ផ្ដល់ឱកាសដល់សិស្សគិតអំពីមតិយោបល់របស់ពួកគេ (ការមិនប្រាប់ពួកគេ = ឱ្យពួកគេស្វ័យសិក្សា)។

### ឧទាហរណ៍សម្មភាពជំរុញការធ្វើសេចក្ដីសម្រេចចិត្ត

គ្រូបង្រៀនអាចប្រើបច្ចេកទេសពីរ ដែលងាយស្រួលដូចខាងក្រោម៖

**១. បច្ចេកទេសធ្វើការសម្រេចចិត្តត្រឹមត្រូវ**

ស្នើ ឬគូរជាមួយសិស្សនូវតារាងដូចខាងក្រោម៖

| ជំហាន | សេចក្ដីអធិប្បាយ |
|---|---|
| កំណត់គោលបំណង (តើអ្វីដែលខ្ញុំចង់ទទួលបាន) | ................................................................ |
| កំណត់ជំហាន និងតម្រូវការ ដើម្បីទទួលបានគោលដៅ (តើអ្វីខ្លះដែលខ្ញុំត្រូវធ្វើ?) | ................................................................<br>................................................................ |
| គិតពីបញ្ហាដែលអាចកើតមានឡើង និងបញ្ហាប្រឈមដែលអាចបង្អាក់ពេលរបស់អ្នកនឹងក្រុម (តើកំហុសអ្វីដែលនឹងអាចកើតមានឡើង?) | ................................................................<br>................................................................<br>................................................................ |
| កំណត់កាលបរិច្ឆេទ តើនៅពេលណាដែលខ្ញុំអាចបញ្ចប់វាបាន? | ................................................................<br>................................................................ |

**ប្រភពបន្ថែម ៖** FinnChurch Aid ' Career Counseling Manual, 2016

**២. តារាងអក្សរ T**




ប្រើនៅពេលដែលអ្នកជួយសិស្សក្នុងការកំណត់ជម្រើសដ៏ល្អបំផុត ហើយ សួរពួកគេឱ្យឆ្លុះបញ្ចាំងលើចំណុចបី៖

- តើជម្រើសទាំងនេះសាកសមទៅនឹងគុណតម្លៃរបស់អ្នកយ៉ាងដូចម្តេច ?
- តើអ្នកនឹងមានអារម្មណ៍បែបណាប្រសិនបើអ្នកជ្រើសរើសជម្រើសមួយនេះ ?
- តើមានអ្នកណាផ្សេងដែលអាចជួយអ្នកក្នុងការសម្រេចចិត្តនេះ ?

## បំណិនសម្រាប់ភាពជាពលរដ្ឋ

**១០-ការគោរពពហុភាព ១១-សមានចិត្ត ១២-ការចូលរួម**

បំណិនសម្រាប់ភាពជាពលរដ្ឋ សំដៅលើបរិបទសង្គម៖ សិស្សានុសិស្សត្រូវការពង្រឹងបំណិនដែលអាចឱ្យពួកគេបំពេញមុខងារបានល្អនៅក្នុងសង្គមដែលគេរស់នៅ ដោយទទួលស្គាល់នូវភាពចម្រុះ និងអាចជំរុញសកម្មភាពផ្លាស់ប្តូរជាវិជ្ជមាន។

**១០. ការគោរពពហុភាព**

សិស្សានុសិស្សនឹងរៀនទង្វើនៃការផ្តល់សេចក្តីគោរពចំពោះមិត្តភក្តិ បើទោះបីមានការបង្ហាត់បង្ហាញ និងគំរូពីគ្រូបង្រៀនផ្សេងៗគ្នាក៏ដោយ។ បំណិនទាំងនេះមានសារៈសំខាន់ដល់សិស្សក្នុងការបង្កើតទំនាក់ទំនងក្នុងជីវិតប្រចាំថ្ងៃ និងក្នុងបរិស្ថានការងារនាពេលអនាគត។

នៅពេលសិស្សបង្ហាញការចង់ដឹងចង់ឃើញ និងការគោរព នៅពេលពួកគេជួបនរណាម្នាក់ថ្មី ដែលខុសពីអ្វីដែលពួកគេធ្លាប់ជួប ( សម្រាប់អាកប្បកិរិយា សាសនា សញ្ជាតិ ភេទ។ល។ )នៅក្នុងភូមិ។

**អនុសាសន៍មួយចំនួនក្នុងការបង្រៀន ( វិធីបង្រៀន )**

សម្របកម្មវិធីសិក្សាទៅនឹងមូលដ្ឋានវប្បធម៌របស់សិស្ស និងតម្រូវការពិសេសរបស់សិស្ស។

- បែងចែកកិច្ចការដល់សិស្សដោយជម្រើសចៃដន្យ ( ដាក់សិស្សចម្រុះគ្នា )។ប្រើបច្ចេកទេសនៃការចូលរួមដោយគ្រប់សិស្សទាំងអស់ត្រូវចូលរួមក្នុងដំណើរការរៀន និងបង្រៀន( សូមមើលបំណិនចូលរួមនៅខាងក្រោម )។

> នៅពេលដែលគ្រូមិនបានចែករំលែកពីប្រវត្តិវប្បធម៌ផ្សេងៗគ្នារបស់សិស្ស ពួកគេអាចមានការលំបាកក្នុងការនាំសិស្សទៅក្នុងមេរៀន។
>
> (Mcintyre, Rosebery & Gonzales, 1994)

- អន្តរាគមន៍ពេលឃើញឥរិយាបថផ្តាំផ្គងរបស់សិស្ស គ្រូបង្រៀនជាជនគំរូទាំងក្នុងសាលា និងសហគមន៍។

- ចាត់ទុកសិស្សទាំងអស់ស្មើភាពគ្នា៖ ផ្តល់ឱកាសចូលរួម។
- ផ្តល់ជំនួយបន្ថែមដល់សិស្សដែលត្រូវការជំនួយ។
- ដាក់បញ្ចូល ផែនទី រូបភាព ដ្យាក្រាម ដែលជួយពង្រឹងដល់ដំណើរការរៀន នៅពេលដែលអ្នកដឹងថា សិស្សមួយចំនួនជួបឧបសគ្គ។
- ចាត់ទុកក្មេងប្រុស និងក្មេងស្រីស្មើៗគ្នា (ទោះបីមានភេទផ្សេងគ្នាក៏ដោយ ក៏សេចក្តីប្រាថ្នា ឱកាស អនាគតដូចគ្នាដែរ)។

### ឧទាហរណ៍សកម្មភាពជំរុញឱ្យមានបំណិនគោរពពហុភាពនៅសាលារៀន៖

- គ្រូបង្រៀនអាចជំរុញឱ្យមានបំណិនគោរពពហុភាព ដោយលើកសំណើប្រធានបទក្នុងមុខវិជ្ជាបំណិន ជីវិតតាមមូលដ្ឋាន ដោយស្វែងយល់ពីប្រពៃណី វប្បធម៌ផ្សេងៗគ្នា សមភាពយេនឌ័រ។ល។
- គ្រូបង្រៀនអាចស្នើធ្វើពិធី ដែលផ្តល់សារប្រយោជន៍ដល់សិស្ស និងទាក់ទងប្រធានបទបំណិនជីវិតតាមមូលដ្ឋាន ដែលបានជ្រើសរើស។ ឧទាហរណ៍៖
  - ទិវាជនពិការពិភពលោក ៣វិច្ឆិកា ទិវាអន្តរជាតិនារី ៨មីនា
  - ពីធីបុណ្យជនជាតិភាគតិចមួយក្រុមក្នុងសាលារៀន( ព្នង ចារាយ ទំពូន គួយ គ្រឹង ចាម ។ល។)
- បង្កើតជ្រុងមួយកន្លែងនៃថ្នាក់ ដោយមានរូបភាពពី សម្លៀកបំពាក់ប្រពៃណី ឧបករណ៍តន្ត្រី។
- ប្រមូលរឿងរ៉ាវប្រពៃណីនៃវប្បធម៌ផ្សេងៗ និងពិភាក្សាជាមួយសិស្សរបស់អ្នក។
- ជំរុញសកម្មភាពសាមគ្គីភាពដល់សិស្ស ឬមនុស្សម្នាដែលចង់បាន (រៀបចំការលក់ចំណីអាហារដែលបានចម្អិនដោយឪពុកម្តាយសិស្ស ឬសិស្សនៅក្នុងសាលា ដើម្បីប្រមូលថវិកាផ្តល់អាហារូបករណ៍ដល់មិត្តភក្តិដែលត្រូវការ ឬកសាងផ្លូវជម្រាលសម្រាប់រទេះជនពិការក្នុងសាលារៀន។ល។

**ប្រភពបន្ថែម ៖** ម៉ូឌុល២ : “ពហុភាព” ម៉ូឌុល៣: “សមភាពយេនឌ័រ” ក្នុងកម្មវិធីសិក្សាវិថីសន្តិភាព WVI, 2009 (គេហទំព័រ ក្រសួងអប់រំយុវជន និងកីឡា)។



១១. សមានចិត្ត

សិស្សនឹងរៀនយល់ពីអារម្មណ៍អ្នកដទៃ និងសម្របទៅតាមអាកប្បកិរិយារបស់ពួកគេ។ គ្រូបង្រៀនជំរុញឱ្យមានសកម្មភាពស្តាប់ និងផ្តល់ឱកាសឱ្យពួកគេបង្ហាញពីអារម្មណ៍ និងវិធីជួយគ្នាទៅវិញទៅមក។

សិស្ស ឬសមាជិកគ្រួសារផ្សេងទៀត នឹងជួយសិស្សដែលកំពុងមានបញ្ហាដូចជា សិស្សនោះមិនបានស្នើសុំរកជំនួយក៏ដោយ ។

## អនុសាសន៍មួយចំនួនក្នុងការបង្រៀន (វិធីបង្រៀន)

- ធ្វើសកម្មភាពជាគំរូដល់សិស្ស៖ សួរសិស្សពីរបៀបដែលពួកគេទទួលនូវអារម្មណ៍ថា ជាអ្នកជួយសិស្សពេញមួយឆ្នាំ (ប្រើឧបករណ៍វាស់អារម្មណ៍)។
- ជួយសិស្សឆ្លុះបញ្ចាំងពីអារម្មណ៍របស់ពួកគេ និងពីរបៀបជួយមិត្តភក្តិ។ សួរសំណួរទៅកាន់សិស្សដូច ជា៖តើអ្វីនឹងកើតមាននៅកន្លែងពួកគេ? តើអ្វីដែលពួកគេអាចជួយគ្នាបាន? ប្រសិនបើពួកគេមានបទពិសោធដូចពីមុនតើពួកគេនឹងដោះស្រាយយ៉ាងដូចម្តេច?
- ជួយសិស្សណាដែលត្រូវការផ្លាស់ប្តូរយោបល់។
- លើកទឹកចិត្តសិស្សឱ្យជួយគ្នាទៅវិញទៅមក នៅពេលមានឱកាសល្អ។

## ឧទាហរណ៍សកម្មភាពជំរុញសិស្សឱ្យមានបំណិនសមានចិត្តនៅសាលារៀន៖



- "តើអ្នកមានអារម្មណ៍យ៉ាងណាដែរថ្ងៃនេះ?" សូមប្រើ**ឧបករណ៍វាស់**អារម្មណ៍ ធ្វើការឆ្លុះបញ្ចាំងជាប្រចាំឬប្រើសំណួរបើកនៅក្នុងថ្នាក់។ លើកទឹកចិត្តសិស្សឱ្យពិភាក្សាគ្នាជាដៃគូ ឬជាក្រុម និងព្យាយាមជួយមិត្តភក្តិរបស់ពួកគេ នៅពេលគេមានអារម្មណ៍ថាអវិជ្ជមាន។ សំខាន់ "យើងអាចជួបរឿងអាក្រក់ រឿងល្អក្នុងមួយថ្ងៃៗ ហើយវាសំខាន់ណាស់ដែលមនុស្សទាំងអស់ត្រូវយល់បញ្ហានេះ"។
- បង្កើត**ប្រអប់សរសើរ ឬថ្លែងអំណរគុណ** ដាក់ក្នុងថ្នាក់ ដោយដាក់វានៅជ្រុងណាមួយនៃថ្នាក់ ហើយពន្យល់សិស្សឱ្យចេះសរសេរសារកោតសរសើរ ឬថ្លែងអំណរគុណដល់សិស្សដទៃទៀត។ ជាកិច្ចចាប់ផ្តើម គ្រូបង្រៀនអាចសរសេរសារ និងលើកទឹកចិត្ត សិស្សឱ្យបន្តធ្វើ។ អានសារទាំងនោះឱ្យឮខ្លាំងៗ រៀងរាល់សប្តាហ៍ មុនពេលបញ្ចប់ម៉ោងសិក្សាមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន(សម្រាប់ថ្នាក់ទី៦ សិស្សអាចអាន)។



- **មិត្តភក្តិជួយមិត្តភក្តិ** ៖ ដាក់កិច្ចការឱ្យសិស្សម្នាក់ៗធ្វើជាដៃគូ ដែលអាចជួយនរណាម្នាក់អវត្តមានក្នុងថ្ងៃណាមួយ ឬពួកគេមិនច្បាស់ពីប្រធានបទ ។ កិច្ចសហប្រតិបត្តិការគ្នាជាគូនេះ ចង់ឱ្យសិស្សមានស្វ័យទំនុកចិត្តនិងធ្វើឱ្យសិស្សមានជំនឿថា ពួកគេអាចមានលទ្ធភាពជួយគ្នាទៅវិញទៅមក។

**ប្រភពបន្ថែម** ៖ ឧបសម្ព័ន្ធ ៤.៥ ឯកសារទស្សនៃការបង្រៀន

## ១២-ការចូលរួម

បទពិសោធបង្រៀននឹងផ្តល់ឱកាសដល់សិស្ស ក្នុងការចូលរួមសកម្មភាពកម្រិតផ្សេងៗគ្នា។ សិស្សនឹងរៀនពីវិធីល្អៗដើម្បីលើកយោបល់ និងធ្វើសកម្មភាពជាមួយអ្នកដទៃ ហើយអាចទទួលផលប្រយោជន៍ពីសកម្មភាពនេះ។

នៅពេលដែលសិស្សចង់ចូលរួមសកម្មភាព និងចែករំលែកនៅសាលា និងនៅផ្ទះជាមួយក្រុមគ្រួសារ និងមិត្តភក្តិ។

### អនុសាសន៍មួយចំនួនក្នុងការបង្រៀន (វិធីបង្រៀន)

- ប្រើបច្ចេកទេសដែលអាចឱ្យសិស្សចូលរួមទាំងអស់គ្នា៖
  - សម្ភាសន៍ជាដៃគូ
  - សួរសំណួរ និងប្រាប់ឱ្យគេគូសជ្រើសរើស
  - ផ្តោតលើបញ្ហាមួយ និងប្រាប់សិស្សឱ្យគិតរកដំណោះស្រាយ៖ ការជ្រើសរើសសិស្សដោយចៃដន្យឱ្យឆ្លើយសំណួរ (សិស្សទាំងអស់ត្រូវតែត្រៀមខ្លួនជាស្រេចក្នុងការឆ្លើយ)
  - ការអនុវត្តបច្ចេកទេសសិក្សាសកម្ម(ជំពូក៣) នឹងជំរុញឱ្យមានការចូលរួម
- រៀបចំសកម្មភាពមិត្តជួយមិត្ត(ក្រុមសិក្សា។ល។)
- ប្រគល់កិច្ចការឱ្យសិស្សម្នាក់ៗក្នុងក្រុម(ក្រុមតូច)ដើម្បីអនុវត្ត។ ត្រួតពិនិត្យការចូលរួមជាក់ស្តែងក្នុងក្រុមការងារ
- យកចិត្តទុកដាក់សិស្សទាំងអស់ មិនមែនយកចិត្តទុកដាក់តែសិស្សរៀនពូកែ និងយល់ដឹងនោះទេ
- ស្នើឱ្យមានការពិភាក្សាផ្អែកតាមសកម្មភាព។

### ឧទាហរណ៍ សកម្មភាពជំរុញឱ្យមានបំណិនចូលរួម នៅសាលារៀន៖



សិស្សចូលរួមក្នុងការជ្រើសរើសប្រធានបទមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន។ កម្មវិធីសិក្សាបែបពិគ្រោះយោបល់នៅកម្រិតតាមសាលារៀន។



ក្រុមប្រឹក្សាសិស្សជួយសិស្សឱ្យចូលរួម។



យុទ្ធនាការ ៖ ជួយសិស្សឱ្យរៀបចំយុទ្ធនាការក្នុង និងក្រៅសាលារៀនដើម្បីឱ្យមានចំណាប់អារម្មណ៍លើប្រធានបទជាក់លាក់ ។



មិត្តជួយមិត្ត៖ ប្រើ បច្ចេកទេសកសាងសមត្ថភាពសិស្ស ឱ្យចេះគាំទ្រគ្នាទៅវិញទៅមក ហើយចូលរួមយ៉ាងសកម្ម។

**ប្រភពបន្ថែម ៖** ឧបសម្ព័ន្ធ៤.៦ ការចាប់ផ្តើមក្លឹបកាសែត។

## ស្វ័យឆ្លុះបញ្ចាំងជំពូក៤

សូមពិនិត្យមើលការយល់ដឹងរបស់អ្នក

| | | |
|---|---|---|
| ១ | តើការសួរសំណួរជាផ្នែកនៃដំណើរការរិះគិតពិចារណាដែរឬទេ ? | ☐ បាទ/ចាស ☐ ទេ |
| ២ | តើភាពធន់ជាបំណិនមួយដែលធ្វើឱ្យសិស្សឈានទៅរកភាពវិជ្ជមាន ការផ្លាស់ប្តូរ និងស្ថានការណ៍ស្មុគស្មាញផ្លូវចិត្តឬទេ ? | ☐ បាទ/ចាស ☐ ទេ |
| ៣ | តើការគោរពពហុភាព មានរួមបញ្ចូលការចាត់ទុកក្មេងប្រុសស្មើគ្នានឹងក្មេងស្រីដែរឬទេ ? | ☐ បាទ/ចាស ☐ ទេ |
| ៤ | តើកិច្ចសហប្រតិបត្តិការជាបំណិនសំខាន់មួយសម្រាប់អនាគតការងាររបស់អ្នកដែរឬទេ ? | ☐ បាទ/ចាស ☐ ទេ |
| ៥ | តើអ្នកគិតថា បំណិនទន់នីមួយៗបញ្ចូលក្នុងដំណើរការវាយតម្លៃតែប៉ុណ្ណោះទេឬ ? | ☐ បាទ/ចាស ☐ ទេ |
| ៦ | ការប្រើប្រភេទផ្សេងៗនៃសម្ភារឧបទេសក្នុងការបង្រៀន អាចជួយឱ្យកើតបំណិនច្នៃប្រឌិតដល់សិស្សដែរឬទេ ? | ☐ បាទ/ចាស ☐ ទេ |
| ៧ | តើការជួយសិស្សឱ្យស្វែងយល់ពីអារម្មណ៍អ្នកដទៃ ជាផ្នែកមួយនៃការបង្រៀនបំណិនសមានចិត្ត ដល់សិស្សឬទេ ? | ☐ បាទ/ចាស ☐ ទេ |
| ៨ | បំណិនទន់មានសារៈខាន់ ព្រោះវាជួយឱ្យមនុស្សម្នាក់ៗប្រឈមមុខទៅនឹងការប្រកួតប្រជែង ហើយជួយឱ្យមានភាពជោគជ័យក្នុងការងារទៅអនាគត តើត្រឹមត្រូវឬទេ ? | ☐ បាទ/ចាស ☐ ទេ |
| ៩ | តើឧបករណ៍វាស់អារម្មណ៍ត្រូវបានប្រើប្រាស់សម្រាប់ប្រធានបទ“អាជីពអនាគតរបស់សិស្ស” បានដែរឬទេ ? | ☐ បាទ/ចាស ☐ ទេ |
| ១០ | ការចូលរួមមានសារប្រយោជន៍ មិនសម្រាប់តែអ្នកចូលរួមទេ ប៉ុន្តែវាមានប្រយោជន៍សម្រាប់ក្រុមទាំងមូល តើត្រឹមត្រូវឬទេ ? | ☐ បាទ/ចាស ☐ ទេ |
| ១១ | តើអ្នកអាចផ្តល់បច្ចេកទេសដោះស្រាយបញ្ហាពីរដែលអ្នកបានប្រើជាមួយសិស្សរបស់អ្នក (ដើម្បីស្វែងយល់ ឬវិភាគបញ្ហា) បានដែរឬទេ ? | 1.______________<br>2.______________ |

**ចម្លើយ ៖** ១-បាទ/ចាស ២-បាទ/ចាស ៣-បាទ/ចាស ៤-បាទ/ចាស ៥-ទេ ៦-បាទ/ចាស ៧-បាទ/ចាស ៨-បាទ/ចាស ៩-ទេ ១០-បាទ/ចាស ១១-( 1.ការដោះស្រាយបញ្ហា 2.ព្យុះគំនិត 3.ឆ្អឹងត្រី 4.ហេតុអ្វី5ដង )

## លំហាត់

សូមមើលរូបភាព ហើយជ្រើសបំណិនទន់ ឬបំណិនរឹងដែលបង្ហាញ។ គ្រូបង្រៀនអាចប្រើលំហាត់នេះ ជាមួយសិស្សផងដែរ ដើម្បីណែនាំពីអ្វីដែលពួកគេសិក្សា ក្នុងពេលរៀនមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន ក្នុងបញ្ញត្តិបំណិនទន់( ជាពិសេសសម្រាប់សិស្សនៅអនុវិទ្យាល័យ )។

| | | | | | |
|---|---|---|---|---|---|
| ១ |  | ☐ បំណិនទន់<br>☐ បំណិនរឹង | ៥ |  | ☐ បំណិនទន់<br>☐ បំណិនរឹង |
| ២ |  | ☐ បំណិនទន់<br>☐ បំណិនរឹង | ៦ |  | ☐ បំណិនទន់<br>☐ បំណិនរឹង |
| ៣ |  | ☐ បំណិនទន់<br>☐ បំណិនរឹង | ៧ |  | ☐ បំណិនទន់<br>☐ បំណិនរឹង |
| ៤ |  | ☐ បំណិនទន់<br>☐ បំណិនរឹង | ៨ |  | ☐ បំណិនទន់<br>☐ បំណិនរឹង |

# ជំពូក ៥ ផែនការបង្រៀន និងប្រភពធនធាន

## ៥.១. ការរៀបចំផែនការបង្រៀន ឬផែនការប្រចាំឆមាស

បំណិនជីវិតតាមមូលដ្ឋានអនុវត្តនូវបច្ចេកទេសបង្រៀនផ្អែកលើបញ្ហា ដែលដំណើរការនៃការបង្រៀនគឺជាធាតុសំខាន់។ កង្វះខាតសៀវភៅសិក្សាផ្តល់ឱ្យសាលារៀននូវសេរីភាពក្នុងការអង្កេតស្រាវជ្រាវ លើប្រធានបទដែលមានភាពពាក់ព័ន្ធសម្រាប់សិស្សក្នុងមូលដ្ឋាន ដោយគ្មានមាតិកាដែលបានកំណត់ជាមុន។ គ្រូត្រូវរៀបចំផែន ការបង្រៀនសម្រាប់ឆមាស(៣៥ម៉ោងសិក្សាសម្រាប់បឋមសិក្សា និង១៧ម៉ោងសិក្សាសម្រាប់អនុវិទ្យាល័យ) និងកិច្ចតែងការបង្រៀនមេរៀននីមួយៗដូចជាមុខវិជ្ជាគោលផ្សេងទៀត។ នៅបឋមសិក្សា និងអនុវិទ្យាល័យត្រូវប្រើទម្រង់ដូចខាងក្រោមសម្រាប់ផែនការបង្រៀនមួយឆមាស៖

### ក-តារាងគំរូផែនការបង្រៀន

| ខែ | សប្តាហ៍ | ម៉ោង | ខ្លឹមសារ/សកម្មភាព និង ដំណាក់កាលទាំង៦ | ធនធាន/ សម្ភារៈ | វិជ្ជាសម្បទា | បំណិនសម្បទា | ចរិយាសម្បទា / គុណតម្លៃ |
|---|---|---|---|---|---|---|---|
| ១០ | | | ប្រធានបទជ្រើសរើស | | | | |
| ១១ | ទី១ | ១ | ដំណាក់កាលទី ១ | | | | |
| | ទី២ | ២ | | | | | |
| | ទី៣ | ៣ | ដំណាក់កាលទី ២ | | | | |
| | ទី៤ | ៤ | | | | | |
| ១២ | ទី៥ | ៥ | | | | | |
| | ទី៦ | ៦ | ដំណាក់កាលទី... | | | | |
| | ទី៧ | ៧ | | | | | |
| | ទី៨ | ៨ | | | | | |
| ១ | ទី៩ | ៩ | | | | | |
| | .... | ... | | | | | |
| ២ | ទី១៧ | ១៧ | ដំណាក់កាលទី ៦ | | | | |

នៅពេលបញ្ចប់ផែនការបង្រៀនឆមាស បំណិនទន់ដែលជាគោលដៅនៅក្នុងជួរឈរនៃ“ បំណិន” គ្រូត្រូវពន្យល់លម្អិតអំពីកិច្ចតែងការមេរៀននីមួយៗដូចដែលពួកគេបានធ្វើសម្រាប់មុខវិជ្ជាផ្សេងទៀត។

## ខ-គំរូសង្គម និងគំរូអាជីពងាយ

ចំណុចចាប់ផ្ដើមសម្រាប់ធ្វើផែនការបង្រៀនគឺត្រូវសម្រេចចិត្តយកគំរូសង្គម ឬគំរូអាជីពងាយ សម្រាប់ការបង្រៀនប្រធានបទបំណិនជីវិតតាមមូលដ្ឋាន។ តាមពិតជម្រើសនេះនឹងសម្រេចថាតើគ្រូបំណិនជីវិតនឹងកំណត់គោលដៅ និងលទ្ធផលសិក្សាទូទៅ៖

| គំរូ | បំណិនគោលដៅ | |
|---|---|---|
| គំរូសង្គម | បំណិនមូលដ្ឋាន | ចំណេះដឹងទាក់ទងនឹងមូលដ្ឋាន |
| | | បំណិនបុរេវិជ្ជាជីវៈ |
| | | ចរិយាសម្បទា និងគុណតម្លៃផ្ទាល់ខ្លួន |
| គំរូអាជីពងាយ | បំណិនអាជីព | បំណិនមូលដ្ឋាន |
| | | បំណិនបច្ចេកទេស |
| | | បំណិនអាជីវកម្ម និងគ្រប់គ្រង |

នៅពេលសម្រេចចិត្តយកគំរូណាហើយ គ្រូត្រូវរៀបចំផែនការបង្រៀនដោយផ្អែកលើដំណើរការបង្រៀន៦ដំណាក់កាល ហើយជ្រើសរើសសកម្មភាពដែលផ្ដោតជាពិសេសលើបំណិនមូលដ្ឋាន ឬបំណិនអាជីព។

ផែនកាបង្រៀនមានសារៈសំខាន់ខ្លាំងណាស់សម្រាប់គ្រូ ក្នុងការយល់ថា មានទំនាក់ទំនងផ្ទាល់រវាងសកម្មភាពដែលគ្រូបានរៀបចំ និងការអភិវឌ្ឍបំណិនទន់។ នៅក្នុងដំណាក់កាលនីមួយៗនៃការអនុវត្ត គ្រូអាចរៀបចំសកម្មភាពដែលជួយសិស្សឱ្យរៀនអនុវត្តក្រុមបំណិនជាក់លាក់។ ឧទាហរណ៍៖

| សកម្មភាព | បំណិនទន់ |
|---|---|
| **ដំណាក់កាលទី១**<br>(រៀបចំឱ្យបង្ហាញគំនិតក្នុងថ្នាក់រៀន ឬក្នុងសាលា) | សិស្សអនុវត្តបំណិនទំនាក់ទំនង និងចរចា ក្នុងការពិភាក្សា និងការពារគំនិតរបស់ខ្លួន |
| **ដំណាក់កាលទី២**<br>(ប្រមូលព័ត៌មាន) | សិស្សកំណត់យកប្រភពព័ត៌មានដែលត្រឹមត្រូវ (ដំណោះស្រាយបញ្ហា) និងហ្វឹកហាត់ការបកស្រាយ។ |
| **ដំណាក់កាលទី៣**<br>(វិភាគព័ត៌មាន) | សិស្សសិក្សាដើម្បីបែងចែកប្រភេទនៃព័ត៌មាន និងវិភាគ (វិភាគពិចារណា)ដើម្បីរកដំណោះស្រាយបញ្ហាមួយ។ |
| **ការឆ្លុះបញ្ចាំង**<br>(រាល់ដំណាក់កាលនីមួយៗ) | ស្វែងយល់ពីខ្លួនឯង និងអ្នកដទៃនូវចំណុចខ្សោយ និងចំណុចខ្លាំង និងសិក្សារកវិធីកែលម្អរាល់ចំណុចអវិជ្ជមាន។ |

នៅពេលអនុវត្តគំរូអាជីពងាយ គ្រូត្រូវបញ្ចូលសកម្មភាពដើម្បីអភិវឌ្ឍបំណិនអាជីវកម្ម និងគ្រប់គ្រង។ដើម្បីជាជំនួយក្នុងការបង្រៀន គ្រូអាចយោងទៅលើឯកសារដែលមាននៅក្នុងគេហទំព័ររបស់ក្រសួងអប់រំ យុវជន និងកីឡា ហើយនៅតាមសាលារៀនភាគច្រើនមានឯកសារនេះដែលផ្តោតជាពិសេសលើបំណិនអាជីវកម្ម និងបំណិនគ្រប់គ្រង។ ឯកសារទាំងនេះមាន៖

1- ការគ្រប់គ្រងប្រាក់

2- ពិភពការងារ

3- ការសន្សំ និងចំណាយ

4- សហគ្រាសសង្គម និងកុមារ

5- ជំនាញទីផ្សារខ្ញុំ

6- អនាគតខ្ញុំ



**ឧទាហរណ៍៖** នៅពេលបង្រៀនការចិញ្ចឹមមាន់ គ្រូអាចបញ្ចូលមេរៀនស្តីពីជំនាញទីផ្សារដែលមាននៅក្នុងសៀវភៅណែនាំឈ្មោះ“ ជំនាញទីផ្សាររបស់ខ្ញុំ” ឬបញ្ចូលមេរៀនមួយចំនួនស្តីពីការអនុវត្តសន្សំ និងចំណាយ ដោយប្រើឯកសារដែលទាក់ទងជាប្រភពព័ត៌មាន។ សៀវភៅណែនាំ និងឯកសារបន្ថែមទាំងនេះសម្រាប់ប្រធានបទសហគ្រិនភាព និងប្រឹក្សាអាជីពអាចរកបានដោយទាញយកនៅក្នុងគេហទំព័ររបស់ក្រសួងអប់រំយុវជន និងកីឡា។ ឯកសាររួមមានសៀវភៅណែនាំពីអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ឬអង្គការអន្តរជាតិ កម្មវិធីសម្រាប់ការតម្រង់ទិសអាជីព ឯកសារបន្ថែមរបស់ក្រសួងអប់រំយុវជន និងកីឡា។ ល។

ផ្អែកតាមឧបសម្ព័ន្ធ ៥.១-ឧទាហរណ៍នៃគំរូអាជីពងាយ និងគំរូសង្គម ឧបសម្ព័ន្ធ ៥.៣-លំនាំបង្រៀន៦ដំណាក់កាល និងឧបសម្ព័ន្ធ ៥.៤ “ផូស្ទ័រ៦ដំណាក់កាល” និងឧបសម្ព័ន្ធនៅលើ “សំណើសកម្មភាព៦ដំណាក់កាល” ។

## ៥.២. ស្តង់ដាបំណិនជីវិតតាមមូលដ្ឋាន

ទាំងគំរូសង្គម និងអាជីពងាយ ការអភិវឌ្ឍបំណិនទន់គឺជាចំណុចសំខាន់ ហើយគ្រូចាំបាច់ត្រូវដាក់បញ្ចូលក្នុងផែនការសកម្មភាពដែលគាំទ្រដល់ការអភិវឌ្ឍបំណិនទន់ទាំងនោះ ដោយត្រូវប្រាកដថា សកម្មភាពទាំងនោះគឺសមស្របនឹងអាយុសិស្ស កម្រិតថ្នាក់ និងសមត្ថភាព។ ផ្អែកលើគោលបំណងនេះ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការកំណត់ស្តង់ដាសិក្សាបំណិនជីវិតតាមមូលដ្ឋាន។

ស្តង់ដាសិក្សា( ឧបសម្ព័ន្ធ៥.២ ស្តង់ដាសិក្សា) សង្ខេបពីរបៀបដែលសិស្សគួរតែបង្ហាញការរីកចម្រើនជាបណ្តើរៗនូវការទទួលបានបំណិន និងសមត្ថភាពទូទៅនៅក្នុងមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន។ នេះមានន័យថា សម្រាប់បំណិនទន់គោលដៅនីមួយៗត្រូវបានបញ្ជាក់នូវអ្វីដែលសិស្សរំពឹងថានឹងអាចដឹង និងអនុវត្តនៅចុងបញ្ចប់នៃថ្នាក់

នីមួយៗ។ ឯកសារនេះពិតជាមានប្រយោជន៍ខ្លាំងណាស់ សម្រាប់គ្រូក្នុងការរៀបចំផែនការសកម្មភាពរបស់ពួកគេ ពីព្រោះវាផ្តល់នូវឯកសារយោងលើអ្វីដែលសិស្សគួរតែអាចធ្វើបាន នៅចុងបញ្ចប់នៃឆ្នាំសិក្សា។ ដូច្នេះការរៀបចំសកម្មភាពចាំបាច់ត្រូវផ្អែកលើវា។ ស្តង់ដាសិក្សាក៏ជាជំនួយដល់ការរៀបចំឧបករណ៍វាយតម្លៃដូចដែលយើងនឹងឃើញបន្ថែមទៀតនៅក្នុងជំពូកទី៧ ។

## របៀបប្រើស្តង់ដាសិក្សា

ដើម្បីប្រើស្តង់ដាសិក្សាគ្រូបង្រៀនចាំបាច់ត្រូវ៖

| ជំហាន | សកម្មភាព | ឧទាហរណ៍ |
|---|---|---|
| ១ | កំណត់បំណិនទន់គោលដៅ<br>នៅក្នុងមេរៀន។ | បំណិនទំនាក់ទំនង |
| ២ | អានស្តង់ដាសិក្សាអំពី បំណិនទន់នោះ។ អ្នកនឹងរៀននូវអ្វីដែលរំពឹងថា សិស្សនឹងដឹងហើយធ្វើអ្វីដែលទាក់ទងនឹងបំណិននោះ<br>នៅចុងបញ្ចប់នៃថ្នាក់។ | ថ្នាក់ទី៦. សិស្សត្រូវប្រាស្រ័យទាក់ទងយ៉ាងច្បាស់ នូវព័ត៌មាន គំនិត និងយោបល់ ដោយប្រើវិធីផ្សេងៗគ្នាក្នុងការប្រាស្រ័យទាក់ទង ជាពិសេសការប្រាស្រ័យទាក់ទងដោយពាក្យសម្តី និងកាយវិការចំពោះបរិបទ វិសាលភាព និងអ្នកត្រូវប្រាស្រ័យទាក់ទង។ |
| ៣ | គិតអំពីសកម្មភាពដែលអាចជួយសិស្សក្នុងការសម្រេចបាននូវស្តង់ដាសិក្សា។ | - តើការប្រាស្រ័យទាក់ទងអាចធ្វើបានតាមវិធីណាខ្លះ?<br>- តើសកម្មភាពអ្វីខ្លះដែលអាចជួយសិស្សក្នុងការរៀនសូត្រ<br>អំពីការប្រាស្រ័យទាក់ទងតាមវិធីផ្សេងៗគ្នា?<br>- តើខ្ញុំអាចជួយពួកគេឱ្យក្លាយជាមនុស្សល្អដោយគ្មានការប្រាស្រ័យទាក់ទងដោយពាក្យសម្តីយ៉ាងដូចម្តេច? |
| ៤ | បញ្ចូលទៅក្នុងសកម្មភាព កិច្ចតែងការបង្រៀនរបស់អ្នកដែលនឹងផ្តល់ឱកាសដល់សិស្សដើម្បីអភិវឌ្ឍ និងអនុវត្តបំណិនទន់ដែលបានជ្រើសរើស។ | - រៀបចំសកម្មភាពមួយដែលសិស្សត្រូវធ្វើបទបង្ហាញនៅចំពោះមុខមិត្តភក្តិដទៃទៀត<br>- រៀបចំការជជែកវែកញែកនៅក្នុងថ្នាក់រៀន<br>- មុនពេលពួកគេនិយាយនៅចំពោះមុខអ្នកដទៃ ត្រូវផ្តល់ឱ្យពួកគេនូវគន្លឹះដើម្បីក្លាយជាអ្នកទំនាក់ទំនងល្អ (សូមមើលឧបសម្ព័ន្ធ)។ |

## ៥.៣. ការសម្របសម្រួលជាមួយគ្រូមុខវិជ្ជាដទៃ និងភាគីពាក់ព័ន្ធ

ជាចុងក្រោយការងារបង្រៀនបំណិនជីវិតតាមមូលដ្ឋាន នឹងទទួលបានអត្ថប្រយោជន៍ខ្ពស់ ពីការសហការជាមួយគ្រូមុខវិជ្ជាផ្សេងទៀតនៅក្នុងសាលារបស់ពួកគេ។ ដំបូងគ្រូដទៃទៀតអាចជាប្រភពនៃការលើកទឹកចិត្តសម្រាប់ការអនុវត្តការបង្រៀន និងរៀនជាមួយគ្នា ស្នើគំនិតដើម្បីដោះស្រាយបញ្ហា និងចែករំលែកព័ត៌មានអំពីសិស្ស ដោយជួយគ្រូបំណិនជីវិតតាមមូលដ្ឋានក្នុងដំណើរការវាយតម្លៃ ជាពិសេសសម្រាប់អ្វីដែលសំដៅទៅលើការវាយតម្លៃបំណិនទន់របស់សិស្ស ពីព្រោះពួកគេអាចចែករំលែកកំណត់សម្គាល់ការសង្កេត នៅក្នុងមុខវិជ្ជារបស់ពួកគេ ក៏ដូចជាឥរិយាបថរបស់សិស្ស។

## ៥.៤. ប្រភពព័ត៌មាន

ក្នុងអំឡុងពេលនៃការធ្វើផែនការបង្រៀន គ្រូត្រូវបញ្ចូលទីកន្លែងដែលសិស្សនឹងស្វែងរកព័ត៌មាន។ ក្នុងអំឡុងពេលរៀបចំកម្មវិធីសិក្សាបែបពិគ្រោះយោបល់នៅកម្រិតសាលារៀន សាលាអាចកំណត់អត្តសញ្ញាណអ្នកជំនាញក្នុងសហគមន៍ ដែលនឹងក្លាយជាប្រភពព័ត៌មានដ៏សំខាន់ ដែលគ្រូនិងសិស្សត្រូវសួរព័ត៌មាន។ នៅពេលចាប់ផ្តើម គ្រូនឹងបញ្ចប់ការកំណត់អត្តសញ្ញាណប្រភពព័ត៌មានជាមួយសិស្ស ដោយជ្រើសរើសប្រភពព័ត៌មានមួយដែលសមស្រប។

### ក-នៅក្នុងសាលា៖

- គ្រូ ៖គ្រូគឺជាប្រភពពត៌មានដ៏ល្អសម្រាប់សិស្ស។ ពួកគេអាចសួរគ្រូនូវសំណួរ និងទទួលបានព័ត៌មានមុនពេលចាប់ផ្តើមការអង្កេត។

- គណៈគ្រប់គ្រងសាលា៖ នាយក នាយករងសាលា និងបុគ្គលិកសាលាដទៃទៀតអាចជាប្រភពព័ត៌មានដ៏ល្អលើប្រធានបទណាមួយដែលទាក់ទងនឹងការអប់រំ។ ឧទាហរណ៍ ការបោះបង់ការសិក្សា ឬគោលនយោបាយនៅក្នុងសាលាដើម្បីគ្រប់គ្រងបញ្ហានានា(ឧទាហរណ៍ បរិស្ថាន គុណភាពអប់រំ ការបោះបង់ការសិក្សា និងការរៀនត្រួតថ្នាក់។ល។)

- មិត្តភក្តិផ្សេងទៀត៖ មិត្តភក្តិផ្សេងទៀតអាចជួយរកព័ត៌មានអំពីប្រធានបទដែលត្រូវបានអង្កេត។

- បណ្ណាល័យ៖ សៀវភៅឯកសារណែនាំការអប់រំបំណិនជីវិតតាមមូលដ្ឋាន ទស្សនាវដ្តីនៅក្នុងបណ្ណាល័យ ក៏ដូចជារបាយការណ៍បំណិនជីវិតតាមមូលដ្ឋានចុងក្រោយពីថ្នាក់ផ្សេងទៀត គឺជាការជំរុញទឹកចិត្តដ៏ធំធេងសម្រាប់សិស្ស និងគ្រូ។ សៀវភៅណែនាំស្តីពីប្រធានបទជាក់លាក់ជាពិសេសសហគ្រិនភាព និងភាពជាអ្នកដឹកនាំ ត្រូវមាននៅក្នុងបណ្ណាល័យក៏ដូចជានៅលើវេបសាយ។ ធនធានសម្ភារៈទាំងអស់ដែលមានសម្រាប់ប្រធានបទសង្គម និងអាជីពងាយមាននៅលើគេហទំព័ររបស់ក្រសួងអប់រំ យុវជន និងកីឡា។

> គ្រូអាចស្នើឱ្យ DOE ឬសាលាផ្សេងទៀតចែកចាយធនធានឯកសារលើប្រធានបទ រួមទាំងឧទាហរណ៍នៃកិច្ចតែងការបង្រៀន។

## ខ-នៅខាងក្រៅសាលា៖

- សមាជិកគ្រួសារ៖ សមាជិកគ្រួសារគឺជាប្រភពព័ត៌មានដំបូងនៅកម្រិតសហគមន៍សម្រាប់សិស្ស។ សមាជិកគ្រួសារជាប្រភពព័ត៌មានដ៏ល្អសម្រាប់សិស្សទាំងអស់ និងជាពិសេសសិស្សបឋមសិក្សា។ នៅក្នុងផ្ទះអ្នកមានយុវជន មនុស្សចាស់ និងមនុស្សផ្សេងទៀតដែលមានបទពិសោធក្នុងជីវិតជាច្រើន។

- អ្នកជំនាញក្នុងមូលដ្ឋាន៖ អ្នកជំនាញក្នុងមូលដ្ឋានមកពីសហគមន៍ តំណាងឱ្យធនធានបច្ចេកទេសដ៏សំខាន់សម្រាប់សាលារៀន។ ពួកគេអាចពន្យល់ដល់សិស្សនូវបទពិសោធរបស់ពួកគេ ហើយសិស្សអាចរៀនសូត្រពីពួកគេ។ អ្នកជំនាញក្នុងមូលដ្ឋានមានសក្តានុពលសម្រាប់ប្រធានបទអាជីពងាយ (ការដាំដំណាំ ការចិញ្ចឹមសត្វ ។ល។) ប៉ុន្តែក៏សម្រាប់ប្រធានបទដែលទាក់ទងនឹងសង្គមផងដែរ។ ជាការពិត នៅពេលសាលារៀនសម្រេចចិត្តធ្វើការអង្កេតលើប្រធានបទសង្គម ពួកគេអាចស្នើសុំឱ្យសមាជិកសហគមន៍ចែករំលែកបទពិសោធរបស់ពួកគេផងដែរ។

- អាជ្ញាធរមូលដ្ឋាន៖ អាជ្ញាធរមូលដ្ឋានរួមមានអាជ្ញាធរខេត្ត ស្រុក និងឃុំដែលពាក់ព័ន្ធនឹងវិស័យផ្សេងៗគ្នាដូចជាការអប់រំ ផលផល កសិកម្ម កិច្ចការនារី។ ល។

- អ្នកពាក់ព័ន្ធសហគមន៍សំខាន់ៗដទៃទៀត៖ (មេដឹកនាំសាសនា ក្លឹបយុវជន ចាស់ព្រឹទ្ធាចារ្យ។ល។)នៅក្នុងសហគមន៍អ្នកអាចមានសមាគមសម្រាប់យុវជន ឬកន្លែងដែលមនុស្សចាស់ជួបជុំគ្នា(ឧ.នៅក្នុងវត្ត) ។ ពួកគេអាចជាប្រភពព័ត៌មានដ៏សំខាន់អំពីប្រពៃណី ប្រវត្តិភូមិឃុំ រឿងព្រេង គុណតម្លៃ។ ល។

- សង្គមស៊ីវិល៖ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិក្នុងនាមជាអង្គការជួយសហគមន៍ គឺជាធនធានដ៏សំខាន់ និងដឹងច្បាស់នៅក្នុងប្រធានបទផ្សេងៗគ្នាដែលសិស្សអាចចាប់អារម្មណ៍។

- ប្រភពផ្សេងៗទៀត៖ សិស្សក៏អាចប្រើកាសែត វិទ្យុ អ៊ិនធឺណែត កម្មវិធី (ប្រសិនបើមាននៅផ្ទះ ឬនៅតាមមជ្ឈមណ្ឌលអ៊ីនធឺណិតមួយចំនួន)។ ឧទាហរណ៍មួយនៃការអនុវត្តគឺជាត្រីវិស័យ ដែលផ្តល់ព័ត៌មានសំខាន់ៗសម្រាប់ការតម្រង់ទិសអាជីពនាពេលអនាគត ហើយអាចបំពេញបន្ថែមការបង្រៀនលើការប្រឹក្សាអាជីព។ សិស្ស ឬគ្រូអាចទាញយកបានតាមរយៈហ្គូហ្គោល។

- បណ្តាញសាលារៀន៖ សាលារៀនទាំងអស់ក្នុងខេត្តនីមួយៗនឹងត្រូវបានអញ្ជើញចូលរួមក្នុងបណ្តាញសាលារៀនដោយPOE។ POE បង្កើត និងគ្រប់គ្រងក្រុមទាំងនេះដោយប្រើបណ្តាញសង្គមមួយ (ជាធម្មតា Telegram ឬ Messenger) ដែលសាលារៀនអាចទំនាក់ទំនងបាន។

## គ-វិធីដែលសាលាអាចប្រើប្រាស់បណ្តាញសាលារៀន៖

- នរណា៖ នាយក នាយករង និងគ្រូបំណិនជីវិតតាមមូលដ្ឋានត្រូវបង្កើតជាក្រុម។ ប្រសិនបើអ្នកមិនមែនជាសមាជិកនៃក្រុមណាមួយសុំឱ្យ POEs ដាក់បញ្ចូលអ្នកក្នុងក្រុម។

- ចែករំលែកបទពិសោធ៖ បិទផ្សាយរូបភាពនៃសកម្មភាព សម្ភារៈដែលសាលាបានអនុវត្ត(របាយការណ៍ វីដេអូ)។ សាលាផ្សេងទៀតអាចរៀនពីការអនុវត្តល្អបំផុតរបស់អ្នក។

- សុំជំនួយ៖ សាលារៀនអាចប្រើបណ្តាញ ដើម្បីស្នើសុំជំនួយក្នុងការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន (ឧទាហរណ៍. ពួកគេមិនអាចចូលរួមក្នុងសហគមន៍ ពួកគេមិនដឹងថាត្រូវរកព័ត៌មាននៅឯណា ពួកគេមិនប្រាកដថា ប្រធានបទដែលស្នើឡើងមានសុវត្ថិភាពសម្រាប់សិស្សឬទេ)។ អ្នកអាចទាក់ទងក្រុមទាំងមូល ឬទាក់ទងសាលារៀនណាមួយដែលមានបទពិសោធ ហើយផ្តល់ការគាំទ្រដល់អ្នក។

- ត្រៀមខ្លួនដើម្បីគាំទ្រ៖ នៅពេលសាលារៀនសុំជំនួយសូមត្រៀមខ្លួនដើម្បីគាំទ្រ។ អ្នកប្រហែលជាត្រូវការជំនួយផងដែរនៅពេលអនាគត។

### ស្វ័យឆ្លុះបញ្ចាំងជំពូក៥

សូមអ្នកចំណាយពេល១០នាទី ដើម្បីត្រួតពិនិត្យមើលការយល់ដឹងរបស់អ្នកនៅជំពូកនេះ។

| | | |
|---|---|---|
| ១ | តើសុវត្ថិភាពគឺជាលក្ខណវិនិច្ឆ័យមួយក្នុងចំណោមលក្ខណវិនិច្ឆ័យដែលត្រូវបានស្នើឱ្យជ្រើសរើសប្រភពព័ត៌មានដែរឬទេ? | ☐ បាទ/ចាំ ☐ ទេ |
| ២ | តើបណ្តាញសាលារៀនត្រូវបានចាត់ទុកថាជាប្រភពព័ត៌មានសម្រាប់សាលារៀនដែរឬទេ? | ☐ បាទ/ចាំ ☐ ទេ |
| ៣ | តើសាលារៀនអាចរកឯកសារសហគ្រិនភាព និងភាពជាអ្នកដឹកនាំនៅឯណា? | ☐ ក្នុងបណ្ណាល័យ<br>☐ នៅក្នុងគេហទំព័រក្រសួងអប់រំ |
| ៤ | តើអ្នកត្រូវការកំណត់បំណិនទន់គោលដៅនៅក្នុងកិច្ចតែងការបង្រៀនឬទេ? ហេតុអ្វី? | ☐ បាទ/ចាំ ☐ ទេ<br>ហេតុអ្វី? |

ចម្លើយ៖ ១-បាទ/ចាំ ២-បាទ/ចាំ ៣-ទាំងពីរ ៤/បាទ/ចាំ ពីព្រោះគ្រូនឹងរៀបចំសកម្មភាពដោយពិចារណាលើបំណិនទន់ដែលត្រូវអភិវឌ្ឍ

# ជំពូក ៦ ការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន និង យន្តការគាំទ្រ

## ៦.១. ការបង្កើតសហគមន៍នៃការរៀន

### តួនាទីអ្នកពាក់ព័ន្ធ និងការទទួលខុសត្រូវ

| | |
|---|---|
| POE<br>អប់រំខេត្ត | • POE ទទួលខុសត្រូវក្នុងការអានឯកសារណែនាំការអនុវត្តការអប់រំបំណិនជីវិតតាមមូលដ្ឋាន<br>• ទទួលខុសត្រូវក្នុងការផ្សព្វផ្សាយ និងចែកចាយឯកសារណែនាំដល់ DTMT នាយកសាលា និងគ្រូបង្រៀន<br>• សាលាបឋមសិក្សា អនុវិទ្យាល័យ និងអធិការ ត្រូវបង្កើតក្រុមមួយជាមួយ DTMT ដើម្បីតាមដានការអនុវត្ត<br>• តាមដានការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន<br>• ជំរុញឱ្យភាគីពាក់ព័ន្ធទាំងអស់ប្រើប្រាស់ឯកសារណែនាំឱ្យបានត្រឹមត្រូវ<br>• ជួយ DTMT ឱ្យយល់ និងគាំទ្រការអនុវត្តការរៀនផ្អែកលើបញ្ហា(៦ដំណាក់កាល)<br>• ចាត់វិធានការណាមួយដើម្បីគាំទ្រសាលារៀន (ឧទាហរណ៍ជួយ DTMT ឬសាលារៀនក្នុងការកំណត់អត្តសញ្ញាណអ្នកជំនាញក្នុងសហគមន៍ ជំរុញឱ្យមានបណ្ដាញពីសាលារៀនទៅសាលារៀន និងពីខេត្តទៅខេត្ត)<br>• នៅពេលរៀបចំរបាយការណ៍ឆមាសសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា សូមបញ្ចូលបច្ចុប្បន្នភាពបំណិនជីវិតតាមមូលដ្ឋាន។ |
| DTMT<br>ក្រុមបច្ចេកទេសស្រុក | • DTMT មានទំនួលខុសត្រូវក្នុងការអានឯកសារណែនាំការអនុវត្តការអប់រំបំណិនជីវិតតាមមូលដ្ឋាន ស្វែងយល់ពីគោលនយោបាយ និងបញ្ញត្តិសំខាន់ៗ រួមមានការជ្រើសរើសប្រធានបទ គំរូនៃការអនុវត្ត ការអភិវឌ្ឍបំណិនទន់ ការរៀនផ្អែកលើបញ្ហា(៦ដំណាក់កាល) ការវាយតម្លៃ<br>• ជំរុញការបង្រៀនបំណិនជីវិតតាមមូលដ្ឋានដល់សាលារៀន អាជ្ញាធរមូលដ្ឋាន សហគមន៍ និងអ្នកជំនាញមូលដ្ឋាន (ជួយសាលាដើម្បីទទួលបានការគាំទ្រពីសហគមន៍)<br>• រៀបចំរបាយការណ៍តាមកាលកំណត់ហើយផ្ញើទៅ POE ។ |

| | |
|---|---|
| **នាយកសាលា** | • ទទួលខុសត្រូវក្នុងការអានឯកសារណែនាំការអនុវត្តការអប់រំបំណិនជីវិតតាមមូលដ្ឋាន ស្វែងយល់អំពីគោលនយោបាយ និងបញ្ញត្តិសំខាន់ៗ<br>• បញ្ចូលការបង្រៀនបំណិនជីវិតតាមមូលដ្ឋានទៅក្នុងផែនការបង្រៀនប្រចាំឆ្នាំ និងសុំឱ្យគ្រូអនុវត្តបំណិនជីវិតតាមមូលដ្ឋាន<br>• ចែករំលែកព័ត៌មានដល់គ្រូទាំងអស់ មិនត្រឹមតែគ្រូបំណិនជីវិតតាមមូលដ្ឋានទេ ហើយលើកទឹកចិត្តដល់ការអនុវត្តនោះ<br>• សម្របសម្រួល និងលើកទឹកចិត្តភាគីពាក់ព័ន្ធទាំងអស់ឱ្យចូលរួមក្នុងកម្មវិធីសិក្សាបែបពិគ្រោះយោបល់នៅកម្រិតសាលារៀន។ |
| **គ្រូបង្រៀន** | • ស្វែងយល់អំពីឯកសារណែនាំ<br>• រៀបចំផែនការ ឬកិច្ចតែងការបង្រៀនដោយប្រើវិធីសាស្ត្រសិក្សាផ្អែកលើបញ្ហា<br>• សម្របសម្រួលសកម្មភាពនានាសម្រាប់សិស្សអនុវត្តដំណាក់កាលទាំង៦<br>• វាយតម្លៃសិស្សអំពីវឌ្ឍនភាពនៃការសិក្សា<br>• ចែករំលែកបទពិសោធបង្រៀនជាមួយគ្រូដទៃទៀតនៅក្នុងសាលា និងសាលាផ្សេងទៀត។ |
| **សិស្ស** | • លើកសំណើប្រធានបទ<br>• ចូលរួមក្នុងការជ្រើសរើសប្រធានបទ<br>• ស្វែងយល់អំពីប្រធានបទ<br>• ចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាព<br>• ចូលរួមក្នុងការងារក្រុម។ |
| **សហគមន៍** | • ចូលរួមជាមួយអ្នកជំនាញក្នុងមូលដ្ឋាននៅតាមសាលារៀន ដែលអាចរកបានសម្រាប់ការសម្ភាស។ ផ្តល់ការគាំទ្រសកម្មភាពសិស្សនៅក្នុងសាលារៀន ដោយផ្អែកលើអ្នកជំនាញ និងពេលវេលា ដែលពួកគេមាន<br>• ជួយគាំទ្រដល់ការរៀនសូត្ររបស់សិស្សទាំងនៅផ្ទះ និងសាលារៀន(ឪពុកម្តាយ)។ |

# ៦.២. ការផ្សព្វផ្សាយបំណិនជីវិតតាមមូលដ្ឋាន និងយន្តការគាំទ្រ

## ក-ការផ្សព្វផ្សាយដល់បុគ្គលិក POE

មន្ត្រីអប់រំថ្នាក់កណ្ដាលមកពីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈជាអ្នកទទួលខុសត្រូវក្នុងការផ្សព្វផ្សាយពីឯកសារពាក់ព័ន្ធ នឹងបំណិនជីវិតតាមមូលដ្ឋាន ការអនុវត្ត និងយន្តការត្រួតពិនិត្យដល់មន្ត្រីថ្នាក់ខេត្ត។ នាយកដ្ឋានបឋមសិក្សា និងមធ្យមសិក្សាជួយសហការផងដែរ។ តារាងខាងក្រោមផ្ដល់នូវសេចក្ដីយោងទៅលើប្រភេទនៃអ្នកចូលរួម និងខ្លឹមសារនៃការប្រជុំផ្សព្វផ្សាយជាមួយ POE ដែលទទួលខុសត្រូវក្នុងការធានាគុណភាពលើការអនុវត្តទូទៅ។

| ថ្នាក់ដឹកនាំមន្ទីរ | មន្ត្រីថ្នាក់កណ្ដាល | ខ្លឹមសារសំខាន់ៗ |
|---|---|---|
| • ប្រធាន/អនុប្រធានមន្ទីរ<br>• ប្រធានការិយាល័យមធ្យមសិក្សា<br>• ប្រធានការិយាល័យអធិការកិច្ច<br>• ប្រធានការិយាល័យយុវជន<br>• ប្រធានការិយាល័យបឋមសិក្សា | • មន្ត្រីអប់រំនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ<br>• មន្ត្រីអធិការកិច្ច<br>• មន្ត្រីនាយកដ្ឋានបឋមសិក្សា<br>• គ្រូឧទ្ទេសមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យខេត្ត | • គោលនយោបាយអប់រំបំណិនជីវិតតាមមូលដ្ឋាន<br>• បទបញ្ញត្តិ និងយុទ្ធសាស្ត្រ<br>• តម្រង់ទិស DTMT និងសាលារៀនលើ៖<br>o ការអភិវឌ្ឍកម្មវិធីសិក្សាបែបពិគ្រោះយោបល់កម្រិតសាលារៀន<br>o បំណិនមូលដ្ឋាន និងបំណិនអាជីព<br>o គំរូសង្គម និងគំរូអាជីពងាយ<br>o ការអនុវត្តវិធីសាស្ត្រ PBL( ៦ដំណាក់កាល )<br>o ការវាយតម្លៃ<br>• បង្កើតភាពជាដៃគូ និងការគាំទ្រពីសហគមន៍<br>• គាំទ្រដល់ថ្នាក់ស្រុក និងសាលារៀនបណ្ដុះបណ្ដាល តាមដានត្រួតពិនិត្យ<br>• បង្កើតបណ្ដាញតេឡេក្រាម រវាងសាលានឹងសាលា ខេត្តនឹងខេត្ត<br>• ប្រជុំប្រចាំត្រីមាស និងប្រចាំឆ្នាំដើម្បីពិនិត្យឡើងវិញការអប់រំបំណិនជីវិតតាមមូលដ្ឋាន<br>• ពង្រីកបំណិនជីវិតតាមមូលដ្ឋានទៅសាលារៀនថ្មី។ |

## ខ-ការតម្រង់ទិសដោយ POE ដល់ DTMT និងគ្រូបំណិនជីវិតតាមមូលដ្ឋាន

មន្ទីរអប់រំខេត្តទទួលខុសត្រូវក្នុងការបណ្ដុះបណ្ដាល DTMT នាយកសាលា និងគ្រូ។ តារាងខាងក្រោមបង្ហាញអំពីប្រភេទនៃអ្នកចូលរួម និងខ្លឹមសារនៃការប្រជុំផ្សព្វផ្សាយជាមួយ DTMT និងសាលារៀន៖

| កម្រិតសាលារៀន | ក្រុមការងារថ្នាក់ស្រុក | ខ្លឹមសារសំខាន់ៗ |
|---|---|---|
| • គ្រូបំណិនជីវិតតាមមូលដ្ឋាន<br>• នាយកសាលា | • ប្រធានការិ.អយក.ស្រុក<br>• សមាជិក DTMT | • បញ្ញត្តិ និងការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន<br>• ការអភិវឌ្ឍកម្មវិធីសិក្សាបែបពិគ្រោះយោបល់<br>• លំនាំនៃការបង្រៀន និងរៀនបំណិនជីវិត (ដំណើរការបង្រៀន៦ដំណាក់កាល)<br>• ការវាយតម្លៃសិស្ស(វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងគុណតម្លៃផ្ទាល់ខ្លួន)<br>• ការគាំទ្រពីសហគមន៍<br>• បណ្ដាញសាលារៀន<br>• ការប្រជុំប្រចាំត្រីមាសពិនិត្យមើលវឌ្ឍនភាព។ |

## គ-ការតម្រង់ទិសដល់សាលា និងសហគមន៍

DTMT ត្រូវសហការជាមួយនាយកសាលាដើម្បីធ្វើការតម្រង់ទិសដល់សហគមន៍អំពីបំណិនជីវិតតាមមូលដ្ឋាន និងសារៈសំខាន់របស់វាដើម្បីធានាការយល់ដឹង និងការចូលរួម។ ការតម្រង់ទិសនេះផ្ដោតលើសារៈសំខាន់នៃបំណិនជីវិតតាមមូលដ្ឋាន និងការគាំទ្រពីសហគមន៍ (ព័ត៌មានលម្អិតនៅក្នុងតារាងខាងក្រោម)។ លើសពីនេះទៀត DTMT មានតួនាទីជួយសម្រួលដល់កិច្ចប្រជុំ ដើម្បីពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន និងចែករំលែកបទពិសោធនៅតាមស្រុករបស់ពួកគេ ផ្អែកតាមលទ្ធផលនៃការអនុវត្ត និងឧបករណ៍វាយតម្លៃ ។

| អ្នកចូលរួម | ខ្លឹមសារសំខាន់ៗ |
|---|---|
| • នាយក/នាយករងសាលា<br>• គណៈកម្មការទ្រទ្រង់សាលា<br>• តំណាងក្រុមប្រឹក្សាឃុំសង្កាត់<br>• អ្នកជំនាញក្នុងសហគមន៍<br>• មាតាបិតាសិស្ស | • ហេតុអ្វីបានជាការសិក្សាបំណិនជីវិតតាមមូលដ្ឋានសំខាន់សម្រាប់សិស្ស?<br>• តួនាទី និងទំនួលខុសត្រូវរបស់សហគមន៍<br>• អត្ថប្រយោជន៍សម្រាប់សហគមន៍<br>• តើសហគមន៍អាចចូលរួមចំណែកបានយ៉ាងដូចម្ដេច?<br>o ចូលរួមក្នុងការជ្រើសរើសប្រធានបទ<br>o គ្រូបង្រៀនគឺជាអ្នកសម្របសម្រួលសម្រាប់ការរៀនសូត្ររបស់សិស្សប៉ុន្តែសហគមន៍អាចជាវាគ្មិន ចែករំលែកបទពិសោធ និងជំនាញ ផ្ដល់ឱកាសសម្រាប់សិស្សសិក្សាស្រាវជ្រាវ ផ្ដល់សម្ភារៈវត្ថុធាតុដើម(ឧទាហរណ៍៖ គ្រាប់ពូជ។ ល។<br>o លើកកម្ពស់ការអភិវឌ្ឍបំណិនទន់នៅផ្ទះ<br>• ការប្រជុំប្រចាំឆមាសរវាងសាលារៀន និងសហគមន៍ដើម្បីពិនិត្យមើលវឌ្ឍនភាពការអប់រំបំណិនជីវិតតាមមូលដ្ឋាន។ |

## ឃ-ការប្រជុំប្រចាំឆ្នាំពិនិត្យឡើងវិញពីការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន

មន្ទីរអប់រំខេត្តនីមួយៗត្រូវរៀបចំការប្រជុំប្រចាំឆ្នាំ ដើម្បីពិនិត្យវឌ្ឍនភាពនៃការអនុវត្តបំណិនជីវិតតាមមូលដ្ឋាននៅតាមខេត្តរៀងៗខ្លួនដោយមានការចូលរួមពី DTMT និងសាលារៀន។ ការប្រជុំគួរផ្តោតលើ៖

- ✓ កម្មវិធីសិក្សាបែបពិគ្រោះយោបល់នៅកម្រិតសាលារៀនសម្រាប់ការអប់រំបំណិនជីវិតតាមមូលដ្ឋាន
- ✓ ដំណើរការបង្រៀន និងរៀន
- ✓ ចែករំលែកបទពិសោធ និងសម្ភារៈសិក្សា
- ✓ ការចូលរួមរបស់សហគមន៍ក្នុងការអប់រំបំណិនជីវិតតាមមូលដ្ឋាន
- ✓ ការវាយតម្លៃសិស្ស(វិជ្ជាសម្បទា  បំណិនសម្បទា និងចរិយាសម្បទា)
- ✓ លើកកម្ពស់ការគាំទ្ររវាងសាលានឹងសាលា។

POEs អាចបន្ថែមក្នុងរបៀបវារៈនូវបច្ចុប្បន្នភាពស្តីពីការអនុវត្តបំណិនជីវិតតាមមូលដ្ឋាននៅពេលប្រជុំ។

## ៦.៣. សកម្មភាពដែលសិស្សត្រូវធ្វើ មិនត្រូវធ្វើ និងការការពារខ្លួនជាមុន

វាជាការសំខាន់ណាស់ដែលគ្រូ ពេលរៀបចំផែនការសកម្មភាព សូមធានាថាសិស្សនឹងត្រូវទទួលបទពិសោធវិជ្ជមានដែលនឹងមិនបង្កអន្តរាយ ឬគ្រោះថ្នាក់ដល់ពួកគេ។ សម្រាប់ហេតុផលនេះ គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនត្រូវ៖

- នៅពេលអញ្ជើញអ្នកជំនាញក្នុងមូលដ្ឋាន សូមជួបជាមួយអ្នកនោះជាមុនហើយធានាថាគាត់នឹងប្រើភាសាសមស្រប ហើយមិនបញ្ចេញអាកប្បកិរិយាដែលធ្វើឱ្យសិស្សភ័យខ្លាច ឬពិបាកយល់នោះទេ។
- ជ្រើសរើសការអញ្ជើញមនុស្សដែលអាចធ្វើជាគំរូល្អសម្រាប់សិស្ស (ឧទាហរណ៍ប្រសិនបើសិស្សកំពុងសិក្សាស្រាវជ្រាវគ្រឿងញៀនសូមកុំអញ្ជើញអ្នកញៀនគ្រឿងញៀនធ្វើជាអ្នកជំនាញ ប៉ុន្តែត្រូវជ្រើសរើសមនុស្សដែលមកពីមណ្ឌលសុខភាព នគរបាល។ ល។ )
- ជានិច្ចកាលទៅជាមួយសិស្ស នៅពេលដែលពួកគេធ្វើសកម្មភាពនៅខាងក្រៅសាលា (ឬផ្ទេរសិទ្ធិឱ្យឪពុកម្តាយសិស្សណាមួយ)
- នៅពេលដែលអ្នករៀបចំធ្វើសកម្មភាពនៅខាងក្រៅសាលាជាមួយសិស្ស សូមទៅមើលកន្លែងនោះជាមុនហើយពិនិត្យមើលថាផ្លូវនោះអាចចូលបាន និងមានសុវត្ថិភាព
- ផ្ញើលិខិតទំនាក់ទំនងទៅមាតាបិតាសិស្ស ដោយប្រើប្រាស់សៀវភៅកំណត់ហេតុរបស់សិស្ស និងស្នើឱ្យគាត់ចុះហត្ថលេខានៅពេលដែលសិស្សចូលរួមសកម្មភាពនៅក្រៅសាលារៀន។

## ស្វ័យឆ្លុះបញ្ចាំងជំពូក៦

សូមចំណាយពេល១០នាទីដើម្បីពិនិត្យមើលការយល់ដឹងរបស់អ្នកអំពីជំពូកនេះ ៖

| | | |
|---|---|---|
| ១ | តើPOE ទទួលខុសត្រូវក្នុងការតម្រង់ទិសបំណិនជីវិតតាមមូលដ្ឋានដល់សាលារៀនដែរឬទេ ? | ☐ បាទ/ចាំ ☐ ទេ |
| ២ | តើបណ្ដាញសាលារៀនត្រូវបានគាំទ្រដោយ POE ដែរឬទេ ? | ☐ បាទ/ចាំ ☐ ទេ |
| ៣ | តើគ្រូមានទំនួលខុសត្រូវក្នុងការចែករំលែកបទពិសោធនៃការបង្រៀន និងការគិតតាមរយៈដំណើរការបង្រៀនជាមួយគ្រូដទៃទៀតនៅក្នុងសាលា និងសាលាផ្សេងទៀតដែរឬទេ ? | ☐ បាទ/ចាំ ☐ ទេ |
| ៤ | តើសិស្សទទួលខុសត្រូវអ្វីខ្លះ ? ធីក( √ )គ្រប់ចំណុចដែលត្រឹមត្រូវ | ☐ ចូលរួមក្នុងការជ្រើសរើសប្រធានបទ<br>☐ ស្វែងយល់ប្រធានបទ<br>☐ ចូលរួមយ៉ាងសកម្មនៅពេលរៀនមេរៀន<br>☐ ចូលរួមធ្វើការងារក្នុងក្រុម |

ចម្លើយ ៖ ១.បាទ/ចាស ២.បាទ/ចាស ៣.បាទ/ចាស ៤.ទាំងអស់

# ជំពូក ៧ ដំណើរការវាយតម្លៃ

## ៧.១. ទិដ្ឋភាពទូទៅនៃការវាយតម្លៃ

ការវាយតម្លៃគឺជាធាតុសំខាន់នៃដំណើរការបង្រៀន និងរៀនសម្រាប់សិស្ស លោកគ្រូ អ្នកគ្រូ ឪពុកម្ដាយ គណៈគ្រប់គ្រងសាលារៀន និងអធិការ។ ការវាយតម្លៃគឺជាការត្រួតពិនិត្យដំណើរការនៃការរៀនសូត្រ ផ្ដល់ព័ត៌មានត្រឡប់ដើម្បីកែលម្អការអនុវត្ត និងវាយតម្លៃប្រៀបធៀបនឹងវត្ថុបំណងនៃការសិក្សា។

ដូច្នេះអ្នកពាក់ព័ន្ធទាំងអស់ត្រូវតែដឹងច្បាស់អំពីដំណើរការនេះ ដោយចងចាំថាគោលបំណងនៃការវាយតម្លៃគឺដើម្បីផ្ដល់ការគាំទ្រដល់សិស្សមិនមែនដើម្បីស្ដីបន្ទោសទេ។ ទាំងសិស្ស និងគ្រូត្រូវតែសកម្មក្នុងដំណើរការវាយតម្លៃ ផ្ដល់ជាពិសេសដល់សិស្សនូវលទ្ធភាពឆ្លុះបញ្ចាំងលើដំណើរការ និងរៀនសូត្រពីវា។

ការអប់រំបំណិនជីវិតតាមមូលដ្ឋាន នឹងអនុវត្តបច្ចេកទេសសិក្សាផ្អែកលើបញ្ហា។ វិធីសាស្ត្រនេះលើកកម្ពស់តួនាទីសកម្មរបស់អ្នកសិក្សានៅក្នុងដំណើរការ ហើយទាមទារឱ្យមានការវាយតម្លៃជាបន្តក្នុងអំឡុងពេលដំណើរការសិក្សាទាំងមូល មិនត្រឹមតែនៅចុងបញ្ចប់ប៉ុណ្ណោះទេ អនុញ្ញាតឱ្យសិស្សរៀនពីរបៀបអនុវត្តបំណិន និងជំនះឧបសគ្គនៅក្នុងសកម្មភាពដែលបានស្នើឡើង ហើយធ្វើតាមការណែនាំរបស់គ្រូ។ ទម្រង់នៃការវាយតម្លៃនេះមានទម្រង់ផ្សេងៗគ្នាតាមរយៈការពិនិត្យតាមដាន(ការសង្កេត) ការឆ្លុះបញ្ចាំង និងព័ត៌មានត្រឡប់ ដូចដែលយើងនឹងឃើញនៅក្នុងកថាខណ្ឌខាងក្រោម។

ជាទូទៅ**ការវាយតម្លៃមានពីរប្រភេទគឺ ការវាយតម្លៃតាមដំណាក់ និងការវាយតម្លៃសរុប។**

| សកម្មភាព | អ្វី? | ហេតុអ្វី? | ដូចម្ដេច? | ពេលណា? |
|---|---|---|---|---|
| វាយតម្លៃតាមដំណាក់ | ការវាយតម្លៃការរៀនមានលក្ខណៈបន្ថែមផ្អែកលើការឆ្លើយតប និងព័ត៌មានត្រឡប់ក្នុងអំឡុងពេលរៀន។ | • ដើម្បីវិនិច្ឆ័យពីការរៀនរបស់សិស្ស<br>• ដើម្បីដឹកនាំសិស្សឱ្យរីកចម្រើន<br>• លើកទឹកចិត្តសិស្ស<br>• លើកកម្ពស់ការបង្រៀន និងរៀន<br>• វាយតម្លៃប្រសិទ្ធភាព ខ្លឹមសារ វិធី លំនាំ និងល្បឿននៃការបង្រៀន។ | • សង្កេតជាប្រចាំ<br>• ឯកសារ និងសំណុំឯកសារស្នាដៃរបស់សិស្សម្នាក់ៗ<br>• សង្កេតស៊ីជម្រៅ និងជាក់លាក់<br>• តាមដានពីសកម្មភាពសិស្ស<br>• ទំនាក់ទំនងជាមួយសិស្ស។ | ចប់មេរៀននីមួយៗ។ |

| | | | | |
|---|---|---|---|---|
| រង្វាយតម្លៃសរុប | វាយតម្លៃពីកម្រិតប្រតិបត្តិនៅចុងបញ្ចប់នៃរយៈពេលច្បាស់លាស់ ឧទាហរណ៍ ចុងបញ្ចប់ឆមាស ផ្តែកលើវត្ថុបំណងឬស្តង់ដាដែលបានកំណត់។ | • ដើម្បីកំណត់កម្រិតជោគជ័យក្នុងការសម្រេចវត្ថុបំណង<br>• ដើម្បីវិនិច្ឆ័យនូវអ្វីដែលសិស្សបានរៀន<br>• ដើម្បីវាយតម្លៃពីប្រសិទ្ធភាពនៃកម្មវិធីសិក្សា។ | • ប្រៀបធៀបកិច្ចការដែលបានបញ្ចប់ទៅនឹងគោលដៅដែលបានគ្រោង<br>• សរសេរសំណួរតេស្តប្រឡង<br>• រង្វាយតម្លៃការបង្រៀន។ | • ប្រចាំខែ<br>• ចុងឆមាស |

លើសពីនេះទៀត រង្វាយតម្លៃតាមដំណាក់ និងរង្វាយតម្លៃសរុបអាចជារង្វាយតម្លៃផ្លូវការ និងក្រៅផ្លូវការ ដូចបានរៀបរាប់ក្នុងតារាងខាងក្រោម៖

| ទម្រង់ | រង្វាយតម្លៃតាមដំណាក់ | រង្វាយតម្លៃសរុប |
|---|---|---|
| ក្រៅផ្លូវការ | សំណួរ<br>ព័ត៌មានត្រឡប់<br>រង្វាយតម្លៃដោយមិត្តភក្តិ<br>ស្វ័យវាយតម្លៃ | សំណុំឯកសារស្នាដៃសិស្ស(ផលប័ត្រ)<br>បទបង្ហាញការងារចុងក្រោយ<br>ស្វ័យវាយតម្លៃ<br>របាយការណ៍ចុងក្រោយស្តីពីសកម្មភាពទូទៅ |
| ផ្លូវការ | វិភាគបន្ថែមទៀតលើការធ្វើតេស្តការប្រឡង។ | ការធ្វើតេស្ត ការប្រឡង ការប្រឡងសំណេរអត្ថបទ ឧបករណ៍ពិនិត្យតាមដានរបស់គ្រូ។ |

• ការវាយតម្លៃផ្លូវការ៖ ទម្រង់ស្តង់ដា ការប្រមូលទិន្នន័យដើម្បីវាយតម្លៃការសិក្សារបស់សិស្ស

• ការវាយតម្លៃក្រៅផ្លូវការ៖ ការធ្វើតេស្ត និងវាយតម្លៃលទ្ធផលរបស់សិស្ស និងការយល់ដឹងរបស់ពួកគេដោយមិនប្រើតេស្តស្តង់ដា ប៉ុន្តែកំណត់លក្ខណវិនិច្ឆ័យទូទៅ។

## ៧.២.រង្វាយតម្លៃបំណិនជីវិតតាមមូលដ្ឋាន

### ក.រង្វាយតម្លៃផ្លូវការ

ការវាយតម្លៃបំណិនជីវិតតាមមូលដ្ឋានផ្តោតលើវឌ្ឍនភាពរបស់កុមារអំពី វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទានិងគុណតម្លៃផ្ទាល់ខ្លួន។ គ្រូត្រូវបញ្ចូលទម្រង់ទាំងពីរជាមួយនឹងការវាយតម្លៃសរុបដើម្បីតាមដាន និងវាស់វិជ្ជាសម្បទា (១) និងបំណិនសម្បទា ចរិយាសម្បទានិងគុណតម្លៃផ្ទាល់ខ្លួន (២) ។

| តើយើងវាយតម្លៃអំពីអ្វី? | | តើយើងវាយតម្លៃដូចម្ដេច? |
|---|---|---|
| **១. វិជ្ជាសម្បទា**<br>• ចំណេះដឹងលើប្រធានបទ<br>• រៀបរាប់ការអនុវត្តសម្រាប់ខ្លួនឯងក្នុងជីវិតប្រចាំថ្ងៃ<br>• រៀបរាប់ការអនុវត្តក្នុងបរិបទជាក់ស្ដែងជាមួយគ្រួសារ និងសហគមន៍។ | • សិស្សទទួលបានចំណេះដឹងជុំវិញប្រធានបទពាក់ព័ន្ធនឹងជីវិតរស់នៅប្រចាំថ្ងៃរបស់គេ<br>• រៀនពីវិធីបង្ការ និងការពារខ្លួនពីស្ថានភាពគ្រោះថ្នាក់(ដូចជាការសេពគ្រឿងញៀន ឬល្បែង)<br>• សិស្សក៏នឹងរៀនពីរបៀបប្រមូល វិភាគ និងផ្សព្វផ្សាយព័ត៌មានក៏ដូចជាធ្វើផែនការសកម្មភាព អនុវត្តផែនការ និងឆ្លុះបញ្ចាំងពីលទ្ធផលនៃសកម្មភាព។ | **វាយតម្លៃតាមដំណាក់**<br>• ការពិភាក្សាក្រុម<br>• ការធ្វើបទបង្ហាញ<br>• ការងារបុគ្គល និងសំណុំឯកសារស្នាដៃសិស្ស<br>**វាយតម្លៃសរុប**<br>• តេស្តសំណេរប្រចាំខែ និងឆមាស<br>• កិច្ចការផ្ទះ<br>• បទបង្ហាញចុងក្រោយ និងរបាយការណ៍ក្រុមអំពីសកម្មភាពទូទៅ។ |
| **២. បំណិនសម្បទា ចរិយាសម្បទា និងគុណតម្លៃផ្ទាល់ខ្លួន**<br>- **បំណិនសម្បទា៖** បំណិនគោល១២+បំណិនផ្សេងទៀតដែលគ្រូអ្នកកំណត់<br>- **ចរិយាសម្បទា និងគុណតម្លៃផ្ទាល់ខ្លួន៖**<br>o ស្រឡាញ់ការសិក្សា<br>o ស្មោះត្រង់<br>o មានទំនួលខុសត្រូវ<br>o ឥរិយាបថវិជ្ជមាន។ | សិស្សអនុវត្តបំណិនទន់ គុណតម្លៃ និងចរិយាសម្បទា ក្នុងពេលដំណើរការបង្រៀន និងរៀនក្រោមការណែនាំរបស់គ្រូ។ ជាក់ស្ដែង គ្រូត្រូវរៀបចំផែនការបង្រៀនដោយជ្រើសរើសសកម្មភាព ដែលជំរុញការរៀនសូត្រសកម្ម និងការអភិវឌ្ឍបំណិនទន់ (ឧទាហរណ៍៖ ធ្វើការងារក្រុម ដើម្បីអភិវឌ្ឍកិច្ចសហប្រតិបត្តិការ ការចូលរួម ការយល់ចិត្ត ការចរចា ការគោរពអ្នកដទៃ) ហើយនឹងដើរតួជាគំរូសម្រាប់សិស្សរបស់ពួកគេដើម្បីលើកកម្ពស់វប្បធម៌នៃគុណតម្លៃ។ | **វាយតម្លៃតាមដំណាក់**<br>• សិស្សស្វ័យវាយតម្លៃ<br>• ការឆ្លុះបញ្ចាំង(ជាក្រុម ឬដៃគូ) ដោយប្រើតារាងវាយតម្លៃ<br>• ការសង្កេតរបស់គ្រូប្រចាំសប្ដាហ៍<br>**ការវាយតម្លៃសរុប**<br>• គ្រូពិនិត្យស្វ័យវាយតម្លៃរបស់សិស្ស។ |

ការវាយតម្លៃមានសារៈសំខាន់ណាស់ក្នុងការគូសបញ្ជាក់ថា គ្រូអាចសម្រេចចិត្តសម្របសម្រួលមាតិកានៃឧបករណ៍វាយតម្លៃលទ្ធផល ដោយផ្អែកលើតម្រូវការរបស់សិស្ស។ នេះបញ្ជាក់ថា សាលារៀនអាចកំណត់បំណិនគោលដៅជាក់លាក់ផ្សេងទៀត ឬបំណិនរងនៃបំណិនគោលទាំង១២ (ឧទាហរណ៍៖ ការស្ដាប់ ការនិយាយជាសាធារណៈ គឺជាប្រភេទបំណិនរងនៃបំណិនទំនាក់ទំនង)។

## ក.១-របៀបរៀបចំ និងការប្រើប្រាស់ទម្រង់វាយតម្លៃផ្លូវការ

ការធ្វើតេស្តលើវិជ្ជាសម្បទា (តេស្តសំណេរ ការវាយតម្លៃសរុប)៖ គឺជាការធ្វើតេស្តលើវិជ្ជាសម្បទាដូចជាមុខវិជ្ជាដទៃទៀត ដើម្បីទទួលបានពិន្ទុសម្រាប់កត់ត្រាចូលទៅក្នុងសៀវភៅបញ្ជីសម្រង់ពិន្ទុរបស់សិស្ស ជារៀងរាល់ខែ។ គ្រូអាចពិនិត្យមើលគំរូខាងក្រោម ដើម្បីកសាងសំណួរតេស្តសំណេរ ឱ្យសមស្របតាមកម្រិតថ្នាក់របស់ពួកគេ។ គ្រូត្រូវបញ្ចូលសំណួរជាច្រើនដែលនឹងត្រូវធ្វើតេស្តពាក់កម្រិតនៃចំណេះដឹង រួមទាំងសំណួរទាក់ទងនឹងការអភិវឌ្ឍបំណិនទន់។

• ចំណេះដឹងទទួលបាន៖ “តើអ្នកអាចប្រាប់ខ្ញុំអំពី...?”

• អនុវត្តចំណេះដឹងសម្រាប់ខ្លួនឯង៖ “តើអ្នកអាចការពារខ្លួនអ្នកពី......ដោយរបៀបណា?” “តើអ្នកនឹងប្រព្រឹត្តយ៉ាងណាប្រសិនបើ...?”

• ការអនុវត្តចំណេះដឹងជាមួយអ្នកដទៃ៖ “តើអ្នកត្រូវធ្វើយ៉ាងដូចម្តេចដើម្បីការពារអ្នកដទៃពី... ដោយរបៀបណា?” “ តើអ្នកអាចជួយអ្នកផ្សេងទៀតពី ... ដោយរបៀបណា?” “ តើអ្នកអាចជួយដល់អ្នកដទៃក្នុងស្ថានភាព... ដោយរបៀបណា?”

• បំណិនទន់៖“ តើអ្នកអាចប្រាប់ខ្ញុំបានទេហេតុអ្វីចាំបាច់ធ្វើការជាក្រុម?” “តើអ្នកអាចពន្យល់ពីគន្លឹះខ្លះៗដើម្បីទំនាក់ទំនងជាសាធារណៈបានឬទេ?” “តើដើមឈើបញ្ហាប្រើប្រាស់សម្រាប់ធ្វើអ្វី?”

**ឧទាហរណ៍នៃការវាយតម្លៃចំណេះដឹង**

គំរូតេស្តសំណេរនៅកម្រិតអនុវិទ្យាល័យ

### ១. ចំណេះដឹងដែលទទួលបាន

ក. តើមានមូលហេតុអ្វីខ្លះដែលបណ្តាលឱ្យកើតមានអំពើហិង្សាក្នុងគ្រួសារ?

ខ. តើការកើតមានអំពើហិង្សាក្នុងគ្រួសារមានផលប៉ះពាល់អ្វីខ្លះ?

គ. តើប្អូនគួរធ្វើយ៉ាងដូចម្តេច ដើម្បីការពារកុំឱ្យកើតមានអំពើហិង្សាក្នុងគ្រួសារ?

### ២. ការប្រើប្រាស់ចំណេះដឹងដែលទទួលបានសម្រាប់ខ្លួនឯង

ឃ. តើប្អូនត្រូវធ្វើដូចម្តេច ដើម្បីការពារខ្លួនអ្នកឱ្យជៀសផុតពីអំពើហិង្សាក្នុងគ្រួសារ?

### ៣. ការប្រើប្រាស់ចំណេះដឹងដែលទទួលបានសម្រាប់គ្រួសារ និងសហគមន៍

ង. តើប្អូនត្រូវធ្វើដូចម្តេចដើម្បីការពារគ្រួសារ និងសហគមន៍ប្អូនឱ្យជៀសផុតពីអំពើហិង្សាក្នុងគ្រួសារ?

ច. តើអ្នកគួរធ្វើអ្វី បើអ្នកសង្ស័យថា មានករណីអំពើហិង្សានៅក្នុងគ្រួសារមិត្តភក្តិរបស់អ្នក?

ឆ. ក្នុងសហគមន៍របស់អ្នក តើអ្នកត្រូវទាក់ទងអាជ្ញាធរណាខ្លះក្នុងករណីមានអំពើហិង្សាក្នុងគ្រួសារ?

## ក.២-ការវាយតម្លៃកិច្ចការប្រតិបត្តិ

(ឧបករណ៍សង្កេតរបស់គ្រូ រួមជាមួយឧបករណ៍ស្វ័យវាយតម្លៃរបស់សិស្ស)

**- ឧបករណ៍សង្កេតសម្រាប់គ្រូ**

ឧបករណ៍នេះអាចឱ្យគ្រូត្រួតពិនិត្យ និងដាក់ពិន្ទុការប្រតិបត្តិរបស់សិស្សក្នុងការអនុវត្តបំណិនសម្បទាចរិយាសម្បទានិងគុណតម្លៃផ្ទាល់ខ្លួន។ គ្រូសង្កេតសិស្សរាល់សប្តាហ៍ ដោយកំណត់ចំណាំ ហើយប្រាប់លទ្ធផលពិន្ទុក្រោយបញ្ចប់ឆមាស។

គ្រូសង្កេតមើលសិស្ស៥-៦នាក់ក្នុងមួយសប្តាហ៍ ហើយកត់ចំណាំពួកគេ។ នៅសប្តាហ៍បន្ទាប់ សង្កេតបន្ថែម៥-៦នាក់ផ្សេងទៀត ដើម្បីធានាឱ្យបានសង្កេតសិស្សទាំងអស់ យ៉ាងហោចណាស់៣ដងក្នុងមួយឆមាស។ ក្នុងករណីបន្ទប់រៀនមានសិស្សច្រើន គ្រូអាចផ្ទេរផ្នែកមួយនៃការសង្កេតសិស្សប្រចាំសប្តាហ៍ ដោយជំរុញឱ្យមានការវាយតម្លៃពីមិត្តភក្តិ។

ឯកសារណែនាំ ផ្តល់នូវឧបករណ៍វាយតម្លៃការប្រតិបត្តិស្តង់ដា ដោយផ្អែកលើបំណិនគោលទាំង១២ (ឧបសម្ព័ន្ធ ៧.១ សម្រាប់កម្រិតបឋមសិក្សា និង ៧.១.១ សម្រាប់អនុវិទ្យាល័យ)។ សាលារៀនអាចប្រើទម្រង់ ស្តង់ដា ឬអាចធ្វើខ្លឹមសារផ្ទាល់ខ្លួន ហើយធ្វើបច្ចុប្បន្នភាពខ្លឹមសារនៃឧបករណ៍ត្រួតពិនិត្យការប្រតិបត្តិផ្សេងទៀត។

នៅក្នុងឧបសម្ព័ន្ធ ៧.២ និង ៧.២.១ យើងបង្ហាញទម្រង់វាយតម្លៃការប្រតិបត្តិតាមស្តង់ដាដែលមានជួរឈរបន្ថែមសម្រាប់កំណត់សម្គាល់ ដើម្បីប្រើប្រាស់ក្នុងការសង្កេតប្រចាំសប្តាហ៍ (មួយសម្រាប់បឋមសិក្សា និងមួយសម្រាប់អនុវិទ្យាល័យ) ។ ចំណែកឧបសម្ព័ន្ធ ៧.២.២ បង្ហាញបញ្ជីសំណួរ ដើម្បីណែនាំគ្រូនៅក្នុងដំណើរការសង្កេត។ ចុងបញ្ចប់ឧបសម្ព័ន្ធ ៧.៣ "កំណត់សម្គាល់ការសង្កេតរបស់គ្រូ" ផ្តល់ឧទាហរណ៍នៃកំណត់សម្គាល់ដែលគ្រូអាចកត់ត្រាក្នុងអំឡុងពេលសង្កេតប្រចាំសប្តាហ៍។

មុនពេលបញ្ចប់ការដាក់ពិន្ទុនៅចុងឆមាស គ្រូត្រូវឆ្លងកាត់ការពិនិត្យពិន្ទុរបស់ខ្លួនជាមួយពិន្ទុស្វ័យវាយតម្លៃរបស់សិស្ស (ឧបសម្ព័ន្ធ ៧.៤ សម្រាប់អនុវិទ្យាល័យ និង៧.៤.១សម្រាប់បឋមសិក្សា) ។

- **ស្វ័យវង្វាយតម្លៃសិស្សអនុវិទ្យាល័យ** (ឧបសម្ព័ន្ធ ៧.៤)៖

ស្វ័យវង្វាយតម្លៃរបស់សិស្សពាក់ព័ន្ធនឹងសិស្សក្នុងការវាយតម្លៃការសិក្សាដោយខ្លួនឯង ឆ្លុះបញ្ចាំងពីអាកប្បកិរិយារបស់ពួកគេ និងតាមដានការរីកចម្រើនខ្លួនឯង។ វាគឺជាសកម្មភាពរៀនដ៏សំខាន់មួយដែលជួយសិស្សក្នុងការកែលម្អការយល់ដឹងរបស់ពួកគេអំពីខ្លួនឯងលើចំណុចល្អ និងចំណុចខ្វះខាតដែលពួកគេត្រូវកែលម្អ។

**ស្វ័យវង្វាយតម្លៃសម្រាប់សិស្សអនុវិទ្យាល័យត្រូវអនុវត្តតាមជំហានដែលបានពិពណ៌នាដូចខាងក្រោម៖**

- សិស្សទទួលបានទម្រង់ស្វ័យវង្វាយតម្លៃនៅពេលចាប់ផ្តើមការបង្រៀនប្រធានបទនីមួយៗ។
- គ្រូពន្យល់ឱ្យច្បាស់អំពីខ្លឹមសារនៃឧបករណ៍ ស្វ័យវង្វាយតម្លៃ និងមូលហេតុដែលពួកគេត្រូវរៀនវាយតម្លៃខ្លួនឯង (គ្រូត្រូវពន្យល់ថា ពួកគេត្រូវមើលសមត្ថភាពរបស់ពួកគេក្នុងការអនុវត្តបំណិនទន់ដែលពួកគេរៀននៅក្នុងថ្នាក់ដោយមានការគាំទ្រពីគ្រូ)។
- សិស្សត្រូវបំពេញក្នុងទម្រង់ និងបញ្ជាក់ពីចម្ងល់។
- សិស្សតាមដានការប្រព្រឹត្តរបស់ពួកគេជារៀងរាល់សប្តាហ៍ ដោយកត់ចំណាំ ហើយបន្ទាប់មកធ្វើការឆ្លុះបញ្ចាំងជាទៀងទាត់ បន្ទាប់ពីរៀនមេរៀននីមួយៗរហូតដល់ចុងបញ្ចប់នៃឆមាសនីមួយៗ។
- នៅចុងបញ្ចប់នៃឆមាស ពួកគេផ្តល់ទម្រង់ដែលបានបំពេញទៅគ្រូ ហើយគ្រូនឹងប្រៀបធៀបពិន្ទុសិស្សជាមួយពិន្ទុរបស់គាត់ និងដាក់ពិន្ទុបញ្ចប់។
- ប្រសិនបើពិន្ទុរវាងគ្រូនិងសិស្សមានភាពខុសគ្នាខ្លាំង គ្រូត្រូវរៀបចំការណាត់ជួបពិភាក្សាជាមួយសិស្សជាលក្ខណៈឯកជន

- ០ ក្នុងពេលពិភាក្សា គ្រូនិយាយអំពីមូលហេតុដែលមានពិន្ទុខុសគ្នា ហើយឱ្យសិស្សបង្ហាញសកម្មភាព ឬព្រឹត្តិការណ៍ជាក់លាក់ណាមួយដែលខ្លួនបានចូលរួម និងអភិវឌ្ឍបំណិនដែលបានលើកឡើង។ គ្រូអាចសង្កេតសិស្សនៅក្នុងឱកាសផ្សេងទៀត ហើយបានមើលឃើញថាសិស្សបានអភិវឌ្ឍបំណិននោះ។ ផ្អែកលើការពិភាក្សានេះ សិស្ស និងគ្រូនឹងទទួលបានពិន្ទុដែលបានព្រមព្រៀងគ្នា។ ការពិភាក្សាជាមួយសិស្សម្នាក់ៗមានរយៈពេលពី ១០ ទៅ ១៥ នាទី។

## ក.៣-របៀបដាក់ពិន្ទុ

### - ពិន្ទុវិជ្ជាសម្បទាប្រចាំខែ

គ្រូបង្រៀនត្រូវវាយតម្លៃវិជ្ជាសម្បទារបស់សិស្សរៀងរាល់ខែ ហើយកត់ត្រាពិន្ទុនៅក្នុងសៀវភៅសម្រង់ពិន្ទុរបស់សិស្ស និងតារាងវាយតម្លៃរួម (ឧបសម្ព័ន្ធ៧.៥)។ គ្រូត្រូវពន្យល់លម្អិត អំពីការធ្វើតេស្តវិជ្ជាសម្បទាដោយពួកគេផ្ទាល់ដូចមុខវិជ្ជាផ្សេងទៀតដែរ។

| ទម្រង់តេស្តវិជ្ជាសម្បទាប្រចាំខែ | |
|---|---|
| ១-ចំណេះដឹងទូទៅដែលសន្មតថាទទួលបាន | (០៦ពិន្ទុ) |
| ក-តើមូលហេតុអ្វីដែលបណ្តាលឱ្យមានអំពើហិង្សាក្នុងគ្រួសារ? (០២) | |
| ខ-តើអ្វីជាផលវិបាកនៃអំពើហិង្សាក្នុងគ្រួសារ? (០២) | |
| គ-តើអ្នកគួរធ្វើអ្វីដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ? (០២) | |
| ២-ប្រើចំណេះដឹងដែលទទួលបានសម្រាប់ខ្លួនឯង។ | (០៧ពិន្ទុ) |
| តើអ្នកគួរធ្វើយ៉ាងណាដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ? | |
| ៣-ប្រើចំណេះដឹងដែលទទួលបានសម្រាប់គ្រួសារ និងសហគមន៍របស់ពួកគេ | (០៧ពិន្ទុ) |
| តើអ្នកគួរធ្វើអ្វីដើម្បីកុំឱ្យអំពើហិង្សាកើតមាននៅក្នុងគ្រួសារ និងសហគមន៍របស់អ្នក? | |
| ពិន្ទុសរុប ៖ ២០ | |
| នៅបឋមសិក្សា ពិន្ទុអតិបរមា ១០ និងនៅមធ្យមសិក្សាបឋមភូមិ ពិន្ទុអតិបរមា ៥០ | |

### - ពិន្ទុប្រចាំឆមាស៖ ពិន្ទុវិជ្ជាសម្បទា និងការប្រតិបត្តិ

ពិន្ទុឆមាសគឺជាការរួមបញ្ចូលគ្នានៃការវាយតម្លៃវិជ្ជាសម្បទា និងការប្រតិបត្តិ (ឧបករណ៍សង្កេតរបស់គ្រូ និងស្វ័យវាយតម្លៃរបស់សិស្ស)។ នៅបឋមសិក្សា និងមធ្យមសិក្សាដំណើរការដាក់ពិន្ទុដូចគ្នា មានតែការដាក់ពិន្ទុសរុបទេដែលខុសគ្នា (សម្រាប់បឋមសិក្សាពិន្ទុអតិបរមា ១០ សម្រាប់អនុវិទ្យាល័យអតិបរមា ៥០)។ សូមមើលដំណើរការដាក់ពិន្ទុលម្អិតដែលពន្យល់ក្នុងតារាងខាងក្រោម៖

| របៀបគណនាពិន្ទុឆមាសសម្រាប់សិស្សបឋម | | |
|---|---|---|
| ១ | ជាដំបូងគ្រូគណនាមធ្យមភាគនៃតេស្តវិជ្ជាសម្បទាប្រចាំខែ (A) (ពិន្ទុប្រឡងប្រចាំខែនីមួយៗ ≤ 10) | A = សរុបពិន្ទុប្រចាំខែ / ចំនួនខែ ≤ 10/10 |
| ២ | ក្រោយបញ្ចប់ឆមាស ឬបញ្ចប់ប្រធានបទមួយ សិស្សត្រូវប្រឡងឆមាស (តេស្តវិជ្ជាសម្បទា) (B) | B = ពិន្ទុប្រឡងឆមាស ≤ 10/10 (តេស្តសរសេរ) |
| ៣ | មធ្យមភាគតេស្តវិជ្ជាសម្បទាប្រចាំឆមាស (A+B)/2=(C) (ពិន្ទុនៃតេស្តសរសេរនេះបានតែ 40% នៃពិន្ទុប្រចាំឆមាស) | C = [(A+B)/2] X40/100 ≤ 4 (ពិន្ទុលើសពី 4 គឺខុស) |
| ៤ | គ្រូដាក់ពិន្ទុលើចរិយាសម្បទា និងការប្រតិបត្តិរបស់សិស្ស (D) (ពិន្ទុនៃតេស្តនេះបាន 60% នៃពិន្ទុប្រចាំឆមាស) | D ≤ 6 |
| ៥ | មធ្យមភាគប្រចាំឆមាស (E) គឺបូកសរុបរវាងមធ្យមភាគតេស្តវិជ្ជាសម្បទាប្រចាំឆមាស (C) (ពិន្ទុ40%) ≤ 4 និងពិន្ទុគ្រូឱ្យលើចរិយាសម្បទា និងការប្រតិបត្តិរបស់សិស្ស (D) (ពិន្ទុ 60%) ≤6 | D ≤ 6<br>E = C + D ≤ 4 + 6 |

| របៀបគណនាពិន្ទុឆមាសសម្រាប់សិស្សអនុវិទ្យាល័យ | | |
|---|---|---|
| ១ | ជាដំបូងគ្រូគណនាមធ្យមភាគនៃតេស្តវិជ្ជាសម្បទាប្រចាំខែ (A)(ពិន្ទុប្រឡងប្រចាំខែនីមួយៗ ≤ 50) | A = សរុបពិន្ទុប្រចាំខែ/ចំនួនខែ ≤ 50 |
| ២ | ក្រោយបញ្ចប់ឆមាស ឬបញ្ចប់ប្រធានបទមួយ សិស្សត្រូវប្រឡងឆមាស(តេស្តវិជ្ជាសម្បទា) (B) | B = ពិន្ទុប្រឡងឆមាស ≤ 50/50 (តេស្តសរសេរ) |
| ៣ | មធ្យមភាគតេស្តវិជ្ជាសម្បទាប្រចាំឆមាស(A+B)/2=(C) (ពិន្ទុនៃតេស្តសរសេរនេះបានតែ 40% នៃពិន្ទុប្រចាំឆមាស) | C = [(A+B)/2] X40/100 ≤ 20 (ពិន្ទុលើសពី 20 គឺខុស) |
| ៤ | គ្រូដាក់ពិន្ទុលើចរិយាសម្បទា និងការប្រតិបត្តិរបស់សិស្ស(D) (ពិន្ទុនៃតេស្តនេះបាន 60% នៃពិន្ទុប្រចាំឆមាស) | D ≤ 30 |
| ៥ | មធ្យមភាគប្រចាំឆមាស(E) គឺបូកសរុបរវាងមធ្យមភាគតេស្តវិជ្ជាសម្បទាប្រចាំឆមាស(C) (ពិន្ទុ40%) ≤ 20 និងពិន្ទុគ្រូឱ្យលើចរិយាសម្បទា និងការប្រតិបត្តិរបស់សិស្ស(D) (ពិន្ទុ 60%) ≤ 30 | E = C + D ≤ 20 + 30 |

ការដាក់ពិន្ទុប្រចាំខែ និងឆមាសត្រូវបញ្ចូលក្នុងតារាងពិន្ទុរួមក្នុងឧបសម្ព័ន្ធ ៧.៥ ។ ឧបសម្ព័ន្ធរួមមានឧទាហរណ៍នៃការគណនាពិន្ទុ។

## ខ-វង្វាយតម្លៃក្រៅផ្លូវការ

ការវាយតម្លៃក្រៅផ្លូវការត្រូវបានប្រើដើម្បីវាយតម្លៃការប្រតិបត្តិរបស់សិស្ស និងការយល់ដឹងរបស់ពួកគេដោយមិនប្រើការធ្វើតេស្តដាក់ពិន្ទុទេប៉ុន្តែប្រើលក្ខណវិនិច្ឆ័យដែលបានកំណត់។ សម្រាប់បំណិនជីវិតតាមមូលដ្ឋាន លក្ខណវិនិច្ឆ័យត្រូវបានកំណត់ដោយតេស្តប្រតិបត្តិ។

វិធីសាស្ត្រនៃការវាយតម្លៃក្រៅផ្លូវការគឺការសន្ទនា ការពិភាក្សាជាក្រុម ការសង្កេតប្រចាំថ្ងៃ ស្វ័យវង្វាយតម្លៃ ការវាយតម្លៃដោយមិត្តភក្តិក្នុងក្រុម ក៏ដូចជាផលប័ត្រ(សំណុំឯកសារស្នាដៃសិស្ស)។ ការវាយតម្លៃគួរតែផ្តោតលើការឆ្លុះបញ្ចាំងអំពី៖ ស្ថានភាព ការប្រព្រឹត្ត ផលប៉ះពាល់ និងសកម្មភាព។

**ក.ស្ថានភាព** ៖ ឱ្យសិស្សពិពណ៌នាអំពីស្ថានភាពជាក់លាក់មួយដែលគេគិតថាពួកគេបានអភិវឌ្ឍបំណិន។

**ខ.ការប្រព្រឹត្ត** ៖ សួរសិស្សថាតើគេមានការប្រព្រឹត្តបែបណា និងរបៀបដែលគេបានអភិវឌ្ឍបំណិនទាំងនោះ។

**គ.ផលប៉ះពាល់** ៖ សួរសិស្សថាលទ្ធផលគឺជាអ្វី? គឺជាពិន្ទុដែលបានកត់ត្រា។

**ឃ.សកម្មភាព** ៖ សួរសិស្សថា តើការកែលម្អអ្វីខ្លះអាចត្រូវបានបង្កើតឡើងនៅក្នុងអនាគត?

## ខ.១-ស្វ័យរង្វាយតម្លៃរបស់សិស្សបឋម

(សូមមើលឧបសម្ព័ន្ធ ៧.៤.១ ស្វ័យរង្វាយតម្លៃនៅបឋមសិក្សា)

ស្វ័យរង្វាយតម្លៃនៅបឋមសិក្សាគឺជាការអនុវត្តដ៏ល្អមួយ ដើម្បីលើកកម្ពស់ការឆ្លុះបញ្ចាំងខ្លួនឯង និងផ្តល់ព័ត៌មានដល់ដំណើរការបង្រៀន។

**លំណៃនាំ៖**

- នៅដើមឆ្នាំសិក្សា គ្រូរៀបចំផ្ទាំងកាតុងមួយ(ផូស្ទ័រ Poster) ដែលមានសំណួរគន្លឹះសម្រាប់សិស្សឆ្លុះបញ្ចាំងជារៀងរាល់សប្តាហ៍។
- ពន្យល់សិស្សនូវប្រយោគនីមួយៗ និងមូលហេតុដែលស្វ័យឆ្លុះបញ្ចាំងមានសារៈសំខាន់ក្នុងការកែលម្អ។
- ចែកទម្រង់ដែលជាច្បាប់ចម្លងដល់សិស្សទាំងអស់(ជាជម្រើសបង្កើតផ្ទាំងកាតុង និងយោងលើខ្លឹមសាររបស់វាគ្រប់ពេលដែលមានបញ្ហា ឬសិស្សប្រព្រឹត្តិមិនត្រឹមត្រូវ)។
- សិស្សស្តាប់ដោយយកចិត្តទុកដាក់នូវការពន្យល់របស់គ្រូសម្រាប់ចំណុចនីមួយៗ ហើយពួកគេត្រូវសរសេរបំពេញក្រដាស។ ឱ្យពួកគេធ្វើការជាដៃគូ ឬក្រុមតូចៗជួយគ្នា ដើម្បីដាក់ពិន្ទុ។ ជាជម្រើសគ្រូត្រូវអាន និងស្នើឱ្យសិស្សពិភាក្សាជាគូដោយផ្ទាល់មាត់។ គ្រូជំរុញការឆ្លុះបញ្ចាំង ដោយសួរសិស្សឱ្យគិតថាតើអ្នកស្តាប់បានច្បាស់ល្អទេ? តើអ្នកស្តាប់បានច្បាស់ល្អត្រូវមានលក្ខណៈអ្វីខ្លះ? តើអ្នកប្រាកដទេថាអ្នកបានធ្វើការទាំងអស់ទាន់ពេល? ។ល។
- នៅពេលបញ្ចប់ការសិក្សា សិស្សត្រូវរក្សាស្វ័យរង្វាយតម្លៃនៅក្នុងថ្នាក់រៀន រក្សាទុកជាមួយគ្រូ ឬនៅក្នុងប្រអប់ពិសេសមួយដែលត្រូវបានបង្កើតឡើងដើម្បីរក្សាទុក។
- រាល់សប្តាហ៍ពួកគេត្រូវយកក្រដាស(ឬផ្ទាំងកាតុង)ត្រឡប់មកវិញ និងធ្វើលំហាត់ដូចមុនម្តងទៀត។
- ប្រមូលទម្រង់នៅចុងឆមាស ឬលទ្ធផលនៃការឆ្លុះបញ្ចាំងចុងក្រោយ (ក្នុងករណីគ្រូប្រើតែផ្ទាំងកាតុងដើម្បីប្រមូលចម្លើយក្រុមទាំងអស់ ដោយរាប់ចម្លើយសម្រាប់សំណួរនីមួយៗ) នៅចុងបញ្ចប់នៃប្រធានបទជាមួយសិស្ស។

## ខ.២-.សំណួរ និងការសន្ទនា

ការសួរសំណួរគឺជាផ្នែកមួយមានសារៈសំខាន់នៃដំណើរការវាយតម្លៃ ពីព្រោះវាជួយបង្កើតនូវអ្វីដែលសិស្សបានដឹងរួចហើយ ឬបានយល់។ ដំណើរការនេះអាចត្រូវបានធ្វើជាមួយសិស្សក្នុងថ្នាក់ទាំងអស់ ឬជាលក្ខណៈបុគ្គល។ ឧទាហរណ៍ខ្លះត្រូវបានបង្ហាញនៅក្នុងតារាងខាងក្រោម៖

| បំណិនទន់ | ស្វ័យឆ្លុះបញ្ចាំងរបស់សិស្ស និង វាយតម្លៃក្រៅផ្លូវការ |
|---|---|
| **បំណិនប្រាស្រ័យទាក់ទង** | • តើខ្ញុំពិតជាយល់ពីអ្វីដែលមិត្តភក្តិខ្ញុំនិយាយទេ ?<br>• តើខ្ញុំសង្ខេប ឬបកស្រាយឡើងវិញនូវអ្វីដែលមិត្តរបស់ខ្ញុំបាននិយាយ ដើម្បីពិនិត្យមើលការយល់ដឹងបានឬទេ ?<br>• តើខ្ញុំបង្ហាញគំនិតរបស់ខ្ញុំបានច្បាស់ និងសាមញ្ញឬទេ ?<br>• តើអ្វីដែលធ្វើឱ្យបទបង្ហាញរបស់ខ្ញុំបានល្អ ?<br>• តើមានអ្វីដែលខ្ញុំអាចកែលម្អនៅលើកក្រោយបានទេ ?<br>• តើខ្ញុំពិបាកធ្វើវាទេ ? ហេតុអ្វី ? |
| **ការងារក្រុម :**<br>**បំណិនសហប្រតិបត្តិការ** | • តើខ្ញុំស្តាប់ដោយយកចិត្តទុកដាក់ចំពោះសមាជិកក្រុមទេ ?<br>• តើខ្ញុំចូលរួមផ្តល់ភាពជោគជ័យដល់ក្រុមដែរឬទេ ?<br>• តើខ្ញុំអនុញ្ញាតឱ្យសមាជិកក្រុមផ្សេងទៀតបញ្ចេញគំនិតរបស់ពួកគេទេ ?<br>• តើខ្ញុំពេញចិត្តចំពោះគំនិតរបស់សមាជិកក្រុម ឬមិនយល់ស្របដែរ ឬទេ ?<br>• តើខ្ញុំអាចលើកឡើងពីចំណុចល្អមួយនៃការធ្វើការជាមួយមិត្តភក្តិនៅក្នុង កិច្ចការនេះបានទេ ?<br>• តើខ្ញុំនឹងធ្វើអ្វីផ្សេងពីនេះនៅលើកក្រោយ ?<br>• តើខ្ញុំចូលចិត្តអ្វីក្នុងការធ្វើការជាក្រុម ? |
| **ការវិភាគ : ការដោះស្រាយបញ្ហា** | • តើខ្ញុំពិតជាយល់ពីអ្វីដែលជាបញ្ហា ?<br>• តើខ្ញុំមានទិន្នន័យ ឬភស្តុតាងគ្រប់គ្រាន់ទេ ?<br>• តើមានដំណោះស្រាយអ្វីខ្លះដែលអាចដោះស្រាយបាន ?<br>• តើដំណោះស្រាយណាមួយអាចអនុវត្តបាន ?<br>• តើខ្ញុំបានធ្វើអ្វីខ្លះដើម្បីដោះស្រាយបញ្ហា ?<br>• តើសំណួរអ្វីខ្លះដែលខ្ញុំបានសួរខ្លួនឯង ?<br>• ហេតុអ្វីបានជាខ្ញុំគិតថានេះជាដំណោះស្រាយល្អបំផុត ? |

## ខ.៣-វាយតម្លៃដោយមិត្តភក្តិ

វាយតម្លៃដោយមិត្តភក្តិពាក់ព័ន្ធនឹងសិស្សមើលការងាររបស់គ្នាទៅវិញទៅមក ហើយការវាយតម្លៃវាផ្អែកនឹងលក្ខណវិនិច្ឆ័យដែលបានព្រមព្រៀងជាមុនដែលសិស្សអាចជួយអភិវឌ្ឍ។ សិស្សរៀនកំណត់ចំណុចខ្លាំង និងចំណុចដែលត្រូវកែលម្អ ព្រមទាំងផ្តល់យោបល់ទៅលើការងាររបស់មិត្តភក្តិ ប្រកបដោយលក្ខណៈវិជ្ជមាន។ ការវាយតម្លៃនេះអាចជាពាក្យសម្តី ឬសរសេរ។ ត្រូវប្រាកដថាសិស្សមុនពេលសិក្សាអំពីលក្ខណវិនិច្ឆ័យ និងរបៀបប្រើភាសាដែលមានលក្ខណៈស្ថាបនា (“អ្នកខំប្រឹងណាស់។ ខ្ញុំអាចមើលឃើញពី...” “ខ្ញុំចូលចិត្តផ្នែកនេះពី ព្រោះ...។” “ស្អាតណាស់...” “ប្រហែលជាលើកក្រោយអ្នកអាចធ្វើបាន ...”) ហើយធានាថា ថ្នាក់រៀនផ្តល់នូវបរិយាកាសផាសុកភាពសម្រាប់ការចែករំលែក និងរៀនពីគ្នា ឬអ្នកផ្សេងទៀតដោយការគោរព។ ដូចដែលបានរៀបរាប់ខាងលើ គ្រូអាចប្រើវាយតម្លៃដោយមិត្តភក្តិសម្រាប់ការវាយតម្លៃការប្រតិបត្តិ។

## ខ.៤-ការវាយតម្លៃការងារជាក្រុម

មានវិធីសាស្ត្រជាច្រើនដើម្បីជួយសិស្សឆ្លុះបញ្ចាំងពីរបៀបដែលពួកគេធ្វើការក្នុងក្រុម(ឧបសម្ព័ន្ធ៧.៦)

| ឧបករណ៍វាយតម្លៃ (ក្រៅផ្លូវការ) | គំរូនៃការគ្រប់គ្រង | តើវាសម្រាប់ធ្វើអ្វី? |
|---|---|---|
| ការវាយតម្លៃចរិយាសម្បទារបស់ក្រុម | ជាលក្ខណៈបុគ្គល | សិស្សឆ្លុះបញ្ចាំងពីអាកប្បកិរិយារបស់ពួកគេដែលធ្វើការនៅក្នុងក្រុម |
| ការវាយតម្លៃនៃការចូលរួមវិភាគទានក្នុងក្រុម"តើក្រុមរបស់ខ្ញុំគិតយ៉ាងណា" | ជាលក្ខណៈបុគ្គល | សិស្សឆ្លុះបញ្ចាំងពីការងាររបស់ក្រុម និងវិធីដែលអាចត្រូវបានកែលម្អ |
| ការវាយតម្លៃនៃចំណង់ចំណូលចិត្ត | ក្រុមតូច ឬក្រុមធំដោយគ្រូជាអ្នកសម្របសម្រួល | សរុបគំនិតសម្រាប់ការកែលម្អការងារជាក្រុម |
| ការត្រួតពិនិត្យក្រុម | ក្រុម | ក្រុមឆ្លុះបញ្ចាំងពីរបៀបដែលសមាជិកធ្វើការជាមួយគ្នា។ |

## ខ.៥-របៀបប្រើទម្រង់វាយតម្លៃក្រៅផ្លូវការ

គ្រូបង្រៀនត្រូវបានលើកទឹកចិត្ត ឱ្យបញ្ចូលរង្វាយតម្លៃក្រៅផ្លូវការ នៅក្នុងការអនុវត្តការបង្រៀនធម្មតារបស់ពួកគេ និងធ្វើឱ្យវាមានភាពរីករាយដល់សិស្សក្នុងថ្នាក់ និងបុគ្គល។ រង្វាយតម្លៃក្រៅផ្លូវការជួយសិស្សក្នុងការបង្កើនការយល់ដឹងអំពីអាកប្បកិរិយារបស់ពួកគេ និងអនុវត្តយន្តការដើម្បីកែលម្អការប្រតិបត្តិរបស់ពួកគេ ដោយអនុវត្តការឆ្លុះបញ្ចាំងជាបន្តបន្ទាប់ក្រោមការណែនាំរបស់គ្រូ។ ការឆ្លុះបញ្ចាំងត្រូវបានលើកទឹកចិត្តតាមរយៈការពិភាក្សាជាក្រុម ឬដៃគូ ឬស្វ័យឆ្លុះបញ្ចាំង និងអាចត្រូវបានធ្វើដោយផ្ទាល់មាត់ក៏ដូចជាការសរសេរ។ ជាក់ស្តែង៖

- លក្ខណវិនិច្ឆ័យនៃការវាយតម្លៃគួរតែបង្ហាញនៅដើមឆ្នាំសិក្សា ធ្វើដូចនេះសិស្សនឹងដឹងច្បាស់អំពីអ្វីដែលត្រូវត្រួតពិនិត្យចាប់តាំងពីចាប់ផ្តើមសិក្សា។
- គ្រូត្រូវរៀបចំស្វ័យរង្វាយតម្លៃរបស់សិស្សនៅពេលចាប់ផ្តើមឆមាសនីមួយៗ(ទាំងបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ)។
- លើសពីនេះទៀត គ្រូអាចបញ្ចូលឧបករណ៍បន្ថែមណាមួយដែលបានស្នើឡើងនៅក្នុងរង្វាយតម្លៃក្រៅផ្លូវការ ដើម្បីគាំទ្រដល់ការឆ្លុះបញ្ចាំងក្នុងពេលបង្រៀន ជាពិសេសនៅចុងបញ្ចប់នៃប្រធានបទនីមួយៗ ក្នុងអំឡុងពេលវាយតម្លៃចុងក្រោយ ឬនៅចុងបញ្ចប់នៃសកម្មភាពជាក់លាក់(សូមមើលឧបសម្ព័ន្ធ៧.៦)។ គ្រូអាចប្រើទម្រង់ទាំងនេះដើម្បីគាំទ្រស្វ័យឆ្លុះបញ្ចាំងក្នុងដំណើរការរៀន(លើការអនុវត្តបំណិនទន់)។
- គ្រូត្រូវប្រមូល និងអានគ្រប់ទម្រង់ដែលផ្តល់ឱ្យសិស្សដើម្បីឱ្យសិស្សយល់ពីការអនុវត្តបំណិនទន់ និងសម្រាប់កែតម្រូវការបង្រៀននៅពេលចាំបាច់។

## ស្វ័យឆ្លុះបញ្ចាំងជំពូកទី៧

ត្រួតពិនិត្យការយល់ដឹងរបស់អ្នក៖

| | | |
|---|---|---|
| ១ | តើអ្នកវាយតម្លៃវិជ្ជាសម្បទារាល់ខែឬទេ ? | □ បាទ/ចា៎ □ ទេ |
| ២ | តើស្វ័យរង្វាយតម្លៃមានសារៈសំខាន់សម្រាប់ការសិក្សារបស់សិស្សដែរឬទេ ? ( សូមគូសគ្រប់ចំណុចដែលត្រឹមត្រូវ ) ។ | □ ក. ស្វ័យរង្វាយតម្លៃគឺសំខាន់ណាស់ព្រោះសិស្សអាចកំណត់បានពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួន<br>□ ខ. ស្វ័យរង្វាយតម្លៃជួយសិស្សឆ្លុះបញ្ចាំងពីអាកប្បកិរិយារបស់ពួកគេ<br>□ គ. ស្វ័យរង្វាយតម្លៃជួយសិស្សកំណត់គោលដៅជាក់ស្តែងដែលគេអាចព្យាយាមសម្រេចបានក្នុងឆ្នាំនិងអាចតាមដានវឌ្ឍនភាពរបស់ពួកគេផ្ទាល់<br>□ ឃ.ចំណុចខាងលើមិនត្រឹមត្រូវ |
| ៣ | តើអ្នកវាយតម្លៃការប្រតិបត្តិដើម្បីសង្កេតមើលបំណិនទន់ គុណតម្លៃ និងចរិយាសម្បទារបស់សិស្សយ៉ាងដូចម្តេច ? | □ រៀងរាល់សប្តាហ៍<br>□ ម្តងក្នុងមួយខែ<br>□ ម្តងក្នុងមួយឆមាស |
| ៤ | តើរង្វាយតម្លៃក្រៅផ្លូវការមានប្រយោជន៍ដើម្បីជំរុញស្វ័យឆ្លុះបញ្ចាំងដែរឬទេ ? | □ បាទ/ចា៎ □ ទេ |
| ៥ | តើអ្នកអាចលើកពីបច្ចេកទេសវាយតម្លៃក្រៅផ្លូវការយ៉ាងហោចណាស់២បានដែរឬទេ ? | ១...................................................................<br>២................................................................... |

ចម្លើយៈ១.បាទ/ចា៎ ២. ត្រឹមត្រូវ៖ ក, ខ និងគ ៣.រៀងរាល់សប្ដាហ៍ ៤. បាទ/ចា៎ ៥. 1.ស្វ័យរង្វាយតម្លៃ 2.រង្វាយតម្លៃពីមិត្ត ភក្តិ 3.រង្វាយតម្លៃពីក្រុមការងារ 4.ការត្រួតពិនិត្យក្រុម 5.រង្វាយតម្លៃចំណង់ចំណូលចិត្ត។

# ឧបសម្ព័ន្ធជំពូក៤

## ៤.១. បញ្ហាព័ត៌មានក្លែងបន្លំ

- **ចងក្រងប្រភពព័ត៌មាន៖**ពិនិត្យមើលព័ត៌មានប្រហាក់ប្រហែលគ្នាដូចជានៅតាមអ៊ីនធើណែត កាសែត បណ្ណាល័យ។
- **បង្កើតព័ត៌មានផ្សេងៗទាក់ទងនឹងប្រធានបទ៖** ពង្រីកចំណេះដឹងរបស់អ្នកតាមរយៈប្រភពផ្សេងៗ។ ប្រៀបធៀបព័ត៌មានបានកាន់តែច្រើន អ្នកនឹងយល់បានកាន់តែច្បាស់ថា អ្វីពិត និងអ្វីមិនពិត។
- **បញ្ជាក់ព័ត៌មានឱ្យច្បាស់ជាមួយអ្នកជំនាញនៅសាលា ឬនៅសហគមន៍៖**( គ្រូ គណៈគ្រប់គ្រងសាលា អាជ្ញាធរមូលដ្ឋាន អ្នកជំនាញក្នុងតំបន់ អ្នកមានជំនាញលើផ្នែកដែលសិស្សកំពុងសិក្សាស្រាវជ្រាវ។

ឧ.ការធ្វើចំណាកស្រុក )។

- **អានអត្ថបទទាំងមូល៖** កុំអានតែចំណងជើង( ចំណងជើងអាចមានការបំផ្លើសដើម្បីឱ្យអ្នកអានចាប់អារម្មណ៍ )។
- **ពិនិត្យកាលបរិច្ឆេទ៖** ការផ្សព្វផ្សាយឡើងវិញនូវព័ត៌មានចាស់ៗ មិនប្រាកដថាវានៅតែមានភាពត្រឹមត្រូវនាពេលបច្ចុប្បន្នទេ។
- **ត្រូវសួរខ្លួនឯងជានិច្ចថា “តើអ្វីដែលអ្នកបានអាន អាចទុកចិត្តបានឬទេ ?”៖** កុំជឿជាក់លើអ្វីៗទាំងអស់ដែលអ្នកបានអានលើអ៊ីនធើណែត។ វេបសាយខ្លះផ្តល់នូវព័ត៌មានមិនពិត។ បញ្ជាក់ឡើងវិញដោយការពិនិត្យមើលគេហទំព័រដទៃទៀតមុននឹងជឿជាក់លើអ្វីមួយ។

ឧទាហរណ៍( មានរូបភាព ) សិស្សបឋមគ្រូអាចបង្ហាញរូបភាពនៃវត្ថុដែលអាចឃើញក្នុងជីវភាពប្រចាំថ្ងៃ និងឱ្យសិស្សគិតពីអ្វីដែលគ្រូបាននិយាយដោយប្រើប្រាស់ឧទាហរណ៍ដូចខាងក្រោម៖

យកប៊ិកមួយ ហើយសួរសំណួរ៣ដូចក្នុងតារាងខាងក្រោម ហើយឱ្យសិស្សគិតថា វាគឺជាការពិត ឬជាគំនិតផ្ទាល់ខ្លួន ?

| តើវាគឺជាការពិត ឬជាគំនិតផ្ទាល់ខ្លួន ? | | ចម្លើយ |
|---|---|---|
|  | ប៊ិកនេះថ្មីប៊ិចនេះពណ៌ខៀវ<br>នេះគឺជាប៊ិកល្អជាងគេនៅកម្ពុជា | គំនិតផ្ទាល់ខ្លួន ការពិត<br>គំនិតផ្ទាល់ខ្លួន |
|  | គោមានជើង៤គោគឺជាសត្វស្អាតជាងគេលើ<br>លោកគោគឺជាសត្វ | ការពិត គំនិតផ្ទាល់ខ្លួន<br>ការពិត |

**ឧទាហរណ៍(មានរូបភាព) សិស្សអនុវិទ្យាល័យ**

| តើវាគឺជាការពិត ឬគំនិតផ្ទាល់ខ្លួន? | | ចម្លើយ |
|---|---|---|
|  | បុរសម្នាក់កំពុងធ្វើការលើវាលស្រែ<br>គាត់មើលទៅដូចជាហត់នឿយ<br>គាត់មើលទៅដូចជារីករាយ<br>ខ្ញុំគិតថាគាត់មានវ័យចំណាស់ | ការពិត<br>គំនិតផ្ទាល់ខ្លួន<br>គំនិតផ្ទាល់ខ្លួន<br>គំនិតផ្ទាល់ខ្លួន |
|  | ស្ត្រីម្នាក់ពាក់មួក<br>ខ្ញុំគិតថាស្ត្រីម្នាក់នោះដូចជាហត់នឿយ<br>ខ្ញុំជឿជាក់ថាស្ត្រីម្នាក់នោះមានវ័យក្មេង | ការពិត<br>គំនិតផ្ទាល់ខ្លួន<br>គំនិតផ្ទាល់ខ្លួន |

ពន្យល់សិស្សថា គំនិតផ្ទាល់ខ្លួនមិនអាចបញ្ជាក់ឱ្យប្រាកដថាវាត្រឹមត្រូវរហូតទេ តែយើងអាចបញ្ជាក់ការពិតថាត្រឹមត្រូវបាន។ ឧទាហរណ៍៖ យើងអាចបញ្ជាក់ថាប៊ិចពិតជាមានពណ៌ខៀវមែន តែវាមិនមែនជាប៊ិចល្អជាងគេនៅកម្ពុជាទេ(សម្រាប់មនុស្សមួយចំនួន ប៉ុន្តែមិនមែនគ្រប់គ្នា។)

## ៤.៣. ឧបករណ៍វាស់អារម្មណ៍

អារម្មណ៍ដើរតួយ៉ាងសំខាន់នៅក្នុងដំណើរការនៃការសម្រេចចិត្តរបស់យើង ហើយជារឿយៗសិស្សក៏មិនដឹងពីអារម្មណ៍របស់ពួកគេ ឬអារម្មណ៍ទាំងនោះមានឥទ្ធិពលលើអាកប្បកិរិយារបស់ពួកគេដែរ។

ឧបករណ៍វាស់អារម្មណ៍ត្រូវបានរចនាឡើងដើម្បីជួយសិស្សឱ្យរៀនស្គាល់អារម្មណ៍ និងឆ្លុះបញ្ចាំងពីពួកគេ និងផលប៉ះពាល់ចំពោះអាកប្បកិរិយារបស់ពួកគេ និងអ្នកដទៃ។ ឧបករណ៍នេះជួយសិស្សដោយផ្ទាល់នូវការអភិវឌ្ឍបំណិនស្វ័យគ្រប់គ្រង ទាក់ទងនឹងចំណេះដឹង និងការគ្រប់គ្រងខ្លួនឯង។

**សម្ភារៈដែលត្រូវការ ៖** ផ្ទាំងក្រដាស ក្រដាស ស្កុត

**ការណែនាំ ៖**

គូសរូបឧបករណ៍វាស់អារម្មណ៍(តារាងវាស់អារម្មណ៍)លើផ្ទាំងក្រដាសឱ្យរួចរាល់ ហើយបិទលើក្តារខៀនមុនពេលសិស្សចូលថ្នាក់ (ទី១.សម្រាប់សិស្សបឋមសិក្សា ទី២.សម្រាប់សិស្សអនុវិទ្យាល័យ)។ ពន្យល់សិស្សថាចាប់ពីថ្ងៃនេះទៅ

មេរៀននឹងចាប់ផ្ដើមដោយសំណួរ “ តើអ្នកមានអារម្មណ៍ដូចម្ដេចថ្ងៃនេះ ?” អ្នកមានចំណាប់អារម្មណ៍ពីអារម្មណ៍របស់សិស្សអ្នក។

- សិស្សទាំងអស់ត្រូវសរសេរឈ្មោះលើក្រដាស។ អាចសរសេរលើក្រដាសធម្មតា ឬក្រដាសកាតុង។
- គ្រប់ម៉ោងសិក្សាប្រាប់សិស្សឱ្យយកក្រដាសដែលមានឈ្មោះ បិទនៅជិតអារម្មណ៍ដែលគេកំពុងមាន។
- សិស្សបិទរួចហើយ ត្រូវឱ្យសិស្សគិតពីចម្លើយរបស់ពួកគេ។
- ពន្យល់ពួកគេថាការបង្ហាញ និងយល់ពីអារម្មណ៍របស់ខ្លួនឯងពិតជាមានសារៈសំខាន់ណាស់។

<table>
<tr><th colspan="2">តើខ្ញុំមានអារម្មណ៍ដូចម្ដេចថ្ងៃនេះ ?</th><th colspan="2">តើខ្ញុំមានអារម្មណ៍ដូចម្ដេចថ្ងៃនេះ ?</th></tr>
<tr><td colspan="2">
</td><td colspan="2"></td></tr>
<tr><td>ខៀវ៖ រីករាយ</td><td>បៃតង៖ ស្ងប់ស្ងាត់</td><td>លឿង ៖ ក្រៀមក្រំ</td><td>ក្រហម៖ ខឹង</td></tr>
<tr><td colspan="2">ឧបករណ៍វាស់អារម្មណ៍នៅកម្រិតបឋមសិក្សា</td><td colspan="2">ឧបករណ៍វាស់អារម្មណ៍នៅកម្រិតអនុវិទ្យាល័យ</td></tr>
</table>

## ៤.៤. ដំណោះស្រាយឈ្នះ-ឈ្នះ

សិស្សត្រូវរកដំណោះស្រាយល្អបំផុត ហើយពួកគេអាចមានគំនិត និងមតិផ្សេងពីគ្នាក្នុងការរកវិធីសាស្ត្រដើម្បីដោះស្រាយ។

គ្រូនឹងដឹកនាំសិស្សដើម្បីឈានទៅរកដំណោះស្រាយមួយដែលល្អសម្រាប់សិស្សទាំងអស់ហើយក្នុងដំណើរការនេះសិស្សត្រូវប្រើបំណិនរបស់ពួកគេក្នុងការចរចា ។




## វិធីដោះស្រាយឈ្នះ-ឈ្នះ




- **ជំហានទី១៖** ពេលដែលយើងដឹងថា យើងមានការមិនយល់ស្របគ្នាជា មួយអ្នកដទៃ យើងត្រូវចាប់ផ្តើមគិតពីឈ្នះ ឬ ចាញ់។ បើអ្នកឈ្នះ ខ្ញុំ ចាញ់។ ការគិតពីបញ្ហា។
- **ជំហានទី២-** យើងទាំងពីរត្រូវរិះរកវិធីដើម្បីយល់ពីគំនិតគ្នាទៅវិញទៅមកដោយពិភាក្សាគ្នាពីបញ្ហានេះ
- **ជំហានទី៣-** យើងទាំងពីរត្រូវប្តេជ្ញាធ្វើការរួមគ្នាដើម្បីឱ្យឈ្នះទាំងសងខាង។
- **ជំហានទី៤-** អ្នកដែលមានចំណែកក្នុងទំនាស់ ត្រូវមើលលើសេចក្តីត្រូវការ និងតម្លៃដែលសំខាន់សម្រាប់ភាគីទាំងសងខាង ហើយត្រូវមានការបង្កើតដំណោះស្រាយ។

- **ជំហានទី៥**- ភាគីទាំងសងខាងត្រូវចំណាយពេលផ្ទាល់ខ្លួនដើម្បីរិះរកវិធីយ៉ាងតិច៣ ដែលអាចឱ្យមានការឯកភាពទាំងសងខាង។

- **ជំហានទី៦**- ភាគីទាំងសងខាងមើលលើវិធីទាំង៦ដែលខ្លួនរកបាន ហើយធ្វើការសម្រេចចិត្តរួមគ្នាថាមួយណាជាដំណោះស្រាយល្អបំផុត។

- **ជំហានទី៧**- ភាគីទាំងពីរនិយាយគ្នាក្រោយពេល២សប្តាហ៍ថាតើការសម្រេចចិត្តខាងលើមានប្រសិទ្ធភាពឬទេ ថាតើការសម្រេចចិត្តនេះធ្វើឱ្យសប្បាយចិត្តឬទេ ? ឬក៏ត្រូវរិះរកវិធីផ្សេងៗទៀត។

ប្រភព៖ Word of Work, IBEC Project, KAPE/WEI, 2015.

## ៤.៥. ការសង្កេតមើលពីទីតាំងផ្សេងគ្នានៅពេលបង្រៀន




**ហេតុអ្វី** ? ព្រោះសកម្មភាពនេះនឹងជួយសិស្សឱ្យចូលរួមក្នុងបទពិសោធជាក់ស្តែង រៀនរកព័ត៌មានគួរឱ្យចាប់អារម្មណ៍
ដើម្បីប្រាប់អ្នកដទៃ អនុវត្តការងារជាក្រុម និងសហការ ក៏ដូចជាអនុវត្តបំណិនសរសេរ និងរៀនពីរបៀបចូលរួមយ៉ាងសកម្មជាមួយអ្វីដែលកំពុងកើតឡើងនៅជុំវិញគាត់។

គ្រូអាចជួយសិស្សក្នុងការរៀបចំផែនការ និងការរៀបចំក្លឹប ហើយលើកទឹកចិត្តពួកគេឱ្យចូលរួមក្នុងដំណើរការ។

ប្រើប្រាស់លេខ៦ និងលេខ៩ ក្នុងការបង្រៀនសិស្សពី ការមើលទិដ្ឋភាពពីចំណុចផ្សេងគ្នា។

ដំបូងឱ្យសិស្សមើលលេខ៦រួចហើយមើលលេខ៩។ ពន្យល់សិស្សថា វិធីសាស្រ្តនេះបានមកពី រឿងព្រេងចំណាស់មួយនៅមជ្ឈឹមបូព៌ា ដែលមានព្រះអង្គម្ចាស់២អង្គ បានធ្វើសង្គ្រាមជាច្រើនឆ្នាំ។ ព្រះអង្គម្ចាស់ទី១ មើលរូបភាពលើតុថាជាលេខ៦ ឯព្រះអង្គម្ចាស់ទី២ថាលេខ៩។ សង្គ្រាមបានផ្ទុះឡើងជាច្រើនឆ្នាំ ហើយនៅថ្ងៃមួយ ព្រះអង្គម្ចាស់ទាំង២អង្គយនៅតរួមគ្នាស្រាប់តែមានក្មេងប្រុសម្នាក់បានបង្វិលកម្រាលតុកន្លះជុំ ភ្លាមនោះ ព្រះអង្គម្ចាស់ទាំងពីរបានឃើញទិដ្ឋភាពពីជ្រុងម្ខាងទៀតរៀងៗខ្លួន។ ការធ្វើសង្គ្រាមត្រូវបានបញ្ចប់ ហើយព្រះអង្គម្ចាស់ទាំងពីរក្លាយជាមិត្តដ៏ជិតស្និទ្ធបំផុត។ បង្ហាញនូវឧទាហរណ៍មួយពីជីវិតផ្ទាល់ខ្លួនអ្នកដែលស្រដៀងទៅនឹងការមានទំនាស់ជាមួយនរណាម្នាក់ ព្រោះតែមើលទិដ្ឋភាពតែមួយពីជ្រុងផ្សេង។

ឱ្យសិស្សផ្តុំជាក្រុមតូចៗហើយពិភាក្សាគ្នា ពីសារៈសំខាន់នៃការយល់ឱ្យច្បាស់ថា ពេលខ្លះយើងមានការខ្វែងគំនិតគ្នាដោយហេតុតែបុគ្គលម្នាក់ៗអាចមើលទៅលើបញ្ហាតែមួយពីជ្រុងផ្សេងគ្នា។

ប្រភព ៖ Edutopia

## ៤.៦. ក្លិបកាសែតនៅសាលារៀន [4]

### ផ្នែកទី១-រៀបចំផែនការអំពីក្រដាសរបស់អ្នក

- សម្រេចចិត្តថាតើត្រូវបោះពុម្ពក្រដាសរបស់អ្នកញឹកញាប់ប៉ុណ្ណា
- សម្រេចចិត្តលើទំហំ និងទ្រង់ទ្រាយសម្រាប់កាសែតរបស់អ្នក
- សម្រេចចិត្តលើធនធានដែលអ្នកត្រូវការ
- ទទួលបានការអនុញ្ញាតពីនាយកសាលារបស់អ្នក
- រៀបចំសកម្មភាពរៃអង្គាសប្រាក់នៅសាលារៀនដើម្បីរកប្រាក់ដែលត្រូវការ និងស្វែងរកការគាំទ្រពីគណៈគ្រប់គ្រងសាលារៀន និងសហគមន៍។

### ផ្នែកទី២-ការចូលរួមរបស់សិស្ស

- កំណត់ពេលប្រជុំដំបូងរបស់អ្នក
- ធ្វើការសម្រេចចិត្តជាក្រុមលើអ្វីដែលនឹងកើតឡើងនៅក្នុងបញ្ហាទីមួយ។

### ផ្នែកទី៣-បោះពុម្ពផ្សាយកាសែតដំបូងរបស់អ្នក

- ជ្រើសរើសគំរូកាសែត
- បង្កើតការចាត់តាំងសម្រាប់ការចេញផ្សាយកាសែតដំបូងរបស់អ្នក
- អាន និងកែតម្រូវឱ្យបានស្អាតនូវកាសែតទាំងមូលមុននឹងផ្សព្វផ្សាយ
- បោះពុម្ព និងចែកចាយកាសែតរបស់អ្នក។

[4] ប្រភព: https://www.makemynewspaper.com/how-to-start-a-school-newspaper.

# ឧបសម្ព័ន្ធជំពូក៥

## ៥.១. តារាងលម្អិតអំពីគំរូសង្គម និងគំរូអាជីពងាយ

| គំរូសង្គម | | គំរូអាជីពងាយ | |
|---|---|---|---|
| ឧទាហរណ៍៖ ការធ្វើចំណាកស្រុកនៅក្នុងភូមិ (បំណិនមូលដ្ឋាន) | | ឧទាហរណ៍៖ ការចិញ្ចឹមមាន់ | |
| ១-ចំណេះដឹងដែលទាក់ទង ក្នុងមូលដ្ឋាន | សិស្សរៀនអំពីការធ្វើចំណាកស្រុកដោយក្រឡេកមើលអ្វីដែលកើតឡើងនៅក្នុងភូមិ។(អ្នកចំណាកស្រុកជោគជ័យ បរាជ័យ) | ១-បំណិនមូលដ្ឋាន | សិស្សរៀនពីអ្នកជំនាញក្នុងមូលដ្ឋាននៅក្នុងភូមិ។ សិស្សអនុវត្ត និងហ្វឹកហាត់បំណិនទន់ក្នុងសកម្មភាពផ្សេងៗគ្នាដែលស្មើឡើងដោយគ្រូ( ឧ. ការងារជាក្រុម ការសម្ភាស ការវិភាគ សកម្មភាពផ្សព្វផ្សាយ)។ |
| ២-បំណិនបុរិវជ្ជីវៈ | នៅក្នុងដំណើរការរៀនសូត្រ សិស្សអនុវត្តបំណិនទន់ ហ្វឹកហាត់ក្នុងសកម្មភាពផ្សេងៗគ្នាដែលស្នើឡើងដោយគ្រូ (ឧទាហរណ៍៖ ទំនាក់ទំនង កិច្ចសហប្រតិបត្តិការ ការចរចា) ។ | ២-បំណិនបច្ចេកទេស | សិស្សសិក្សាពីអ្នកជំនាញក្នុងមូលដ្ឋានចែករំលែកពី<br>• បច្ចេកទេសចិញ្ចឹម<br>• បំណិនចិញ្ចឹម និង<br>• បទពិសោធន៍<br>• ...។ |
| ៣-ចរិយាសម្បទា និងគុណតម្លៃផ្ទាល់ខ្លួន | គុណតម្លៃ និងចរិយាសម្បទាដូចជាសាមគ្គីភាពជាមួយមនុស្សដទៃទៀត ការទទួលខុសត្រូវចំពោះកិច្ចការនីមួយៗដែលបានអភិវឌ្ឍគ្រូដើរតួជាគំរូ បរិស្ថានសិក្សាចាំបាច់ត្រូវបង្រៀន ការគោរព ភាពស្មោះត្រង់ សាមគ្គីភាព។ល។ | ៣-បំណិនអាជីវកម្ម និងការគ្រប់គ្រង | សិស្សរៀនដើម្បីមានជោគជ័យលើអាជីវកម្មចិញ្ចឹមមាន់ពីកសិករជំនាញ។<br>រៀនអំពីមូលដ្ឋានគ្រឹះលើជំនាញទីផ្សារ ដោយត្រូវដឹងពីវិធីល្អបំផុតក្នុងការលក់មាន់ដើម្បីរកប្រាក់ចំណេញពីអ្នកជំនាញក្នុងមូលដ្ឋាន។<br>រៀនពីអ្នកជំនាញក្នុងមូលដ្ឋាន និងពីឯកសារដើម្បីធ្វើបានប្រសើរជាងមុន។ |

# ៥.២. ស្តង់ដាសិក្សា

## * សម្រាប់កម្រិតថ្នាក់ ទី៤ ទី៥ និងទី៦

<table>
<tr><th colspan="5">សមត្ថភាពទី ៤.៤. បាស្រ្រ័យទាក់ទង និងធ្វើការងារជាក្រុម</th></tr>
<tr><th colspan="2">សម្បទា</th><th>ថ្នាក់ទី ៤</th><th>ថ្នាក់ទី៥</th><th>ថ្នាក់ទី ៦</th></tr>
<tr><td colspan="2">វិជ្ជាសម្បទា</td><td>ការប្រាស្រ័យទាក់ទង៖ សិស្សអាចប្រាប់ពីស្ថានភាព និងវិធីដែលពួកគេបានបង្ហាញពីគំនិតយោបល់មួយនៅក្នុងថ្នាក់ ហើយពួកគេអនុវត្តវាយ៉ាងដូចម្តេច។<br>ការងារក្រុម៖ សិស្សអាចលើកឡើងពីហេតុផលវិជ្ជមានមួយចំនួនក្នុងការសហការជាមួយមិត្តភក្តិក្នុងក្រុមតូចៗ។</td><td>ការប្រាស្រ័យទាក់ទង៖ សិស្សអាចប្រាប់ពីស្ថានភាព និងវិធីដែលពួកគេបានបង្ហាញពីគំនិតយោបល់មួយនៅក្នុងថ្នាក់ ហើយពួកគេអនុវត្តវាយ៉ាងដូចម្តេច។<br>ការងារក្រុម៖ សិស្សអាចលើកឡើងពីហេតុផលវិជ្ជមានមួយចំនួនក្នុងការសហការជាមួយមិត្តភក្តិក្នុងក្រុមតូចៗ។</td><td>ការប្រាស្រ័យទាក់ទង៖ សិស្សអាចបង្ហាញនៅក្នុងថ្នាក់ពីស្ថានការណ៍អ្វីមួយ ឬពីអ្វីដែលពួកគេបានធ្វើប្រសើរពីមុន។<br>ការងារក្រុម៖ សិស្សអាចកំណត់ និងលើកឡើងពីហេតុផលវិជ្ជមានក្នុងការសហការគ្នា។</td></tr>
<tr><td rowspan="4">បំណិនសម្បទា</td><td>ប្រាស្រ័យទាក់ទង</td><td>សិស្សចាប់ផ្តើមប្រើវិធីទំនាក់ទំនងផ្សេងៗ ក្នុងការទទួលយកព័ត៌មាន និងគំនិតយោបល់។</td><td>សិស្សអាចប្រើវិធីផ្សេងៗនៃទំនាក់ទំនង ទាំងពាក្យសម្តី និងកាយវិការ ដើម្បីទទួលព័ត៌មាន និងគំនិតយោបល់។</td><td>សិស្សអាចប្រើព័ត៌មាន គំនិត យោបល់ ជាមធ្យោបាយដើម្បីប្រាស្រ័យទាក់ទងបានច្បាស់លាស់ ទាំងពាក្យសម្តី និងកាយវិការទៅតាមបរិបទ។</td></tr>
<tr><td>ការងារក្រុម (កិច្ចសហប្រតិបត្តិការ)</td><td>សិស្សធ្វើការងារងាយស្រួលក្នុងការងារក្រុមតូច និងដៃគូ</td><td>សិស្សធ្វើការងារងាយស្រួលក្នុងការងារក្រុមតូចនិងទទួលតួនាទីដែលគ្រូដាក់ឱ្យ។</td><td>សិស្សទទួលយកតួនាទីកិច្ចការ ដែលក្រុម ឬគ្រូផ្តល់ឱ្យពួកគេធ្វើ។</td></tr>
<tr><td>ការងារក្រុម (ការចរចា)</td><td>សិស្សអាចស្តាប់ និងចែករំលែកគំនិតយោបល់នៅពេលពួកគេប្រឈមមុខនឹងបញ្ហារួម។</td><td>សិស្សអាចស្វែងរកគំនិតទស្សនៈផ្សេងៗនិងចែករំលែកគំនិតយោបល់របស់ពួកគេនៅពេលដែលប្រឈមមុខបញ្ហារួម។</td><td>សិស្សអាចសាកសួរ ឬស្តាប់មតិយោបល់គ្នាដើម្បីស្វែងយល់ពីតម្រូវការ និងការពារទស្សនៈរួមរបស់ខ្លួននៅពេលពួកគេប្រឈមនឹងបញ្ហារួមណាមួយ។</td></tr>
<tr><td>ការងារក្រុម (ការចូលរួម)</td><td>សិស្សចូលរួម ការងារជាក្រុមតូចក្នុងការសិក្សា។</td><td>សិស្សចូលរួមក្នុងសកម្មភាពរៀបចំការងារក្រុម។</td><td>សិស្សមានភាពសកម្មក្នុងការចូលរួមសកម្មភាពក្រុម។</td></tr>
</table>

## សមត្ថភាពទី៤.៥. ពិចារណា និងការបង្កើតថ្មី

| សម្បទា | | ថ្នាក់ទី ៤ | ថ្នាក់ទី៥ | ថ្នាក់ទី ៦ |
|---|---|---|---|---|
| វិជ្ជាសម្បទា | | ពិចារណា៖ សិស្សអាចផ្តល់ឧទាហរណ៍ពីវិធីដែលគេបានប្រើក្នុងការដោះស្រាយបញ្ហាក្នុងជីវិតរបស់ពួកគេ។<br>ការបង្កើតថ្មី៖ សិស្សអាចផ្តល់ឧទាហរណ៍ពីលទ្ធផលដែលគេទទួលបាននៅពេលពួកគេរៀនមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន។ | ពិចារណា៖<br>សិស្សអាចផ្តល់ឧទាហរណ៍ពីវិធី និង បំណិនដែលគេបានប្រើក្នុងការដោះស្រាយបញ្ហាក្នុងជីវិតរបស់ពួកគេ។<br>ការបង្កើតថ្មី៖ សិស្សអាចផ្តល់ឧទាហរណ៍ពីលទ្ធផលដែលគេទទួលបាននៅពេលពួកគេរៀនមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានដែលជាលទ្ធផលនៃគំនិតផ្ទាល់របស់ពួកគេ។ | ពិចារណា៖ សិស្សអាចពន្យល់ពីវិធីផ្សេងៗក្នុងការវិភាគពីបញ្ហា និងផ្តល់ដំណោះស្រាយដែលអាចមាន [5] ។<br>ការបង្កើតថ្មី៖ សិស្សអាចរៀបរាប់អំពីផលិតផលផ្សេងៗទៀតដែលពួកគេបានដឹងក្នុងអំឡុងពេលរៀនបំណិនជីវិតតាមមូលដ្ឋាននៅក្នុងថ្នាក់រៀន។ |
| បំណិនសម្បទា | ការវិភាគ (ការដោះស្រាយបញ្ហា) | សិស្សអាចលើកពីដំណោះស្រាយបញ្ហាផ្សេងៗហើយអាចអនុវត្តដំណោះស្រាយនោះ។ | សិស្សអាចលើកពីដំណោះស្រាយបញ្ហាផ្សេងៗ ដោយអាចអនុវត្ត និងផ្ទៀងផ្ទាត់ពីសុពលភាពនៃដំណោះស្រាយនោះ។ | សិស្សអាចស្នើឡើងនូវដំណោះស្រាយផ្សេងៗ (ច្រើនជាងមួយ) អនុវត្តដំណោះស្រាយដែលបានកំណត់ ផ្ទៀងផ្ទាត់និងវាយតម្លៃលើដំណោះស្រាយទាំងនោះ នៅមានឬគ្មានសុពលភាព។ |
| | ការវិភាគ (ការរិះគិតពិចារណា) | សិស្សអាចបន្សុីគ្នារវាងព័ត៌មានចាស់ និងថ្មី។ | សិស្សអាចបន្សុីគ្នារវាងព័ត៌មានចាស់ និងថ្មីដែលជាព្រឹត្តិការណ៍ ឬដំណើរការ ហើយអាចកំណត់រកភាពដូចគ្នា និងភាពផ្សេងគ្នាបាន។ | សិស្សអាចកំណត់ភាពស្រដៀងគ្នា និងភាពខុសគ្នា និងអាចធ្វើទំនាក់ទំនងរវាងព័ត៌មានចាស់ និងថ្មី។ |
| | ការបង្កើតថ្មី | សិស្សអាចបង្ហាញពីគំនិតផ្តួចផ្តើម និងការបង្កើតថ្មីនៅក្នុងថ្នាក់រៀន។ | សិស្សលើកពីគំនិតយោបល់ថ្មីៗក្នុងថ្នាក់តាមរយៈស្នាដៃផ្សេងៗ (ឧ. ការគូរគំនូរ...)។ | សិស្សលើកឡើងនូវគំនិតថ្មីៗទៅកាន់មិត្តរួមថ្នាក់ (ឧ. ការគូររូប ការនិពន្ធរឿងខ្លីៗ...)។ |

[5] : ស្នើសិស្សឱ្យលើកពីឧទាហរណ៍ពីបញ្ហាដែលគេបានដោះស្រាយកាលពីខែមុន

## សមត្ថភាពទី ៤.៧. អភិវឌ្ឍបុគ្គល គ្រួសារ និងសង្គម

| | | | | |
|---|---|---|---|---|
| វិជ្ជាសម្បទា | | ការអភិវឌ្ឍបុគ្គល៖ សិស្សអាចលើកបាន ១ចំណុច ពីចំណុចខ្លាំងរបស់ខ្លួន។ ការអភិវឌ្ឍគ្រួសារ និងសង្គម៖ សិស្សអាចរៀបរាប់អំពីការងាររបស់អ្នកជំនាញមកពីសហគមន៍ ដែលបានជួបក្នុងអំឡុងពេលបង្រៀនបំណិនជីវិតតាមមូលដ្ឋាន។ | ការអភិវឌ្ឍបុគ្គល៖ សិស្សអាចលើកបាន ១ចំណុច ពីចំណុចខ្លាំងរបស់ខ្លួន។ ការអភិវឌ្ឍគ្រួសារ និងសង្គម៖ សិស្សអាចរៀបរាប់អំពីការងាររបស់អ្នកជំនាញមកពីសហគមន៍ ដែលបានជួបក្នុងអំឡុងពេលបង្រៀនបំណិនជីវិតតាមមូលដ្ឋាន។ | ការអភិវឌ្ឍបុគ្គល៖ សិស្សអាចកំណត់បានពីចំណុចខ្លាំងសំខាន់បំផុត និងដែនកំណត់របស់ខ្លួន។ ការអភិវឌ្ឍគ្រួសារ និងសង្គម៖ សិស្សអាចពិពណ៌នាពីកិច្ចការប្រចាំថ្ងៃរបស់មនុស្សម្នាក់ក្នុងសហគមន៍ និងពន្យល់ពីវិធីដែលផ្តល់ចំណេញដល់សហគមន៍។ |
| បំណិនសម្បទា | ការគ្រប់គ្រងខ្លួនឯង (បុគ្គល) | • សិស្សបង្ហាញពីវិធីត្រឹមត្រូវក្នុងការគ្រប់គ្រងអារម្មណ៍មិនល្អ។<br>• សិស្សមានទំនួលខុសត្រូវរាល់កិច្ចការដែលខ្លួនធ្វើ។ | • សិស្សចាប់ផ្តើមអភិវឌ្ឍវិធីសមស្របមួយចំនួនដើម្បីបង្ហាញ និងគ្រប់គ្រងអារម្មណ៍មិនល្អ។<br>• សិស្សមានទំនួលខុសត្រូវ និងច្បាស់លាស់លើរាល់កិច្ចការដែលខ្លួនធ្វើ។ | • សិស្សអាចបង្ហាញ និងគ្រប់គ្រងអារម្មណ៍ក្នុងបរិបទផ្សេងដែលកើតមាន។<br>• សិស្សមានភាពទៀតទាត់ និងទទួលខុសត្រូវនៅពេលដែលពួកគេធ្វើកិច្ចការអ្វីមួយ។ |
| | ការសម្រេចចិត្ត (បុគ្គល) | សិស្សអាចកំណត់គោលដៅសិក្សា និងជីវិតរស់នៅក្នុងរយៈពេលខ្លី។ | សិស្សអាចកំណត់គោលដៅសិក្សា និងជីវិតរស់នៅក្នុងរយៈពេលខ្លី ដោយការពិនិត្យលើជម្រើស និងគំនិតយោបល់នៃទស្សនវិស័យផ្សេងៗ។ | សិស្សអាចកំណត់គោលដៅរយៈពេលខ្លី ឬមធ្យមសម្រាប់ការសិក្សា និងអនាគតរបស់ពួកគេ ដោយផ្អែកតាមព័ត៌មានដែលមាន។ |
| | ភាពធន់ | សិស្សអាចស្នើសុំឱ្យគ្រូជួយនៅពេលពួកគេជួបបញ្ហាប្រឈមទាំងក្នុងការសិក្សា និងជីវិតរស់នៅប្រចាំថ្ងៃ។ | សិស្សអាចមានទំនាក់ទំនងនៅពេលពួកគេប្រឈមនឹងបញ្ហាក្នុងការសិក្សា និងជីវិតរស់នៅប្រចាំថ្ងៃ ហើយគេក៏អាចស្នើសុំឱ្យមិត្តភក្តិ និងគ្រូបង្រៀនជួយពួកគេផងដែរ។ | សិស្សស្នើសុំជំនួយពេលពួកគេប្រឈមនឹងបញ្ហាក្នុងការសិក្សាពីមិត្តភក្តិ គ្រូបង្រៀន ឬគ្រួសាររបស់ពួកគេ ហើយសម្របឥរិយាបថរបស់ខ្លួនដើម្បីជម្នះការប្រឈម។ |
| | ការយល់ចិត្តគ្នា (បុគ្គល ឬគ្រួសារ) | សិស្សអាចយល់ពីអារម្មណ៍របស់ខ្លួន និងអារម្មណ៍មិត្តភក្តិដទៃថាអាចមានភាពខុសគ្នា។ | សិស្សយល់ថាអ្នកដទៃមានអារម្មណ៍ និងគំនិតផ្ទាល់របស់គេ ហេតុនេះត្រូវចេះសម្រប និងគោរពអ្នកដទៃ។ | សិស្សយល់ និងបង្ហាញពីចំណាប់អារម្មណ៍ចំពោះអារម្មណ៍អ្នកដទៃ និងសម្របឥរិយាបថរបស់ខ្លួន គោរពអ្នកដទៃ។ |

| | | | | |
|---|---|---|---|---|
| | ការគោរពភាពផ្សេងគ្នា (ការអភិវឌ្ឍសង្គម) | សិស្សអាចទទួលស្គាល់ និងគោរពលក្ខណៈផ្សេងគ្នា។ | សិស្សអាចទទួលស្គាល់ និងគោរពលក្ខណៈផ្សេងគ្នា និងលើកម្ពស់ការរួបរួមគ្នាជាមួយមិត្តភក្តិ។ | សិស្សទទួលស្គាល់ដោយគោរព និងចែករំលែកចំពោះភាពទីទៃពីគ្នា និងលើកកម្ពស់មិត្តភាពសង្គមនៅសាលាជាមួយមិត្តភក្តិរបស់ពួកគេ។ |
| | ចរិយាសម្បទា និងគុណតម្លៃ | • ស្រឡាញ់ និងឱ្យតម្លៃការសិក្សានៅសាលារៀន និងទទួលខុសត្រូវចំពោះសកម្មភាពរបស់ពួកគេនៅក្នុងការសិក្សា។<br>• សិស្សចូលរួមជាវិជ្ជមានក្នុងក្រុមការងារ ជាមួយមិត្តភក្តិដទៃទៀត និងឱ្យតម្លៃក្រុមការងារ។<br>• សិស្សគោរព និងផ្តល់តម្លៃដល់វប្បធម៌ និងប្រពៃណីក្នុងស្រុក។ | | |

## * សម្រាប់កម្រិតថ្នាក់ ទី៧ ទី៨ និងទី៩

**សមត្ថភាពទី ៤.៤. បាស្រ័យទាក់ទង និងធ្វើការងារជាក្រុម**

| សម្បទា | | ថ្នាក់ទី ៧ | ថ្នាក់ទី៨ | ថ្នាក់ទី ៩ |
|---|---|---|---|---|
| វិជ្ជាសម្បទា | | ការប្រាស្រ័យទាក់ទង៖ សិស្សរៀបចំខ្លឹមសារបានសមស្របសម្រាប់ការឡើងបង្ហាញក្នុងថ្នាក់ ឬនៅសាលារៀន ដោយបញ្ជាក់ប្រាប់ពីកត្តាមួយចំនួនដែលជួយពួកគេឱ្យធ្វើការបង្ហាញបានល្អ។<br>ការងារជាក្រុម៖ សិស្សអាចរៀបរាប់ពីសារប្រយោជន៍នៃការធ្វើការងារក្រុម។ | ការប្រាស្រ័យទាក់ទង៖ សិស្សអាចប្រាប់ពីការឡើងបង្ហាញក្នុងថ្នាក់ នៅសាលារៀន ឬនៅសហគមន៍ និងពន្យល់ប្រាប់ពីអ្វីដែលគេបានធ្វើល្អ និងកាន់តែប្រសើរ។<br>ការងារជាក្រុម៖ សិស្សអាចរៀបរាប់ និងផ្តល់ឧទាហរណ៍ពីសារប្រយោជន៍នៃការធ្វើការងារជាក្រុម។ | ការប្រាស្រ័យទាក់ទង៖ សិស្សអាចប្រាប់ពីអ្វីដែលពួកគេបានបង្ហាញនៅក្នុងថ្នាក់ ឬក្នុងសាលារៀនទៅកាន់សហគមន៍ ពីកត្តាដែលធ្វើឱ្យពួកគេធ្វើបានប្រសើរ<br>ការងារជាក្រុម៖ សិស្សពន្យល់ពីអត្ថប្រយោជន៍នៃការងារក្រុមច្បាស់លាស់។ |
| បំណិនសម្បទា | ប្រាស្រ័យទាក់ទង | សិស្សអាចប្រើវិធីផ្សេងៗក្នុងការធ្វើទំនាក់ទំនងទាំងការសរសេរពាក្យសម្តី និងកាយវិការ។ | សិស្សអាចប្រើវិធីផ្សេងៗក្នុងការធ្វើទំនាក់ទំនង ទាំងការសរសេរ ពាក្យសម្តី និងកាយវិការ និងអាចប្រើបច្ចេកវិទ្យាក្នុងទំនាក់ទំនងនៅពេលត្រូវការ។ | សិស្សអាចប្រើមធ្យោបាយនានាដើម្បីទំនាក់ទំនងទាំងការសរសេរ ពាក្យសម្តី កាយវិការ និងបច្ចេកវិទ្យាក្នុងការទំនាក់ទំនងប្រកបដោយទំនុកចិត្ត។ |

| | | | | |
|---|---|---|---|---|
| | ធ្វើការងារជាក្រុម (កិច្ចសហប្រតិបត្តិការ) | សិស្សអាចសហការបំពេញការងារជាក្រុម និងចេះជួយគ្នាក្នុងក្រុម។ | សិស្សអាចធ្វើការងារ និងចេះចែករំលែកក្នុងក្រុម ដោយអាចគ្រប់គ្រងគ្រប់ស្ថានការណ៍នៃបញ្ហា។ | សិស្សមានភាពសកម្មក្នុងការធ្វើការងារជាក្រុម និងដោះស្រាយក្នុងស្ថានការណ៍ជម្លោះ។ |
| | ធ្វើការងារជាក្រុម (ការចរចា) | សិស្សបញ្ជាក់បានពីតម្រូវការរបស់អ្នកដទៃ នៅពេលប្រឈមនឹងបញ្ហារួម ពួកគេខិតខំស្វែងរកដំណោះស្រាយល្អបំផុតសម្រាប់ខ្លួនឯង និងអ្នកដទៃ។ | សិស្សយល់ និងគោរពតម្រូវការរបស់អ្នកដទៃ ដោយនៅពេលប្រឈមនឹងបញ្ហារួម ពួកគេខិតខំស្វែងរកដំណោះស្រាយល្អបំផុតសម្រាប់ខ្លួនឯង និងអ្នកដទៃ។ | សិស្សអាចដឹកនាំដើម្បីរកដំណោះស្រាយសមស្របមួយសម្រាប់ភាគីទាំងពីរ ទាក់ទងនឹងតម្រូវការ និងចំណាប់អារម្មណ៍របស់អ្នកដទៃ។ |
| | ធ្វើការងារជាក្រុម (ការចូលរួម) | សិស្សអាចចូលរួមចែករំលែក ក្នុងដំណើរសិក្សារបស់ ក្រុម។ | សិស្សអាចចូលរួមចែករំលែកក្នុងដំណើរសិក្សានៃក្រុម និងអាចចូលរួមជាផ្នែកមួយ ក្នុងការធ្វើសេចក្ដីសម្រេចចិត្ត។ | សិស្សអាចចូលរួមចែករំលែកបទពិសោធក្នុងដំណើរការសិក្សា និងចូលរួមសកម្មភាពជាការសម្រេចចិត្តដោយគោរពសិទ្ធិគ្នាទៅវិញទៅមក។ |
| **សមត្ថភាពទី៤.៥. ពិចារណា និងការបង្កើតថ្មី** | | | | |
| **វិជ្ជាសម្បទា** | | ការពិចារណា៖ សិស្សប្រាប់បានពីវិធីសាស្ត្រផ្សេងៗគ្នាដែលត្រូវប្រើដើម្បីវិភាគបញ្ហា មានដំណោះស្រាយជាច្រើនត្រូវបានអនុវត្តក្នុងសាលា ហើយសិស្សអាចពិពណ៌នាពីដំណោះស្រាយដែលគេបានប្រើកាលពីមុន។<br>ការបង្កើតថ្មី/គិតវិភាគ៖ សិស្សអាចផ្តល់ឧទាហរណ៍ពីចំណងជើងប្រធានបទសង្គម ឬប្រធានបទអាជីពងាយដែលមានសារប្រយោជន៍បំផុត ក្រោយពីពួកគេបានរៀនមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន។ | ការពិចារណា៖ សិស្សស្វែងយល់ពីវិធីសាស្ត្រច្រើនជាងមួយ ដើម្បីប្រើក្នុងការវិភាគបញ្ហា និងរកដំណោះស្រាយផ្សេងៗដែលអាចជាដំណោះស្រាយបញ្ហា ព្រមទាំងអាចលើកបង្ហាញជាឧទាហរណ៍ពីបទពិសោធផ្ទាល់។<br>ការបង្កើតថ្មី/គិតវិភាគ៖ សិស្សអាចលើកបង្ហាញពីឧទាហរណ៍ល្អៗ ទាក់ទងទៅនឹងការសិក្សាប្រធានបទសង្គម និងអាជីពងាយដែលគេបានអនុវត្តនៅសហគមន៍។ | ការពិចារណា៖ សិស្សដឹងពីវិធីជ្រើសរើសវិធីសាស្ត្រល្អបំផុតដើម្បីប្រើក្នុងការវិភាគបញ្ហា។ សិស្សអាចផ្តល់ជាឧទាហរណ៍នៅក្នុងជីវិតរស់នៅជាក់ស្តែងរបស់ពួកគេនៅពេលពួកគេបានប្រើវា។<br>ការបង្កើតថ្មី/គិតវិភាគ៖ សិស្សអាចកំណត់អត្តសញ្ញាណនៃការច្នៃប្រឌិត និងការអនុវត្តល្អៗ នៅក្នុងសហគមន៍ទាក់ទងនឹងប្រធានបទអាជីពងាយ និងប្រធានបទសង្គមដែលបានសិក្សា។ |

| | | | | |
|---|---|---|---|---|
| បំណិនសម្ទោ | ការវិភាគ (ការដោះស្រាយបញ្ហា) | សិស្សអាចបង្កើតនូវដំណោះស្រាយមួយចំនួន រួចជ្រើសរើសយកដំណោះស្រាយមួយដើម្បីអនុវត្ត នៅពេលដែលពួកគេជួបនឹងបញ្ហាសាមញ្ញណាមួយ។ | សិស្សអាចបង្កើតនូវដំណោះស្រាយមួយចំនួន នៅពេលពួកគេប្រឈមមុខនឹងស្ថានការណ៍មានបញ្ហាដោយកំណត់រកប្រភពព័ត៌មានដែលសមស្រប រួចគិតវិភាគ និង ផ្តល់ដំណោះស្រាយស្របទៅតាមប្រភេទនៃបញ្ហា។ | នៅពេលប្រឈមមុខនឹងស្ថានភាពដែលមានបញ្ហានិងស្មុគស្មាញ សិស្សអាចបង្កើតដំណោះស្រាយសមស្រប កំណត់ ប្រភពព័ត៌មានត្រឹមត្រូវ វិភាគទិន្នន័យ និងលើកយកដំណោះស្រាយដែលសម្របទៅនឹងប្រភេទនៃបញ្ហា។ |
| | ការវិភាគ (ការរិះគិតពិចារណា) | សិស្សអាចស្រាវជ្រាវព័ត៌មានដែលពួកគេត្រូវការក្នុង បរិបទសិក្សាផ្លូវការក៏ដូចជាក្នុងជីវិតប្រចាំថ្ងៃ។ | សិស្សអាចគិតវិភាគព័ត៌មានដែលពួកគេបានទទួល នៅសាលា និងសហគមន៍។ | សិស្សអាចបង្កើតឱ្យមានសម្មតិកម្មផ្សេងៗ និងបង្ហាញពីទំនាក់ទំនងទាំងឡាយដោយមានហេតុ និងផល។ |
| | ការបង្កើតថ្មី | សិស្សដាក់បញ្ចូលគំនិតថ្មីតាមរយៈផលិតផលរបស់គេនៅសាលា។ | សិស្សមានទំនុកចិត្តក្នុងការផ្តល់នូវដំណោះស្រាយថ្មីៗក្នុងការដោះស្រាយបញ្ហា។ | សិស្សមានទំនុកចិត្តក្នុងការស្នើឡើងនូវដំណោះស្រាយថ្មីចំពោះបញ្ហា និងការពារគំនិតរបស់ពួកគេជាមួយគ្រូ និងមិត្តភក្តិ។ |
| **សមត្ថភាពទី ៤.៧. អភិវឌ្ឍបុគ្គល គ្រួសារ និងសង្គម** | | | | |
| វិជ្ជាសម្ទោ | | អភិវឌ្ឍបុគ្គល៖ សិស្សចាប់ផ្តើមកំណត់បានពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួន។ សិស្សអាចរៀបរាប់ពីមាគ៌ានៃអាជីពនៅអនាគត ដែលអាចមាននៅកម្រិតមូលដ្ឋាន។ អភិវឌ្ឍគ្រួសារ និងសង្គម៖ សិស្សរៀបរាប់បានពីចំណុចសំខាន់ ដែលខ្លួនត្រូវទទួលខុសត្រូវ ក្នុងការធ្វើសកម្មភាពជាមួយមិត្តភក្តិ និងគ្រួសារ។ | អភិវឌ្ឍបុគ្គល៖ សិស្សចាប់ផ្តើមស្គាល់ពីចំណុចខ្លាំងនិងចំណុចខ្សោយរបស់ខ្លួន។ សិស្សអាចរៀបរាប់ពីមាគ៌ានៃអាជីពនៅអនាគតដែលអាចមាននៅកម្រិតមូលដ្ឋាន។ អភិវឌ្ឍគ្រួសារ និងសង្គម៖ សិស្សយល់ថាពួកគេមានតួនាទី និងការទទួលខុសត្រូវចំពោះមិត្តភក្តិ និងគ្រួសារ។ | អភិវឌ្ឍបុគ្គល៖ សិស្សអាចកំណត់ និងពិពណ៌នានូវចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួនបានច្រើន។ សិស្សអាចរៀបរាប់ពីមាគ៌ាអាជីពអនាគតដែលអាចមាននៅកម្រិតថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ដោយផ្អែកលើប្រភពព័ត៌មានច្បាស់លាស់។ អភិវឌ្ឍគ្រួសារ និងសង្គម៖ សិស្សយល់ដឹងពីសារៈសំខាន់នៃតួនាទី និងការទទួលខុសត្រូវរបស់បុគ្គល នៅក្នុងគ្រួសារ និងសហគមន៍។ |

| | | | | |
|---|---|---|---|---|
| | ការគ្រប់គ្រងខ្លួនឯង (បុគ្គល) | សិស្សអាចចាត់ចែងពេលវេលាសិក្សាផ្ទាល់ខ្លួន និងការបំពេញកិច្ចការសាលា។ | សិស្សអាចរៀបចំចាត់ចែងការសិក្សារបស់ខ្លួនប្រកបដោយទំនួលខុសត្រូវដោយសម្របទៅតាមពេលវេលានិងវិធីសិក្សារបស់ខ្លួន។ | សិស្សអាចចាត់ចែងប្រភពផ្សេងៗនៃព័ត៌មានសិក្សាដោយសម្របទៅនឹងពេលវេលា និងវិធីសិក្សារបស់ខ្លួន ផ្ទាល់។ |
| | ការសម្រេចចិត្ត (បុគ្គល) | សិស្សអាចកំណត់គោលដៅរយៈពេលខ្លី ទាំងផ្នែកនៃការសិក្សា និងអាជីពអនាគត។ | សិស្សអាចកំណត់បាននូវគោលដៅរយៈពេលមធ្យមក្នុងការរៀនសូត្រ និងអាជីពនាពេលអនាគត។ | សិស្សអាចកំណត់បាននូវគោលដៅរយៈពេលវែង និងមធ្យម ចំពោះការសិក្សា និងអាជីពអនាគតរបស់ពួកគេ។ |
| | ភាពអត់ធន់ | សិស្សអាចស្នើសុំឱ្យ មិត្តភក្តិ សាលារៀន ឬគ្រួសារ ជួយពួកគេនៅពេលដែលពួកគេត្រូវការ។ | សិស្សអាចស្នើសុំជំនួយពីមិត្តភក្តិ សាលារៀន ឬគ្រួសារ ដើម្បីជួយពេលដែលគេត្រូវការ។ | សិស្សចាត់ទុកមិត្តភក្តិ សាលារៀន សហគមន៍ជាផ្នែកមួយនៃបណ្តាញសុវត្ថិភាពរបស់គេ ដែលពួកគេអាចស្នើសុំឱ្យជួយនៅពេលដែលពួកគេត្រូវការ។ |
| | ការយល់ចិត្តគ្នា (បុគ្គល ឬគ្រួសារ) | សិស្សកំណត់បានពីអារម្មណ៍ និងការគិតរបស់អ្នកដទៃ ហើយអាចបត់បែនឥរិយាបថរបស់ខ្លួនទៅតាមអ្នកដទៃបាន។ | សិស្សយល់ពីអារម្មណ៍ និងការគិតរបស់អ្នកដទៃដោយសម្របឥរិយាបថរបស់ខ្លួនបានទៅតាមអ្នកដទៃ។ | សិស្សអាចយល់ពីអ្វីដែលជាអារម្មណ៍ និងការគិតរបស់នរណាម្នាក់ ហើយសម្របឥរិយាបថដោយផ្អែកលើអារម្មណ៍អ្នកដទៃ។ |
| | ការគោរពភាពផ្សេងគ្នា (ការអភិវឌ្ឍសង្គម) | សិស្សអាចទទួលស្គាល់ គោរព និងចែករំលែកជាមួយភាពផ្សេងៗគ្នា ហើយគាត់អាចទទួលស្គាល់ភាពអយុត្តិធម៌ដែលជាប់ទាក់ទងនឹងភាពចម្រុះ។។ | សិស្សអាចទទួលស្គាល់ គោរពនិងចែករំលែកជាមួយភាពផ្សេងៗគ្នា និងទទួលស្គាល់ភាពអយុត្តិធម៌ដែលពាក់ព័ន្ធទៅនឹងភាពចម្រុះ និងធ្វើសកម្មភាពឆ្លើយតប។ | សិស្សអាចទទួលស្គាល់ គោរព និងចែករំលែកជាមួយភាពផ្សេងៗគ្នា ហើយគេអាចទទួលស្គាល់ភាពអយុត្តិធម៌ដែលពាក់ព័ន្ធនឹងភាពចម្រុះ និងធ្វើសកម្មភាពឆ្លើយតប។ |
| | ចរិយាសម្បទា និងគុណតម្លៃ | • ស្រឡាញ់ និងឱ្យតម្លៃការសិក្សានៅសាលារៀន ជាមនុស្សដែលមានទំនួលខុសត្រូវក្នុងការសម្រេចចិត្ត ចំពោះខ្លួនឯង និងអ្នកដទៃ។<br>• សិស្សចូលរួមប្រកបដោយភាពវិជ្ជមានជាមួយក្រុមនិងដៃគូ និងគោរពគ្នាទៅវិញទៅមក។<br>• សិស្សឱ្យតម្លៃកិច្ចសហប្រតិបត្តិការ និងមានគំនិតផ្តួចផ្តើមសាមគ្គីភាព។ | | |

## ៥.៣. ព័ត៌មានលម្អិតអំពីគម្រោងបង្រៀន៦ដំណាក់កាល

| សមត្ថភាពទី៤.៥. ពិចារណា និងការបង្កើតថ្មី | | | | |
|---|---|---|---|---|
| **ដំណាក់កាល** | **ប្រភេទសកម្មភាព** | **វិជ្ជាសម្បទា និងបំណិនសម្បទា ដែលបានអភិវឌ្ឍ (បំណិនមូលដ្ឋាន និងបំណិនអាជីព)** | **ធនធាន/ សម្ភារៈចាំបាច់** | **រយៈពេល** |
| ១. ស្វែងយល់ប្រធានបទ គោលបំណង ៖ កំណត់បាននូវអ្វីដែលសិស្សចេះស្រាប់ និងមធ្យោបាយនានា ដើម្បីបង្កើនចំណេះដឹងរបស់សិស្សចំពោះប្រធានបទដែលបានជ្រើសរើស (បញ្ហា ឬឱកាសពីបរិបទមូលដ្ឋានដែលពួកគេរស់នៅ)។ | • បំផុសសំណួរលើចំណេះដឹងមានស្រាប់<br>• អញ្ជើញអ្នកជំនាញមកធ្វើបទឧទ្ទេស(អ្នកមានចំណេះដឹងបទពិសោធស្របតាមប្រធានបទ)<br>• ការអានឯកសារ(នៅបណ្ណាល័យ ឬសហគមន៍)<br>• ការប្រើករណីសិក្សា | **វិជ្ជាសម្បទា**<br>• សិស្សអាចប្រាប់នូវអ្វីដែលពួកគេដឹងរួចហើយលើប្រធានបទ សិស្សនឹងបង្កើតសម្មតិកម្ម<br>• សិស្សកំណត់ប្រភពដែលអាចមានសម្រាប់ព័ត៌មានថ្មី<br>**បំណិនសម្បទា**<br>• ការដោះស្រាយបញ្ហា(ការស្រាវជ្រាវ ...)<br>• ការត្រិះរិះពិចារណា(ចាត់ថ្នាក់ចំណេះដឹង ដែលមានស្រាប់។ល។)<br>• ការទំនាក់ទំនង(ការស្តាប់ ការប្រាស្រ័យទាក់ទងផ្ទាល់មាត់) ចរិយាសម្បទា និងគុណតម្លៃផ្ទាល់ខ្លួន<br>• ផ្តល់តម្លៃដល់សហគមន៍ និងគ្រួសារ | • ធនធានមនុស្ស<br>• ឯកសារទាក់ទងនឹងប្រធានបទ | ២ម៉ោង |
| ២. ការស្រង់ព័ត៌មានពីសហគមន៍គោលបំណង៖ បង្កើតឧបករណ៍ និងចុះប្រមូលព័ត៌មានពីសហគមន៍ដែលអាចឱ្យសិស្សវាយតម្លៃការយល់ដឹង និងឥរិយាបថរបស់ពួកគេលើប្រធានបទដែលបានជ្រើសរើស។ | • បង្កើតកម្រងសំណួរ<br>• កំណត់ប្រភពព័ត៌មាន (អ្នកជំនាញក្នុងស្រុក ក្រុមប្រឹក្សាឃុំ ប៉ូលីស បណ្ណាល័យ។ ល។)<br>• ការត្រៀមសម្ភាសន៍<br>• ការសម្ភាសន៍<br>• ការធ្វើរបាយការណ៍ | **វិជ្ជាសម្បទា**<br>• សិស្សរៀនអភិវឌ្ឍឧបករណ៍ដើម្បីស្វែងរកព័ត៌មានថ្មីៗ<br>• សិស្សទទួលបានចំណេះដឹងទាក់ទងនឹងមូលដ្ឋានកាន់តែច្រើនតាមរយៈប្រធានបទបំណិនសម្បទា<br>• ការច្នៃប្រឌិត<br>• កិច្ចសហប្រតិបត្តិការ (បំណិនបុគ្គល ការធ្វើការជាក្រុម)<br>• ការទំនាក់ទំនង (ពាក្យសម្តី បំណិនសរសេរ)<br>• ការចរចា (ជឿជាក់លើខ្លួនឯងម្ចាស់ការ។ល។)<br>• បំណិនអាជីវកម្ម ទីផ្សារ។ ល។<br>• បំណិនបច្ចេកទេសចរិយាសម្បទា និងគុណតម្លៃផ្ទាល់ខ្លួន<br>• សាមគ្គីភាព (ពេលជួបជនរងគ្រោះ)<br>• ការគោរព (ពេលជួបអ្នកភូមិ ឬអាជ្ញាធរមូលដ្ឋាន) | • សៀវភៅសរសេរ<br>• ឯកសារណែនាំ<br>• ផ្ទាំងក្រដាស<br>• ប៊ិក ខ្មៅដៃ ... | ៨ម៉ោង<br><br>(សិស្សអាចប្រើពេលវេលាផ្ទាល់ខ្លួនដើម្បីបំពេញភារកិច្ចនេះ) |

| | | | | |
|---|---|---|---|---|
| ៣. ការវិភាគព័ត៌មាន<br>គោលបំណង៖ វិភាគព័ត៌មានដើម្បីកំណត់មូលហេតុចម្បងនៃបញ្ហា និងដំណោះស្រាយដែលអាចកើតមានដោយប្រើវិធីសាស្ត្រដោះស្រាយបញ្ហា។ | • បង្ហាញលទ្ធផលស្រាវជ្រាវ<br>• វិភាគដើមឈើបញ្ហា<br>• កំណត់យកដំណោះស្រាយនិងសង្ខេបខ្លឹមសារចងក្រងជាមេរៀនបំណិនជីវិត | **វិជ្ជាសម្បទា**<br>• សិស្សរៀនពីវិធីវិភាគព័ត៌មាន<br>• សិស្សអាចកំណត់ទំនាក់ទំនងរវាងហេតុ នឹងផល<br>• សិស្សរៀនញែកមតិយោបល់និងការពិត និងការសន្មត<br>**បំណិនសម្បទា**<br>• ការសម្រេចចិត្ត (ការធ្វើផែនការ ការកំណត់គោលដៅ។ ល។ )<br>• ការត្រិះរិះពិចារណា (ការវិភាគទិន្នន័យ លក្ខណវិនិច្ឆ័យ ។ល។)<br>• ការដោះស្រាយបញ្ហា (វិភាគបញ្ហា, កំណត់អត្តសញ្ញាណ)<br>• ការគោរពលក្ខណៈចម្រុះ (បែងចែកទិន្នន័យសម្រាប់ភេទ ជនជាតិដើម ប្រវត្តិសង្គម។ល។)<br>ចរិយាសម្បទា និងគុណតម្លៃផ្ទាល់ខ្លួន គោរពអ្នកដទៃ | • ផូស្ទ័រ<br>• ប៊ិកហ្វឺត<br>• បណ្ណពាក្យ<br>• កន្ត្រៃ<br>• ស្កុត | ២ម៉ោង |
| ៤. ការអភិវឌ្ឍផែនការសកម្មភាពផ្សព្វផ្សាយ<br>គោលបំណង៖ កំណត់ដំណោះស្រាយដែលអាចអនុវត្តជាក់ស្តែង (មួយ ឬច្រើន) ដើម្បីដោះស្រាយបញ្ហា និងរៀបចំផែនការសម្រាប់ការអនុវត្ត។ | • ការជ្រើសរើសយកដំណោះស្រាយ<br>• រៀបចំផែនការសកម្មភាពផ្សព្វផ្សាយដល់សហគមន៍ (រួមមាន ល្បែង សរសេររឿង សម្តែងតួ។ល។)<br>• បង្ហាញផែនការ និងហ្វឹកហាត់<br>• ការរៀបចំអនុវត្តផែនការ | • សិស្សអាចប្រាប់វិធីផ្សេងៗគ្នាក្នុងការបញ្ចូញដំណោះស្រាយ<br>• សិស្សរៀនពីរបៀបធ្វើផែនការបំណិនសម្បទា<br>• ការច្នៃប្រឌិត(ដោះស្រាយបញ្ហាដោយច្នៃប្រឌិត រកដំណោះស្រាយថ្មីៗ)<br>• កិច្ចសហប្រតិបត្តិការ(បែងចែកភារកិច្ចធ្វើការជាមួយគ្នា)<br>• ការសម្រេចចិត្ត(ការកំណត់គោលដៅ និងការធ្វើផែនការ)<br>• ការចរចា(យល់ស្របជាមួយមិត្តភក្តិ)<br>• ការដោះស្រាយបញ្ហា(កំណត់ និងជ្រើសរើសដំណោះស្រាយ)<br>ចរិយាសម្បទា និងគុណតម្លៃផ្ទាល់ខ្លួន ស្រឡាញ់សហគមន៍របស់ពួកគេ សាមគ្គីភាព | • ផូស្ទ័រ<br>• ប៊ិកហ្វឺត<br>• ក្រដាសផ្ទាំងធំ<br>• កន្ត្រៃ<br>• ស្កុត | ២ម៉ោង |

| | | | | |
|---|---|---|---|---|
| ៥. ការអនុវត្តផែនការនៅតាមសហគមន៍គោលបំណង៖ លើកកម្ពស់ការយល់ដឹងអំពីបញ្ហាឱ្យបានទូលំទូលាយ និងចូលរួមជាមួយភាគីពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហារួមគ្នា។ | • ការផ្តល់ការណែនាំ<br>• ការអនុវត្តជាក់ស្តែងនៅសហគមន៍<br>• ការផ្តល់ព័ត៌មានត្រឡប់ និងការថ្លែងអំណរគុណ | វិជ្ជាសម្បទា<br>• សិស្សរៀនអំពីការចូលរួម និងការឆ្លើយតបជាមួយសហគមន៍<br>• សិស្សរៀនអំពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួនក្នុងការអនុវត្តផែនការ<br>• សិស្សរៀនពីអត្ថប្រយោជន៍នៃការធ្វើការជាក្រុមបំណិនសម្បទា<br>• ការចូលរួម(ចូលរួមចំណែកយ៉ាងសកម្មក្នុងសកម្មភាព)<br>• ការប្រាស្រ័យទាក់ទង(សិស្សនឹងធ្វើបទបង្ហាញ សរសេរចម្រៀង សម្តែងតួ។ល។)<br>• កិច្ចសហប្រតិបត្តិការ(ជួយគ្នាក្នុងការអនុវត្តផែនការ)<br>• ការគោរពចំពោះលក្ខណៈចម្រុះ(ធ្វើការជាមួយសមាជិកទាំងអស់ អនុវត្តសកម្មភាពដែលលើកកម្ពស់ និងការពារលក្ខណៈចម្រុះនៅក្នុងសហគមន៍)<br>• បំណិនបច្ចេកទេស(ការដាំដំណាំ សិប្បកម្ម។ល។)<br>• ការធ្វើផែនការ ទីផ្សារ។ ល។<br>ចរិយាសម្បទា និងគុណតម្លៃផ្ទាល់ខ្លួន ស្រឡាញ់ និងគោរពសហគមន៍ភាពស្មោះត្រង់ និងការទទួលខុសត្រូវ គោរពភារកិច្ច នឹងមិត្តភក្តិ | • ផ្អែកតាមសកម្មភាពដែលបានជ្រើសរើស | ២ម៉ោង (សិស្សអាចប្រើពេលវេលាផ្ទាល់ខ្លួនដើម្បីបំពេញភារកិច្ចនេះ) |
| ៦. ការឆ្លុះបញ្ចាំង និង វង្វាយតម្លៃគោលបំណង៖លើកទឹកចិត្តសិស្សឱ្យឆ្លុះបញ្ចាំង និងរៀនសូត្រពីគ្រប់ដំណាក់កាលរួមទាំងបទពិសោធក្នុងការអនុវត្តសកម្មភាពផ្សព្វផ្សាយនៅតាមសហគមន៍។ | • ឆ្លុះបញ្ចាំងលើសកម្មភាពតាមមូលដ្ឋាន<br>• ការសរសេររបាយការណ៍ | **វិជ្ជាសម្បទា**<br>• សិស្សរៀនដាក់ស្លាកសញ្ញាអារម្មណ៍<br>• សិស្សរៀនកំណត់ និងពិពណ៌នាអំពីភាពទន់ខ្សោយផ្ទាល់ខ្លួន និងពង្រឹងភាពទន់ខ្សោយនោះ<br>**បំណិនសម្បទា**<br>• ការយល់ចិត្ត(ឆ្លុះបញ្ចាំងពីអារម្មណ៍របស់អ្នកដទៃ)<br>• ការត្រិះរិះពិចារណា(វិភាគថាតើសកម្មភាពបានប្រព្រឹត្តិទៅយ៉ាងដូចម្តេច)<br>• ស្វ័យគ្រប់គ្រង(ឆ្លុះបញ្ចាំងពីអារម្មណ៍របស់សិស្ស)<br>• ភាពធន់(ឆ្លុះបញ្ចាំងពីរបៀបដែលសិស្សសម្របខ្លួនទៅនឹងបញ្ហាប្រឈម)<br>ចរិយាសម្បទា និងគុណតម្លៃផ្ទាល់ខ្លួន ភាពស្មោះត្រង់ និងទំនួលខុសត្រូវ អាកប្បកិរិយាវិជ្ជមាន | • សៀវភៅសិស្ស ប៊ិក និងខ្មៅដៃ<br>• ផូស្ទ័រស្វ័យឆ្លុះបញ្ចាំង<br>• ក្រដាសផ្ទាំងធំ | ២ម៉ោង |

# ៥.៤. ផ្លូវនៃការបង្រៀន ៦ដំណាក់កាល ( សកម្មភាព និង បំណិនទន់ )




ទាំងនេះជាឧទាហរណ៍នៃបំណិនទន់ដែលអ្នកអាចកំណត់តាមដំណាក់កាល

ដំណាក់កាលទាំង៦

ទាំងនេះជាឧទាហរណ៍នៃសកម្ម ភាពដែលអ្នកអាច អនុវត្តតាមដំណាក់កាល

# ឧបសម្ព័ន្ធជំពូក៧

## ៧.១. ឧបករណ៍វាយតម្លៃការប្រតិបត្តិ-ការអន្តេតផ្លូវការរបស់គ្រូនៅកម្រិតបឋមសិក្សា

| | | | | | |
|---|---|---|---|---|---|
| ឈ្មោះសិស្ស:.............................. ថ្នាក់ទី..............សាលា ................................ ស្រុក.................................. ប្រចាំឆមាស: ....................................... | | | | | |
| ពិន្ទុប្រចាំឆមាស តេស្តវិជ្ជាសម្បទា + ការអង្កេតរបស់គ្រូ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ | | | | | |
| តេស្តវិជ្ជាសម្បទាប្រចាំឆមាស ( 40% ) | (A)=........./4 | | | | |
| បំណិនទន់ ចរិយាសម្បទានិងគុណតម្លៃ ( 60% ) | (B)=........./6 | | | | |
| ពិន្ទុសរុប ( 100% ) 1-20 ខ្សោយ 20-30 ល្អ 35-50 ល្អណាស់ | (C)=(A)+(B)....../10 | | | | |
| **សមត្ថភាព៤.៤. ការប្រាស្រ័យទាក់ទង និងធ្វើការងារជាក្រុម** | | 0.1 | 0.25 | 0.35 | 0.50 |
| 1 | ( ការប្រាស្រ័យទាក់ទង ) សិស្សបង្ហាញគំនិត និងយោបល់ហើយសួរសំណួរដោយច្បាស់លាស់ ( ជាពិសេសពាក្យសម្តី និងកាយវិកា ) ។ | | | | |
| 2 | ( ការចរចា ) នៅពេលប្រឈមមុខនឹងជម្លោះជាមួយមិត្តភក្តិសិស្សស្តាប់អ្នកដទៃឱ្យយល់ពីអ្វីដែលពួកគេគិត ហើយរកដំណោះស្រាយដែលល្អសម្រាប់ភាគីទាំងពីរ។ | | | | |
| 3 | ( កិច្ចសហប្រតិបត្តិការ និងការចូលរួម )សិស្សធ្វើតាមការណែនាំដែលបានផ្តល់សម្រាប់ក្រុម និងចូលរួមផ្តល់គំនិត និងជួយក្នុងការសម្រេចបាន។ | | | | |
| **សមត្ថភាព៤.៥. ការពិចារណា និងការបង្កើតថ្មី** | | | | | |
| 4 | ( ការដោះស្រាយបញ្ហា និងការត្រិះរិះពិចារណា ) សិស្សរៀបចំព័ត៌មានដែលប្រមូលបានហើយអាចស្នើដំណោះស្រាយច្រើនជាងមួយសម្រាប់បញ្ហា និងវាយតម្លៃប្រសិនបើដំណោះស្រាយបានជ្រើសរើសត្រឹមត្រូវ។ | | | | |
| 5 | ( ការបង្កើតថ្មី ) សិស្សប្រើផលិតផលដូចជាគំនូរ ឬរឿងងាយៗ ដើម្បីបង្ហាញគំនិត ឬអារម្មណ៍។ | | | | |

| សមត្ថភាព៤.៥. ការពិចារណា និងការបង្កើតថ្មី | | | | | |
|---|---|---|---|---|---|
| 4 | (ការដោះស្រាយបញ្ហា និងការត្រិះរិះពិចារណា) សិស្សរៀបចំព័ត៌មានដែលប្រមូលបានហើយអាចស្នើដំណោះស្រាយច្រើនជាងមួយសម្រាប់បញ្ហា និងវាយតម្លៃប្រសិនបើដំណោះស្រាយបានជ្រើសរើសត្រឹមត្រូវ។ | | | | |
| 5 | (ការបង្កើតថ្មី) សិស្សប្រើផលិតផលដូចជាគំនូរ ឬរឿងងាយៗ ដើម្បីបង្ហាញគំនិត ឬអារម្មណ៍។ | | | | |
| 8 | (ភាពធន់) សិស្សសុំជំនួយនៅពេលគាត់ត្រូវការ។ | | | | |
| 9 | (ការគោរពភាពចម្រុះ) សិស្សធ្វើការយ៉ាងងាយស្រួលជាមួយមិត្តភក្តិទាំងអស់នៅក្នុងថ្នាក់។ | | | | |
| ចរិយាសម្បទា និងគុណតម្លៃ | | | | | |
| 10 | សិស្សស្មោះត្រង់ ហើយគិតពីអ្វីដែលខ្លួនកំពុងធ្វើ។ សិស្សធ្វើអន្តរកម្មជាវិជ្ជមាន និងគាំទ្រគ្នាទៅវិញទៅមក។ សិស្សឱ្យតម្លៃ និងចូលចិត្តការសិក្សានៅសាលា។ | | | | |
| សរុបបំណិនទន់ និងឥរិយាបថ | | K | L | M | N |
| | | =(K+L+M+N)/5=……./6 | | | |

0=មិនដែល, 1 = ម្តងម្កាល, 2 = ភាគច្រើន 3 = ជានិច្ច
បង្គត់ឡើងកាលណាពិន្ទុក្រោយខ្ទង់ទសភាគធំជាង៥។បង្គត់ចុះកាលណាពិន្ទុក្រោយខ្ទង់ទសភាគតូចជាង៥។
ឧទាហរណ៍៖ពិន្ទុសរុប 12: 12 / 5 = 2.4 បង្គត់ចុះបាន 2។ 13 / 5 = 2.6 បង្គត់ឡើងបាន 3 ។

# ៧.១.១. ឧបករណ៍វាយតម្លៃការប្រតិបត្តិ-ការអង្កេតផ្លូវការរបស់គ្រូនៅកម្រិតមធ្យមសិក្សាបឋមភូមិ

| | | | | | | |
|---|---|---|---|---|---|---|
| ឈ្មោះសិស្ស:................................ ថ្នាក់ទី..............សាលា ................................. ស្រុក.................................<br>ប្រចាំឆមាស: ........................................ | | | | | | |
| ពិន្ទុប្រចាំឆមាស តេស្តវិជ្ជាសម្បទា + ការអង្កេតរបស់គ្រូ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ | | | | | | |
| តេស្តវិជ្ជាសម្បទាប្រចាំឆមាស (40%) | | | ........../20 | | | |
| បំណិនទន់ ចរិយាសម្បទានិងគុណតម្លៃ (60%) | | | ........../30 | | | |
| ពិន្ទុសរុប (100%) 1-20 ខ្សោយ 20-30 ល្អ 35-50 ល្អណាស់ | | | ............/50 | | | |
| **សមត្ថភាព៤.៤. ការប្រាស្រ័យទាក់ទង និងធ្វើការងារជាក្រុម** | | 0 | 1 | 2 | 3 | |
| 1 | (ការប្រាស្រ័យទាក់ទង) សិស្សបង្ហាញពីគំនិត និងយោបល់ដោយប្រើបច្ចេកទេសទំនាក់ទំនងជាច្រើនរួមទាំងបច្ចេកវិទ្យាព័ត៌មាន (ICT) នៅពេលមាន។ | | | | | |
| 2 | (ការចរចា) នៅពេលប្រឈមនឹងជម្លោះសាមញ្ញជាមួយក្រុមសិស្សសួរសំណួរដើម្បីយល់ពីទស្សនៈរបស់អ្នកដទៃមុនពេលរកដំណោះស្រាយដើម្បីទទួលយកបានទាំងសងខាង។ | | | | | |
| 3 | (កិច្ចសហប្រតិបត្តិការនិងការចូលរួម) សិស្សមានអារម្មណ៍សុខស្រួលក្នុងក្រុម និងចូលរួមសកម្មភាព។ | | | | | |
| **សមត្ថភាព ៤.៥. ការពិចារណា និងការបង្កើតថ្មី** | | | | | | |
| 4 | (ការដោះស្រាយបញ្ហា និងការត្រិះរិះពិចារណា) សិស្សអាចកំណត់នូវដំណោះស្រាយដែលអាចធ្វើបានហើយជ្រើសរើសយកមួយដែលត្រឹមត្រូវដែលគាត់គិតថាអាចដោះស្រាយវាបាន។ សួរគាត់ថា □ប្រសិនបើខ្ញុំធ្វើបែបនេះ តើនឹងមានអ្វីកើតឡើង? តើមានដំណោះស្រាយណាជំនួសទេ? តើអ្វីខ្លះជាមូលហេតុពិតរបស់វា? | | | | | |
| 5 | (ភាពច្នៃប្រឌិត) សិស្សអាចលើកសំណើ និងបង្ហាញគំនិតរបស់ពួកគេដោយប្រើឧបករណ៍ផ្សេងៗដូចជាគំនូរ ឬរឿងខ្លី។ | | | | | |
| **សមត្ថភាព ៤.៧ . ការអភិវឌ្ឍបុគ្គល គ្រួសារ និងសង្គម** | | | | | | |
| 6 | (ការគ្រប់គ្រងខ្លួនឯង និងការយល់ចិត្ត) សិស្សអាចដាក់ស្លាកអារម្មណ៍របស់ពួកគេ ហើយឆ្លើយតបនៅពេលដែលមិត្តភក្តិដទៃទៀតមានអារម្មណ៍មិនល្អ។ | | | | | |

| | | | | | |
|---|---|---|---|---|---|
| 7 | (ការធ្វើសេចក្តីសម្រេចចិត្ត) សិស្សប្រមូលព័ត៌មានជាច្រើន ឬពិគ្រោះជាមួយអ្នកជំនាញមុនពេលធ្វើការសម្រេចចិត្ត។ | | | | |
| 8 | (ភាពធន់) សិស្សសុំជំនួយនៅពេលគាត់ត្រូវការ។ | | | | |
| 9 | (ការគោរពភាពចម្រុះ) សិស្សធ្វើការយ៉ាងងាយស្រួលជាមួយមិត្តភក្តិទាំងអស់នៅក្នុងថ្នាក់។ | | | | |
| **ចរិយាសម្បទា និងគុណតម្លៃ** | | | | | |
| 10 | សិស្សមានភាពស្មោះត្រង់ និងទទួលខុសត្រូវចំពោះអ្វីដែលខ្លួនកំពុងធ្វើ។ សិស្សលើកកម្ពស់ និងការពារការគោរពគ្នា និងផ្តល់តម្លៃដល់ការអប់រំសម្រាប់ការរីកចម្រើនផ្ទាល់ខ្លួន និងអនាគត។ | | | | |
| **សរុបបំណិនទន់ និងគុណតម្លៃ** | | | | | |
| | | ........../30 | | | |
| សរុបបំណិនទន់ និងគុណតម្លៃ<br>0=មិនដែលសោះ, 1 = ម្តងម្កាល 2 = ភាគច្រើន 3 = ជានិច្ច | | | | | |

## ៧.២. ឧទាហរណ៍នៃទម្រង់សង្កេតសម្រាប់គ្រូបឋមសិក្សា

### (ដើម្បីកត់សម្គាល់ប្រចាំឆមាស)

ឈ្មោះសិស្ស:................................ ថ្នាក់ទី..............សាលា ................................ ស្រុក..............................
ឆមាស: ........................................

| | | |
|---|---|---|
| **សមត្ថភាព៤.៤. ការប្រាស្រ័យទាក់ទង និងធ្វើការងារជាក្រុម** | | **កំណត់សម្គាល់** |
| 1 | (ការប្រាស្រ័យទាក់ទង) សិស្សបង្ហាញគំនិត និងយោបល់ហើយសួរសំណួរដោយច្បាស់ (ជាពិសេសពាក្យសម្តី និងកាយវិការ)។ | |
| 2 | (ការចរចា) នៅពេលប្រឈមមុខនឹងជម្លោះជាមួយមិត្តភក្តិសិស្សស្តាប់អ្នកដទៃឱ្យយល់ពីអ្វីដែលពួកគេគិត ហើយស្វែងរកដំណោះស្រាយដែលល្អសម្រាប់ភាគីទាំងពីរ។ | |
| 3 | (កិច្ចសហការ និងការចូលរួម) សិស្សធ្វើតាមការណែនាំដែលបានផ្តល់សម្រាប់ក្រុមនិងចូលរួមផ្តល់គំនិត និងជួយក្នុងការសម្រេចឱ្យបាន។ | |
| **សមត្ថភាព៤.៥. ការពិចារណា និងការបង្កើតថ្មី** | | |
| 4 | (ការដោះស្រាយបញ្ហា និងការត្រិះរិះពិចារណា) សិស្សរៀបចំព័ត៌មានដែលប្រមូលបានហើយអាចស្នើដំណោះស្រាយច្រើនជាងមួយ សម្រាប់បញ្ហា និងវាយតម្លៃប្រសិនបើដំណោះស្រាយបានជ្រើសរើសត្រឹមត្រូវ។ | |
| 5 | (ការបង្កើតថ្មី) សិស្សប្រើផលិតផលដូចជាគំនូរ ឬរឿងងាយៗ ដើម្បីបង្ហាញគំនិត ឬអារម្មណ៍។ | |
| **សមត្ថភាព ៤.៧ . ការអភិវឌ្ឍបុគ្គល គ្រួសារ និងសង្គម** | | |
| 6 | (ការគ្រប់គ្រងខ្លួនឯង និងការយល់ចិត្ត) សិស្សអាចនិយាយអំពីអារម្មណ៍របស់ខ្លួនហើយអាចសម្របឥរិយាបថរបស់ខ្លួនទៅតាមអារម្មណ៍អ្នកដទៃ។ | |
| 7 | (ការសម្រេចចិត្ត) សិស្សអាចបំពេញកិច្ចការដែលបានទទួល និងស្នើសុំជំនួយនៅពេលគាត់ត្រូវការ។ | |
| 8 | (ភាពធន់) សិស្សសុំជំនួយនៅពេលគាត់ត្រូវការ។ | |
| 9 | (ការគោរពភាពចម្រុះ) សិស្សធ្វើការយ៉ាងងាយស្រួល ជាមួយមិត្តភក្តិទាំងអស់នៅ | |
| **ចរិយាសម្បទា និងគុណតម្លៃ** | | |
| 10 | សិស្សស្មោះត្រង់ ហើយគិតពីអ្វីដែលខ្លួនកំពុងធ្វើ។ សិស្សធ្វើអន្តរកម្មជាវិជ្ជមាន និងគាំទ្រគ្នាទៅវិញទៅមក។ សិស្សឱ្យតម្លៃ និងចូលចិត្តការសិក្សានៅសាលា។ | |

## ៧.២.១. ឧទាហរណ៍នៃទម្រង់សង្ខេបសម្រាប់គ្រូអនុវិទ្យាល័យ

### (សម្រាប់កត់សម្គាល់ប្រចាំឆមាស)

គ្រូអាចប្តូរមាតិកាស្តង់ដាផ្អែកលើតម្រូវការរបស់សិស្ស

| | | |
|---|---|---|
| ឈ្មោះសិស្ស:................................ ថ្នាក់ទី..............សាលា ................................. ស្រុក.............................. ឆមាស: ........................................ | | |
| **សមត្ថភាព៤.៤. ការប្រាស្រ័យទាក់ទង និងធ្វើការងារជាក្រុម** | | **កំណត់សម្គាល់** |
| 1 | (ការប្រាស្រ័យទាក់ទង) សិស្សបង្ហាញពីគំនិត និងយោបល់ដោយប្រើបច្ចេកទេសទំនាក់ទំនងជាច្រើនរួមទាំងបច្ចេកវិទ្យាព័ត៌មាន (ICT) នៅពេលមាន។ | |
| 2 | (ការចរចា) នៅពេលប្រឈមនឹងជម្លោះសាមញ្ញជាមួយក្រុម សិស្សសួរសំណួរដើម្បីយល់ពីទស្សនៈរបស់អ្នកដទៃមុនពេលរកដំណោះស្រាយដើម្បីទទួលយកបានទាំងសងខាង។ | |
| 3 | (កិច្ចសហប្រតិបត្តិការ និងការចូលរួម) សិស្សមានអារម្មណ៍សុខស្រួលក្នុងក្រុម និងចូលរួមសកម្មភាពក្នុងក្រុម។ | |
| **សមត្ថភាព៤.៥ . ការពិចារណា និងការបង្កើតថ្មី** | | |
| 4 | (ការដោះស្រាយបញ្ហា និងការត្រិះរិះពិចារណា) សិស្សអាចកំណត់នូវដំណោះស្រាយដែលអាចធ្វើបាន ហើយជ្រើសរើសយកមួយដែលត្រឹមត្រូវ ដែលគាត់គិតថាអាចដោះស្រាយវាបាន។ សួរគាត់ថា “ ប្រសិនបើខ្ញុំធ្វើបែបនេះ តើនឹងមានអ្វីកើតឡើង? តើមានដំណោះស្រាយណាជំនួសទេ? តើអ្វីខ្លះជាមូលហេតុពិតរបស់វា?” | |
| 5 | (ការច្នៃប្រឌិត) សិស្សអាចលើកសំណើ និងបង្ហាញគំនិត ឬអារម្មណ៍របស់ពួកគេដោយប្រើឧបករណ៍ផ្សេងៗដូចជាគំនូរ ឬរឿងខ្លី។ | |
| **សមត្ថភាព៤.៧ .ការអភិវឌ្ឍបុគ្គល គ្រួសារ និងសង្គម** | | |
| 6 | (ការគ្រប់គ្រងខ្លួនឯង និងការយល់ចិត្ត) សិស្សអាចដាក់ស្លាកអារម្មណ៍របស់ពួកគេហើយអាចសម្រួលអាកប្បកិរិយាដោយផ្អែកតាមអារម្មណ៍អ្នកដទៃ។ | |
| 7 | (ការធ្វើសេចក្តីសម្រេចចិត្ត) សិស្សប្រមូលព័ត៌មានជាច្រើន ឬពិគ្រោះជាមួយអ្នកជំនាញមុនពេលធ្វើការសម្រេចចិត្ត។ | |
| 8 | (ភាពធន់) សិស្សសុំជំនួយនៅពេលគាត់ត្រូវការ។ | |
| 9 | (ការគោរពភាពចម្រុះ) សិស្សធ្វើការយ៉ាងងាយស្រួលជាមួយមិត្តភក្តិទាំងអស់នៅក្នុងថ្នាក់។ | |
| **ចរិយាសម្បទា និងគុណតម្លៃផ្ទាល់ខ្លួន** | | |
| 10 | សិស្សមានភាពស្មោះត្រង់ និងទទួលខុសត្រូវចំពោះអ្វីដែលខ្លួនកំពុងធ្វើ។ សិស្សលើកកម្ពស់និងការពារការគោរពគ្នាទៅវិញទៅមក និងឱ្យតម្លៃទៅលើការអប់រំសម្រាប់ការរីកចម្រើនផ្ទាល់ខ្លួន និងអនាគតរបស់គេ។ | |

## ៧.២.២. លំនៃណនាំការសង្កេត

<table>
<tr><td colspan="3">សំណួរដើម្បីជួយគ្រូពេលសង្កេតប្រចាំសប្ដាហ៍<br>ប្រសិនបើអ្នកឆ្លើយថា បាទ ឬ ចាស វាមានន័យថាសិស្សកំពុងចាប់ផ្ដើមអនុវត្តបំណិនយ៉ាងត្រឹមត្រូវ ក្រោមការណែនាំរបស់អ្នក ខណៈពេលដែលអ្នកឆ្លើយថា ទេ អ្នកប្រហែលជាត្រូវសង្កេតបន្ថែមទៀត និងស្វែងយល់ពីបញ្ហាដើម្បីជួយសិស្សឱ្យសម្រេចបាន។ ឧទាហរណ៍៖សំណើដែលបានស្នើគឺផ្អែកលើលក្ខណវិនិច្ឆ័យនៃរង្វាយតម្លៃការប្រតិបត្តិនៅអនុវិទ្យាល័យ។</td></tr>
<tr><td>1</td><td>( ការប្រាស្រ័យទាក់ទង )<br>សិស្សបង្ហាញពីគំនិត និងយោបល់ដោយប្រើបច្ចេកទេសទំនាក់ទំនងជាច្រើនរួមទាំងបច្ចេកវិទ្យាព័ត៌មានវិទ្យា ( ICT ) នៅពេលមាន។</td><td>ការទំនាក់ទំនងពាក្យសម្ដី<br>• តើសិស្សសួរសំណួរឬទេ ? តើអ្នកយល់ពីអ្វីដែលសិស្សកំពុងសួរទេ ? តើសិស្សផ្សេងទៀតយល់ទេ ?<br>• តើសិស្សស្ដាប់អ្នក និងមិត្តភក្តិ មុនពេលឆ្លើយទេ ?<br>• តើសិស្សអាចប្រាប់ពីគំនិតរបស់ខ្លួនដោយងាយ និងច្បាស់ឬទេ ?<br>ការប្រាស្រ័យទាក់ទងដោយកាយវិការ<br>• នៅពេលដែលអ្នកសង្កេតឃើញសិស្សប្រាស្រ័យទាក់ទងជាមួយអ្នក ឬមនុស្សផ្សេងទៀត តើអ្នកអាចដឹងថាគាត់៖ ញញឹម មានចលនារាងកាយដើម្បីពង្រឹងសារ ការប្រើក្រសែភ្នែកក្នុងទំនាក់ទំនង ការធ្វើចលនា ការលើកដាក់សំឡេង ការប្រើកាយវិការឬទេ ?<br>ការទំនាក់ទំនងជាលាយលក្ខណ៍អក្សរ<br>• តើសិស្សប្រើបច្ចេកវិទ្យាដើម្បីធ្វើបទបង្ហាញឬទេ ? វីដេអូ អូឌីយ៉ូ ។ ល។</td></tr>
<tr><td>2</td><td>( ការចរចា ) នៅពេលប្រឈមនឹងជម្លោះសាមញ្ញជាមួយក្រុមសិស្សសួរសំណួរដើម្បីយល់ពីទស្សនៈរបស់អ្នកដទៃមុនពេលរកដំណោះស្រាយដើម្បីទទួលយកបានទាំងសងខាង។</td><td>• តើសិស្សអាចជ្រើសរើសដំណោះស្រាយណាដែលល្អសម្រាប់ក្រុមទាំងអស់ ហើយមិនត្រឹមតែសម្រាប់គាត់ប៉ុណ្ណោះទេ ? នៅពេលមានជម្លោះនៅក្នុងថ្នាក់ តើសិស្សជួយក្នុងការស្វែងរកដំណោះស្រាយទេ ?<br>• តើសិស្សទទួលយកការផ្ដល់យោបល់ពីអ្នកដទៃទៀតឬទេ ? តើគាត់សម្របតវិយាបថ និងធ្វើការសម្រេចចិត្តផ្អែកលើមតិឆ្លើយតបដែលបានទទួលឬអត់ ?<br>• តើគាត់បង្ហាញការចាប់អារម្មណ៍ទៅលើអ្វីដែលមិត្តភក្តិផ្សេងទៀតចង់បាននៅពេលពួកគេពិភាក្សាជាក្រុមនៅក្នុងថ្នាក់រៀនឬទេ ? តើអ្នកបានសង្កេតឃើញសិស្សសួរអ្នកដទៃនូវអ្វីដែលពួកគេត្រូវការឬទេ ?</td></tr>
</table>

| | | |
|---|---|---|
| 3 | (**កិច្ចសហប្រតិបត្តិការ និងការចូលរួម**) សិស្សមានអារម្មណ៍សុខស្រួលក្នុងក្រុម និងចូលរួមសកម្មភាពក្នុងក្រុម។ | • តើសិស្សសប្បាយចិត្តនឹងអ្វីដែលពួកគេធ្វើនៅក្នុងក្រុមដែរឬទេ? <br> • តើអ្នកអាចសង្កេតឃើញសិស្សកំពុងជួយមិត្តភក្តិម្នាក់ទៀតនៅក្នុងសកម្មភាពណាមួយនៅក្នុង និងក្រៅថ្នាក់រៀនឬទេ? ឧទាហរណ៍៖ជួយក្នុងការសរសេរឯកសារ ដើម្បីស្វែងយល់អំពីសកម្មភាព ឯកសារផ្សេងៗ ការណែនាំផ្សេងៗ។ល។ <br> • តើអ្នកអាចសង្កេតឃើញសិស្សចែករំលែកគំនិតរបស់គាត់ជាមួយអ្នកដទៃ ដើម្បីឱ្យមានសកម្មភាពនៅក្នុងក្រុម(មិនដាច់ឆ្ងាយពីក្រុមផ្សេងទៀតទេ)ឬទេ? <br> • ជាធម្មតាតើសិស្សជួយគ្នានៅពេលមានបញ្ហាក្នុងក្រុមដែរឬទេ? តើគាត់នៅដាច់ដោយឡែកឬជាផ្នែកនៃដំណោះស្រាយ? |
| 4 | (**ការដោះស្រាយបញ្ហា និងការត្រិះរិះពិចារណា**) សិស្សអាចកំណត់នូវដំណោះស្រាយដែលអាចធ្វើបានហើយជ្រើសរើសយកមួយដែលត្រឹមត្រូវដែលគាត់គិតថាអាចដោះស្រាយវាបាន ។សួរគាត់ថា “ប្រសិនបើខ្ញុំធ្វើបែបនេះ តើនឹងមានអ្វីកើតឡើង? តើមានដំណោះស្រាយណាជំនួសទេ? តើអ្វីខ្លះជាមូលហេតុពិតរបស់វា? | • តើសិស្សយល់ពីរបៀបប្រើដើមឈើបញ្ហា ឬឧបករណ៍ផ្សេងទៀតដែរឬទេ? តើគាត់មានទំនុកចិត្តទេពេលប្រើវា? <br> • តើសិស្សអាចស្នើសុំជម្រើសផ្សេងទៀតឬទេ? <br> • តើសិស្សសួរសំណួរ ឬស្វែងរកព័ត៌មានដែលអាចជួយឱ្យគាត់យល់បានឬទេ? <br> • តើអ្នកធ្លាប់សង្កេតឃើញសិស្សប្រើព្យុះគំនិត ផែនទីគំនិត ឬឧបករណ៍ផ្សេងទៀតដែលអ្នកពន្យល់ និងប្រើក្នុងថ្នាក់ទេ? <br> • តើសិស្សធ្វើសម្មតិកម្មអំពីអ្វីដែលអាចនឹងកើតឡើង ឬនឹងកើតឡើងនាពេលអនាគតអំពីបញ្ហាឬទេ? <br> • តើសិស្សអាចទាក់ទងនឹងព្រឹត្តិការណ៍នានា ហើយដឹងថាអ្វីកើតឡើងមុន ឬអ្វីកើតឡើងបន្ទាប់បានឬទេ? <br> • តើសិស្សអាចបែងចែកការពិតចេញពីគំនិតយោបល់បានឬទេ? |
| 5 | (**ភាពច្នៃប្រឌិត**) សិស្សអាចលើកសំណើ និងបង្ហាញគំនិតរបស់ពួកគេដោយប្រើឧបករណ៍ផ្សេងៗដូចជាគំនូរ ឬរឿងខ្លី។ | • នៅពេលដែលអ្នកធ្វើសកម្មភាពព្យុះគំនិត តើសិស្សចូលរួមផ្តល់គំនិតដែរឬទេ? <br> • នៅពេលសិស្សគូរ ឬសរសេរអត្ថបទ តើអ្នកឃើញអ្វីថ្មីទេ?តើគាត់ធ្វើឱ្យអ្នកភ្ញាក់ផ្អើលជាមួយនឹងខ្លឹមសារ ឬវិធីដែលធ្វើដែរឬទេ? |

| | | |
|---|---|---|
| 6 | (**ការគ្រប់គ្រងខ្លួនឯង និងការយល់ចិត្ត**) សិស្សអាចដាក់ស្លាកអារម្មណ៍របស់ពួកគេ ហើយឆ្លើយតបនៅពេលដែលមិត្តភក្តិដទៃទៀតមានអារម្មណ៍មិនល្អ។ | • តើសិស្សទៅនិយាយជាមួយមិត្តភក្តិថាអ្នកមិនអីទេ នៅពេលដែលគាត់ឃើញមិត្តភក្តិដែលមើលទៅដូចជាមានទុក្ខព្រួយឬទេ ? <br>• គាត់រួសរាយជាមួយសិស្សដទៃទៀត នៅពេលមើលទៅពួកគេហាក់ដូចជាមិនសប្បាយចិត្ត ឬក៏គាត់នៅតែមានឥរិយាបថដដែល ? <br>• តើគាត់ទៅជួយមិត្តភក្តិដែលមានបញ្ហាទេ ? |
| 7 | (**ការធ្វើសេចក្តីសម្រេចចិត្ត**) សិស្សប្រមូលព័ត៌មានជាច្រើន ឬពិគ្រោះជាមួយអ្នកជំនាញមុនពេលធ្វើការសម្រេចចិត្ត។ | • តើសិស្សមើលព័ត៌មានដែលគាត់មានមុនពេលសម្រេចចិត្តដែរទេ ? <br>• តើសិស្សអាចពន្យល់ហេតុអ្វីគាត់បានធ្វើការសម្រេចចិត្តឬទេ ? <br>• តើសិស្សស្នើសុំការបំភ្លឺពីអ្នក មុនពេលសម្រេចចិត្តលើប្រធានបទដែលអ្នកអាចជួយបានឬទេ ? |
| 8 | (**ភាពធន់**) សិស្សសុំជំនួយនៅពេលគាត់ត្រូវការ។សិស្សសុំជំនួយនៅពេលគាត់ត្រូវការ។ | • តើសិស្សសុំមិត្តភក្តិឱ្យជួយទេ ? ទៅអ្នក ? ទៅគ្រូផ្សេងទៀតឬទេ ? <br>• តើសិស្សមានទំនោរប្រតិកម្មជាវិជ្ជមាននៅចំពោះមុខឧបសគ្គថ្មីៗដែរឬទេ ? <br>• តើសិស្សព្យាយាមតស៊ូបំពេញភារកិច្ចរបស់ខ្លួនដែរឬទេ ? |
| 9 | (**ការគោរពភាពចម្រុះ**) សិស្សធ្វើការយ៉ាងងាយស្រួលជាមួយមិត្តភក្តិទាំងអស់នៅក្នុងថ្នាក់។ | • តើសិស្សរីករាយនឹងធ្វើការជាមួយមិត្តរួមថ្នាក់ទាំងអស់ទេ ? <br>• តើគាត់ជួយសិស្សដែលមានសមត្ថភាពខុសគ្នាដែរឬទេ ? <br>• តើគាត់មានមតិយោបល់ ឬសកម្មភាពប្រឆាំងនឹងមិត្តភក្តិផ្សេងទៀត ដោយផ្អែកលើភេទ ឬសាវតា ភាពខុសគ្នានៃសេដ្ឋកិច្ចសង្គម ឬពិការភាពផ្សេងៗដែរឬទេ ? |
| 19 | សិស្សមានភាពស្មោះត្រង់និងទទួលខុសត្រូវចំពោះអ្វីដែលខ្លួនកំពុងធ្វើ។ សិស្សលើកកម្ពស់និងការពារការគោរពគ្នា និងផ្តល់តម្លៃដល់ការអប់រំសម្រាប់ការរីកចម្រើនផ្ទាល់ខ្លួន និងអនាគត។ | • តើគាត់ទទួលខុសត្រូវចំពោះសកម្មភាពផ្ទាល់ខ្លួនរបស់គាត់ទេ ? <br>• តើមិត្តភក្តិដទៃទៀតទុកចិត្តសិស្សដែរឬទេ ? <br>• តើគាត់បង្ហាញការគោរពចំពោះអ្នកដទៃឬទេ ? <br>• តើគាត់មានវិធីវិជ្ជមានក្នុងការប្រឈមមុខនឹងបញ្ហា និងឧបសគ្គដែរឬទេ ? |

## ៧.៣. កំណត់សម្គាល់ការសង្កេតរបស់គ្រូ

| ឈ្មោះសិស្ស៖ ......... ម៉ន ដារ៉ា.........ថ្នាក់ទី៖.........៧គ.........សាលារៀន៖ .........អនុវិទ្យាល័យរំដួល......... ស្រុក៖ .........ឈ្យូក.........ឆមាស៖ .........ទី១......... | | |
|---|---|---|
| **សមត្ថភាព៤.៤.ការប្រាស្រ័យទាក់ទង និងការងារជាក្រុម** | | **កំណត់សម្គាល់** |
| 1 | (**ការប្រាស្រ័យទាក់ទង**) សិស្សបង្ហាញពីគំនិត និងយោបល់ដោយប្រើបច្ចេកទេសទំនាក់ទំនងជាច្រើនរួមទាំងបច្ចេកវិទ្យាព័ត៌មាន(ICT) នៅពេលមាន។ | សប្តាហ៍ទី១៖ ដារ៉ាពន្យល់យ៉ាងច្បាស់នូវទស្សនៈរបស់គាត់អំពីការធ្វើចំណាកស្រុកនៅក្នុងសហគមន៍របស់គាត់។ |
| 2 | (ការចរចា) នៅពេលប្រឈមនឹងជម្លោះសាមញ្ញជាមួយក្រុមសិស្ស សួរសំណួរដើម្បីយល់ពីទស្សនៈរបស់អ្នកដទៃមុនពេលរកដំណោះស្រាយដើម្បីទទួលយកបានទាំងសងខាង។ | សប្តាហ៍ទី៣៖ គាត់បានការពារគំនិតរបស់គាត់នៅចំពោះមុខមិត្តភក្តិរបស់គាត់។ |
| 3 | (**កិច្ចសហប្រតិបត្តិការ និងការចូលរួម**) សិស្សមានអារម្មណ៍សុខស្រួលក្នុងក្រុម និងចូលរួមសកម្មភាពក្នុងក្រុម។ | សប្តាហ៍ទី១៤៖ ដារ៉ាជួយក្រុមក្នុងកិច្ចការដែលគ្រូបានដាក់ឱ្យ។ |
| **សមត្ថភាព៤.៥. ការពិចារណា និងការបង្កើតថ្មី** | | |
| 4 | (**ការដោះស្រាយបញ្ហា និងការត្រិះរិះពិចារណា**) សិស្សអាចកំណត់នូវដំណោះស្រាយដែលអាចធ្វើបាន ហើយជ្រើសរើសយកមួយដែលត្រឹមត្រូវ ដែលគាត់គិតថាអាចដោះស្រាយវា បាន។ សួរគាត់ថា ៖ “ប្រសិនបើខ្ញុំធ្វើបែបនេះ តើនឹងមានអ្វីកើតឡើង? តើមានដំណោះស្រាយណាជំនួសទេ? តើអ្វីខ្លះជាមូលហេតុពិតរបស់វា? | សប្តាហ៍ទី៤៖ ដារ៉ាថ្ងៃនេះបានរកឃើញដំណោះស្រាយចំពោះបញ្ហាដែលយើងនិយាយនៅក្នុងថ្នាក់។ |
| 5 | (**ភាពច្នៃប្រឌិត**) សិស្សអាចលើកសំណើ និងបង្ហាញគំនិតរបស់ពួកគេដោយប្រើឧបករណ៍ផ្សេងៗដូចជាគំនូរ ឬរឿងខ្លី។ | សប្តាហ៍ទី១៣៖ ដារ៉ាថ្ងៃនេះបានគូររូបដើម្បីពន្យល់ថាតើបង្គន់ស្អាតគួរមានលក្ខណៈដូចម្តេច? |
| **សមត្ថភាព៤.៧៖ ការអភិវឌ្ឍបុគ្គល គ្រួសារ និងសង្គម** | | |
| 6 | (**ការគ្រប់គ្រងខ្លួនឯង និងការយល់ចិត្ត**) សិស្សអាចដាក់ស្លាកអារម្មណ៍របស់ពួកគេហើយឆ្លើយតបនៅពេលដែលមិត្តភក្តិដទៃទៀតមានអារម្មណ៍មិនល្អ។ | សប្តាហ៍ទី៣៖ ថ្ងៃនេះដារ៉ាពន្យល់ដល់មិត្តភក្តិព្រោះគាត់ពិបាកចិត្ត។ |

| | | |
|---|---|---|
| 7 | (**ការធ្វើសេចក្ដីសម្រេចចិត្ត**) សិស្សប្រមូលព័ត៌មានជាច្រើន ឬពិគ្រោះជាមួយអ្នកជំនាញមុនពេលធ្វើការសម្រេចចិត្ត។ | ថ្ងៃនេះដារ៉ាបានមកសុំខ្ញុំឱ្យផ្ដល់ព័ត៌មានបន្ថែមទៀតដល់គាត់ដើម្បីដោះស្រាយភារកិច្ច។ |
| 8 | (**ភាពធន់**) សិស្សសុំជំនួយនៅពេលគាត់ត្រូវការ។ | សប្ដាហ៍ទី១៖ ដារ៉ាថ្ងៃនេះបានស្នើសុំឱ្យសុភ័ក្រជួយគាត់ក្នុងការងាររបស់គាត់។ |
| 9 | (**ការគោរពភាពចម្រុះ**) សិស្សធ្វើការយ៉ាងងាយស្រួលជាមួយមិត្តភក្ដិទាំងអស់នៅក្នុងថ្នាក់។ | សប្ដាហ៍ទី៣៖ ដារ៉ាបានផ្លាស់ប្ដូរក្រុម ហើយគាត់ក៏បានធ្វើការល្អជាមួយពួកគេផងដែរ។ |
| **ចរិយាសម្បទា និងគុណតម្លៃផ្ទាល់ខ្លួន** | | |
| 10 | សិស្សមានភាពស្មោះត្រង់ និងទទួលខុសត្រូវចំពោះអ្វីដែលខ្លួនកំពុងធ្វើ។ សិស្សលើកកម្ពស់ និងការពារការគោរពគ្នា និងផ្ដល់តម្លៃដល់ការអប់រំសម្រាប់ការរីកចម្រើនផ្ទាល់ខ្លួន និងអនាគត។ | ដារ៉ាថ្ងៃនេះបាននិយាយថាគាត់ពិតជាគិតថាការសិក្សាមានសារៈសំខាន់ណាស់ដើម្បីសម្រេចគោលដៅអនាគតរបស់គាត់។ |

## ៧.៤. ស្វ័យវាយតម្លៃរបស់សិស្សនៅអនុវិទ្យាល័យ

| **បំណិនទន់** | | 0 | 1 | 2 | 3 | **សម្គាល់៖ (សម្រាប់សិស្សបំពេញ)** |
|---|---|---|---|---|---|---|
| 1 | (**ការប្រាស្រ័យទាក់ទង**) ខ្ញុំមានអារម្មណ៍ស្រួលក្នុងការសួរសំណួរ និងបង្ហាញពីគំនិតរបស់ខ្ញុំ។ ខ្ញុំចូលចិត្តធ្វើបទបង្ហាញ វីដេអូ អូឌីយ៉ូ ដើម្បីបង្ហាញគំនិតរបស់ខ្ញុំ។ | | | | | |
| 2 | (**ការចរចា**) ខ្ញុំព្យាយាមរកដំណោះស្រាយល្អសម្រាប់ទាំងអស់គ្នាពេលខ្ញុំធ្វើការជាមួយមិត្តភក្ដិធ្វើអ្វីមួយជាមួយគ្នា។ | | | | | |
| 3 | (**កិច្ចសហប្រតិបត្តិការ និងការចូលរួម**) ខ្ញុំចូលចិត្តធ្វើការជាមួយមិត្តរួមថ្នាក់របស់ខ្ញុំ និងជួយក្នុងក្រុម។ | | | | | |
| 4 | (**ការដោះស្រាយបញ្ហា**) ខ្ញុំជឿជាក់ថាមានដំណោះស្រាយបញ្ហាជាច្រើនដែលអាចកើតមាន ហើយខ្ញុំតែងតែសួរខ្លួនឯងថា “ ប្រសិនបើខ្ញុំធ្វើបែបនេះតើនឹងមានអ្វីកើតឡើង ? តើមានដំណោះស្រាយផ្សេងទៀតទេ ? តើអ្វីខ្លះជាមូលហេតុពិតរបស់វា?” | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| 5 | (**ការច្នៃប្រឌិត**) ខ្ញុំចូលចិត្តច្នៃប្រឌិតនៅពេលខ្ញុំបង្ហាញគំនិតរបស់ខ្ញុំ(ប្រើគំនូរ ចម្រៀង វីដេអូ ។ល។)។ | | | | | |
| 6 | (**ការគ្រប់គ្រងខ្លួនឯង និងការយល់ចិត្ត**) អារម្មណ៍របស់ខ្ញុំ និងអារម្មណ៍អ្នកផ្សេងទៀតគឺសំខាន់សម្រាប់ខ្ញុំ ហើយខ្ញុំពិចារណាពីពួកគេមុនពេលនិយាយ។ | | | | | |
| 7 | (**ការសម្រេចចិត្ត**)ខ្ញុំតែងតែប្រមូលព័ត៌មានជាច្រើន ឬពិគ្រោះជាមួយអ្នកជំនាញមុនពេលធ្វើការសម្រេចចិត្ត។ | | | | | |
| 8 | (**ភាពធន់**) ខ្ញុំសុំជំនួយនៅពេលខ្ញុំត្រូវការ។ | | | | | |
| 9 | (**ការគោរពលក្ខណៈចម្រុះ**) ខ្ញុំគោរពមិត្តភក្តិរបស់ខ្ញុំទាំងអស់ ខ្ញុំនិយាយដោយទន់ភ្លន់ ស្តាប់ និងយកចិត្តទុកដាក់ពួកគេ។ | | | | | |
| **ចរិយាសម្បទា និងគុណតម្លៃផ្ទាល់ខ្លួន** | | | | | | |
| 10 | ខ្ញុំស្មោះត្រង់ ហើយខ្ញុំទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្ញុំ។ ខ្ញុំគោរពអ្នករាល់គ្នា ហើយខ្ញុំគិតថាការអប់រំមានសារៈសំខាន់សម្រាប់អនាគតរបស់ខ្ញុំ។ | | | | | |
| សរុប | | | | | | |
| | | ............................ | | | | |
| 0=មិនដែលសោះ, 1 = ម្តងម្កាល 2 = ភាគច្រើន 3 = ជានិច្ច | | | | | | |

## ៧.៤.១. ស្វ័យវាយតម្លៃសិស្សនៅកម្រិតបឋមសិក្សា

លំណែនាំ ៖ រៀបចំផ្ទាំងកាតុង(ផូស្ទ័រ) ឬថតចម្លងសន្លឹកស្វ័យវាយតម្លៃរបស់សិស្ស (ឬអ្នកក៏អាចឱ្យសិស្សចម្លងសំណួរដាក់ក្នុងសៀវភៅរបស់ពួកគេជំនួសក៏បាន) ដោយមានប្រយោគដែលអ្នកចាត់ទុកថាសមស្របដោយផ្អែកលើតម្រូវការរបស់សិស្ស និងផែនការបង្រៀនរបស់អ្នក។ អ្នកអាចប្រើទម្រង់ស្តង់ដា ឬបញ្ចូលប្រយោគផ្សេងទៀតដែលអ្នកគិតថាសំខាន់។ (ក្នុងតារាងខាងក្រោមយើងមានឧទាហរណ៍បន្ថែមដែលអ្នកអាចប្រើបាន) ។ អានប្រយោគទៅកាន់សិស្ស ហើយត្រូវប្រាកដថាពួកគេយល់ច្បាស់។ រៀងរាល់សប្តាហ៍ សូមប្រើវាសម្រាប់ការឆ្លុះបញ្ចាំង នៅចុងបញ្ចប់នៃមេរៀន។

| ស្វ័យវាយតម្លៃប្រចាំសប្តាហ៍ | |
|---|---|
| ខ្ញុំតែងតែស្តាប់ | ☺ 😐 ☹ |
| ខ្ញុំធ្វើការធ្ងន់បំផុត | ☺ 😐 ☹ |
| ការងាររបស់ខ្ញុំត្រូវបានធ្វើយ៉ាងល្អ | ☺ 😐 ☹ |
| ខ្ញុំគោរពខ្លួនឯង និងអ្នកដទៃ | ☺ 😐 ☹ |
| ខ្ញុំសុំជំនួយនៅពេលដែលខ្ញុំមិនដឹងថាត្រូវធ្វើដូចម្តេច | ☺ 😐 ☹ |
| ខ្ញុំចូលរួមក្នុងការពិភាក្សា | ☺ 😐 ☹ |

ប្រយោគដែលអាចធ្វើបានផ្សេងទៀតដែលគ្រូអាចប្រើដើម្បីផ្លាស់ប្តូរផ្ទាំងកាតុង(ផូស្ទ័រ)នៅឆ្នាំក្រោយ (ផ្អែកលើឧបករណ៍វាយតម្លៃការប្រតិបត្តិសម្រាប់បឋមសិក្សា)៖

| បំណិនទន់ | ប្រយោគ | បំណិនទន់ | ប្រយោគ |
|---|---|---|---|
| ការប្រាស្រ័យទាក់ទង | • ខ្ញុំសួរសំណួរអំពីប្រធានបទដែលខ្ញុំចាប់អារម្មណ៍។<br>• ខ្ញុំមើលទៅមិត្តភក្តិ និងគ្រូនៅពេលខ្ញុំនិយាយ។ | ស្វ័យគ្រប់គ្រង និងសមានចិត្ត | • ខ្ញុំចំណាយពេល និងធ្វើឱ្យអស់ពីសមត្ថភាព។<br>• ខ្ញុំបញ្ចប់ការងាររបស់ខ្ញុំទាន់ពេល។<br>• ខ្ញុំដឹងថាខ្ញុំជានរណា ហើយមានអ្វីពិសេសពីខ្ញុំ។<br>• ខ្ញុំធ្វើតាមការណែនាំរបស់គ្រូ។<br>• ខ្ញុំដឹងថាពេលណាមិត្តរួមថ្នាក់ពិបាកចិត្ត ខ្ញុំព្យាយាមជួយ។ |
| ការចរចា | • ខ្ញុំព្យាយាមសម្រេចចិត្តដែលធ្វើឱ្យខ្ញុំ និងអ្នកដទៃទៀតសប្បាយចិត្ត។ | ការធ្វើសេចក្តីសម្រេចចិត្ត | • ខ្ញុំស្វែងរកព័ត៌មានមុនពេលធ្វើការសម្រេចចិត្ត។ |

| | | | |
|---|---|---|---|
| កិច្ចសហប្រតិបត្តិការ និងការចូលរួម | • ខ្ញុំចូលចិត្តធ្វើការជាមួយអ្នកដទៃ។ | ភាពធន់ | • ខ្ញុំមានភាពវិជ្ជមាននៅពេលដែលខ្ញុំប្រឈមមុខនឹងការប្រកួតប្រជែង។<br>• ខ្ញុំមានអារម្មណ៍ជឿជាក់ ហើយខ្ញុំមិនខ្លាចទេនៅពេលដែលស្ថានភាពផ្លាស់ប្តូរ (ឧទា. នៅពេលខ្ញុំផ្លាស់ប្តូរ កម្រិតថ្នាក់ មិត្តរួមថ្នាក់ ភារកិច្ច... ។ |
| ការដោះស្រាយបញ្ហា និងការត្រិះរិះពិចារណា | • ខ្ញុំចែករំលែកគំនិត។<br>• ខ្ញុំរកវិធីខុសគ្នាក្នុងការធ្វើអ្វីផ្សេងៗ។ | ការគោរពលក្ខណៈចម្រុះ | • ខ្ញុំមានចិត្តល្អចំពោះអ្នកដទៃ។<br>• ខ្ញុំចង់ដឹងអំពីវប្បធម៌ផ្សេងទៀត។<br>• ខ្ញុំគោរព និងពេញចិត្តចំពោះមិត្តភក្តិទាំងអស់។ |
| ការច្នៃប្រឌិត | • ខ្ញុំព្យាយាមរកគំនិតថ្មីនៅពេលដែលអ្វីមួយមិនដំណើរការ។ | គុណតម្លៃ | • ខ្ញុំតែងតែជាមិត្តល្អជាមួយសិស្សដទៃទៀត។<br>• ខ្ញុំទទួលខុសត្រូវ ហើយគ្រូនិងមិត្តរួមថ្នាក់របស់ខ្ញុំអាចពឹងផ្អែកលើខ្ញុំ។ |

## ៧.៥. ទម្រង់រួម ការវាយតម្លៃផ្អែកលើថ្នាក់រៀន

ថ្នាក់ទី.................. សាលា .................. ស្រុក ..................... ឆមាស ...........................

| ទម្រង់រួមក្នុង១ឆ្នាំសិក្សា | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ល.រ | ឈ្មោះសិស្ស | 1 | 2 | 3 | 4 | ពិន្ទុមធ្យម (តេស្តវិជ្ជាសម្បទា) | បញ្ចប់ឆមាសទី១ | | | 5 | 6 | 7 | 8 | ពិន្ទុមធ្យម (តេស្តវិជ្ជាសម្បទា) | បញ្ចប់ឆមាសទី២ | | |
| | | តេស្តវិជ្ជាសម្បទាប្រចាំខែ | | | | | តេស្តវិជ្ជាសម្បទាឆមាស | តេស្តប្រតិបត្តិ | ពិន្ទុសរុប (E) | តេស្តវិជ្ជាសម្បទាប្រចាំខែ | | | | | តេស្តវិជ្ជាសម្បទាឆមាស | តេស្តប្រតិបត្តិ | ពិន្ទុសរុប (E1) |
| | | | | | | A | B | D | C6+D= E | | | | | A1 | B1 | D 1 | C17+D1= E1 |
| 1 | | | | | | | | | | | | | | | | | |
| 2 | | | | | | | | | | | | | | | | | |
| 3 | | | | | | | | | | | | | | | | | |
| 4 | | | | | | | | | | | | | | | | | |
| 5 | | | | | | | | | | | | | | | | | |
| 6 | | | | | | | | | | | | | | | | | |
| 7 | | | | | | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 8 | | | | | | | | | | | | | | | | | |
| 9 | | | | | | | | | | | | | | | | | |
| 10 | | | | | | | | | | | | | | | | | |
| 11 | | | | | | | | | | | | | | | | | |
| 12 | | | | | | | | | | | | | | | | | |
| 13 | | | | | | | | | | | | | | | | | |
| 14 | | | | | | | | | | | | | | | | | |
| 15 | | | | | | | | | | | | | | | | | |
| 16 | | | | | | | | | | | | | | | | | |
| 17 | | | | | | | | | | | | | | | | | |
| 18 | | | | | | | | | | | | | | | | | |
| 19 | | | | | | | | | | | | | | | | | |
| 20 | | | | | | | | | | | | | | | | | |
| 21 | | | | | | | | | | | | | | | | | |
| 22 | | | | | | | | | | | | | | | | | |
| 23 | | | | | | | | | | | | | | | | | |
| 24 | | | | | | | | | | | | | | | | | |
| 25 | | | | | | | | | | | | | | | | | |

[6]C ពិន្ទុតេស្តឆមាសទី១ = ( A + B )/2, ប៉ុន្តែ C ≤ 40% នៃពិន្ទុឆមាស => C = (A + B)/2 x40/100 ≤ 4 សម្រាប់បឋមសិក្សា

= ( A + B )/2, ប៉ុន្តែ C ≤ 40% នៃពិន្ទុឆមាស => C = (A + B)/2 x40/100 ≤ 20 សម្រាប់អនុវិទ្យាល័យ

[7]C1 ពិន្ទុតេស្តឆមាសទី២ ដូចគ្នានឹងការកំណត់ពិន្ទុសម្រាប់តេសត្តឆមាសទី១ 5 C ដែរ។

ឧទាហរណ៍១.សាលាបឋមសិក្សា.ពិន្ទុអតិបរិមា១០

**ទម្រង់សរុបក្នុង១ឆមាស (បឋមសិក្សា)**

| លរ | ឈ្មោះសិស្ស | 1 | 2 | 3 | 4 | ពិន្ទុមធ្យម (តេស្តវិជ្ជាសម្បទា) | ចុងឆមាសទី១ | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | តេស្តវិជ្ជាសម្បទាប្រចាំខែ | | | | | តេស្តវិជ្ជាសម្បទាឆមាស | ពិន្ទុឆមាសវិជ្ជាសម្បទាសរុប | តេស្តប្រតិបត្តិ | ពិន្ទុសរុប(E) |
| | | | | | | A | B | C | D | C + D = E |
| ១ | ដារ៉ា មេត្តា | 6 | 7 | 7 | 5 | 6 | 8 | 2.8 | 6 | 9 |
| ២ | | | | | | | | | | |
| ៣ | | | | | | | | | | |
| ... | | | | | | | | | | |

របៀបគណនាពិន្ទុសរុបក្នុងឆមាសទី១

A = (6+7+7+5) = 25/4 = 6,25 ប្រហែល 6

B = 8

C = (6+8)/2x40/100 = 2.8

D = 6

E = 2.8+6 = 8.8 ប្រហែល 9

ឧទាហរណ៍២.សាលាអនុវិទ្យាល័យ.ពិន្ទុអតិបរិមា៥០

**ទម្រង់សរុបក្នុង១ឆមាស (បឋមសិក្សា)**

| លរ | ឈ្មោះសិស្ស | 1 | 2 | 3 | 4 | ពិន្ទុមធ្យម (តេស្តវិជ្ជាសម្បទា) | ចុងឆមាសទី១ | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | តេស្តវិជ្ជាសម្បទាប្រចាំខែ | | | | | តេស្តវិជ្ជាសម្បទាឆមាស | ពិន្ទុឆមាសវិជ្ជាសម្បទាសរុប | តេស្តប្រតិបត្តិ | ពិន្ទុសរុប(E) |
| | | | | | | A | B | C | D | C + D = E |
| ១ | សុភាព ដារី | 20 | 30 | 30 | 40 | 30 | 40 | 14 | 26 | 40 |
| ២ | | | | | | | | | | |
| ៣ | | | | | | | | | | |
| ... | | | | | | | | | | |

របៀបគណនាពិន្ទុសរុបក្នុងឆមាសទី១

A = (20+30+30+40) = 120/4 = 30

B = 40

C = (30+40)/2x40/100 = 14

D = 26

E = 14+26 = 40

# ៧.៦. ឧបករណ៍វាយតម្លៃក្រៅផ្លូវការផ្សេងៗទៀត

## ក.ការវាយតម្លៃលើឥរិយាបថរបស់សមាជិកក្រុម

សិស្សគូសរង្វង់រូបមុខមនុស្ស ដែលតំណាងឱ្យអារម្មណ៍របស់គេពីសមាជិកនៅក្នុងក្រុមដែលគេធ្វើការជាមួយ។

ខ្ញុំលើកទឹកចិត្តសមាជិកដទៃទៀតនៅក្នុងក្រុម។ ☺ ☹

..........................................................................................................

ខ្ញុំផ្ដល់គំនិត និងព័ត៌មានទៅឱ្យសមាជិកផ្សេងទៀត។ ☺ ☹

..........................................................................................................

សមាជិកផ្សេងទៀតនៅក្នុងក្រុមរបស់ខ្ញុំបានលើកទឹកចិត្តខ្ញុំ។ ☺ ☹

..........................................................................................................

សមាជិកផ្សេងទៀតបានផ្ដល់គំនិត និងព័ត៌មានដល់ខ្ញុំ។ ☺ ☹

## ខ.រង្វាយតម្លៃការងារក្រុមពីចំណុចចូលចិត្ត

ការវាយតម្លៃពីចំណុចចូលចិត្ត និងចំណុចកែលម្អអ្វីដែលយើងចូលចិត្ត អ្វីដែលយើងចង់កែលម្អ៖

..........................................................................................................................................

..........................................................................................................................................

គំនិតសម្រាប់ពេលក្រោយនៅពេលដែលយើងធ្វើការក្នុងក្រុមសហការ៖

..........................................................................................................................................

..........................................................................................................................................

## គ.ការគិតរបស់ក្រុមខ្ញុំ

ការគិតអំពីក្រុមរបស់ខ្ញុំ

១.តើអ្នកបានធ្វើអ្វីខ្លះ នៅក្នុងក្រុម ដើម្បីធ្វើឱ្យក្រុមរបស់អ្នកមានដំណើរការល្អ?

..........................................................................................................................................

..........................................................................................................................................

២.តើអ្នកមើលឃើញអ្វីកើតឡើង ដែលបណ្ដាលឱ្យមានបញ្ហានៅក្នុងក្រុមរបស់អ្នក?

..........................................................................................................................................

..........................................................................................................................................

៣.តើក្រុមរបស់អ្នកអាចធ្វើអ្វីលើកក្រោយ ដើម្បីឱ្យការធ្វើការរបស់អ្នកបានល្អជាមួយគ្នា?

..........................................................................................................................................

..........................................................................................................................................

## ឃ.តារាងពិនិត្យតាមដានក្រុម

ចូរគូសរង្វង់ត្រង់ចម្លើយណាមួយដែលអ្នកពេញចិត្ត សូមបញ្ជាក់ថាអ្នកមិនអាចគូសយកចម្លើយលើសពីមួយបានឡើយ។ ឧទាហរណ៍៖

១.យើងបានផ្តល់ឱកាសឱ្យសមាជិកក្រុមបញ្ចេញយោបល់បានគ្រប់ៗគ្នា។

ជានិច្ចកាល　　　ម្តងម្កាល　　　មិនដែលសោះ

២.យើងបានត្រួតពិនិត្យដើម្បីប្រាកដថាយើងបានយល់ពីការណែនាំ។

ជានិច្ចកាល　　　ម្តងម្កាល　　　មិនដែលសោះ

៣.យើងបានចែករំលែកសម្ភារៈរបស់យើង និងប្តូរវេនគ្នាដើម្បីប្រើប្រាស់សម្ភារៈទាំងនោះ។

ជានិច្ចកាល　　　ម្តងម្កាល　　　មិនដែលសោះ

៤.យើងបានជួយគ្នាទៅវិញទៅមក។

ជានិច្ចកាល　　　ម្តងម្កាល　　　មិនដែលសោះ

៥.យើងបានលើកសរសើរគ្នាទៅវិញទៅមក។

ជានិច្ចកាល　　　ម្តងម្កាល　　　មិនដែលសោះ

៦.យើងបានស្តាប់ដោយគ្មានការរំខាន។

ជានិច្ចកាល　　　ម្តងម្កាល　　　មិនដែលសោះ

៧.យើងអាចធ្វើបានប្រសើរលើបំណិនសហប្រតិបត្តិការ។

ជានិច្ចកាល　　　ម្តងម្កាល　　　មិនដែលសោះ

# សកម្មភាពបង្រៀនតាម ៦ដំណាក់កាល

## ដំណាក់កាលទី១- ការស្វែងយល់ប្រធានបទ

### ១-គោលបំណង

គ្រូជួយសិស្សក្នុងការកំណត់អ្វីដែលពួកគេបានដឹង និងវិធីសាស្រ្តដើម្បីទទួលបានព័ត៌មានបន្ថែមលើប្រធានបទដែលពួកគេកំពុងអង្កេត។

### ២-បំណិនគោលដៅ ចរិយាសម្បទា និងគុណតម្លៃ

ការត្រិះរិះពិចារណា ការដោះស្រាយបញ្ហា ការប្រាស្រ័យទាក់ទង ការគ្រប់គ្រងខ្លួនឯង ការទទួលខុសត្រូវចំពោះខ្លួនឯង និងសហគមន៍។ ល។

### ៣-ល្បិចបង្រៀន ( សកម្មភាពដែលបានស្នើ )

#### សកម្មភាពទី១ - ការបំផុសគំនិត

បច្ចេកទេសនៃការបំផុសគំនិតគឺការឱ្យប្រមូលគំនិតជាច្រើនក្នុងរយៈពេលដ៏ខ្លី ហើយផ្តល់ឱ្យគ្រូនូវព័ត៌មានត្រឡប់ភ្លាមៗ អំពីចំនួនសិស្សដែលយល់ពីប្រធានបទ។

#### ក-វិធានក្នុងការបំផុសគំនិត

- គំនិតកាន់តែច្រើនកាន់តែប្រសើរ
- គ្មានការរិះគន់
- គ្មានគំនិតណាជាគំនិតមិនល្អ
- ជួយបង្កើតគំនិតគ្នាទៅវិញទៅមក
- បង្ហាញគំនិតទាំងអស់

#### ខ-វិធីប្រតិបត្តិដើម្បីអនុវត្តការបំផុសគំនិត៖

វិធីខាងក្រោមអ្នកអាចយកទៅធ្វើការបំផុសគំនិត៖

- គ្រូបង្រៀនសរសេរសំណួរសំខាន់ នៅលើក្តារខៀន។ ឧទាហរណ៍ "ហេតុអ្វីចាំបាច់ស្តាប់ ?" គ្រូបង្រៀនគូសវង់ជុំវិញពាក្យនេះ រួចគូសព្រួញមួយចំនួនពីវង់ ហើយសួរសិស្សថា តើពួកគេដឹងអំពីប្រធានបទនេះយ៉ាងដូចម្តេច ? គ្រូសរសេរចម្លើយសិស្សជុំវិញពាក្យនោះ។




*រូបភាព-ឧទាហរណ៍នៃផ្កាក្រោមព្យុះគំនិត*

- ឬបន្ទាប់ពីសរសេរសំណួររួច គ្រូទុកពេលវេលាឱ្យសិស្ស២-៣នាទី ដើម្បីកត់ចំណាំគំនិតរបស់គេ ជាបុគ្គល ឬជាដៃគូ។ បន្ទាប់មកគ្រូសរសេរគំនិតរបស់ពួកគេដាក់លើក្តារខៀន។
- សកម្មភាពបំផុសគំនិតអាចធ្វើនៅលើ ផូសស្ទ័រ ដែលអាចប្រើប្រាស់នៅមេរៀនបន្ទាប់ទៀត ដោយប្រើជាឯកសារយោង ឬសម្រាប់បន្ថែមគំនិតថ្មីៗនៅលើផូស្ទ័រនោះ។

ដើម្បីរៀបចំរាល់ព័ត៌មានដែលប្រមូលបានដោយប្រើព្យុះគំនិត គ្រូប្រើផ្ទាំងកាតុង(ផូស្ទ័រ)ថ្មី ដោយគូរតារាងដែលមានលក្ខណវិនិច្ឆ័យចាំបាច់ដូចខាងក្រោម។ នៅពេលដែលប្រើព្យុះគំនិតអំពីបញ្ហាមួយលក្ខណវិនិច្ឆ័យអាចបញ្ចូលពាក្យ៖ អ្វី នៅឯណា ហេតុអ្វី នៅពេលណា នរណា៖

| អ្វី | នៅឯណា | នៅពេលណា | ហេតុអ្វី | នរណា |
|---|---|---|---|---|
| | | | | |

សកម្មភាពនេះសិស្ស និងគ្រូអាចមើលឃើញព័ត៌មាននៅជួរឈរភ្លាមៗ (ជួរឈរណាមួយអាចទទេគ្មានព័ត៌មាន)។ ព័ត៌មាននេះនឹងប្រាប់សិស្សនូវអ្វីដែលពួកគេត្រូវការរកមើល។

## សកម្មភាពទី២-ការអញ្ជើញអ្នកជំនាញក្នុងមូលដ្ឋានមកធ្វើបទឧទ្ទេស

(សកម្មភាពនេះក៏អាចជាផ្នែកមួយនៃដំណាក់កាលទី២)

### ក-សេចក្តីផ្តើម

ការអញ្ជើញអ្នកមានបទពិសោធមកឧទ្ទេសអំពីប្រធានបទជាក់លាក់ ជួយសិស្សឱ្យទទួលបានព័ត៌មានគួរឱ្យចាប់អារម្មណ៍បន្ថែមទៀត។ ទន្ទឹមនឹងនេះដែរ សិស្សអនុវត្តបំណិនប្រាស្រ័យទាក់ទង (ឧទាហរណ៍.ការស្តាប់ និងការសួរសំណួរ)។ វាក៏គ្មិនត្រូវធ្វើជាគំរូនៃការអនុវត្តល្អ ជាអ្នកជំនាញលើប្រធានបទ។ សាលាអាចកំណត់អត្តសញ្ញាណអ្នកជំនាញក្នុងមូលដ្ឋានក្នុងកំឡុងពេលធ្វើកម្មវិធីសិក្សាបែបពិគ្រោះយោបល់ នៅកម្រិតសាលារៀន ឬក្នុងដំណាក់កាលទី១ បន្ទាប់ពីបានដឹងច្បាស់ថាតើសិស្សត្រូវប្រមូលព័ត៌មានអ្វីខ្លះ។

### ខ-វិធានក្នុងការអញ្ជើញ

- ត្រូវមានទំនាក់ទំនងអ្នកជំនាញមូលដ្ឋានជាមុន និងកំណត់កាលវិភាគច្បាស់លាស់។ សុំឱ្យសិស្សជួយទាក់ទងពួកគេហើយផ្ញើលិខិតអញ្ជើញឱ្យគាត់មកធ្វើបទឧទ្ទេសនៅសាលារៀន។ បើចាំបាច់សូមស្នើមេឃុំ ឬមេភូមិជួយអញ្ជើញអ្នកជំនាញក្នុងមូលដ្ឋាន។
- កុំបង្ខំអ្នកជំនាញក្នុងមូលដ្ឋានឱ្យនិយាយអំពីប្រធានបទដែលគាត់មិនមានទំនុកចិត្ត។ សូមអញ្ជើញតែអ្នកជំនាញក្នុងមូលដ្ឋានដែលអ្នកគិតថា អាចទាក់ទាញចំណាប់អារម្មណ៍សម្រាប់កុមារ និងលើកទឹកចិត្តកុមារ។ រៀបចំផែនការព័ត៌មាន និងសកម្មភាពផ្សេងៗគ្នាដើម្បីបង្ហាញដល់សិស្ស។
- សួរសិស្សថា តើពួកគេស្គាល់អ្នកជំនាញក្នុងមូលដ្ឋានដែលអ្នកចង់អញ្ជើញ សម្រាប់ប្រធានបទនេះដែរឬទេ។ គ្រូអាចផ្តល់ឱកាសឱ្យកុមារដើម្បីជ្រើសរើសមនុស្សដែលពួកគេស្គាល់ (ក្នុងករណីមិនទាន់ត្រូវបានគេស្គាល់អត្តសញ្ញាណ)។
- ត្រូវប្រាកដថាបានផ្តល់ព័ត៌មានដល់នាយកសាលា និងទទួលការអនុញ្ញាតរួចហើយ។

- រំលឹកភ្ញៀវជាវាគ្មិនអំពីកាលបរិច្ឆេទដែលជិតមកដល់ ដើម្បីប្រាកដថាអ្នកនោះនឹងមក។
- ដឹងឱ្យច្បាស់នូវតម្រូវការដែលពាក់ព័ន្ធក្នុងការអញ្ជើញភ្ញៀវ។ ភ្ញៀវខ្លះអាចស្នើសុំថ្លៃធ្វើដំណើរ ប្រសិនបើពួកគេរស់នៅឆ្ងាយ ហើយពួកគេប្រហែលជាមិនមានពេលវេលាទំនេរច្រើនដែរ។
- សុំឱ្យសិស្សអរគុណអ្នកជំនាញក្នុងមូលដ្ឋាន ហើយរៀបចំឱ្យពួកគេសរសេរលិខិតថ្លែងអំណរគុណ ដល់អ្នកជំនាញក្នុងមូលដ្ឋាន។ អ្នកជំនាញក្នុងមូលដ្ឋានអាចត្រូវបានស្នើសុំឱ្យត្រឡប់មកម្តងទៀត សម្រាប់សកម្មភាពផ្សព្វផ្សាយ (ដំណាក់កាលទី៥)។

## គ-វិធីប្រតិបត្តិដើម្បីអនុវត្តការផ្តល់បទឧទ្ទេសៈ

វិធីច្រើនដែលគេអាចយកទៅអនុវត្តក្នុងពេលឧទ្ទេសៈ

- ប្រាប់សិស្សអំពីភ្ញៀវដែលនឹងមកជួបពួកគេពី(ឈ្មោះ អាយុ ភេទ ប្រវត្តិរូប បទពិសោធ និងមូលហេតុដែលអ្នកជ្រើសរើសគាត់មកធ្វើបទឧទ្ទេស)។
- មុនពេលចាប់ផ្តើមមេរៀន ឱ្យសិស្សគិតរកសំណួរដែលគេចង់សួរទៅភ្ញៀវដែលបង្ហាញពីប្រធានបទ។
- ឱ្យសិស្សអានអត្ថបទអំពីប្រធានបទ ដើម្បីបង្កើតសំណួរដែលគេចង់សួរភ្ញៀវ។
  - ❖ បន្ទាប់ពីភ្ញៀវចាកចេញទៅគ្រូអាចឱ្យសិស្សពិភាក្សាសំណួរចម្លើយ និងពិភាក្សាពីអ្វីដែលគេបានរៀនសូត្រពីភ្ញៀវទាំងខ្លឹមសារ និងបំណិនលើការបង្ហាញ។

## ឃ-តើនរណាអាចធ្វើជាវាគ្មិនសម្រាប់សិស្ស?

- អ្នកមានជំនាញលើប្រធានបទអាចជាមន្ត្រីរាជរដ្ឋាភិបាល ឬក្រុមការងារឃុំសង្កាត់ដែលធ្វើការលើបញ្ហាសុខភាព បញ្ហាសង្គម នាយកសាលា គ្រូបង្រៀន ព្រះសង្ឃ កសិករ ។ល។
- បុគ្គលិកអង្គការដែលយល់អំពីការងារអប់រំ និងប្រធានបទដែលពាក់ព័ន្ធ។
- សមាជិកសហគមន៍ដែលមានបទពិសោធ និងបញ្ហាផ្ទាល់ខ្លួនដែលពាក់ព័ន្ធទៅនឹងប្រធានបទ(បញ្ហាពាក់ព័ន្ធទៅនឹងអនាម័យនិងសុខភាព ការបោះឆ្នោតឃុំសង្កាត់។ល។)
- យុវជនក្នុងសហគមន៍ដែលមានបទពិសោធទាក់ទងនឹងប្រធានបទ(ចំណាកស្រុកទៅធ្វើការនៅភ្នំពេញក្នុងរោងចក្រកាត់ដេរ កុមារឬយុវជនដែលបោះបង់ចោលសាលា យុវជនដែលកំពុងធ្វើការងារជាដើម)។

# សកម្មភាពទី៣- គម្រោងស្រាវជ្រាវងាយៗ

## ក-សេចក្តីផ្តើម

ការស្រាវជ្រាវងាយៗគឺជាសកម្មភាពដែលមានគោលបំណង ប្រមូលព័ត៌មានអំពីប្រធានបទ ដើម្បីឱ្យមានការយល់ដឹងកាន់តែច្រើន។ ការអនុវត្តសកម្មភាពស្រាវជ្រាវងាយៗទាំងនេះ ផ្តល់ឱកាសដល់កុមារទទួលបានបទពិសោធក្នុងការស្រាវជ្រាវ និងប្រមូលព័ត៌មាន។

## ខ-វិធាននៃសកម្មភាពស្រាវជ្រាវងាយៗក្នុងសហគមន៍៖

- ត្រូវត្រៀមប្រភពព័ត៌មានជាស្រេច ហើយឱ្យកុមារទាំងអស់បានដឹងពីប្រភពព័ត៌មានទាំងនោះ។
- ត្រូវប្រាកដថា សិស្សមានជំនឿចិត្តក្នុងការអនុវត្តសកម្មភាពស្រាវជ្រាវងាយៗនេះ។
- មិនត្រូវធ្វើឱ្យសិស្សមានសម្ពាធក្នុងការអនុវត្តសកម្មភាពស្រាវជ្រាវឡើយ ឬមិនត្រូវបង្ខំសិស្សធ្វើឱ្យសិស្សខឹងឡើយ ប្រសិនជាសិស្សមិនអាចប្រមូលទិន្នន័យ ដែលអាចជឿជាក់បាន។
- មិនត្រូវឱ្យសិស្សរៀបចំសំណួរច្រើនពេកទេ(អតិបរិមាចំនួន ៦សំណួរ គឺគ្រប់គ្រាន់)។
- ផ្តល់ឱកាស ឱ្យសិស្សហ្វឹកហាត់ធ្វើការអនុវត្តសកម្មភាពស្រាវជ្រាវជាមួយមិត្តភក្តិក្នុងថ្នាក់រៀនរបស់គេ។ រៀបចំសិស្សឱ្យមានសុជីវធម៌ក្នុងការនិយាយទៅកាន់អ្នកផ្តល់ព័ត៌មាន និងត្រូវពន្យល់ពីគោលបំណងនៃការធ្វើសម្ភាស និងការស្រាវជ្រាវរបស់គេ។
- ជូនពរឱ្យសិស្សមានសំណាងល្អមុនពេលចុះស្រាវជ្រាវ និងទទួលបាននូវបទពិសោធល្អ ព្រមទាំងទទួលបាននូវភាពសប្បាយរីករាយក្នុងការងារនេះ។
- លើកទឹកចិត្តសិស្សឱ្យព្យាយាមធ្វើឡើងវិញ ប្រសិនបើការធ្វើលើកទី១មិនបានទទួលជោគជ័យ ដោយពន្យល់ថាការងារនេះនឹងបានប្រសើរនៅពេលក្រោយ។

## គ-វិធីប្រតិបត្តិដើម្បីអនុវត្តសកម្មភាពស្រាវជ្រាវងាយៗ ការរៀបចំសកម្មភាពស្រាវជ្រាវងាយៗដូចជា៖

- បំផុសគំនិតរកប្រភពអ្នកផ្តល់ព័ត៌មានលើប្រធានបទជាក់លាក់មួយ (អ្នកភូមិ កុមារ គណៈគ្រប់គ្រងសាលា មន្ត្រីរាជរដ្ឋាភិបាល ឯកសារក្នុងបណ្ណាល័យ វិទ្យុ ទូរទស្សន៍។ល។)
- សួរសិស្សថាតើពួកគេចង់រកប្រភេទព័ត៌មានបែបណា? ឱ្យសិស្សកំណត់នូវប្រភពព័ត៌មាន ដែលល្អបំផុតសម្រាប់ប្រធានបទដែលបានជ្រើសរើស ហើយវាជាវិធីមួយងាយបំផុតក្នុងការអនុវត្ត ដើម្បីស្វែងរកព័ត៌មានដែលគេត្រូវការ។
  - ❖ ពន្យល់ថា ពួកគេត្រូវការដើម្បីកំណត់អត្តសញ្ញាណ និងសួរសំណួរទៅប្រភពច្រើនជាងមួយ(ល្អបំផុត២ឬ៣) ដើម្បីធានាថា ព័ត៌មានដែលពួកគេប្រមូល គឺអាចជឿទុកចិត្តបាន (ត្រីកោណទិន្នន័យ)៖
  - ❖ **ភាពងាយស្រួល** ៖ តើមានភាពងាយស្រួលក្នុងការអនុវត្តឬទេ? តើយើងត្រូវការការអនុញ្ញាតទេ?
  - ❖ **ចំងាយ** ៖ តើវានៅជិត ឬឆ្ងាយពីសាលារៀន
  - ❖ **តម្លៃ** ៖ តើវាមានតម្លៃថ្លៃក្នុងការប្រើប្រាស់ប្រភពព័ត៌មាននេះដែរឬទេ (តើសៀវភៅដែលយើងត្រូវការថ្លៃមែនទេ? តើការធ្វើដំណើរទៅសម្ភាសន៍មានតម្លៃថ្លៃឬទេ?
- ឧទាហរណ៍. សិស្ស១ក្រុមស្វែងរកព័ត៌មាន នៅក្នុងបណ្ណាល័យ ១ក្រុមនៅក្នុងសហគមន៍ ១ក្រុមនៅក្នុងគ្រួសារ ឬក្នុងគេហទំព័រ។




*រូបភាព-ត្រីកោណទិន្នន័យ*

*រូបភាព-ត្រីកោណទិន្នន័យ*

## សកម្មភាពទី៤- ការប្រើករណីសិក្សា

ករណីសិក្សាជាទម្រង់មួយនៃឧបករណ៍ការសិក្សាផ្អែកលើបញ្ហា និងសំដៅទៅលើរឿងរ៉ាវដែលមានព័ត៌មានពាក់ព័ន្ធលើប្រធានបទដែលសិស្សកំពុងសិក្សា។ ជាធម្មតា វាផ្តល់សេណារីយ៉ូសម្រាប់សិស្សដើម្បីវិភាគស្ថានភាព បញ្ហា និងស្វែងរកដំណោះស្រាយដែលអាចកើតមាន។ គ្រូអាចសម្របខ្លឹមសារទាក់ទងនឹងប្រធានបទដែលសិស្សកំពុងសិក្សា និងប្រើប្រាស់វានៅក្នុងដំណាក់កាលផ្សេងគ្នានៃការងាររបស់ពួកគេ (ដើម្បីណែនាំបង្ហាញប្រធានបទ វិភាគទិដ្ឋភាពជាក់លាក់នៃប្រធានបទ ហ្វឹកហាត់បំណិនរបស់សិស្សក្នុងការដោះស្រាយបញ្ហា ឬការត្រិះរិះពិចារណា។ ល។) ។ លក្ខណវិនិច្ឆ័យដើម្បីសរសេរករណីសិក្សា៖

- ធានាថាករណីសិក្សាមានអត្ថន័យ ងាយអាន និងងាយយល់
- ធានាថាអ្នកជ្រើសរើសករណីសិក្សាដែលទាក់ទងនឹងប្រធានបទ
- ធានាថាសំណួរដែលត្រូវបានប្រើនៅក្នុងករណីសិក្សានឹងធ្វើឱ្យសិស្សអភិវឌ្ឍចំណេះដឹង និងសមត្ថភាពរបស់ពួកគេក្នុងការឆ្លុះបញ្ចាំង និងជំរុញវិធីសាស្ត្រហេតុផលផ្សេងៗគ្នា (អនុមានរួម និងអនុមានញែក)
- ធានាថាករណីសិក្សាមិនវែងពេកទេ។

គុណសម្បត្តិដែលពាក់ព័ន្ធបំផុតនៃវិធីសាស្ត្រករណីសិក្សាគឺសិស្សពិភាក្សាយ៉ាងសកម្ម និងបើកទូលាយដើម្បីដោះស្រាយបញ្ហា និងវិភាគស្ថានភាព។ វិធីសាស្ត្រនេះជួយអភិវឌ្ឍបំណិនដូចជា៖ ការដោះស្រាយបញ្ហា ការវិភាគ ការវាយតម្លៃ ការធ្វើសេចក្តីសម្រេចចិត្ត។

### ក-ឧទាហរណ៍ទី១ នៃករណីសិក្សា (ដំបូន្មានអាជីព)

សុភាពចាស់ជាងគេក្នុងចំណោមបងប្អូន៥នាក់។ ឪពុករបស់នាងមានជំងឺ ហើយម្តាយរបស់នាងធ្វើស្រែលើដីពួកគេនៅខាងក្រោយផ្ទះ ប៉ុន្តែការប្រមូលផលគឺតិចជាងរាល់ឆ្នាំ ខណៈដែលគ្រួសារមានតម្រូវការកើនឡើងព្រោះបងប្អូនទាំងអស់កំពុងធំធាត់។ សុភាពនឹងបញ្ចប់ការសិក្សានៅថ្នាក់ទី១១ក្នុងឆ្នាំនេះ។

កាលពីសប្តាហ៍មុន មានមនុស្សម្នាក់មកពីរោងចក្រធំមួយនៅភ្នំពេញ បានមកក្នុងភូមិដើម្បីជ្រើសរើសកម្មករថ្មី។ ពួកគេនឹងផ្តល់កន្លែងស្នាក់នៅ និងប្រាក់ខែប្រចាំខែយ៉ាងតិច១០០ដុល្លារ ហើយពួកគេនឹងបណ្តុះបណ្តាលកម្មកររបស់ពួកគេលើការកាត់ដេរ។ ក្រុមគ្រួសារសុភាពត្រូវបានក្រុមហ៊ុនទាក់ទងដើម្បីពិនិត្យមើលថាតើសមាជិកគ្រួសារណាម្នាក់ចាប់អារម្មណ៍។ សុភាពដឹងថា ប្រាក់បន្ថែមនេះនឹងមានប្រយោជន៍ ប៉ុន្តែនាងស្រឡាញ់ការសិក្សា ហើយនាងគ្រោងនឹងបញ្ចប់ថ្នាក់ទី១២ ហើយបន្តទៅសកលវិទ្យាល័យ។ ម្តាយរបស់សុភាពប្រាប់នាងថា ក្រុមគ្រួសារត្រូវការជំនួយពីនាង ប៉ុន្តែគាត់មិនចង់ឱ្យនាងទៅធ្វើការទេ។

**សំណួរ៖ តើសុភាពគួរតែធ្វើអ្វី? តើនាងគួរទៅភ្នំពេញដើម្បីធ្វើការងារឬ? តើនាងគួរបន្តការសិក្សាយ៉ាង**

ហោចណាស់បញ្ចប់ថ្នាក់ទី១២ឬ? តើអ្នកធ្វើដូចម្តេចបើអ្នកស្ថិតក្នុងស្ថានភាពរបស់នាង? តើអ្នកនឹងមានអារម្មណ៍យ៉ាងណា?

*១-ការអភិវឌ្ឍ និងការសួរសំណួរ : វាសំខាន់ណាស់សម្រាប់គ្រូបង្រៀនក្នុងការសួរសំណួរដើម្បី៖*

- ពិនិត្យការយល់ដឹងរបស់សិស្ស
- លើកទឹកចិត្តដល់ការចូលរួមរបស់សិស្ស
- អនុញ្ញាតឱ្យសិស្សអនុវត្តបំណិនដោះស្រាយបញ្ហា។

*២-ប្រភេទសំណួរ*

- សំណួរបើក៖ ឧទា. តើសុភាពគួរទៅភ្នំពេញដើម្បីធ្វើការងារដែរឬទេ ?តើនាងសម្រេចចិត្តដូចម្តេច ?
- សំណួរប្រៀបធៀប៖ ឧទាហរណ៍.តើកុមារីនៅក្នុងរឿងសម្រេចចិត្តទៅធ្វើការនៅភ្នំពេញដោយខ្លួនឯង ឬដោយមានការជំរុញពីឳពុកម្តាយរបស់គេ ?
- សំណួរទស្សន៍ទាយ៖ ឧទា. ប្រសិនបើ.............តើមានអ្វីនឹងកើតឡើង..........? ប្រសិនបើនាងបន្តរៀនឱ្យបានចប់ចុងចប់ដើម តើនាងនឹងអាចទ្រទ្រង់គ្រួសាររបស់នាងច្រើនដូចម្តេចនាពេលអនាគត ?
- សំណួរដែលចាប់ផ្តើមដោយពាក្យ ហេតុអ្វី ? ឯណា ? នរណា ? ពេលណា ? របស់នរណា ?របៀបណា ?

**ឧទាហរណ៍៖** ហេតុអ្វីបានជាអ្នកគិតថាម្តាយរបស់សុភាពចង់ឱ្យនាងស្នាក់នៅក្នុងភូមិ ?

## ខ-វិធីប្រើប្រាស់ករណីសិក្សា

1- អ្នកអាចចែកសិស្សជាក្រុមតូចៗ មានសិស្ស៤នាក់ក្នុងមួយក្រុម ដោយមានករណីសិក្សាពីរផ្សេងគ្នា។ ដៃគូ២នាក់ធ្វើការលើករណីសិក្សារបស់ពួកគេ។ នៅចុងបញ្ចប់ពួកគេចែករំលែកចម្លើយរបស់ពួកគេ។

2- អ្នកអាចផ្តល់ករណីសិក្សាដូចគ្នាដល់ក្រុមទាំងអស់ ប៉ុន្តែមានសំណួរខុសគ្នា។ ចុងបញ្ចប់ក្រុមនីមួយៗនឹងចែករំលែកសំណួរ និងចម្លើយ ហើយពិភាក្សាជាមួយក្រុមផ្សេងទៀត។

3- អ្នកអាចផ្តល់ការណែនាំអំពីករណីសិក្សាដល់សិស្ស (តួអង្គ ទីតាំង និងទិដ្ឋភាពទូទៅនៃករណីសិក្សា) បន្ទាប់មកអ្នកអាចសួរសិស្សអំពីតួអង្គសំខាន់ៗ និងខ្លឹមសារសំខាន់ៗនៅក្នុងករណីសិក្សាទាក់ទងនឹងប្រធានបទ។ ឱ្យសិស្សអានករណីសិក្សា ហើយសួរសំណួរ និងពិនិត្យមើលថាតើចម្លើយប៉ុន្មានដែលពួកគេបានផ្តល់ឱ្យ។

*៣- ការឆ្លុះបញ្ចាំងលើបំណិនដែលបានអភិវឌ្ឍ*

ជាប្រការសំខាន់ណាស់ ដើម្បីឆ្លុះបញ្ចាំងជាមួយសិស្សអំពីសកម្មភាពដែលបានធ្វើ នៅក្នុងដំណាក់កាលនេះ ដើម្បីឱ្យពួកគេឆ្លុះបញ្ចាំងពីអ្វីដែលពួកគេបានជួបប្រទះទាក់ទងនឹងសកម្មភាពដែលបានធ្វើ និងបំណិនដែលបានអភិវឌ្ឍ។ ការឆ្លុះបញ្ចាំងអាចធ្វើនៅក្នុងក្រុមធំ ក្រុមតូច ឬដៃគូ។

គ្រូអាចសួរសំណួរងាយៗដូចខាងក្រោមដើម្បីឆ្លុះបញ្ចាំង៖

1- តើអ្នកមានសកម្មភាពណាមួយដែលពិបាកធ្វើដែរឬទេ ? ហេតុអ្វី ?

2- តើសកម្មភាពអ្វីខ្លះដែលអ្នកបានធ្វើដើម្បីរកដំណោះស្រាយ ?

3- តើអ្នកចូលចិត្តធ្វើការជាមួយមិត្តរួមថ្នាក់របស់អ្នកឬទេ ? ហេតុអ្វី ? តើវាពិបាកឬទេ ?

4- តើអ្វីដែលអ្នកអាចកែលម្អនាពេលអនាគត ?

# ដំណាក់កាលទី២- ការប្រមូលព័ត៌មាន

## ១-គោលបំណង

បង្កើតកម្រងសំណួរងាយៗ និងប្រមូលព័ត៌មាននៅតាមសាលារៀន និងពីសហគមន៍ទាក់ទងនឹងប្រធានបទដែលសិស្សកំពុងធ្វើការអង្កេត។ កម្រិតលំបាកនៃកម្រងសំណួរអាស្រ័យលើកម្រិតថ្នាក់ និងសមត្ថភាពរបស់សិស្ស។

## ២-បំណិនគោលដៅ ចរិយាសម្បទា និងគុណតម្លៃ

ការច្នៃប្រឌិត កិច្ចសហប្រតិបត្តិការ ការប្រាស្រ័យទាក់ទង ការចរចា ការដោះស្រាយបញ្ហា ការឱ្យតម្លៃលើខ្លួនឯង និងឥរិយាបថវិជ្ជមានចំពោះសហគមន៍ ការគោរព និងការទទួលខុសត្រូវ។

## ៣-ល្បិចបង្រៀន

### សកម្មភាពទី១-ការបង្កើតកម្រងសំណួរ

#### ក-សេចក្តីណែនាំ

ជាប្រការចាំបាច់ណាស់ក្នុងការរៀបចំសិស្សមុនពេលគេទៅសហគមន៍ ដើម្បីប្រមូលព័ត៌មានស្តីពីការយល់ដឹងរបស់គេលើប្រធានបទ។ ការកសាងកម្រងសំណួរនឹងជួយសិស្សឱ្យយល់កាន់តែច្បាស់ពីអ្វីដែលត្រូវសួរក្នុងសហគមន៍។

តារាងគំរូនៃប្រភពទិន្នន័យសម្រាប់ការស្រាវជ្រាវងាយៗ

| សំណួរ | | ប្រភពព័ត៌មាន | | ការឆ្លើយតប/សម្គាល់ |
|---|---|---|---|---|
| 1 | | | | |
| 2 | | | | |
| 3 | | | | |
| 4 | | | | |
| 5 | | | | |
| 6 | | | | |

#### ខ-ល្បិចបង្រៀន

- រំលឹកឡើងវិញនូវអ្វីដែលបានពិភាក្សាក្នុងដំណាក់កាលទី១ ដោយដាក់ពណ៌ចំណាំលើព័ត៌មាន និងគំនិតសំខាន់ៗដែលប្រមូលបាន ហើយនិងអ្វីដែលសិស្សបានដឹងរួចហើយ។
- ធ្វើយ៉ាងណាឱ្យសិស្សយល់ពីអ្វីដែលពួកគេចង់ស្វែងរក ដោយប្រើទម្រង់សំណួរ “អ្វីដែលយើងចង់ដឹង ? តើយើងត្រូវសួរអ្វីខ្លះ ?”
- ដាក់សំណួរដែលទើបតែបង្កើតទៅតាមក្រុមគំនិត និងជ្រើសរើសសំណួរសំខាន់យ៉ាងច្រើនចំនួន១០ដើម្បីប្រើប្រាស់ពេលធ្វើសម្ភាស។ សិស្សមិនចាំបាច់ទន្ទេញសំណួរឱ្យចាំឡើយ គឺគេគ្រាន់តែចាំពីគំនិត

សំខាន់ៗដែលត្រូវសួរ និងសួរសំណួរបន្តបន្ទាប់ទៅពេលដែលគេចង់ដឹងបន្ថែម។

- ភ្ជាប់សំណួរទៅនឹងប្រភពនៃអត្តសញ្ញាណដែលបានកំណត់ក្នុងដំណាក់កាលទី១។
- គ្រូធ្វើយ៉ាងណាឱ្យសិស្សចេះបត់បែនតវិយាបថជាក់ស្តែងនៅពេលចុះសម្ភាស។
- សកម្មភាពនេះអាចធ្វើបានក្នុងថ្នាក់ទាំងមូល ឬក្នុងក្រុមតូចៗ។ បើធ្វើក្នុងក្រុមតូច ក្រុមនីមួយៗត្រូវបង្ហាញកម្រងសំណួររបស់ពួកគេទៅដល់ថ្នាក់ទាំងមូល ហើយដឹកនាំការពិភាក្សា ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ថាពួកគេក្តោបយកព័ត៌មានចាំបាច់សម្រាប់ដំណាក់កាលបន្ទាប់។
- សិស្សម្នាក់ៗមានកម្រងសំណួរដែលសរសេរលើសៀវភៅរបស់គេ។
- គ្រូត្រូវរៀបចំផែនការលម្អិតជូននាយកសាលា ឬក្រុមការងារ ដើម្បីពួកគាត់ផ្តល់ព័ត៌មានដល់សហគមន៍នៅពេលបញ្ចប់សកម្មភាពទី២ ស្តីពីការត្រៀមធ្វើសម្ភាស។

## គ-គំរូកម្រងសំណួរ

1- តើលោកពូអ្នកមីងដឹងពីរឿងរ៉ាវដែលទាក់ទងទៅនឹង................?
2- តើធ្លាប់មានរឿងនេះកើតនៅក្នុងសហគមន៍លោកពូ-អ្នកមីងដែរឬទេ?
3- តើលោកពូ-អ្នកមីងដឹងទេថា តើមូលហេតុអ្វីដែលនាំឱ្យមានរឿងរ៉ាវនោះកើតឡើង?
4- តើលោកពូ-អ្នកមីងដឹងទេថារឿងនោះវានឹងមានផលប៉ះពាល់អ្វីខ្លះ?
5- តើលោកពូ-អ្នកមីងគិតថារឿងនោះនាំឱ្យប៉ះពាល់អ្វីខ្លះដល់ជីវិត និងគ្រួសាររបស់ពួកគេ?
6- តើលោកពូ-អ្នកមីងធ្វើដូចម្តេច ដើម្បីដោះស្រាយរឿងរ៉ាវនេះកន្លងមក?
7- តើពេលកើតមានរឿងរ៉ាវនោះមាននរណាម្នាក់ជួយធ្វើអន្តរាគមន៍ដែរឬទេ?
8- តើលោកពូ-អ្នកមីងចង់ឃើញបញ្ហាបែបនេះកើតមាននៅក្នុងសហគមន៍លោកពូ-អ្នកមីងដែរឬទេ?
9- តើលោកពូ-អ្នកមីងគិតថាយើងអាចរួមគ្នាដោះស្រាយបញ្ហាទាំងនោះបានដែរឬទេ?ហេតុអ្វី?
10- តើលោកពូ-អ្នកមីងគិតថាគួរមានដំណោះស្រាយដូចម្តេចខ្លះ?

# សកម្មភាពទី២- ការត្រៀមធ្វើសម្ភាស

ការត្រៀមធ្វើសម្ភាសជួយសិស្សឱ្យអនុវត្ត និងយល់ពីរបៀបសួរសំណួរ របៀបសរសេរសំណួរ និងសម្ភារៈដែលពួកគេត្រូវការ(ប៊ិច ក្រដាស កម្រងសំណួរ អូឌីយ៉ូ វីដេអូ ជាដើម)។ វាជួយសិស្សឱ្យមានការយល់ដឹងកាន់តែច្បាស់អំពីសកម្មភាព និងរបៀបសួរសំណួរ។

## ល្បិចបង្រៀន

- កំណត់គោលបំណងនៃការសម្ភាសៈ សិស្សអាចពន្យល់អ្នកត្រូវសម្ភាសពីគោលបំណងដែលគេត្រូវជួប
- រៀបចំបញ្ជីត្រួតពិនិត្យមុនពេលសម្ភាសន៍ៈ ការថតចម្លងកម្រងសំណួរដែលចាំបាច់ តួនាទី និងទំនួលខុសត្រូវរបស់សមាជិកម្នាក់ៗនៃក្រុម ការផ្តល់ព័ត៌មានសម្រាប់អ្នកត្រូវសម្ភាស ការហ្វឹកហាត់ដោយប្រើប្រាស់កម្រងសំណួរ កំណត់ចំនួន និងមុខសញ្ញាដែលយើងធ្វើសម្ភាស កំណត់កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវសម្ភាស។

- បង្ហាញផែនការសម្ភាសន៍ទៅនាយកសាលា ឬក្រុមការងារដើម្បីទទួលបានការគាំទ្រពីពួកគេ។
- ចែករំលែកការទទួលខុសត្រូវក្នុងចំណោមសមាជិកក្នុងក្រុម៖ តើអ្នកណានឹងណែនាំក្រុមដល់អ្នកដែលត្រូវសម្ភាសន៍? តើអ្នកណានឹងសួរសំណួរ? តើអ្នកណាកត់ត្រា?។ល។ បន្ទាប់មកទុកពេលឱ្យសិស្សហាត់សម។
- ដើរតួធ្វើបទសម្ភាសន៍ដោយធ្វើសកម្មភាពជាដៃគូ។ ម្នាក់សួរសំណួរម្នាក់ទៀតជាអ្នកឆ្លើយ។ សុំឱ្យពួកគេកត់ត្រា និងចងចាំដោយអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖
  - អានសំណួរមុនពេលសម្ភាសន៍
  - គួរសម និងអរគុណអ្នកត្រូវសម្ភាសន៍សម្រាប់ពេលវេលាដែលគាត់ផ្ដល់ឱ្យអ្នក
  - ត្រូវច្បាស់លាស់ក្នុងការសួរសំណួររបស់អ្នក (ប្រើពាក្យសាមញ្ញ បង្កើតសំណួរខ្លី)
  - ផ្ដល់ពេលវេលាដល់អ្នកត្រូវសម្ភាសន៍ដើម្បីឆ្លើយ
  - កុំណែនាំចម្លើយ។

## សកម្មភាពទី៣- សម្ភាសន៍ជាក់ស្ដែង

សកម្មភាពនេះត្រូវបានអនុវត្តនៅកម្រិតសហគមន៍ ឬនៅសាលារៀន។ បំណិនជីវិតតាមមូលដ្ឋានជំរុញអន្តរកម្មរវាងសាលារៀន និងសហគមន៍ដើម្បីធ្វើឱ្យសិស្សរៀនពីបញ្ហា ឬស្ថានភាពជាក់ស្ដែងអំពីប្រធានបទដែលពួកគេចាប់អារម្មណ៍។

សម្រាប់សិស្សបឋមសិក្សាគ្រូត្រូវរៀបចំធ្វើបទសម្ភាសន៍សាមញ្ញនៅកម្រិតគ្រួសារ និងអ្នកជិតខាង ហើយអ្នកជំនាញក្នុងមូលដ្ឋាននឹងត្រូវបានអញ្ជើញឱ្យទៅសាលារៀនដើម្បីនិយាយនៅសាលា ឬនៅក្បែរសាលា។ ម៉្យាងទៀត សិស្សអនុវិទ្យាល័យនឹងត្រូវបានលើកទឹកចិត្តឱ្យទៅជួបអ្នកជំនាញក្នុងមូលដ្ឋាន ដែលអមដំណើរដោយគ្រូ ឬតំណាងឪពុកម្ដាយសិស្ស ហើយសម្ភាសពួកគេដោយផ្ទាល់ និងសរសេររបាយការណ៍ស្ដីពីលទ្ធផល។

### ល្បិចបង្រៀន

- ស្វាគមន៍ចំពោះអ្នកដែលត្រូវសម្ភាសន៍ ហើយពន្យល់ពីគោលបំណងនៃសម្ភាសន៍។
- ណែនាំសមាជិកក្រុមដល់អ្នកដែលត្រូវសម្ភាសន៍ហើយអរគុណដល់គាត់ដែលបានចំណាយពេលវេលាសម្រាប់សម្ភាសន៍នេះ។
- ចាប់ផ្ដើមសម្ភាសដោយសមាជិកក្រុមនីមួយៗត្រូវប្រកាន់តួនាទី និងការទទួលខុសត្រូវរបស់ខ្លួនតាមកម្មវិធីដែលបានរៀបចំទុកកាលពីសកម្មភាពលើកមុន។
- នៅចុងបញ្ចប់ អរគុណដល់អ្នកដែលត្រូវសម្ភាសន៍សារជាថ្មី ហើយជម្រាបពួកគាត់ថា "យើងខ្ញុំសង្ឃឹមថានឹងបានសហការជាមួយលោកពូ-អ្នកមីង ដើម្បីដោះស្រាយបញ្ហានេះនៅពេលអនាគត"។

## សកម្មភាពទី៤- ការធ្វើរបាយការណ៍

បន្ទាប់ពីធ្វើសម្ភាសរួចហើយ ក្រុមនីមួយៗត្រូវរៀបចំនូវអ្វីដែលគេបានរកឃើញ ដើម្បីបង្ហាញដល់ថ្នាក់ទាំងមូល ដោយកត់សម្គាល់នូវចំណុចសំខាន់ៗដែលរកឃើញ។ ក្រុមនីមួយៗក៏ត្រូវរៀបចំរបាយការណ៍ផងដែរពីបទពិសោធ និងការប្រឈមទាំងឡាយ ដែលគេជួបប្រទះនៅពេលចុះសម្ភាស ព្រមទាំងកំណត់បាននូវអ្វីដែលគេត្រូវការជំនួយបន្ថែម នៅពេលដែលគេចុះធ្វើសម្ភាស។

### ក-ល្បិចបង្រៀន

- សកម្មភាពនេះអាចធ្វើដាច់ដោយឡែកពីគ្នានៅក្រៅថ្នាក់រៀន ដោយក្រុមផ្ទាល់ខ្លួនរបស់គេ ឬធ្វើក្នុងថ្នាក់រៀនដោយមានជំនួយពីគ្រូប្រចាំថ្នាក់។
- ក្រុមនីមួយៗត្រូវរៀបចំផ្ទាំងរូបភាពសម្រាប់ធ្វើបទបង្ហាញពីការរកឃើញ។
- ក្រុមនីមួយៗត្រូវធ្វើបទបង្ហាញពីការរកឃើញនេះ។

### ខ-គំរូនៃការបង្ហាញលទ្ធផល

គោលបំណង៖......................................................

ក្រុមគោលដៅ៖......................................................

វិធីសាស្ត្រ៖..........................................................

លទ្ធផល៖ ១- ចំណេះដឹង៖ គិតទាំងព័ត៌មានទូទៅ មូលហេតុ និងផលប៉ះពាល់។ល។

២- ការអនុវត្ត៖ គិតទាំងផលប៉ះពាល់លើសហគមន៍ វិធីសាស្ត្រក្នុងការបញ្ចៀសបញ្ហាសកម្មភាពអនុវត្ត...។

៣- ឥរិយាបថ៖ គិតទាំងឆន្ទៈក្នុងការដោះស្រាយបញ្ហា។ល។

បទពិសោធដែលបានរៀន៖ ១- ការលំបាក ឬបញ្ហាប្រឈម។

២- ការកែលម្អសម្រាប់អនាគត។

## ៤- ការឆ្លុះបញ្ចាំងលើបំណិនដែលបានអភិវឌ្ឍ (ការវាយតម្លៃក្រៅផ្លូវការ)

ជាប្រការសំខាន់ណាស់ ដើម្បីឆ្លុះបញ្ចាំងជាមួយសិស្សអំពីសកម្មភាពដែលបានធ្វើ នៅក្នុងដំណាក់កាលនេះ ដើម្បីឱ្យពួកគេឆ្លុះបញ្ចាំងពីអ្វីដែលពួកគេមានបទពិសោធ ទាក់ទងនឹងសកម្មភាពដែលបានធ្វើ និងបំណិនដែលបានអភិវឌ្ឍ។ ការឆ្លុះបញ្ចាំងអាចធ្វើនៅក្នុងក្រុមធំ ក្រុមតូច ឬដៃគូ។ គ្រូអាចសួរសំណួរងាយៗដូចខាងក្រោមដើម្បីឆ្លុះបញ្ចាំង៖

1- តើអ្នកមានសកម្មភាពណាមួយដែលពិបាកធ្វើដែរឬទេ? ហេតុអ្វី?
2- តើអ្នកបានធ្វើសកម្មភាពអ្វីខ្លះដើម្បីរកដំណោះស្រាយ?
3- តើអ្នកចង់ធ្វើការជាមួយមិត្តរួមថ្នាក់របស់អ្នកទេ? ហេតុអ្វី? តើវាពិបាកទេ?
4- តើអ្នកអាចកែលម្អអ្វីនៅពេលអនាគត?

# ដំណាក់កាលទី៣- ការវិភាគព័ត៌មាន

## ១-គោលបំណង

សិស្សរៀនវិភាគព័ត៌មានដែលប្រមូលបាន ក្នុងដំណាក់កាលទី២ រៀបចំព័ត៌មានដោយផ្អែកលើទំនាក់ទំនងរវាងហេតុ និងផល ដើម្បីកំណត់មូលហេតុដើមនៃបញ្ហា និងដើម្បីរកដំណោះស្រាយដែលអាចកើតមាន។




## ២-បំណិនគោលដៅ ចរិយាសម្បទា និងគុណតម្លៃ

ការធ្វើសេចក្តីសម្រេចចិត្ត ការត្រិះរិះពិចារណា ការដោះស្រាយបញ្ហា ការវិភាគ និងឥរិយាបថវិជ្ជមានចំពោះការដោះស្រាយបញ្ហាសហគមន៍។

## ៣-ល្បិចបង្រៀន

### សកម្មភាពទី១- ការបង្ហាញលទ្ធផលព័ត៌មានដែលប្រមូលបាន

ការបង្ហាញលទ្ធផលព័ត៌មានដែលបានប្រមូលទៅកាន់ថ្នាក់ទាំងមូល ជួយឱ្យសិស្សបំពេញព័ត៌មានបានពេញលេញអំពីរឿងរ៉ាវដែលមាននៅក្នុងសហគមន៍។ ធ្វើដូចនេះ គេអាចវិភាគដោយល្អិតល្អន់ និងអាចរកឃើញនូវដំណោះស្រាយជាក់ស្តែងចំពោះបញ្ហា។

#### ល្បិចបង្រៀន

- ឱ្យក្រុមនីមួយៗបិទរបាយការណ៍ លើក្រដាសផ្ទាំងធំរបស់គេ ដែលបានរៀបចំនៅក្នុងដំណាក់កាលទី២ ហើយត្រូវប្រាកដថា ក្រុមនីមួយៗបានត្រៀមលក្ខណៈគ្រប់គ្រាន់សម្រាប់ការបង្ហាញ។
- អញ្ជើញក្រុមនីមួយៗឡើងបង្ហាញលទ្ធផល ព័ត៌មានប្រមូលបានពីសហគមន៍ (មិនមែនជាគំនិតបន្ថែមរបស់ក្រុមទេ)ហើយសមាជិកក្រុមដទៃទៀតសួរសំណួរ ឬធ្វើការបកស្រាយឱ្យច្បាស់ប្រសិនជាចាំបាច់។
- ចាត់តាំងសមាជិកម្នាក់នៅឈរចាំក្បែរក្រដាសផ្ទាំងធំរបស់ខ្លួន ដើម្បីបកស្រាយរាល់ចម្ងល់ផ្សេងៗ បើចាំបាច់ ឬអាចរៀបចំសមាជិកក្នុងក្រុមនីមួយៗបង្ហាញផ្នែកណាមួយដែលបានរកឃើញ។



- បូកសរុបដោយកំណត់នូវលទ្ធផលសំខាន់ៗ និងសរសេរនៅលើក្រដាសផ្ទាំងធំ ឱ្យបានរួចជាស្រេច សម្រាប់ការវិភាគដើមឈើបញ្ហា។ លទ្ធផលចម្បងគឺតំណាងដោយមូលហេតុ និងផលប៉ះពាល់នៃបញ្ហាដែលសិស្សកំពុងអង្កេត។

## សកម្មភាពទី២- ការវិភាគបញ្ហា

**ក-ការវិភាគដើមឈើបញ្ហា៖** ការវិភាគដើមឈើបញ្ហាជួយសិស្សឱ្យរៀបចំព័ត៌មាន និងបែងចែករវាងមូលហេតុផ្សេងៗពីផលប៉ះពាល់ផ្សេងៗនៃបញ្ហា។ បន្ទាប់មកព័ត៌មាននេះនឹងត្រូវបានប្រើក្នុងជំហានខាងក្រោម ដើម្បីកំណត់ដំណោះស្រាយដែលអាចកើតមាន។

### ខ-ល្បិចបង្រៀន

- ប្រើក្រដាសផ្ទាំងធំ ឬផូស្ទ័រនៃព័ត៌មានសំខាន់ៗដែលបានរៀបចំនៅក្នុងសកម្មភាពមុន។
- គូរដើមឈើហើយសរសេរពាក្យនៅខាងក្រោមអំពី “ មូលហេតុ” នៅចំកណ្ដាល “បញ្ហា” និងនៅខាងលើ “ផលប៉ះពាល់” ។

### ជំហានទី១.ដើមឈើបញ្ហា-ការវិភាគមូលហេតុ និងផលប៉ះពាល់




*ឧទាហរណ៍ ដើមឈើបញ្ហា- បញ្ហា : គ្រោះថ្នាក់ចរាចរណ៍ច្រើន*

- គ្រូសរសេរបញ្ហាដែលសិស្សកំពុងអង្កេតនៅកណ្តាល “ បញ្ហា...”
- គ្រូសួរសិស្សថា តើមូលហេតុ និងផលប៉ះពាល់អ្វីខ្លះដែលត្រូវបានកំណត់អត្តសញ្ញាណ? ហើយរៀបចំព័ត៌មាននៅក្នុងក្រដាសផ្ទាំងធំ។ ចែកចាយព័ត៌មាននៅកន្លែងដែលត្រឹមត្រូវ (បែងចែករវាងមូលហេតុនៅខាងក្រោម និងផលប៉ះពាល់នៅផ្នែកខាងលើ នៅកណ្តាលអ្នកសរសេរបញ្ហា។) ម៉្យាងទៀតគ្រូអាចស្នើឱ្យសិស្សធ្វើវាដោយខ្លួនឯង ធ្វើការជាក្រុម ហើយបន្ទាប់មកបង្ហាញលទ្ធផលទៅកាន់ថ្នាក់។ ទីបញ្ចប់សង្ខេបលទ្ធផលដាក់នៅក្នុងក្រដាសផ្ទាំងធំចុងក្រោយមួយ ដោយមានរូបដើមឈើបញ្ហាស្តីអំពីមូលហេតុ-ផលប៉ះពាល់ដែលបានព្រមព្រៀង។
- បន្ទាប់មកគូសសម្គាល់មូលហេតុសំខាន់ៗដើម្បីរកដំណោះស្រាយនៅជំហានបន្ទាប់។
- ទុកក្រដាសផ្ទាំងធំ(រូបខាងលើ)ដើម្បីប្រើក្នុងសកម្មភាពបន្ទាប់(រកដំណោះស្រាយ) ។

**ឧបករណ៍ជំនួសដើមឈើបញ្ហា ប្រើសម្រាប់ការវិភាគពីមូលហេតុ និងផលប៉ះពាល់ ហេតុអ្វី៥ដង**

ចង្អុលបង្ហាញជាពិសេស នៅពេលអ្នកត្រូវការកំណត់បញ្ហា ហើយសិស្សមិនដឹងថាតើមូលហេតុអាចបណ្តាលមកពីអ្វីទេ។ នេះគឺជាបច្ចេកទេសសាមញ្ញមួយដែលអាចជួយកំណត់មូលហេតុដើមនៃបញ្ហា។

**សេចក្តីណែនាំ៖** ចាប់ផ្តើមពីបញ្ហាហើយសួរថា ហេតុអ្វីបានជាវាកើតឡើង? សិស្សផ្តល់ចម្លើយ សួរបន្តហេតុអ្វីបានជាដូចនេះ? សួរបន្ត សិស្សឆ្លើយ...។




**ដ្យាក្រាមឆ្អឹងត្រី ឬដ្យាក្រាមមូលហេតុ-ផលប៉ះពាល់** : រៀបចំ និងជ្រើសរើសព័ត៌មានដែលប្រមូលបាន និងញែកមូលហេតុអំពីផលប៉ះពាល់៖




**របៀបប្រើដ្យាក្រាមឆ្អឹងត្រី:**



1- គ្រូគូរឆ្អឹងត្រីលើក្ដារខៀន

2- គ្រូសរសេរបញ្ហា ឬសំណួរក្នុងរូបត្រីកោណខាងមុខ ដែលជាក្បាលត្រី

3- គ្រូ ឬសិស្សសរសេរនៅចុងឆ្អឹងនីមួយៗអំពីមូលហេតុដែលពួកគេបានរកឃើញ ជាមួយនឹងការអង្កេតរបស់ពួកគេ។ ដ្យាក្រាមនេះនឹងជួយក្នុងការរៀបចំព័ត៌មាន និងស្វែងយល់មូលហេតុដើម។




## សកម្មភាពទី៣- ការកំណត់ដំណោះស្រាយចំពោះបញ្ហា

ផ្អែកលើការវិភាគដើមឈើបញ្ហា ឬឧបករណ៍ផ្សេងទៀតដែលបានប្រើ (ហេតុអ្វី៥ដង ឬឆ្អឹងត្រី) សិស្សអាចកំណត់ដំណោះស្រាយបញ្ហាជាច្រើន។ សកម្មភាពនេះផ្ដល់ឱកាសឱ្យសិស្សមានគំនិតច្នៃប្រឌិត និងស្វែងរកគំនិតថ្មី ដើម្បីដោះស្រាយបញ្ហាដែលមាននៅក្នុងសហគមន៍របស់ពួកគេ។ តួនាទីរបស់គ្រូគឺដើម្បីលើកទឹកចិត្តសិស្សឱ្យរកដំណោះស្រាយថ្មីៗ ហើយមិនត្រូវបង្អាក់វាឡើយ។ នេះជាផ្នែកមួយនៃការរៀនសូត្ររបស់សិស្ស ដើម្បីក្លាយជាពលរដ្ឋដែលមានការទទួលខុសត្រូវ យកចិត្តទុកដាក់ចំពោះសហគមន៍របស់ពួកគេ ហើយព្យាយាមចូលរួមយ៉ាងសកម្ម។

### ក-ល្បិចបង្រៀន

គ្រូដាក់ក្រដាសផ្ទាំងធំនៃការវិភាគដើមឈើបញ្ហា ឬឧបករណ៍ផ្សេងទៀតដែលបានប្រើនៅលើក្ដារខៀន ហើយសិស្សទាំងអស់ត្រូវផ្អែកលើក្រដាសផ្ទាំងធំនោះនៅពេលដែលគេបូកសរុប និងរកដំណោះស្រាយផ្សេងៗ។

## ក.១-នៅពេលប្រើដើមឈើបញ្ហា៖

យកផ្ទាំងក្រដាសថ្មី ហើយបំលែងបញ្ហាទៅជាដើមឈើវត្ថុបំណង (សិស្សក៏អាចពិភាក្សាអំពីដំណោះស្រាយដោយមិនចាំបាច់គូរដើមឈើវត្ថុបំណង ប៉ុន្តែគ្រាន់តែសរសេរនូវដំណោះស្រាយដែលអាចកើតមាន)។ ក្នុងករណីសាលាសម្រេចចិត្តគូរដើមឈើវត្ថុបំណង៖ អ្វីដែលសិស្សត្រូវធ្វើគឺការបំលែងមូលហេតុ ផលប៉ះពាល់ និងបញ្ហាទាំងអស់ទៅជាឱកាស ដូចដែលបានបង្ហាញក្នុងឧទាហរណ៍ខាងក្រោម៖

### ជំហានទី១- ដើមឈើបញ្ហា-ការវិភាគមូលហេតុ និងផលប៉ះពាល់




### ជំហានទី២- ដើមឈើវត្ថុបំណង-កំណត់ដំណោះស្រាយដែលអាចមាន



### ក.២-លំណែនាំ

អ្វីដែលយើងធ្វើបានគឺបំលែង៖ ដើមឈើបញ្ហាជាដើមឈើវត្ថុបំណង មូលហេតុក្លាយជាសកម្មភាព ហើយ ផលប៉ះពាល់អវិជ្ជមានទៅជាផលប៉ះពាល់វិជ្ជមាន បញ្ហាក្លាយជាវត្ថុបំណង ប្រសិនបើយើងធ្វើអ្វីមួយដើម្បីផ្លាស់ប្តូរស្ថានភាព។ បន្ទាប់មកសិស្សត្រូវសម្រេចថា តើសកម្មភាពមួយណាដែលពួកគេអាចធ្វើបាន។ សកម្មភាពខ្លះមានទំហំខ្លាំងពេក សកម្មភាពខ្លះមិនអាចធ្វើដោយខ្លួនឯងបាន ខ្លះអាចនឹងធ្វើបាន...។ ឧបករណ៍នេះមានអត្ថប្រយោជន៍ណាស់ ក្នុងការបង្ហាញសិស្សនូវដំណោះស្រាយដែលអាចមាន។

ពេលប្រើឧបករណ៍ផ្សេងទៀត ( ដ្យាក្រាមឆ្អឹងត្រី និង ហេតុអ្វី៥ដង )

- ដឹកនាំការពិភាក្សា ឬស្នើសុំឱ្យសិស្សនៅក្នុងក្រុមនីមួយៗឆ្លុះបញ្ចាំង និងរកមូលហេតុនិងផលប៉ះពាល់ និងស្វែងរកដំណោះស្រាយនៃបញ្ហា។
- វាយដំណោះស្រាយដែលអាចមាននៅលើក្រដាសផ្ទាំងធំ ហើយរក្សាទុកវាសម្រាប់សកម្មភាពបន្ទាប់ក្នុងដំណាក់កាលទី៤ ។

## ៤-ការឆ្លុះបញ្ចាំងលើបំណិនដែលបានអភិវឌ្ឍ ( ការវាយតម្លៃក្រៅផ្លូវការ )

ជាប្រការសំខាន់ណាស់ ដើម្បីឆ្លុះបញ្ចាំងជាមួយសិស្សអំពីសកម្មភាពដែលបានធ្វើ និងដើម្បីឱ្យពួកគេគិតឡើងវិញអំពីអ្វីដែលពួកគេបានជួបប្រទះ ទាក់ទងនឹងសកម្មភាពដែលបានធ្វើ និងបំណិនដែលបានអភិវឌ្ឍ។ ការឆ្លុះបញ្ចាំងអាចធ្វើជាក្រុមធំ ក្រុមតូច ឬដៃគូ។ គ្រូអាចសួរសំណួរងាយៗសម្រាប់ការឆ្លុះបញ្ចាំង៖

1- តើអ្នកមានសកម្មភាពណាមួយដែលពិបាកធ្វើដែរឬទេ ? ហេតុអ្វី ?

2- តើសកម្មភាពអ្វីខ្លះដែលអ្នកបានធ្វើដើម្បីរកដំណោះស្រាយ ?

3- តើអ្នកចូលចិត្តធ្វើការជាមួយមិត្តរួមថ្នាក់របស់អ្នកឬទេ ? ហេតុអ្វី ? តើវាពិបាកទេ ?

4- តើអ្វីដែលអ្នកអាចកែលម្អនាពេលអនាគត ?

# ដំណាក់កាលទី៤- ការរៀបចំផែនការសកម្មភាព

## ១-គោលបំណង

សិស្សនឹងរៀនពីវិធីដើម្បីរកដំណោះស្រាយសមស្របបំផុតសម្រាប់បញ្ហា និងវិធីរៀបចំផែនការ ដើម្បី អនុវត្តសកម្មភាពផ្សព្វផ្សាយ។ ពួកគេនឹងរៀនដើម្បីកំណត់អត្តសញ្ញាណធនធាន និងបែងចែកទំនួលខុសត្រូវនៅក្នុងក្រុម។

## ២-បំណិនគោលដៅ ចរិយាសម្បទា និងគុណតម្លៃ

ការច្នៃប្រឌិត កិច្ចសហប្រតិបត្តិការ ការធ្វើសេចក្តីសម្រេចចិត្ត បំណិនចរចា ភាពជឿជាក់លើខ្លួនឯង និងអាកប្បកិរិយាវិជ្ជមានក្នុងការដោះស្រាយបញ្ហា។

## ៣-ល្បិចបង្រៀន

### សកម្មភាពទី១- ការជ្រើសរើសដំណោះស្រាយសម្រាប់ការផ្សព្វផ្សាយ

នៅដំណាក់កាលទី៣ សិស្សបានកំណត់នូវដំណោះស្រាយ ឬសកម្មភាពដែលអាចកើតមានដើម្បីឆ្លើយតបនឹងបញ្ហា។ ដំណោះស្រាយទាំងអស់មិនសុទ្ធតែអាចយកប្រើប្រាស់តាមតែយើងអាចគិតបាននោះទេ ព្រោះវាអាស្រ័យលើធនធានដែលមាន។ ដូច្នេះ យើងត្រូវយកដំណោះស្រាយណាដែលអាចអនុវត្តបានទៅតាមធនធានដែលមានសម្រាប់សិស្ស។

#### ល្បិចបង្រៀន

សកម្មភាពនេះអាចត្រូវបានអនុវត្តជាក្រុមតូចៗ ឬជាមួយថ្នាក់ទាំងមូលអាស្រ័យលើគ្រូ។ គោលដៅគឺត្រូវសម្រេចចិត្តថាតើត្រូវផ្សព្វផ្សាយព័ត៌មានយ៉ាងដូចម្តេច។ គ្រូត្រូវគាំទ្រគំនិតច្នៃប្រឌិតថ្មី។

- ដំណោះស្រាយដែលបានកំណត់នៅក្នុងសកម្មភាពមុនត្រូវបានប្រមូល និងសរសេរក្នុងតារាងខាងក្រោម ហើយបន្ទាប់មក គ្រូគួរតែដឹកនាំការពិភាក្សាដើម្បីរកដំណោះស្រាយដែលល្អបំផុត។
- ប្រសិនបើយើងចង់អនុវត្តសកម្មភាពនេះជាក្រុមតូចៗ ក្រុមទាំងអស់ត្រូវផ្តល់បទបង្ហាញ និងពិភាក្សាអំពីដំណោះស្រាយជាមួយថ្នាក់ទាំងមូល។ នៅចុងបញ្ចប់នៃបទបង្ហាញ សិស្សជ្រើសរើសដំណោះស្រាយល្អបំផុត។

**សកម្មភាពអ្វី៖** ឧទាហរណ៍នៃសកម្មភាពផ្សព្វផ្សាយ៖ ការសម្តែងតួ ជាយុទ្ធនាការ មិត្តអប់រំមិត្ត ការជជែកដេញដោលជាសាធារណៈ សរសេរបទចម្រៀងគូររូបភាពនៅជញ្ជាំងសាលាឬក្នុងសហគមន៍លើប្រធានបទទៅនិយាយតាមវិទ្យុក្នុងតំបន់ បង្កើតក្លឹបកាសែតនៅសាលារៀន សរសេរសញ្ញាសម្គាល់នៅទីធ្លាសាលា និងក្នុងសហគមន៍។ល។

តារាង- ឧទាហរណ៍ដើម្បីវិភាគដំណោះស្រាយដែលបានកំណត់

| ដំណោះស្រាយ | ធនធានចាំបាច់ | ធនធានដែលមាន | ភាពអាចធ្វើបាន | ការទទួលខុសត្រូវ |
|---|---|---|---|---|
| ១...........<br>២...........<br>៣...........<br>៤...........<br>៥...........<br>៦........... | ប្រសិនបើយើងអនុវត្តដំណោះស្រាយនេះ តើយើងត្រូវការធនធានអ្វីខ្លះ? ដូចជា៖ ធនធានមនុស្ស សម្ភារៈ និងហិរញ្ញវត្ថុជាដើម។ | តើយើងអាចស្វែងរកធនធានទាំងអស់បាន ដោយងាយដែរឬទេ? | បើយើងឱ្យពិន្ទុ៥ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ។ (ពិន្ទុ៥គឺជាពិន្ទុខ្ពស់បំផុតដែលចាត់ទុកថា ជាដំណោះស្រាយល្អដើម្បីយកទៅអនុវត្ត ហើយពិន្ទុ១ជាពិន្ទុដែលទាបបំផុតដែលវាពុំមែនជាដំណោះស្រាយដែលអាចអនុវត្តបានឡើយ។ | តើយើងចង់អនុវត្តវាយ៉ាងដូចម្ដេច? តើអ្នកចង់អនុវត្តវាជាក្រុមតូច ឬក្នុងថ្នាក់ទាំងមូល ដូចនេះ អ្នកអាចកំណត់ថាតើដំណោះស្រាយចំនួនប៉ុន្មានដែលគួរជ្រើសរើសសម្រាប់សកម្មភាពបន្ទាប់? |

ឧទាហរណ៍ជាមួយដើមឈើវត្ថុបំណង៖ ដោយប្រើឧទាហរណ៍ដូចគ្នានឹង "មានគ្រោះថ្នាក់ចរាចរណ៍ច្រើន" សិស្សអាចសម្រេចថា ដំណោះស្រាយល្អបំផុតគឺត្រូវធ្វើសកម្មភាពលើ "មនុស្សពាក់មួកសុវត្ថិភាព" ពីព្រោះពួកគេអាចធ្វើអ្វីៗអំពីវា ហើយវាមិនថ្លៃទេ។ សកម្មភាពផ្សេងទៀត គឺជាទំនួលខុសត្រូវរបស់រដ្ឋាភិបាល ឬពិបាកពេកសម្រាប់ពួកគេក្នុងការធ្វើអ្វីមួយអំពីរឿងនេះ។

ពួកគេត្រូវផ្ដោតលើសកម្មភាពចំនួន២៖

- បង្កើនចំណេះដឹងអំពីច្បាប់ចរាចរណ៍ ដោយការសរសេរបទចម្រៀងអំពីច្បាប់ចរាចរណ៍ និងហានិភ័យសំខាន់ៗ និងច្រៀងចម្រៀងនោះ នៅជិតដល់ពេលវិស្សមកាល។
- សិស្សត្រូវធ្វើស្លាកសញ្ញាចរាចរណ៍ និងផ្ទាំងកាតុងពន្យល់អំពី ច្បាប់ចរាចរណ៍ ហើយព្យួរនៅក្នុងសាលាសម្រាប់សិស្សដទៃទៀត។



## សកម្មភាពទី២- ការរៀបចំផែនការសកម្មភាពសម្រាប់ផ្សព្វផ្សាយ

ការធ្វើផែនការសកម្មភាព គឺជាឯកសារមួយដែលណែនាំអំពីការអនុវត្តឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធ។ វាអាចជួយឆ្លើយទៅនឹងសំណួរថា ហេតុអ្វី? ពេលណា? របៀបណា? និងនរណា? សំណួរទាំងអស់នេះនឹងជួយសិស្សឱ្យងាយស្រួលក្នុងការរៀបចំអនុវត្តរបស់គេ។

### ល្បិចបង្រៀន

ហេតុអ្វីបានជាធ្វើសកម្មភាពផ្សព្វផ្សាយ? គោលបំណងទូទៅនៃសកម្មភាពផ្សព្វផ្សាយ គឺដើម្បីលើកកម្ពស់ការយល់ដឹងក្នុងចំណោមសមាជិកសហគមន៍លើបញ្ហាដែលសិស្សបានកំណត់ ដែលជាលទ្ធផលនៃការសិក្សាបំណិនជីវិត និងសកម្មភាពស្រាវជ្រាវតូចៗជាមួយក្រុមគោលដៅ។ ជាលទ្ធផល យើងសង្ឃឹមថាអ្នកភូមិនឹងផ្តោតការយកចិត្តទុកដាក់ចំពោះបញ្ហា និងជួយដោះស្រាយបញ្ហាក្នុងសហគមន៍ និងធ្វើឱ្យសហគមន៍ចេះរួបរួមសាមគ្គីគ្នា។

- **អ្វី** : ចង់បង្ហាញលទ្ធផលនៃការអង្កេត៖ មូលហេតុដើម និងដំណោះស្រាយដែលអាចកើតមាន។
- **ពេលណា** : សកម្មភាពនេះត្រូវបានអនុវត្តនៅចុងបញ្ចប់នៃប្រធានបទនីមួយៗ ឬនៅពេលមានព្រឹត្តិការណ៍មួយចំនួនដូចជា ទិវាកុមារអន្តរជាតិ ទិវាពលកម្មអន្តរជាតិ ទិវានារីអន្តរជាតិ បុណ្យចូលឆ្នាំថ្មី ឬថ្ងៃឈប់សម្រាកផ្សេងទៀត។ ល។
- **កន្លែងណា** : តើពួកគេអាចធ្វើសកម្មភាពនេះនៅទីណា? នៅសាលារៀន សួនសាធារណៈ វត្តអារាម ក្នុងភូមិ។ ល។
- **របៀបណា** : តើពួកគេធ្វើសកម្មភាពនេះយ៉ាងដូចម្តេច? ប្រភេទសកម្មភាពដែលអ្នកចង់ឱ្យនរណាអាចជួយធ្វើផែនការ និងអាចអនុវត្តសកម្មភាពបានតាមធនធានដែលត្រូវការ។ល។
- **នរណា** : តើនរណាជាក្រុមគោលដៅ? សិស្សផ្សេងទៀត ក្រុមដែលរងផលប៉ះពាល់ ឪពុកម្តាយសិស្សសមាជិកសហគមន៍ អាជ្ញាធរមូលដ្ឋាន និងអ្នកនយោបាយ ក្នុងគោលបំណងធ្វើឱ្យពួកគេផ្តោតលើបញ្ហានិងមានទំនាក់ទំនងល្អជាមួយបុគ្គលដែលគួរឱ្យគោរពនៅក្នុងសហគមន៍ ដើម្បីទទួលបានការគាំទ្រពីពួកគាត់។ល។
- តើយើងអាចអញ្ជើញភ្ញៀវតាមវិធីណា ដើម្បីឱ្យគាត់ចូលរួមបានច្រើន? គ្រូណែនាំសិស្សឱ្យសរសេរលិខិតអញ្ជើញដោយមានត្រាពីនាយកសាលា។ បន្ទាប់មកឱ្យសិស្សទៅអញ្ជើញភ្ញៀវដោយផ្ទាល់ (បើមានគ្រូ ឬលោកនាយកសាលាទៅជាមួយជាការប្រសើរ)។

| សកម្មភាព | ធនធានសម្ភារៈ | អ្នកទទួលខុសត្រូវ | ពេលណា | វឌ្ឍនភាព |
|---|---|---|---|---|
| សរសេរ និងកត់ត្រាបទចម្រៀង | ឧបករណ៍ថតសំឡេង | សុភាព ដារ៉ា | មករា កុម្ភៈ | បានបញ្ចប់អត្ថបទចម្រៀង |
| រៀបចំស្លាកសញ្ញាចរាចរណ៍ចំនួន ២០ដើម្បីព្យួរនៅសាលារៀន | ក្រដាសកាតុង ថ្នាំលាប ប៊ិច ហ្វឺតកន្ត្រៃ។ | ក្រុមសិស្ស២ក្រុម | មករា | ស្លាកសញ្ញាចំនួន ៥ បានធ្វើរួចរាល់ |
| រៀបចំលិខិតអញ្ជើញ | ក្រដាស | ធារី និងគាន ជាមួយគ្រូ និងនាយកសាលា | កុម្ភៈ | មិនទាន់ចាប់ផ្តើមទេ |

# គំរូសកម្មភាពផ្សព្វផ្សាយតាមសហគមន៍

...



## ការសម្តែងតួ

ការសម្តែងតួជាសកម្មភាពមួយ ដែលអាចធ្វើបានទាំងក្នុង និងក្រៅថ្នាក់រៀន ដើម្បីពង្រឹងនូវអ្វីដែលសិស្សបានរៀន ដោយធ្វើឱ្យការរៀនសូត្រកាន់តែមានន័យ ហើយសប្បាយរីករាយ។ វាពាក់ព័ន្ធនឹងការរៀបចំការសម្តែង និងការឆ្លុះបញ្ចាំងនៅចុងបញ្ចប់នៃការសម្តែងតួ។

### ១.ការរៀបចំ

- ចាប់ផ្តើមជាមួយនឹងការកំណត់អត្តសញ្ញាណមូលហេតុ និងផលប៉ះពាល់នៃបញ្ហាដែលបានវិភាគក្នុងដំណាក់កាលទី៣ ។
- កំណត់ស្ថានភាព៖ សម្រេចចិត្តយករឿង និងតួអង្គសម្តែងក្នុងរឿង។
- រៀបចំសេណារីយ៉ូមួយ និងធ្វើឱ្យប្រាកដថា សិស្សទាំងអស់យល់ច្បាស់អំពីបញ្ហាដែលអ្នកកំពុងព្យាយាមធ្វើបទបង្ហាញ ហើយពួកគេដឹងពីអ្វីដែលពួកគេចង់បង្ហាញជាមួយការសម្តែង។
- កំណត់សម្ភារៈដែលចាំបាច់សម្រាប់ការសម្តែងដើម្បីធ្វើឱ្យវាកាន់តែចាប់អារម្មណ៍ រួមទាំងរូបភាព និងស្លាកសញ្ញា។
- បែងចែកតួនាទីរបស់តួអង្គនីមួយៗ ហើយចាប់ផ្តើមហាត់សម។
- កំណត់អត្តសញ្ញាណអ្នកណាម្នាក់នៅក្នុងសហគមន៍ដែលអាចជួយក្នុងការស្លៀកសម្លៀកបំពាក់ ឬការហ្វឹកហាត់សម្តែង។

### ២. ការសម្តែង

- ស្វាគមន៍ទស្សនិកជន និងបង្ហាញពីគោលបំណងនៃការសម្តែង។
- សម្តែងតាមតួអង្គជាក់ស្តែង។
- សួរសំណួរទៅកាន់ទស្សនិកជន ឬសុំយោបល់ពីទស្សនិកជនចំពោះការសម្តែង។
- អរគុណចំពោះទស្សនិកជន។

### ៣. ការឆ្លុះបញ្ចាំង

- តើការសម្តែងនិយាយអំពីអ្វី?
- តើអ្នកគិតថាតួអង្គ “ក” ដូចម្តេចដែរ?
- ប្រសិនអ្នកជាតួអង្គ “ក” តើអ្នកគួរធ្វើដូចម្តេចវិញ?

## យុទ្ធនាការផ្សព្វផ្សាយ



យុទ្ធនាការផ្សព្វផ្សាយ គឺជាសកម្មភាពដែលសិស្សរៀបចំបង្ហាញ អំពីប្រធានបទទៅកាន់មហាជន ជាពិសេសសមាជិកសហគមន៍ ឬមិត្តភក្តិផ្សេងទៀត។ សកម្មភាពនេះត្រូវការធនធាន ការធ្វើផែនការ និងការរៀបចំដោយប្រុងប្រយ័ត្ន។ សកម្មភាពនេះអាចរៀបចំធ្វើបាន១ ឬ ២ដងក្នុងមួយឆ្នាំ។ វានឹងទាក់ទាញការចាប់អារម្មណ៍ពីប្រជាជនជាច្រើនមុខសញ្ញាក្នុងសហគមន៍ រួមទាំងប្រជាជនទូទៅ អាជ្ញាធរក្នុងតំបន់ អ្នកនយោបាយ និងអ្នកជំនួញ។ល។

### ១.ការរៀបចំ

គោលបំណងនៃយុទ្ធនាការផ្សព្វផ្សាយគឺ ដើម្បីបង្កើនការយល់ដឹងលើប្រធានបទជាក់លាក់មួយ និងទាក់ទាញការយកចិត្តទុកដាក់។

- បង្កើតក្រុមដែលទទួលខុសត្រូវសម្រាប់ដំណើរការដឹកនាំយុទ្ធនាការ (ចាត់តាំងមេដឹកនាំម្នាក់ដែលអាចបញ្ជាក់បានថាអ្វីៗត្រូវបានរៀបចំឡើងមុនពេលយុទ្ធនាការផ្សព្វផ្សាយ។ តែងតាំងមនុស្សឱ្យទទួលខុសត្រូវដើម្បីសុំការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន អញ្ជើញអ្នកនយោបាយ និងជាអ្នកដឹកនាំ ផ្តល់ព័ត៌មានដល់សហគមន៍ស្តីពីការផ្សព្វផ្សាយ ជួលមេក្រូ ... )។
- បង្កើតក្រុមដែលទទួលខុសត្រូវក្នុងការរៀបចំខ្លឹមសារយុទ្ធនាការ និងប្រតិទិន (ធ្វើរបៀបវារៈរួមទាំងពេលវេលា និងទីកន្លែង) និងរបៀបបង្ហាញព័ត៌មាន។ ល។
- មុនថ្ងៃយុទ្ធនាការ ក្រុមទាំងពីរត្រូវផ្តល់ព័ត៌មានអំពីការងារទៅវិញទៅមក និងសម្របសម្រួល ដើម្បីឱ្យប្រាកដថាមានអ្វីគ្រប់យ៉ាងត្រៀមសម្រាប់ថ្ងៃយុទ្ធនាការ និងពិភាក្សាអំពីរបៀបដែលពួកគេចង់ធ្វើ។

### ២.ការអនុវត្ត

- ធ្វើសេចក្តីប្រកាស និងសេចក្តីណែនាំចំពោះអ្នកចូលរួមស្តីពីការធ្វើយុទ្ធនាការណែនាំពីទិសដៅ រយៈពេល និងទីកន្លែង។
- ផ្តើមយុទ្ធនាការដោយគ្រប់គ្នាគោរពតាមតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។
- អរគុណចំពោះអ្នកចូលរួមក្នុងយុទ្ធនាការផ្សព្វផ្សាយ ហើយសង្ឃឹមថា ពួកគេនឹងបានចូលរួមនៅពេលក្រោយទៀត។

### ៣.ការឆ្លុះបញ្ចាំង

- គណៈកម្មការរៀបចំ និងគណៈកម្មការអភិវឌ្ឍខ្លឹមសារត្រូវជួបគ្នាដើម្បីឆ្លុះបញ្ចាំងថា តើដំណើរការនៃការធ្វើយុទ្ធនាការប្រព្រឹត្តទៅយ៉ាងដូចម្តេច? តើយើងបានរៀនបទពិសោធអ្វីខ្លះ? តើលើកក្រោយយើងអាចធ្វើវាយ៉ាងដូចម្តេច?។ល។
- រៀបចំ និងសរសេររបាយការណ៍ពីសកម្មភាពទាំងអស់នេះ ទុកជាឯកសារសម្រាប់ប្រើនៅពេលក្រោយ។
- សរសេរលិខិតថ្លែងអំណរគុណចំពោះអ្នកដែលជួយធ្វើយុទ្ធនាការនេះឱ្យបានចប់ចុងចប់ដើម និងការចូលរួមសហការនៅពេលក្រោយទៀត។

## មិត្តអប់រំមិត្ត

ការអប់រំមិត្ត ជាទម្រង់មួយនៃសកម្មភាពផ្សព្វផ្សាយចំពោះមិត្តម្នាក់ទល់ម្នាក់ ឬម្នាក់ជាមួយក្រុមតូច ឬក្រុមតូចជាមួយនឹងក្រុមធំៗ។ល។ គេអាចធ្វើសកម្មភាពនេះបាន ក្នុងចំណោមសិស្ស និងក្នុងចំណោមយុវជនដែលមិនចូលសាលារៀនផងដែរ ដើម្បីផ្តល់ព័ត៌មានដល់គេជានិច្ចនូវអ្វីដែលអាចប៉ះពាល់ដល់ពួកគេ។



### ១.ការរៀបចំ

- រៀបចំសម្ភារៈបង្រៀនទាក់ទងនឹងប្រធានបទ៖ សៀវភៅរឿង ចម្រៀង ពាក្យស្លោក បណ្ណពាក្យ ក្រដាសផ្ទាំងធំ ។ល។
- រៀបចំផែនការសកម្មភាពសម្រាប់សកម្មភាពមិត្តអប់រំមិត្ត ដោយរៀបរាប់លម្អិតអំពីប្រភេទសកម្មភាពដែលត្រូវធ្វើ។
- ជាផ្នែកមួយនៃសកម្មភាពផ្សព្វផ្សាយ រៀបចំថ្ងៃជាក់លាក់មួយនៅឯសាលារៀន នៅពេលដែលសិស្សមកពីថ្នាក់បំណិនជីវិតតាមមូលដ្ឋាននឹងជួបមិត្តភក្តិផ្សេងទៀត។
- ធានាថា ពួកគេទាំងអស់មានការយល់ដឹងច្បាស់ អំពីប្រធានបទដែលពួកគេត្រូវពន្យល់ដល់សិស្សដទៃទៀត។
- រៀបចំសម្ភារៈដែលពួកគេអាចប្រើដើម្បីពន្យល់(ផូស្ទ័រ រូបភាព បណ្ណពាក្យ វីដេអូ) និងសម្ភារៈដែលពួកគេអាចចែកចាយ (ខិត្តបណ្ណតូចៗ សៀវភៅផ្នត់ធ្វើដោយដៃអំពីប្រធានបទ។ល។)
- ធ្វើគ្រាប់តាមសកម្មភាពនៅក្នុងថ្នាក់រៀន។

### ២.ការអនុវត្ត

- ណែនាំខ្លួនចំពោះមិត្តដែលត្រូវអប់រំ និងគោលបំណងនៃសកម្មភាព។
- ធ្វើឱ្យមិត្តដែលត្រូវអប់រំចាប់អារម្មណ៍នឹងប្រធានបទ ដោយលើកឡើងនូវសារៈសំខាន់ និងផលប៉ះពាល់លើពួកគេ។
- បង្ហាញប្រធានបទ និងពិភាក្សាឱ្យបានស៊ីជម្រៅលើប្រធានបទតាមរយៈសំណួរ ហេតុអ្វី? អ្វីនឹងកើតឡើងប្រសិនបើ...?។ល។
- ធ្វើសេចក្តីសង្ខេបនៅចុងបញ្ចប់ និងធ្វើសេចក្តីសន្និដ្ឋាន តើព័ត៌មាននេះជះឥទ្ធិពលដូចម្តេចខ្លះចំពោះជីវិតគេ។
- អរគុណចំពោះមិត្តដែលបានរៀនជាមួយយើងអំពីប្រធានបទ និង សង្ឃឹមថានឹងបានជួបគ្នាទៀតនៅពេលក្រោយ។

### ៣.ការឆ្លុះបញ្ចាំង

- ឆ្លុះបញ្ចាំងថា តើសកម្មភាពបានប្រព្រឹត្តទៅយ៉ាងដូចម្តេច? តើយើងបានរៀនបទពិសោធអ្វីខ្លះ? តើអ្នកគិតថាងាយស្រួលធ្វើឬទេ? តើអ្វីជាបញ្ហាប្រឈមចម្បងដែលអ្នកបានប្រឈម?
- តើសកម្មភាពនេះអាចកែលម្អយ៉ាងណាទៀតនៅពេលក្រោយ?

## វេទិកាសាធារណៈ



វេទិកាសាធារណៈគឺជាសកម្មភាពដែល ផ្តល់ឱកាសដល់អ្នកជំនាញ ក្នុងការពិភាក្សាអំពីប្រធានបទជាក់លាក់ ចែករំលែកគំនិតរបស់ពួកគេ និងពិភាក្សាជាមួយអ្នកចូលរួម។ អ្នករៀបចំអាចកំណត់អត្តសញ្ញាណអ្នកដែលអាចចូលរួមបាន និងកំណត់ជាមុននូវសំណួរសំខាន់ៗដែលអ្នកចូលរួមនឹងត្រូវឆ្លើយ។ អ្នកអាចចែកចាយសំណួរជាមុនដល់អ្នកចូលរួម ដើម្បីឱ្យពួកគេបានត្រៀមរៀបចំ។

### ១.ការរៀបចំ

- កំណត់អត្តសញ្ញាណជាមួយសិស្សនូវចំណុចសំខាន់ៗនៃការពិភាក្សាក្នុងវេទិកា។
- កំណត់ទីកន្លែងសម្រាប់ធ្វើវេទិកា និងរៀបចំលិខិតអញ្ជើញ។
- កំណត់មុខសញ្ញាវាគ្មិន ដែលត្រូវបានអញ្ជើញឱ្យចូលរួមក្នុងវេទិកា និងផ្តល់ព័ត៌មានដល់គេ អំពីប្រធានបទដែលត្រូវពិភាក្សា និងចែករំលែកដើម្បីគេអាចត្រៀមលក្ខណៈបានល្អ ក្នុងការជជែកពិភាក្សា។
- ធ្វើសេចក្តីប្រកាសជាសាធារណៈដើម្បីអំពាវនាវឱ្យសហគមន៍ចូលរួមក្នុងវេទិកា។

### ២.ការអនុវត្ត

- ស្វាគមន៍អ្នកចូលរួម និងភ្ញៀវកិត្តិយស។
- ណែនាំប្រធានបទ និងគោលបំណងនៃវេទិកាពិភាក្សា។
- បើកវេទិកាពិភាក្សាជាសាធារណៈ និងអញ្ជើញវាគ្មិនបញ្ចេញគំនិត។
- បើកវេទិកាសំណួរ-ចម្លើយ។
- បូកសរុប និងអរគុណចំពោះអ្នកចូលរួម។

### ៣.ការឆ្លុះបញ្ចាំង

- ឆ្លុះបញ្ចាំងថា តើសកម្មភាពបានប្រព្រឹត្តទៅយ៉ាងដូចម្តេច? អ្វីដែលដំណើរការបានល្អ? និង អ្វីជាបញ្ហាប្រឈម? តើយើងបានរៀនបទពិសោធអ្វីខ្លះ?
- ត្រូវពិនិត្យថាតើសកម្មភាពនេះអាចកែលម្អយ៉ាងណាទៀតនៅពេលក្រោយ។

## ការជជែកដេញដោល (ក្រុមគាំទ្រ និងក្រុមបដិសេធ)

ការជជែកដេញដោល គឺជាទម្រង់នៃសកម្មភាពមួយទៀត ស្រដៀងគ្នាទៅនឹងវេទិកាសាធារណៈដែរ ប៉ុន្តែវាជុំវិញឱ្យមានការពិភាក្សាទៅលើប្រធានបទមួយដែលមានទស្សនៈពីរផ្ទុយគ្នាស្រឡះ ដែលលើកឡើងដោយក្រុមគាំទ្រផ្សេងៗគ្នា។ ឧទាហរណ៍៖ មានក្រុមចំនួនពីរនឹងជជែកលើប្រធានបទដែលទាក់ទងនឹងការអប់រំកុមារី ហើយក្រុមនីមួយៗត្រូវគាំទ្រគំនិតផ្ទាល់ខ្លួនរបស់គេ។ ក្រុមមួយអាចគាំទ្រលើគំនិត «ស្ត្រីមិនចាំបាច់រៀនជ្រៅជ្រះទេព្រោះ ...» ក្រុមមួយទៀតគាំទ្រគំនិត «ស្ត្រីត្រូវតែរៀនឱ្យបានជ្រៅជ្រះ ...»។

### ១.ការរៀបចំ

- រៀបចំក្រុមចំនួនពីរដើម្បីធ្វើការងារលើប្រធានបទជាមួយនឹងគំនិតពីរដែលខុសគ្នា។
- កំណត់ទីកន្លែងសម្រាប់ជជែកដេញដោល និងធ្វើសេចក្តីប្រកាសជាសាធារណៈ។
- កំណត់អ្នកដែលត្រូវអញ្ជើញចូលរួមការជជែកដេញដោល និងផ្តល់ព័ត៌មានដល់គេអំពីប្រធានបទដែលនឹងត្រូវជជែក ដើម្បីគេអាចរៀបចំវាបានប្រសើរ។

### ២.ការអនុវត្ត

- ស្វាគមន៍អ្នកចូលរួម និងភ្ញៀវកិត្តិយស។
- ណែនាំបង្ហាញប្រធានបទ និងគោលបំណងនៃការជជែកពិភាក្សា។
- សួរអ្នកចូលរួម តើគំនិតមួយណាដែលគាំទ្រ? (ដើម្បីពិនិត្យមើលការវិវត្តនៃការគិតរបស់គេ នៅចុងបញ្ចប់នៃវេទិកា) ហើយចាប់ផ្តើមការជជែក។
- នៅចុងបញ្ចប់នៃការជជែក សួរអ្នកចូលរួមថា តើគេអាចផ្លាស់ប្តូរគំនិតរបស់គេទៅគាំទ្រគំនិតមួយទៀតដែរឬទេ? ហើយសួរហេតុអ្វី?
- បូកសរុប និងអរគុណចំពោះអ្នកចូលរួម។

### ៣.ការឆ្លុះបញ្ចាំង

- ឆ្លុះបញ្ចាំងថា តើសកម្មភាពបានប្រព្រឹត្តទៅយ៉ាងដូចម្តេច? តើយើងបានរៀនបទពិសោធអ្វីខ្លះ? ។ល។
- ត្រូវគិតថាតើសកម្មភាពនេះអាចកែលម្អយ៉ាងណាទៀតនៅពេលក្រោយ។

## ទិវាបង្ហាញ (ពិព័រណ៍ស្នាដៃ)

ទិវាបង្ហាញជាសកម្មភាពដែលរៀបចំឡើងដោយនាយកសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សដើម្បីផ្តល់ឱកាសដល់សិស្សបង្ហាញស្នាដៃ និងអ្វីដែលពួកគេបានរៀនក្នុងអំឡុងពេលនៃការអង្កេតរបស់ពួកគេ។

ទិវាបង្ហាញនេះគឺជាសកម្មភាពដើម្បីលើកទឹកចិត្តសិស្សានុសិស្សឱ្យចែករំលែកការរៀនសូត្ររបស់ពួកគេជាមួយមិត្តភក្តិ ឪពុកម្តាយ និងសហគមន៍ ជាពិសេសជាមួយអាជ្ញាធរមូលដ្ឋានដែលអាចមានឥទ្ធិពល និងគាំទ្រការកែលម្អ នៅក្នុងបរិបទមូលដ្ឋានទាក់ទងនឹងប្រធានបទដែលបានសិក្សា ទទួលយកសកម្មភាពគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់សិស្ស ដើម្បីអនុវត្តដំណោះស្រាយដែលអាចកើតមាន។ លើសពីនេះទៅទៀតសកម្មភាពនេះ វាជាការលើកកម្ពស់សមត្ថភាពរបស់សិស្ស ក្នុងការប្រើប្រាស់ ចែករំលែកចំណេះដឹង និងបទពិសោធរបស់ពួកគេ សម្រាប់ដោះស្រាយបញ្ហាងាយៗដែលកើតឡើងនៅក្នុងសហគមន៍។

### ១.ប្រភេទស្នាដៃ

ការសរសេរពាក្យស្លោក ការសរសេររឿងនិទាន ការសរសេរកំណាព្យ ចម្រៀង គំនូរ ករណីសិក្សា ការសម្តែងតួ វីដេអូ ការធ្វើស្ទួនបន្លែ។ល។

### ២.ការរៀបចំ

- កំណត់ពីគោលបំណង ខ្លឹមសារ សម្ភារៈ សកម្មភាព និងវិធីសាស្រ្តបង្ហាញ។
- កំណត់មុខសញ្ញាដែលត្រូវអញ្ជើញចូលរួមក្នុងទិវាបង្ហាញ និងផ្តល់ព័ត៌មានដល់អាជ្ញាធរមូលដ្ឋាន ដើម្បីសុំការអនុញ្ញាត និងចូលរួមគាំទ្រ។
- កំណត់កាលបរិច្ឆេទ ទីកន្លែងសម្រាប់ធ្វើទិវាបង្ហាញ និងរៀបចំលិខិតអញ្ជើញ។
- ផ្សព្វផ្សាយព័ត៌មានជាសារធារណៈ ដើម្បីឱ្យសហគមន៍អាចចូលរួមក្នុងវេទិកានេះ។

### ៣.ការអនុវត្ត

- ស្វាគមន៍អ្នកចូលរួម និងភ្ញៀវកិត្តិយស
- ណែនាំបង្ហាញគោលបំណង និងខ្លឹមសារនៃទិវាបង្ហាញ
- បើកកម្មវិធី និងអញ្ជើញគណៈអធិបតីឡើងថ្លែងសុន្ទរកថា
- សកម្មភាពបង្ហាញរបស់ក្រុមសិស្ស
- វេទិកាសំណួរចម្លើយរវាងក្រុមសិស្ស និងអ្នកចូលរួម
- ចំណាប់អារម្មណ៍ និងអនុសាសន៍របស់គណៈអធិបតី
- បូកសរុប និងអរគុណចំពោះអ្នកចូលរួម។

### ៤.ការឆ្លុះបញ្ចាំង

- ឆ្លុះបញ្ចាំងថាតើសកម្មភាពបានប្រព្រឹត្តទៅយ៉ាងដូចម្តេច? តើយើងបានរៀនបទពិសោធអ្វីខ្លះ?។ល។
- ត្រូវគិតថាតើសកម្មភាពនេះអាចកែលម្អយ៉ាងដូចម្តេចនៅពេលក្រោយ។

## សកម្មភាពទី៣- ការបង្ហាញផែនការ និងការហាត់សម

ការបង្ហាញផែនការផ្តល់នូវឱកាសដល់ក្រុមផ្សេងៗគ្នាដើម្បីចែករំលែក និងពិភាក្សាគ្នាដើម្បីបញ្ចប់នូវផែនការទូលំទូលាយមួយ។ សកម្មភាពនេះជំរុញដល់ការអភិវឌ្ឍ ការត្រិះរិះពិចារណា បំណិនធ្វើផែនការក៏ដូចជាការចរចា ការចូលរួម ឬ បំណិនកិច្ចសហប្រតិបត្តិការ។

### ល្បិចបង្រៀន

- បន្ទាប់ពីក្រុមបញ្ចប់ផែនការសកម្មភាពរបស់ពួកគេ (ពួកគេអាចលើកយកឧទាហរណ៍នៃសកម្មភាពផ្សព្វផ្សាយដែលបានរៀបរាប់ខាងលើ ឬការរួមបញ្ចូលគ្នា) សិស្សត្រូវចែករំលែកគំនិតរបស់ពួកគេដើម្បីបញ្ចប់ផែនការ។
- គ្រូត្រូវជំរុញសិស្សឱ្យពិភាក្សាគ្នារវាងក្រុមនីមួយៗដោយបញ្ជាក់ថា តើផែនការនោះជាក់លាក់ និងសម្រេចបានទេ។ សំណួរគួរផ្តោតជុំវិញ៖
- តើអនុវត្តផែនការដូចម្តេច? អ្នកណាខ្លះពាក់ព័ន្ធនៅក្នុងសកម្មភាព? តើធ្វើយ៉ាងណាដើម្បីឱ្យគេចូលរួមក្នុងសកម្មភាព?
- តើមានធនធានអ្វីខ្លះ?(ធនធានសម្ភារៈ និងធនធានមនុស្សដែលចាំបាច់សម្រាប់សកម្មភាព)
- តើនរណាទទួលខុសត្រូវសម្រាប់ភារកិច្ចនីមួយៗ?(លិខិតអញ្ជើញ អភិវឌ្ឍសម្ភារៈ រៀបចំប្រដាប់ប្រដារ...)
- តើអ្នកត្រូវការអ្វីខ្លះសម្រាប់ធ្វើសកម្មភាពនេះ? តើមានពេលគ្រប់គ្រាន់ឬទេ?
- តើពិធីប្រព្រឹត្តទៅនៅឯណា? តើវេទិកាបានកក់ទុកហើយឬនៅ?
- បន្ទាប់ពីបានទទួលអនុសាសន៍ និងសំណូមពររួចហើយ ក្រុមដែលបានឡើងបង្ហាញផែនការត្រូវពិចារណា ធ្វើបច្ចុប្បន្នភាព និងបញ្ចប់ផែនការសកម្មភាពទាំងមូល។

### ៤-ការឆ្លុះបញ្ចាំងលើបំណិនដែលបានអភិវឌ្ឍ

នៅពេលដែលបានបញ្ចប់ផែនការរួច សូមពិនិត្យសកម្មភាពក្នុងមេរៀន ដើម្បីឆ្លុះបញ្ចាំងពីដំណើរការទាំងមូល និងស្វែងយល់ថាតើសិស្សប្រឈមនឹងអ្វីខ្លះ តើពួកគេអាចជម្នះលើបញ្ហាប្រឈម និងអ្វីដែលពួកគេអាចពិចារណាធ្វើខុសពីនេះនៅលើកក្រោយ។ ការឆ្លុះបញ្ចាំងផ្តោតលើបំណិនគោលដៅសំខាន់ៗ សម្រាប់ដំណាក់កាលនេះ។

# ដំណាក់កាលទី៥- ការអនុវត្តផែនការសកម្មភាព

## ១-គោលបំណង

សិស្សអនុវត្តផែនការដោយផ្អែកលើដំណោះស្រាយដែលពួកគេបានជ្រើសរើស ដែលពាក់ព័ន្ធនឹងសហគមន៍ក្នុងការផ្សព្វផ្សាយ ដើម្បីជូនដំណឹងដល់ពួកគេអំពីដំណោះស្រាយដែលអាចកើតមាន។

## ២-បំណិនគោលដៅ ចរិយាសម្បទា និងគុណតម្លៃ

ការចូលរួម បំណិនទំនាក់ទំនង កិច្ចសហប្រតិបត្តិការ ការគោរពភាពចម្រុះ ទំនុកចិត្តលើខ្លួនឯង និងអាកប្បកិរិយាវិជ្ជមានក្នុងការដោះស្រាយបញ្ហា។

## ៣-លំនាំបង្រៀន

### សកម្មភាព- ការអនុវត្តផែនការផ្សព្វផ្សាយ

ជាប្រការសំខាន់ណាស់ក្នុងការណែនាំដល់អ្នកចូលរួម មុនពេលចាប់ផ្តើមសកម្មភាព។ ការណែនាំរួមមាន សមាសភាពអ្នកដែលត្រូវចូលរួម គោលបំណងនៃព្រឹត្តិការណ៍ ប្រធានបទ ដំណើរការ ពេលវេលា។ល។ ការធ្វើបែបនេះ អ្នកចូលរួមនឹងសហការយ៉ាងសកម្មក្នុងសកម្មភាព ហើយទទួលយកដោយពេញចិត្ត។

#### លំនាំបង្រៀន

#### ក.ការចាប់ផ្តើម

- អ្នករៀបចំត្រូវមកកាន់កន្លែងជួបជុំឱ្យបានមុនគេ ហើយរៀបចំអ្វីៗមុនពេលសកម្មភាពចាប់ផ្តើម
- ស្វាគមន៍អ្នកចូលរួម និងថ្លែងអំណរគុណចំពោះការចំណាយពេលដ៏មានតម្លៃរបស់ពួកគេ
- ណែនាំបង្ហាញព្រឹត្តិការណ៍
- សង្ខេបពីគោលបំណងនៃសកម្មភាព និងត្រួតពិនិត្យអ្វីដែលអ្នកចូលរួមបានដឹង។

#### ខ.ការអនុវត្តសកម្មភាព ធ្វើសកម្មភាពទៅតាមផែនការ ។

#### គ.ការផ្តល់ព័ត៌មានត្រឡប់

ក្នុងអំឡុងពេលធ្វើបទបង្ហាញ សូមសួរសំណួរដល់អ្នកចូលរួម ដើម្បីពិនិត្យមើលការយល់ដឹងរបស់ពួកគេ។ នៅចុងបញ្ចប់នៃបទបង្ហាញ ក៏សួរប្រសិនបើមានសំណួរ ហើយត្រូវបើកទូលាយដើម្បីទទួលបានយោបល់ណាមួយ។ ឧទាហរណ៍៖

- តើបទបង្ហាញនិយាយអំពីអ្វី ?
- តើនឹងមានអ្វីខ្លះកើតឡើងនៅក្នុងសហគមន៍ ?
- តើបញ្ហានេះវានឹងជះឥទ្ធិពលដល់ជីវិតរបស់អ្នកយ៉ាងដូចម្តេច ?
- តើអ្នកអាចធ្វើអ្វីខ្លះដើម្បីដោះស្រាយវា ?

## ៤- ការឆ្លុះបញ្ចាំងលើបំណិនដែលបានអភិវឌ្ឍ

ឆ្លុះបញ្ចាំងជាមួយសិស្សអំពីការអនុវត្តផែនការ។ ឆ្លុះបញ្ចាំងនៅចុងបញ្ចប់នៃសកម្មភាព និងផ្តល់យោបល់នៅពេលពួកគេកំពុងធ្វើសកម្មភាព ដើម្បីជួយពួកគេក្នុងការសម្រេចផែនការ។

### សំណួរដែលអាចសួរមាន៖

- តើអ្នកបានចាត់ចែងតាមផែនការឬទេ ? បើមិនបានហេតុអ្វី ? តើមានអ្វីកើតឡើង ?
- តើអ្នកមានអារម្មណ៍ល្អក្នុងការធ្វើការជាមួយក្រុមឬទេ ? តើអ្នកបានប្រឈមមុខនឹងបញ្ហាណាមួយទេ ?
- តើអ្នកនឹងកែលម្អអ្វីខ្លះនៅពេលក្រោយ ?

### គន្លឹះនៃការប្រាស្រ័យទាក់ទង- ការប្រាស្រ័យទាក់ទងដោយកាយវិការ និងពាក្យសម្តី

រៀបចំសិស្សរបស់អ្នកមុនពេលធ្វើបទសម្ភាសន៍ សកម្មភាពផ្សព្វផ្សាយ ឬសកម្មភាពផ្សេងទៀតដែលបង្ហាញពីការប្រាស្រ័យទាក់ទង។ ខាងក្រោមនេះ អ្នកនឹងឃើញនូវសំណើមួយចំនួនសម្រាប់ការប្រាស្រ័យទាក់ទងដោយកាយវិការ និងពាក្យសម្តី។ សង្កេតមើលពួកគេ និងផ្តល់យោបល់វិជ្ជមាន!

| កាយវិការ | ពាក្យសម្តី |
|---|---|
| 1- ការប្រើក្រសែភ្នែក៖ សូមក្រឡេកមើលទស្សនិកជនដើម្បីចូលរួមជាមួយពួកគេ។<br>2- ការលើកដាក់សំឡេង៖ បង្រៀនសិស្សឱ្យលើកដាក់សំឡេងរបស់ពួកគេដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់ទស្សនិកជន។<br>3- ទីតាំងនៅក្នុងបន្ទប់៖ ផ្លាស់ប្តូរទីតាំងនៅក្នុងបន្ទប់កុំនៅអង្គុយគ្រប់ពេល ដើម្បីរក្សាចំណាប់អារម្មណ៍របស់ទស្សនិកជន។<br>4- ទឹកមុខ៖ ការបង្ហាញទឹកមុខពិតជាសំខាន់ណាស់ បង្ហាញទឹកមុខធម្មតា (មិនរំភើប មិនញញឹម)។ | 1- ប្រើភាសាសាមញ្ញ និងច្បាស់។<br>2- កុំធ្វើឱ្យប្រយោគវែងពេក ប្រសិនបើមានមនុស្សមិនសូវយកចិត្តទុកដាក់ស្តាប់។<br>3- ស្តាប់ទស្សនិកជន អន្តរទំនាក់ទំនងជាមួយពួកគេ។<br>4- និយាយម្តងទៀតនូវគំនិតសំខាន់ៗ។<br>5- នៅពេលដែលអ្នកប្រើសម្ភារៈសំណេរដើម្បីគាំទ្រការនិយាយរបស់អ្នក សូមធ្វើប្រភេទដូចជា៖ ផូស្ទ័រ រូបភាព បទបង្ហាញខ្លីៗ។ |

# ដំណាក់កាលទី៦- ការឆ្លុះបញ្ចាំង និងវាយតម្លៃ

## ១-គោលបំណង

លើកទឹកចិត្តសិស្សឱ្យឆ្លុះបញ្ចាំង និងរៀនពីបទពិសោធក្នុងការអនុវត្តសកម្មភាព និងការអភិវឌ្ឍបំណិន។

## ២-បំណិនគោលដៅ ចរិយាសម្បទា និងគុណតម្លៃ

ការគ្រប់គ្រងខ្លួនឯង ការយល់ចិត្ត ការរិះគិតពិចារណា ភាពធន់ អាកប្បកិរិយាវិជ្ជមានក្នុងការដោះស្រាយបញ្ហា។

## ៣-ល្បិចបង្រៀន

គ្រូអាចប្រើឧបករណ៍ណាមួយដែលបានស្នើឡើងសម្រាប់ការវាយតម្លៃផ្លូវការ និងក្រៅផ្លូវការ។

## សកម្មភាពទី១- ការឆ្លុះបញ្ចាំងលើដំណើរការទាំងមូល

ការឆ្លុះបញ្ចាំងគឺជាបណិនដ៏សំខាន់មួយ ដែលជួយបុគ្គលគ្រប់រូបត្រូវចៀសវាងកំហុសដដែលៗនៅអនាគត។ វាជំរុញឱ្យមានការគិត និងការវិភាគដោយហ្មត់ចត់ ហើយនិងអាចទាញបាននូវគំនិត និងដំណោះស្រាយល្អប្រសើរសម្រាប់ជីវិតប្រចាំថ្ងៃ។ គ្រូត្រូវឆ្លុះបញ្ចាំង៖

- នៅចុងបញ្ចប់នៃមេរៀននីមួយៗ (ដោយផ្ទាល់មាត់)
- នៅចុងបញ្ចប់នៃដំណាក់កាលនីមួយៗដើម្បីឆ្លុះបញ្ចាំងដំណើរការបំណិនគោលដៅ(ដោយផ្ទាល់មាត់)
- នៅចុងបញ្ចប់នៃឆមាស (ដោយផ្ទាល់មាត់ និងសំណេរ។)

### ល្បិចបង្រៀន

គ្រូអាចប្រើឧបករណ៍ណាមួយ ដែលបានស្នើឡើងសម្រាប់ការវាយតម្លៃក្រៅផ្លូវការ ដែលពួកគេអាចរកបាននៅក្នុងឧបសម្ព័ន្ធ៧.៦។ គ្រូអាចឱ្យឧទាហរណ៍ដោយសរសេរសំណួរឆ្លុះបញ្ចាំងមួយចំនួន នៅក្នុងក្រដាសដែលដាក់វានៅក្នុងប្រអប់មួយ( យកគំនិតនៃសំណួរពីបញ្ជីខាងក្រោម និងពីឧបសម្ព័ន្ធ៧.៦ ។ ការឆ្លុះបញ្ចាំងអាចត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ឬសំណេរ។

- បឋមសិក្សា៖ ឱ្យសិស្សជ្រើសរើសក្រដាសមួយហើយអានសំណួរឱ្យឮខ្លាំងៗ។ សុំឱ្យសិស្សក្នុងថ្នាក់ទាំងអស់ឆ្លើយ។ ធ្វើលំហាត់ដូចនេះឱ្យបានច្រើនដងតាមដែលអ្នកអាចធ្វើបាន។ ជាអតិបរមា អានសំណួរចំនួន៦-៨សំណួរ។
- អនុវិទ្យាល័យ៖ ឱ្យសិស្សមកយកក្រដាសមួយ ឬពីរសន្លឹក ហើយឆ្លើយសំណួរជាក្រុមតូចៗដែលមួយក្រុមមានចំនួន ៤នាក់។ ទុកពេល៣០នាទីឱ្យពួកគេគិត និងសរសេរចម្លើយ។

<table>
<tr><th colspan="2">សំណួរដែលអាចសួរសម្រាប់ការឆ្លុះបញ្ចាំងចុងក្រោយ</th></tr>
<tr><td>

**១.លទ្ធផលសម្រេចបាន និងដំណោះស្រាយ**

- តើអ្នកសប្បាយចិត្តនឹងការងារដែលបានធ្វើឬទេ ?
- តើសកម្មភាពបានអនុវត្តតាមផែនការឬទេ ?
- តើអ្វីសំខាន់បំផុតដែលខ្ញុំបានរៀនដោយខ្លួនឯង ?
- តើអ្នកបានប្រឈមមុខនឹងបញ្ហាប្រឈមណាមួយក្នុងគម្រោងឆមាសនេះឬទេ ?
- តើអ្នកចូលចិត្តអ្វីជាងគេ ?
- តើអ្នករកឃើញការពិបាកអ្វីឬទេ ?
- តើអ្នកនឹងកែលម្អអ្វីខ្លះនៅពេលក្រោយ ?
- តើខ្ញុំនឹងប្រើអ្វីដែលខ្ញុំបានរៀនយ៉ាងដូចម្តេចនាពេលអនាគត ?

</td><td>

**៣.ការអភិវឌ្ឍបំណិន**

- តើអ្វីខ្លះជាការរកឃើញគួរឱ្យចាប់អារម្មណ៍ដែលខ្ញុំបានធ្វើនៅពេលកំពុងធ្វើការលើគម្រោងនេះ ? អំពីបញ្ហា ? អំពីខ្លួនឯង ? អំពីអ្នកដទៃ ?
- តើអ្នកពេញចិត្តធ្វើការក្នុងក្រុមជាមួយមិត្តភក្តិរបស់អ្នកឬទេ ?
- តើអ្នកពិបាកធ្វើតាមការណែនាំ ឬយោបល់ពីគ្រូឬទេ ?
- ហេតុអ្វីបានជាអ្នកគិតថា យើងបានធ្វើស្វ័យឆ្លុះបញ្ចាំងនៅចុងបញ្ចប់នៃដំណាក់កាលនីមួយៗ ?
- តើអ្នកបានជួបប្រទះនឹងបញ្ហាណាមួយក្នុងពេលធ្វើសកម្មភាពជាមួយក្រុមឬទេ ?<br>តើអ្នកបានដោះស្រាយវាដោយរបៀបណា ?
- តើមានអ្វីខ្លះដែលមិត្តរួមក្រុមរបស់ខ្ញុំបានធ្វើដែលជួយខ្ញុំរៀន ឬជម្នះឧបសគ្គ ?

</td></tr>
<tr><td>

**២.ការចូលរួមរបស់សហគមន៍**

- តើអ្នកមានការចាប់អារម្មណ៍ក្នុងការជួបជាមួយសមាជិកសហគមន៍ (នៅក្នុងសាលារៀន ឬនៅសហគមន៍ )ដែរឬទេ ?
- តើសហគមន៍បានចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយរបស់អ្នកដែរឬទេ ?
- តើអ្នកគិតថាពួកគេចាប់អារម្មណ៍នឹងការងាររបស់អ្នកឬទេ ?

</td><td>



</td></tr>
</table>

កុំភ្លេចរំឭកសិស្សឱ្យជ្រើសរើស ១-២ប្រធានបទដែលពួកគេចាប់អារម្មណ៍ សម្រាប់ការអង្កេតនៅឆ្នាំក្រោយ។ ប្រធានថ្នាក់ត្រូវទទួលខុសត្រូវក្នុងការបញ្ជូនព័ត៌មានទៅក្រុមប្រឹក្សាសិស្ស។ ក្រុមប្រឹក្សាសិស្សត្រូវប្រមូលប្រធានបទដែលបានជ្រើសរើសទាំងអស់ពីសិស្ស ហើយត្រូវបង្ហាញជូនពួកគេនៅឆ្នាំក្រោយ ក្នុងអំឡុងពេលធ្វើកម្មវិធីសិក្សាបែបពិគ្រោះយោបល់នៅកម្រិតនៅសាលារៀន។

## សកម្មភាពទី២- ការសរសេររបាយការណ៍

ការសរសេររបាយការណ៍គឺជាទម្រង់ឯកសារមួយ ដែលសិស្សនឹងប្រើដើម្បីកត់ត្រាលទ្ធផលសំខាន់ៗ លទ្ធផលសម្រេចបាន និងអនុសាសន៍នានានៃដំណើរការទាំងមូល។

របាយការណ៍នឹងប្រើជាឯកសារយោង នៅពេលរៀបចំសកម្មភាពផ្សព្វផ្សាយលើកក្រោយ ហើយនឹងត្រូវរក្សាទុកនៅក្នុងបណ្ណាល័យ សម្រាប់សិស្សដទៃទៀតប្រើប្រាស់ជាធនធានព័ត៌មាននៅឆ្នាំបន្ទាប់។ សិស្សអនុវិទ្យាល័យនឹងត្រូវបានស្នើឱ្យសរសេររបាយការណ៍ រីឯសិស្សបឋមសិក្សានឹងជួយគ្រូឱ្យបំពេញរបាយការណ៍សង្ខេប ឬសង្ខេបនៅក្នុងផ្ទាំងផូស្ទ័រ ឬឯកសារខ្លីៗ ដោយមានគន្លឹះនៃការរៀន ការឆ្លុះបញ្ចាំង និងគំនិតយោបល់ដែលលើកឡើងដោយសិស្ស។

### គំរូទម្រង់របាយការណ៍

1- **តើប្រធានបទមានទំនាក់ទំនងយ៉ាងដូចម្តេច នៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង។** (សូមសង្ខេបខ្លឹមសារនៃប្រធានបទ និងផលប៉ះពាល់លើជីវិតរស់នៅប្រចាំថ្ងៃរបស់អ្នកនៅក្នុងសាលារៀន និងសហគមន៍)។

2- **ប្រភពព័ត៌មានណាមួយដែលយើងបានប្រើដើម្បីអង្កេត** (បណ្ណាល័យ អ្នកជំនាញក្នុងមូលដ្ឋាន។ល។)៖ ពិពណ៌នា អំពីសកម្មភាពដែលបានធ្វើដើម្បីស្វែងរកព័ត៌មាន (អ្វីដែលយើងបានធ្វើ នៅពេលណា ធ្វើយ៉ាងដូចម្តេច?)



រូបភាព៖ របាយការណ៍ពីសាលាអនុវិទ្យាល័យចាន់ស ខេត្តសៀមរាប

3- **ការរកឃើញសំខាន់ៗ** (អ្វីដែលយើងបានរកឃើញ) ពិពណ៌នា៖...

4- **ផែនការសកម្មភាពផ្សព្វផ្សាយ និងលទ្ធផល** (រូបភាពបើមាន) ពិពណ៌នា៖...

5- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍** (វិធីដែលយើងនឹងអនុវត្តចំណេះដឹងថ្មីនេះនៅក្នុងជីវិតប្រចាំថ្ងៃ តើយើងអាចកែលម្អអ្វីនៅពេលក្រោយ)។

# ធនធានសម្ភារៈផ្សេងទៀត


- វីដេអូអំពីដំណើរការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន (២០១៩): ការជ្រើសប្រធានបទ ដំណើរការបង្រៀនតាម ៦ដំណាក់កាល ដំណើរការវង្វាយតម្លៃ ផលិតដោយនា.អកស និងគាំទ្រដោយអង្គការយូនីសេហ្វ នៅលើគេហទំព័រក្រសួងអយក.
- CARD, MoEYS and FAO (2017). Life Skill Education. School Gardening and Nutrition Education. A Trainer’s Manual and Teachers Guide for Grade 4, 5 and 6. MoEYS Website.
- FinnChurch Aid. (2016). Career Councelling Manual. (target: Lower Secondary students). MoEYS Website.
- Growth_and_Changes_Cambodia Grow & Know, Inc (2012). was developed with Cambodian adolescent girls to provide guidance on puberty and menstrual management at school. http://tiny.cc/vhysaz
- KAPE Application Career Counselling. (Trey Visay) is an e-career counselling App: https://play.google.com/store/apps/details?id=com.treyvisay
- UNICEF, Family resilience in emergency. https://www.unicef.org/cambodia/reports/actions-must-performed-during-and-after-flood and MoEYS website.
- UNICEF (2017).The Curriculum to Buddhism responses against children violence: https://www.unicef.org/cambodia/reports/buddhism-responses-violence-against-children
- VVOB (2013) Life Skills Teaching Manuals. Agriculture (Chicken Raising, Fish Raising, Organic Gardening) available for download in Khmer and English: https://www.vvob.org/en/news/life-skills-teaching-manuals-can-be-downloaded-vvob-cambodia-website and MoEYS Website.
- World Education, KAPE (2015). IBEC 28 Manuals on Social, Entrepreneurship and Leadership and Livelihood Topics are available for download at http://ibec.worlded.org/Life%20Skill%20Manuals/Life_Skill_Manual.html#social and MoEYS Website.
- World Vision International (2009) Peace Road Curriculum (Target: Youth). MoEYS Website.
- World Vision International (2014), Training Smart Navigator Manual. (Target: Youth). MoEYS Website.

# បទានុក្រម

| បញ្ញត្តិ | និយមន័យ |
|---|---|
| រង្វាយតម្លៃ<br>Assessment | រង្វាយតម្លៃគឺជាដំណើរការជាប្រព័ន្ធនៃការចងក្រងឯកសារ និងប្រើប្រាស់ទិន្នន័យជាក់ស្តែងលើចំណេះដឹង បំណិន ឥរិយាបថនិងគុណតម្លៃ។ |
| បំណិនមូលដ្ឋាន<br>Basic Skills | បំណិន មូលដ្ឋានគឺជាផ្នែកមួយនៃបំណិនជីវិត និងជាការរួមបញ្ចូលគ្នានៃ ចំណេះដឹងទូទៅ បំណិនបុរេវិជ្ជាជីវៈ ឥរិយាបថនិងគុណតម្លៃផ្ទាល់ខ្លួន ។ |
| បំណិនអាជីព<br>Career Skills | បំណិនអាជីពគឺជាផ្នែកមួយនៃបំណិនជីវិត និងជាការរួមបញ្ចូលបំណិនមូលដ្ឋាន បំណិនអាជីវកម្មនិងការគ្រប់គ្រង និងបំណិនបច្ចេកទេស។ |
| ការវាយតម្លៃ<br>Evaluation | ការវាយតម្លៃគឺជាការពិនិត្យចុងក្រោយលើការបង្រៀន ដើម្បីពិនិត្យមើលគុណភាពនៃដំណើរការបង្រៀននិងរៀន។ |
| ចំណេះដឹងទូទៅ<br>General knowledge | ភាសាខ្មែរ និងគណិតវិទ្យា ចំណេះដឹងពាក់ព័ន្ធក្នុងមូលដ្ឋាន ការយល់ដឹងពីពលរដ្ឋវិជ្ជា ការយល់ដឹងអំពីសុខភាព ការយល់ដឹងអំពីបរិស្ថាន និងការយល់ដឹងអំពីវប្បធម៌ (ជាសមាសធាតុមួយក្នុងចំណោមសមាសធាតុទាំងបីនៃបំណិន មូលដ្ឋាន) ។ |
| បំណិនរឹង<br>Hard skills | បំណិនរឹងសំដៅទៅលើបំណិនបច្ចេកទេសដូចជា កាត់ដេរ ជួសជុលម៉ូតូ ធ្វើម៉ូតសក់ ភាសា ជំនាញកុំព្យូទ័រ។ ល។ |
| ការរៀនបែបរិះរក<br>Inquiry based learning | គឺជាវិធីសាស្រ្តបង្រៀនដែលជំរុញការរៀនសូត្រយ៉ាងសកម្ម និងចាប់ផ្តើមពី បញ្ហាមួយ សេណារីយ៉ូ ឬតម្រូវការ។ |
| បំណិនជីវិត<br>Life Skills | បំណិនជីវិតសំដៅទៅលើសំណុំនៃសមត្ថភាពមូលដ្ឋានដែលមនុស្សម្នាក់ត្រូវការដើម្បីការរស់នៅប្រចាំថ្ងៃ។ នៅប្រទេសកម្ពុជាបំណិនជីវិតត្រូវបានកំណត់ជាការរួមបញ្ចូលគ្នារវាងបំណិនមូលដ្ឋាន និងបំណិនអាជីព។ |
| ប្រធានបទអាជីពងាយ<br>Livelihood topics | ប្រធានបទ កសិកម្ម សិប្បកម្ម សេវាកម្ម និងប្រធានបទសហគ្រិនភាពនិងភាពជាអ្នកដឹកនាំ ក្នុងការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន។ |
| បំណិនជីវិតតាមមូលដ្ឋាន<br>Local Life Skills | មុខវិជ្ជាដែលសិស្សត្រូវបានណែនាំឱ្យ បង្កើតគម្រោង ស្រាវជ្រាវ និងរៀនសូត្រពីបរិបទក្នុងតំបន់របស់ពួកគេដោយសំដៅពិសេសទៅលើប្រធានបទអាជីពងាយ និងសង្គម។ វាមានគោលបំណងផ្សារភ្ជាប់សិស្សានុសិស្សជាមួយពិភពពិតជាក់ស្តែង អភិវឌ្ឍ និងអនុវត្តបំណិនជីវិតដែលនឹងជួយពួកគេឱ្យចេះដោះស្រាយបញ្ហាប្រឈមក្នុងជីវិតប្រចាំថ្ងៃ ដោយផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត។ |
| ចំណេះដឹងពាក់ព័ន្ធក្នុងមូលដ្ឋាន<br>Locally Relevant Knowledge | ស្ថានភាពដែលកើតឡើងនៅកម្រិតមូលដ្ឋានដែលអាចជំរុញសិស្សឱ្យកំណត់បញ្ហា ឬឱកាសដែលពួកគេចង់អង្កេត។ ពួកគេអាចចាប់ផ្តើមពីមូលដ្ឋានដើម្បីប្រៀបធៀបជាមួយនិន្នាការតំបន់។ |
| ការសិក្សាផ្អែកលើបញ្ហា<br>Problem based learning | ជាផ្នែកនៃការរៀនបែបរិះរក។ វាគឺជាបច្ចេកទេសរៀនដែលជំរុញវិធីសាស្រ្តសិស្សមជ្ឈមណ្ឌល និងការរៀនសូត្រយ៉ាងសកម្ម។ ចាប់ផ្តើមជាមួយ សំណួរ បញ្ហា សេណារីយ៉ូ ដើម្បីដោះស្រាយ និងស្វែងរកចម្លើយ។ |

| បញ្ញត្តិ | និយមន័យ |
|---|---|
| កម្មវិធីសិក្សាបែបពិគ្រោះយោបល់នៅកម្រិតសាលារៀន School based negotiated curriculum | កម្មវិធីសិក្សា(ការជ្រើសរើសប្រធានបទ) ត្រូវបានរៀបចំតាមមូលដ្ឋាននៅសាលារៀនផ្ទាល់ មិនមែនជាកម្មវិធីដែលផ្តល់ដោយថ្នាក់ជាតិទេ។ |
| បំណិន Skills | សមត្ថភាពក្នុងការធ្វើអ្វីមួយ។ |
| គំរូសង្គម និងគំរូអាជីព Social and Livelihood Models | សំដៅទៅលើគំរូនៃការអនុវត្ត។ នៅក្នុងមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានយើងមានគំរូសំខាន់ពីរគឺគំរូសង្គមដែលផ្តោតសំខាន់លើការបង្រៀន ការអភិវឌ្ឍបំណិនមូលដ្ឋាន និងគំរូអាជីពដែលផ្តោតលើ ការអភិវឌ្ឍបំណិនអាជីព។ |
| ប្រធានបទសង្គម Social topics | ក្រុមនៃប្រធានបទដែលសំដៅទៅលើបញ្ហាទាក់ទងនឹងសង្គម និងអាចត្រូវបានជ្រើសរើសនៅក្នុងការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន។ |
| បំណិនទន់ Soft Skills | ត្រូវបានគេហៅថាបំណិនបុរេវិជ្ជាជីវៈ បំណិនសតវត្សរ៍ទី២១ " បំណិនទន់សំដៅទៅលើចង្កោមនៃចរិតលក្ខណៈផ្ទាល់ខ្លួនដូចជា ការប្រាស្រ័យទាក់ទង ការរិះគិតពិចារណា ការដោះស្រាយបញ្ហា ការច្នៃប្រឌិត..."។ នៅក្នុងឯកសារណែនាំនេះបំណិនបុរេវិជ្ជាជីវៈ និងបំណិនអាជីវកម្មនិងការគ្រប់គ្រងត្រូវបានគេចាត់ទុកថាជាសំណុំនៃបំណិនទន់។ |
| កម្មវិធីសិក្សាលម្អិត Syllabus | កម្មវិធីសិក្សាលម្អិតមានបញ្ញត្តិផ្សេងៗនៅក្នុងមុខវិជ្ជាមួយ។ កម្មវិធីសិក្សាលម្អិតខុសគ្នាអាស្រ័យលើមុខវិជ្ជាដែលបង្រៀនដោយគ្រូ។ |

# ឯកសារយោង


- នា.អកស (2016) ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស
- នា.អកស (2018) កម្មវិធីសិក្សាលម្អិតមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានសម្រាប់កម្រិតបឋមសិក្សា
- នា.អកស (2018) កម្មវិធីសិក្សាលម្អិតមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានសម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ
- Bruner, J. S. (1957). Going beyond the information given. New York: Norton.
- Bruner, J. S. (1960). The Process of education. Cambridge, Mass.: Harvard University Press.
- Bruner, J. S. (1966). Toward a theory of instruction, Cambridge, Mass.: Belkapp Press.
- DCD (2011), Curriculum for ICT-Based Professional Skills, EVEP Course for grad e 11.
- Ester Care, Patrick Griffin, Mark Wilson (2019). 'Assessment and Teaching of 21st Century Skills', Springer.
- FinnChurch Aid, 2016, Career Counselling Manual.
- FOD,2014, Fundación Omar Dengo. Competencias para el siglo XXI : guía práctica para promover su aprendizaje y evaluación. /. - - San José, Costa Rica.
- KAPE (2016), Constructivist learning Training Manual, New Generation Schools.
- ILO, (2017), GET AHEAD, Gender and Entrepreneurship Together, Trainer Guide.
- ILO, READY FOR BUSINESS, Critical thinking, Problem Solving, Self-Assessment and Teamwork, Decent Work Technical Support Team for East and South-East Asia and the Pacific
- ILO (2017). In Business, Creative Thinking, Strategies for boosting creativity, Enterprise development, growth, and enhancement through peer-learning networks
- LSCE Initiative, The Twelve Core Life Skills for MENA, http://www.lsce-mena.org/uploads/resources/lsce_(171002)/04-c_12_factsheets_English_(1-14).pdf
- Open Institute, DIT (2009), ICT-Based Professional Skills, Grade 11th.
- Prak Pov, Khin Vanddy, Ban Kakada (2018), Teaching Methodology, Khmer Books.
- Rachel Parker (2017), Southeast Asia, Primary Learning Metrics (SEA-PLM), Global Citizenship Domain Assessment Framework
- Room To Read (2016), Life Skills Education Learning Outcomes.
- Room To Read. Life Skills Teacher Guide for Grade 7, 8 and 9.
- WEI/KAPE (2015), IBEC Manuals, USAID.
- WVI (2009) Peace Road Curriculum.
- WVI (2014), Training Smart Navigator Manual.
- Wood, D. J., Bruner, J. S., & Ross, G. (1976). The role of tutoring in problem solving. Journal of Child Psychiatry and Psychology, 17(2), 89-100.